# ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២

## កម្ពុជា-នីហ្សេរីយ៉ា
## អាចពិនិត្យលទ្ធភាពចុះ MOU លើកិច្ចសហប្រតិបត្តិការ ការងារឧក្រិដ្ឋកម្មឆ្លងដែន

https://dap-news.com/ ByDR103Posted on July 29, 2022

**ភ្នំពេញ ៖** កម្ពុជា-នីហ្សេរីយ៉ា អាចពិនិត្យលទ្ធភាពចុះអនុស្សារណៈ នៃការយោគយល់គ្នា (MOU) លើកិច្ចសហប្រតិបត្តិការនូវការងារឧក្រិដ្ឋកម្មឆ្លងដែនដូចជា ជួញដូរមនុស្ស ជួញដូរគ្រឿងញៀន និងអំពើភេរវកម្ម ជាដើម។

នាឱកាសអនុញ្ញាតជូន លោកស្រី Folakemi I.Akinleye ឯកអគ្គរដ្ឋទូត នីហ្សេរីយ៉ាប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម នាថ្ងៃទី២៨ កក្កដា សម្តេច ស ខេងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានលើកឡើងជាគំនិតផ្តួចផ្តើម ដែលភាគីទាំងពីរអាចពិនិត្យលទ្ធភាព ក្នុងការរៀបចំយន្តការសហប្រតិបត្តិការ ជាទម្រង់អនុស្សារណៈ ឬក៏កិច្ចព្រមព្រៀងជាមួយគ្នា ដែលអាចផ្តល់លទ្ធភាពដល់ភាគីទាំងពីរ ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការ ទៅលើវិស័យជាផ្នែក ដែលភាគីទាំងពីរយល់ឃើញថា មានតម្រូវការចាំបាច់។ សម្តេច បានលើកឡើងដែរថា «ភារកិច្ចស្នូលដ៏ធំមួយ នៅក្នុងក្របខ័ណ្ឌ នៃសមត្ថកិច្ចទទួលខុសត្រូវ របស់ក្រសួងមហាផ្ទៃ គឺការងារសន្តិសុខ ដូច្នេះហើយភាគីទាំងពីរ ក៏អាចពិនិត្យលទ្ធភាព ក្នុងការដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀង ឬក៏ជាអនុស្សារណៈ នៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការ ក្នុងការងារសន្តិសុខ ជាពិសេសការងារឧក្រិដ្ឋកម្មឆ្លងដែន មានជាអាទិ៍អំពើជួញដូរមនុស្ស ការជួញដូរគ្រឿងញៀនខុសច្បាប់ និងអំពើភេរវកម្មជាដើម»។

ជាការឆ្លើយតប លោកស្រី ឯកអគ្គរដ្ឋទូត បានសម្តែងសេចក្តីរីករាយ ចំពោះគំនិតផ្តួចផ្តើមរបស់ សម្តេច ស ខេង ក្នុងការរៀបចំឲ្យមានក្របខ័ណ្ឌផ្លូវការ នៃកិច្ចសហប្រតិបត្តិការតាមរយៈ MOU ឬកិច្ចព្រមព្រៀងណាមួយ រវាងភាគីទាំងពីរ។ លោកស្រីបញ្ជាក់ថា នីហ្សេរីយ៉ា ក៏ត្រៀមខ្លួនធ្វើកិច្ចសហការ ជាមួយក្រសួងមហាផ្ទៃកម្ពុជា ក៏ដូចជាស្ថាប័នពាក់ព័ន្ធ រួមទាំងក្រសួងការបរទេសកម្ពុជា ដើម្បីធ្វើយ៉ាងណា ឈានទៅសម្រេចបានគោលដៅរួម នៃគំនិតផ្តួចផ្តើមលើឯកសារ កិច្ចសហប្រតិបត្តិការផ្លូវការ៕

## កម្ពុជា-វៀតណាម
## ប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការលើការងារប្រឆាំងគ្រឿងញៀន និងជួញដូរមនុស្ស

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 29 July 2022 | 09:46 ICT

**ភ្នំពេញៈ** កម្ពុជា-វៀតណាម ប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការគ្នាលើការងារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស ដោយប្រទេសទាំង ២ ចាត់ទុកកិច្ចការទាំងនេះជាការងារដ៏ស្មុគស្មាញ ហើយត្រូវតែបន្តយុទ្ធនាការ ក៏ដូចជាអនុវត្តយ៉ាងយកចិត្តទុកដាក់ ប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់។ ការបង្ហាញឆន្ទៈក្នុងការប្តេជ្ញារួមគ្នានេះ តាមរយៈជំនួបរវាងលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោក Pham Quang Hieu អនុរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម កាលពីថ្ងៃទី ២៧ ខែកក្កដា នៅរដ្ឋសភាកម្ពុជា។

នាឱកាសនោះ លោក ស ខេង បានលើកឡើងពីការងារសមត្ថកិច្ចក្រសួងមហាផ្ទៃថា ទោះបីជា ប្រឈមនឹងបញ្ហាជំងឺកូវីដ ១៩ ក៏ដោយ ក៏ក្រសួងមហាផ្ទៃ និងសមភាគីវៀតណាមបានបន្តទំនាក់ទំនងជាបន្តបន្ទាប់តាមយន្តការដែលមានស្រាប់។ លោកថ្លែងថា បច្ចុប្បន្ន ពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ គឺមានកិច្ចការសំខាន់ៗចំនួន ២ ក្នុងនោះ ទី ១ គឺពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងទី ២ គឺការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ លោកបញ្ជាក់ថា៖ «កិច្ចការទាំងនេះ ជាការងារដ៏ស្មុគស្មាញ ហើយដែលកម្ពុជាកំពុងតែបន្តយុទ្ធនាការក៏

ដូចជាបន្តអនុវត្តយ៉ាងយកចិត្តទុកដាក់ប្រកបដោយឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់»។ លោកបន្ថែមថា មួយវិញទៀតកម្ពុជាក៏កំពុងតែខិតខំប្រយុទ្ធប្រឆាំងនឹងបទល្មើសសម្អាតប្រាក់ និងការប្រឆាំងទៅនឹងការរីកសាយភាយនៃអាវុធមហាប្រល័យផងដែរ។ លោក ស ខេង បញ្ជាក់ថា៖ «កន្លងមកទាំងការប្រជុំខេត្តជាប់ព្រំដែនរវាងប្រទេសទាំង ២ និងការប្រជុំរវាងក្រសួងនគរបាលវៀតណាមជាមួយក្រសួងមហាផ្ទៃ តែងតែអនុវត្តទៅតាមការកំណត់តាមប្រព័ន្ធអនឡាញ ដែលកិច្ចការទាំងនេះក៏បានរួមចំណែក ធ្វើការងារថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែនរវាងប្រទេសទាំង ២ មានភាពល្អប្រសើរផងដែរ»។

លោក Pham Quang Hieu បានថ្លែងអំណរគុណលោក ស ខេង ចំពោះការវាយតម្លៃទៅលើកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង ២ កន្លងមកនេះ។ លោកក៏ឯកភាពចំពោះការលើកឡើងរបស់លោក ស ខេង ទៅលើទិដ្ឋភាពល្អប្រសើរនៃការរក្សាសន្តិសុខនៅតាមខ្សែបន្ទាត់ព្រំដែននៃប្រទេសទាំង ២ ផងដែរ។ លោក Pham Quang Hieu ថ្លែងថា៖ «សូមឯកភាពថា បញ្ហាគ្រឿងញៀន និងការជួញដូរមនុស្ស គឺជាកិច្ចការមួយដែលប្រឈម និងត្រូវតែបន្តធ្វើយ៉ាងណាខិតខំសហការ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប»។

លោក ស ខេង បានស្នើតាមរយៈមន្ត្រីការទូតជាន់ខ្ពស់វៀតណាមរូបនេះ ដើម្បីឱ្យភាគីទាំង ២ ពិនិត្យលទ្ធភាពស្វែងរកពេលវេលាសមស្រប ដើម្បីរៀបចំសម្ពោធដាក់ឱ្យដំណើរការច្រកទ្វារព្រំដែនអន្តរជាតិ ម៉ឺនជ័យខេត្តព្រៃវែងជាប់ខេត្តតៃនិញប្រទេសវៀតណាម ដែលមកដល់ពេលនេះបានដាក់ឱ្យដំណើរការបណ្តោះអាសន្នរួចហើយ។ លោក ស ខេង បង្ហាញការជឿជាក់ថា ភាគីទាំង ២ នឹងរកពេលវេលាសមស្រប ដើម្បីប្រមុខ រដ្ឋាភិបាលនៃប្រទេសទាំង ២ អញ្ជើញជាអធិបតីភាពក្នុងការសម្ពោធច្រកទ្វារអន្តរជាតិនេះ ដើម្បីជួយរួមចំណែកបន្ថែមទៀតទៅលើទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-វៀតណាម ជាពិសេសទំនាក់ទំនងទៅលើផ្នែកពាណិជ្ជកម្មរវាងប្រទេសទាំង ២ និងក៏ជាការរំឭកដល់អនុស្សាវរីយ៍កាលពីសម័យតស៊ូ។

លោក Pham Quang Hieu បានទទួលយកប្រសាសន៍របស់លោកឧបនាយករដ្ឋមន្ត្រី ស ខេង និងសន្យាថានឹងរាយការណ៍ជូនថ្នាក់ដឹកនាំប្រទេសវៀតណាម។ លោក ក៏បង្ហាញការកត់សម្គាល់ឃើញនូវការកើនឡើងទំហំពាណិជ្ជកម្មរវាងប្រទេសទាំង ២ កាលពីឆ្នាំកន្លងទៅក៏ដូចជាក្នុងឆមាសទី ១ ក្នុងឆ្នាំ ២០២២ នេះដោយបានចាត់ទុកថា កំណើននេះក៏បានកើតចេញពីការផ្លាស់ប្តូរពាណិជ្ជកម្មតាមច្រកទ្វារ ម៉ឺនជ័យ ផងដែរ៕

## បទអត្ថាធិប្បាយ៖ ការពិត នៃអំពើជួញដូរមនុស្សនៅក្នុងសហរដ្ឋអាមេរិក

https://www.btv.com.kh/ 2022/07/29 11:20:26 am

យោងតាមរបាយការណ៍ ស្តីពីការជួញដូរមនុស្សឆ្នាំ ២០១១ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក អាមេរិកគឺជាប្រទេសលំដាប់ទី ១ សម្រាប់ការជួញដូរ។ កម្រិតទី ១ មានន័យថា រដ្ឋាភិបាលអនុលោមតាមស្តង់ដាររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក នៃច្បាប់ការពារជនរងគ្រោះនៃការជួញដូរ និងអំពើហិង្សាឆ្នាំ ២000 ដើម្បីលុបបំបាត់ការជួញដូរ។ ជនរងគ្រោះនៃការជួញដូរភាគច្រើន គឺជាកុមារ ក្នុងនោះរួមមានការចាប់រំលោភ ឬចាប់ជំរិត ឬបណ្តាលឱ្យស្លាប់ជាដើម។ សហរដ្ឋអាមេរិកកំពុងធ្វើការ ដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅក្នុងសហរដ្ឋអាមេរិក និងទូទាំងពិភពលោក។ ជារៀងរាល់ឆ្នាំ ក្រសួងការបរទេសចេញផ្សាយទិន្នន័យដែលបានចងក្រងអំពីស្ថានភាពនៃការជួញដូរមនុស្សនៅក្នុងប្រទេសផ្សេងៗគ្នាជាច្រើន រួមទាំងសហរដ្ឋអាមេរិក។ ទោះបីជាយ៉ាងណាក៏ដោយ ទិន្នន័យនេះប្រហែលជាមិនមានជាក់លាក់នោះទេ ដោយសារតែទាំងការខ្វះការសហការគ្នារវាងរដ្ឋ និងភ្នាក់ងារជាច្រើនដែលប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងអសមត្ថភាពក្នុងការគណនេយ្យជនរងគ្រោះដែលមិនទាន់រកឃើញ។

បើយោងតាមការចុះផ្សាយរបស់គេហទំព័រ The Exodus Road បានពិពណ៌នាថា ប្រសិនបើអ្នករស់នៅក្នុង "Land of the Free" អ្នកប្រហែលជាភ្ញាក់ផ្អើលនៅពេលដឹងថាការជួញដូរមនុស្សនៅសហរដ្ឋអាមេរិកគឺជាការពិត។ ប្រហែលជាវាកើតឡើងនៅក្នុងសហគមន៍របស់អ្នក។ ជាក់ស្តែង ស្ថិតិឆ្នាំ 2018 បង្ហាញថា ការជួញដូរមនុស្សបានកើតឡើងនៅគ្រប់រដ្ឋ។ ខណៈពេលដែលការជួញដូរមនុស្សអាចមើលទៅខុសប្លែកគ្នាជាសកល ប្រជាជនដែលរស់នៅក្នុងសហរដ្ឋអាមេរិកមិនតិចទេដែលរងផលប៉ះពាល់។ ជារឿយៗមានការភាន់ច្រឡំជាមួយការរត់ពន្ធមនុស្ស ការជួញដូរមនុស្សមិនមានពាក់ព័ន្ធនឹងការផ្លាស់ទីមនុស្សឆ្លងកាត់ព្រំដែននោះទេ។ ការរត់ពន្ធមនុស្សអាចនិងកើតឡើងពេលខ្លះ រួមជាមួយនឹងការជួញដូរ ប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីភាពខុសគ្នា។ ដូចដែលបានកំណត់ដោយក្រសួងការបរទេសសហរដ្ឋអាមេរិក៖ "ការជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចលើនរណាម្នាក់សម្រាប់គោលបំណងនៃការងារបង្ខំ ឬសកម្មភាពផ្លូវភេទពាណិជ្ជកម្មតាមរយៈការប្រើប្រាស់កម្លាំងឬការបង្ខិតបង្ខំ។ ការរត់ពន្ធមនុស្សពាក់ព័ន្ធនឹងការផ្តល់សេវា ការដឹកជញ្ជូន ឬក្លែងបន្លំឯកសារ ដល់បុគ្គលដែលស្ម័គ្រចិត្តស្វែងរកការចូលប្រទេសក្រៅដោយខុសច្បាប់។" តួលេខនៃការជួញដូរមនុស្សនៅសហរដ្ឋអាមេរិក បណ្តាញទំនាក់ទំនងការជួញដូរមនុស្ស បានរាយការណ៍ករណីជួញដូរមនុស្សជាង ១០,000 ករណីនៅសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០១៨ ។ ក្នុងចំណោមនោះ ជាង ៧,000 ជាស្ត្រី ឬក្មេងស្រី និងជិត ៨,000 ជាករណីជួញដូរផ្លូវភេទ។ មួយចំនួនទៀតគឺការជួញដូរកម្លាំងពលកម្ម ឬការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្មរួមបញ្ចូលគ្នា។ ជាង ២,000 នៃជនរងគ្រោះសរុបទាំងនេះគឺជាកុមារ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺថា ទាំងនេះគ្រាន់តែជាករណីដែលបានរាយការណ៍តែប៉ុណ្ណោះ។

បើតាមរបាយការដែលបង្ហាញដោយគេហទំព័រ The Exodus Road កាលពីឆ្នាំ២០២០ ទាសករសម័យទំនើប ដែលគេហៅថា ទាសករបច្ចេកវិទ្យា ត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនជាង ៤០៣,000នាក់ នៅក្នុងឆ្នាំ ២០១៨ ថាមាននៅក្នុងសហរដ្ឋអាមេរិក ជាពិសេសរដ្ឋកាលីហ្វ័រញ៉ា តិចសាស់។ តើការជួញដូរមនុស្សកើតឡើងយ៉ាងណានៅសហរដ្ឋអាមេរិក? បើយោងតាមក្រុមអ្នកជំនាញ ការជួញដូរមនុស្សអាចកើតឡើងចំពោះនរណាម្នាក់ដែលអ្នកជួញដូរជារឿយៗបានកំណត់គោលដៅជាជនងាយរងគ្រោះ។ នៅសហរដ្ឋអាមេរិក ជនងាយរងគ្រោះជាច្រើនគឺជាកុមារ រួមទាំងអ្នកនៅក្នុងប្រព័ន្ធចិញ្ចឹម អ្នករត់ចោលស្រុក និងយុវជនដែលគ្មានផ្ទះសម្បែង អ្នកដែលតស៊ូជាមួយការញៀនថ្នាំ ឬជំងឺផ្លូវចិត្ត និងជនបរទេសដែលទើបមានទីតាំងថ្មី។ នៅថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៨ អតីតប្រធានាធិបតីសហរដ្ឋអាមេរិក Donald Trump បានចុះហត្ថលេខាលើច្បាប់បញ្ឈប់ការជួញដូរផ្លូវភេទទៅជាច្បាប់ដែលមានគោលបំណងបិទគេហទំព័រដែលអាចឱ្យឧក្រិដ្ឋកម្មកើតឡើង។ អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងសហរដ្ឋអាមេរិក បានខិតខំដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅក្នុងសហរដ្ឋអាមេរិក។ ក្នុងរយៈពេលពីរទស្សវត្សចុងក្រោយនេះ មេដឹកនាំរដ្ឋាភិបាលរបស់យើងនៅតែបន្តកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេត និងកាត់ទោសអ្នកជួញដូរ។ ប៉ុន្តែករណីនៃការជួញដូរមនុស្សនៅក្នុងសហរដ្ឋអាមេរិកនៅតែបន្តកើនឡើងជារៀងរាល់ថ្ងៃ។

គួរំលឹកថា កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ក្រសួងការបរទេសអាមេរិក បានផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០២២ ស្តីពីការជួញដូរមនុស្ស។ ក្នុងបាយការណ៍នោះ គឺអាមេរិក បានដាក់កម្ពុជា វៀតណាម តំបន់ម៉ាកាវរបស់ចិន និងប្រទេសផ្សេងទៀត ពីបញ្ជីស្ថិតក្រោមការឃ្លាំមើលនៅកម្រិត២ ទៅកម្រិត៣ ដែលគេស្គាល់ជាទូទៅថា បញ្ជីខ្មៅ ដែលជាកម្រិតដ៏អាក្រក់។ អាមេរិកចោទប្រកាន់ថា កម្ពុជា និងប្រទេសទាំងនោះ មានកិច្ចខិតខំតិចតួច និងមិនបានគោរពតាមស្តង់ដារនៃការលុបបំបាត់ការជួញដូរមនុស្ស។ អាមេរិកក៏បានដាក់ចិនជាប្រទេសមួយស្ថិតក្នុងកម្រិត៣ នៃការជួញដូរមនុស្សផងដែរ ហើយរដ្ឋាភិបាលចិន បានច្រានចោល និងបានលើកឡើងថា អាមេរិកជាប្រទេស ដែលមានអំពើជួយដូរច្រើនជាងគេបំផុតក្នុងលោកផងដែរ។

លោក Wang Wenbin អ្នកនាំពាក្យក្រសួងការបរទេសចិន បានថ្លែងកាលពីថ្ងៃទី ២០ ខែកក្កដាថា យោងតាមការប៉ាន់ប្រមាណ របស់ក្រសួងការបរទេសអាមេរិក ជារៀងរាល់ឆ្នាំ មានមនុស្សចំនួន ១០ម៉ឺននាក់ ត្រូវបានជួញដូរពីបរទេស ទៅកាន់សហរដ្ឋអាមេរិក សម្រាប់ធ្វើពលកម្មក្រោមការបង្ខិតបង្ខំ ។លោកបានបន្តថា ប្រទេសចិនជាស់តឿនឱ្យភាគីសហរដ្ឋអាមេរិក ផ្តោតការយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស ដោយប្រតិបត្តិការជាក់ស្តែងដើម្បីប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋសិទ្ធិមនុស្ស ដូចជាការជួញដូរមនុស្ស និងការបង្ខំឱ្យធ្វើពលកម្មជាដើម នៅក្នុងប្រទេសខ្លួន ព្រមនិងពិនិត្យមើលខ្លួនឯងតាម «ស្តង់ដាខ្ពស់បំផុត» ដែលខ្លួនតែងអួតអាងនោះ ហើយឈប់មួលបង្កាច់ និងលាបពណ៌ប្រទេសផ្សេងទៀត។

សម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្ហាញការបារម្ភ និងភ្ញាក់ផ្អើលជាខ្លាំង ចំពោះការសម្រេចរបស់រដ្ឋាភិបាលអាមេរិកដែលបានដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ៣ ចូលទៅក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្សក្នុងចំណោមប្រទេសចំនួន ៥។ សម្តេចក្រឡាហោមជឿថា កម្ពុជាមិនបានធ្វើឱ្យល្អឥតខ្ចោះនោះទេ តែមិនអាក្រក់និងអត់មានឆន្ទៈធ្វើនោះដែរ។ សម្តេចក្រឡាហោមនៅតែមានការបារម្ភលើលក្ខខណ្ឌនៃការវាយតម្លៃ ឬមនោសញ្ចេតនានៃការវាយតម្លៃ ព្រោះថាប្រទេសខ្លះ ដូចជាធ្វើការងារនេះមិនបានល្អទេ តែបែរជាបានពិន្ទុល្អវិញ។ ជាមួយនេះ សម្តេចក្រឡាហោមសន្យាថា នឹងរឹតបន្តឹងនូវកិច្ចការមួយនេះដោយត្រួតពិនិត្យឱ្យបានហ្មត់ចត់ថា បញ្ហាអ្វីខ្លះដែលនៅសេសសល់ និងមូលហេតុដែលធ្វើឱ្យកម្ពុជាធ្លាក់មកចំណាត់ថ្នាក់លេខ៣ ជុំវិញបញ្ហាជួញដូរមនុស្ស។ ដូច្នេះ ប្រសិនបើសហរដ្ឋអាមេរិកនិយាយអំពីបញ្ហាសិទ្ធិមនុស្ស ការជួញដូរមនុស្ស នៅក្នុងប្រទេសដទៃ អាមេរិកខ្លួនឯងគួរតែពិនិត្យមើលអំពីបញ្ហាទាំងនេះ ដែលកំពុងកើតឡើងជារៀងរាល់ថ្ងៃ នៅក្នុងប្រទេសបិតាប្រជាធិបតេយ្យខ្លួនឯងផង៕

## ក្រសួងការងារណែនាំឱ្យពលករខ្មែរជំនាញធ្វើតេស្តភាសា ធ្វើការនៅប្រទេសជប៉ុន

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៩ កក្កដា ២០២២ដោយ KC Virak

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានណែនាំដល់ពលករខ្មែរជំនាញសូមចុះឈ្មោះ និងធ្វើតេស្តភាសាជប៉ុនដើម្បីបានទៅធ្វើការនៅប្រទេសជប៉ុនទទួលបានបទពិសោធន៍ល្អៗ និងទទួលប្រាក់ខែខ្ពស់។

លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងនៅក្នុងសេចក្តីជូនដំណឹង ចុះថ្ងៃទី ២៩ ខែកក្កដានេះថា តាមសេចក្តីជូនដំណឹងពីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តភាសាតាមរយៈប្រព័ន្ធកុំព្យូទ័រ។ លោករដ្ឋមន្ត្រីបានបន្តថា ការធ្វើតេស្តភាសាជប៉ុននឹងប្រព្រឹត្តិទៅនៅសាកលវិទ្យាល័យអន្តរជាតិប៊ែលធី សាខាទួលស្លែង នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២២ និងថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០២២ និងមួយទីតាំងមួយទៀតនៅវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ ដែលមានអាសយដ្ឋាន នៅសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយធ្វើតេស្តនៅថ្ងៃទី ២៧ ខែសីហា ថ្ងៃទី ០៣ ១០ និងទី១៦ ខែកញ្ញា ឆ្នាំ២០២២។ លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា ចំពោះការចុះឈ្មោះធ្វើតេស្តភាសាជប៉ុន បេក្ខជនត្រូវបង់ប្រាក់តម្លៃ ២២ ដុល្លារអាមេរិក ដោយបេក្ខជនត្រូវមានអាយុចាប់ពី ១៧ ឆ្នាំឡើងទៅ ដោយមិនគិតពីមក្រិតវប្បធម៌ឡើយ និងត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា ការបរិច្ឆេទនៃការធ្វើតេស្តនេះអាចនឹងផ្លាស់ប្តូរអាស្រ័យទៅលើស្ថានភាពជំងឺកូវីដ-១៩។

យោងតាមក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានឱ្យដឹងថា បច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាង ១ លាន ២ សែន នាក់ធ្វើការនៅក្រៅប្រទេស ក្នុងនោះមានពលករចំនួន ១១ ៤៥៣ នាក់ ធ្វើការនៅប្រទេសជប៉ុន៕ **អត្ថបទ៖ សំអឿន**

## អាជ្ញាធរខណ្ឌទួលគោក
## ចាត់វិធានការក្តៅលើផ្ទះបម្រើសេវាកម្មផ្លូវភេទក្រោមរូបភាពកោសជប់ ម៉ាស្សា

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៩ កក្កដា ២០២២ដោយ deth leng

លោក ជា ពិសី អភិបាលខណ្ឌទួលគោកបានបញ្ជាកម្លាំងចម្រុះចុះពិនិត្យមើលផ្ទះបម្រើសេវាកម្មផ្លូវភេទក្រោមរូបភាពកោសជប់ម៉ាស្សា ដែលប្រជាពលរដ្ឋកំពុងស្អប់ខ្ពើមបំផុត។ ប្រតិបត្តិការនេះបានធ្វើឡើងនៅវេលាម៉ោង ១៥៖១០ នាទីរសៀលថ្ងៃទី ២៩ ខែកក្កដា ស្ថិតនៅតាមបណ្តោយផ្លូវ ៦០៧ ជាប់របងវត្តនាគវ័ន្តភូមិ២២ សង្កាត់បឹងកក់២ ខណ្ឌទួលគោករាជធានីភ្នំពេញ។

យោងតាមប្រភពពីមន្រ្តីចម្រុះ ដែលចុះមកប្រតិបត្តិការបង្ក្រាបទៅលើផ្ទះបម្រើសេវាកម្មផ្លូវភេទក្រោមរូបភាពកោសជប់ និងម៉ាស្សានេះបានឲ្យដឹងថា មូលហេតុដែលកម្លាំងចម្រុះចុះមកពិនិត្យនិងបង្ក្រាបទីតាំងទាំងនេះគឺតាមបញ្ជាពីលោក ជា ពិសី អភិបាលខណ្ឌទួលគោកខណៈដែលលោកអភិបាលខណ្ឌបានដឹងច្បាស់ពីសកម្មភាពក្រុមនារីៗ ភាគច្រើនជាជនជាតិវៀតណាមនេះគឺពួកគេបម្រើសេវារួមភេទ ពុំមែនកោសជប់ម៉ាស្សានោះទេ។ ទីតាំងដែលបើករបរខុសច្បាប់នេះស្ថិតនៅជាប់របងវត្តនាគវ័ន្ត ក្បែរសាលារៀននិងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋទៀតផង ដែលមានចំនួន៩កន្លែង។ ក្នុងប្រតិបត្តិការខាងលើនេះត្រូវបានបងប្អូនប្រជាពលរដ្ឋរស់នៅភូមិ ២២ សង្កាត់បឹងកក់២ បានសំដែងការគាំទ្រទៅលើចំណាត់ការដ៏ក្តៅគគុករបស់លោក ជា ពិសី អភិបាលខណ្ឌទួលគោក ព្រោះលោកអភិបាលខណ្ឌបានគិតគូរពីសុខទុក្ខរបស់ប្រជាពលរដ្ឋដែលរងការមើលងាយមើលថោកពីសំណាក់មនុស្សមួយវាយតម្លៃទៅលើប្រជាពលរដ្ឋនៅក្បែរខាងជាស្ត្រីលក់ខ្លួនទាំងអស់នោះ។

ប្រជាពលរដ្ឋសូមប្រកាសគាំទ្ររាល់សកម្មភាពដឹកនាំការងាររបស់លោក ជា ពិសី អភិបាលខណ្ឌទួលគោកជានិច្ចនឹងជារៀងរហូត៕

## ទូកសង្ស័យរត់ពន្ធមនុស្ស
## លិចកណ្ដាលសមុទ្រការីបៀន បាត់បង់ជីវិតនិងសង្គ្រោះទាន់ជាង៧០នាក់

https://cen.com.kh/ Posted ByPen Srey NeatJuly 29, 2022

រដ្ឋធានីសានជួន (San Juan) ៖ ទូកដឹកជនចំណាកស្រុកមួយគ្រឿង បានលិច បណ្ដាលឲ្យមានមនុស្សយ៉ាងតិច៥នាក់បាត់បង់ជីវិត និង ជិត៧០នាក់ផ្សេងទៀត បានជួយសង្គ្រោះទាន់ពេលវេលា នៅភាគខាងលិចកោះព័រតូរីកូ (Puerto Rico) ស្ថិតក្នុងសមុទ្រការីបបៀន (Caribbean) ប៉ុន្តែករណីនេះ ធ្វើឲ្យអាជ្ញាធរ និង ឆ្មាំសមុទ្រសហរដ្ឋអាមេរិក បានដាក់ការសង្ស័យ ទៅលើការរត់ពន្ធមនុស្សតាមទូក។ សារព័ត៌មាន Al Jazeera បានចេញផ្សាយ កាលពីថ្ងៃព្រហស្បតិ៍ ទី២៨ ខែកក្កដា ថា ទូកដែលសង្ស័យ អំពីការរត់ពន្ធមនុស្សនេះ ជាទូកចុងក្រោយបំផុត នៅក្នុងការធ្វើដំណើរតាមសមុទ្រ ប្រកបដោយគ្រោះថ្នាក់បំផុត ឆ្លងកាត់ភាគខាងជើង សមុទ្រការីបបៀនដែលដឹកជនចំណាកស្រុក។

លោក រីកាដូ (Ricardo) អ្នកនាំពាក្យ ឆ្មាំសមុទ្រ សហរដ្ឋអាមេរិក បានបញ្ជាក់ កាលពីថ្ងៃព្រហស្បតិ៍ ថា នៅក្នុងឧបទ្ទវហេតុនោះ យ៉ាងហោចណាស់ មានជនចំណាកស្រុក ចំនួន៥នាក់ បានបាត់បង់ជីវិត ហើយមនុស្សចំនួន៦៦នាក់ផ្សេងទៀត បានជួយសង្គ្រោះ ផុតពីគ្រោះថ្នាក់។ ប៉ុន្តែអាជ្ញាធរ បានដាក់ការសង្ស័យថា ទូករត់ពន្ធ

មនុស្ស បានទម្លាក់ក្រុមជនចំណាកស្រុកទាំងនេះ ទៅក្នុងទឹក នៅក្បែរកោះដែលគ្មានមនុស្សរស់ ស្ថិតនៅភាគខាងលិច កោះព័រតូរីកូ។ លោក រីកាដូ (Ricardo) អ្នកនាំពាក្យ ឆ្មាំសមុទ្រសហរដ្ឋអាមេរិក បានបន្ថែមថា ក្រោយការសាកសួររួចមក អាជ្ញាធសហពន្ធ័ និង អាជ្ញាធរក្នុងតំបន់ បានកំណត់ថា មិនមានជនរងគ្រោះណាផ្សេង ពីជនចំណាកស្រុកទាំងនេះឡើយ៕រក្សាសិទ្ធិដោយ ៖ សារាយSN

## ស្ត្រី និងកុមារនៅអ៊ុយក្រែនកំពុងប្រឈមមុខនឹងការជួញដូរមនុស្ស

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២

(អន្តរជាតិ)៖ កាលពីដើមខែនេះ អាជ្ញាធរក្នុងទីក្រុង Kyiv បានចាប់ខ្លួនមេដឹកនាំនៃក្រុមឧក្រិដ្ឋជន ដែលបានជួញដូរស្ត្រីឱ្យរកស៊ីផ្លូវភេទ ជាមួយនឹងការសន្យាថា ផ្តល់ការងារស្របច្បាប់នៅបរទេស។ នេះបើ យោងតាមការចុះផ្សាយរបស់សារព័ត៌មានCNAនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២២។ យោងតាមអង្គការសហប្រជាជាតិ ស្ត្រី និងកុមារដែលភៀសខ្លួន ចេញពីជម្លោះក្នុងប្រទេសអ៊ុយក្រែន មានហានិភ័យខ្ពស់ នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច។ សូម្បីតែប៉ុន្មានខែ បន្ទាប់ពីការចាប់ផ្តើមនៃជម្លោះនេះ អ្នកតស៊ូមតិសិទ្ធិមនុស្សនៅទូទាំងសហភាពអឺរ៉ុប នៅតែព្រមានមន្ត្រីឱ្យមានការប្រុងប្រយ័ត្នបន្ថែមទៀត អំពីបញ្ហានេះ៕ អត្ថបទ៖ សាន លីម៉ា

# ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២

## ថៃចាប់ខ្លួនជនសង្ស័យពីរនាក់ពីបទ «ជ្រើសរើសពលករ» ឱ្យមជ្ឈមណ្ឌលឆបោកតាមទូរស័ព្ទ នៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times July 30, 2022

នគរបាលថៃ មកពីនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា Technology Crime Suppression Division (TCSD) បានចាប់ខ្លួនបុរស និងស្ត្រីម្នាក់ ពីបទជ្រើសរើសជនជាតិថៃ ឱ្យធ្វើការជាមួយនឹងក្រុមឆបោកតាមប្រព័ន្ធទូរស័ព្ទនៅប្រទេសកម្ពុជា។

យោងតាមនគរបាលប្រឆាំងបទល្មើសបច្ចេកវិទ្យា ជនសង្ស័យជាស្ត្រីជនជាតិថៃត្រូវបានចាប់ខ្លួនជាមួយជនរងគ្រោះមួយចំនួននៅក្នុងរថយន្តដោយប្រើផ្លូវវាងឆ្ពោះទៅស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ជាប់ព្រំប្រទល់ក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា។ ក្នុងអំឡុងពេលសាកសួរបន្ទាប់ពីចាប់ខ្លួន ស្ត្រីរូបនេះបានអះអាងថា គាត់បានទទួលសេវាកម្មជ្រើសរើសពីបងប្រុស និងមិត្តប្រុសរបស់គាត់ ដែលស្ថិតនៅក្នុងការឃុំឃាំងរបស់នគរបាល ដោយបន្ថែមថា គាត់នឹងទទួលបានកម្រៃជើងសារពីអ្នកបោកប្រាស់នៅមជ្ឈមណ្ឌលទូរស័ព្ទក្នុងប្រទេសកម្ពុជាសម្រាប់រាល់ការជ្រើសរើសដែលបញ្ជូនមកគាត់។ ជនសង្ស័យទី២ ត្រូវបាននគរបាលចាប់ខ្លួននៅផ្ទះមួយក្នុងសង្កាត់ On Nut Soi 17 ទីក្រុងបាងកក។ គាត់បានបដិសេធថាគាត់មិនបានដឹងពីការឆបោកដែលបានចោទប្រកាន់ទេ។ ជនសង្ស័យទាំង២នាក់ ត្រូវបានចោទប្រកាន់ពីបទឆបោកជាសាធារណៈ ជាសមាជិកនៃក្រុមឧក្រិដ្ឋជន ពីបទធ្វើការជាមួយអង្គការឧក្រិដ្ឋកម្មឆ្លងដែន និងពីបទលាងលុយកខ្វក់៕

## កម្ពុជា-ចិន ពិភាក្សាពីការពង្រឹងការទប់ស្កាត់បទឧក្រិដ្ឋកម្មឆ្លងដែន

https://www.postkhmer.com/national/ វី សុចាន់ | Publication date 30 July 2022 | 15:44 ICT

**ភ្នំពេញៈ** អាជ្ញាធរកម្ពុជាប្តេជ្ញាបន្តពង្រឹងការចែករំលែកព័ត៌មានពីស្ថានភាពឧក្រិដ្ឋកម្មឆ្លងដែន ជាមួយអាជ្ញាធរចិន ដើម្បីរួមគ្នាប្រយុទ្ធ និងទប់ស្កាត់បទឧក្រិដ្ឋកម្មឆ្លងដែន។ កាលពីថ្ងៃទី២៧ ខែកក្កដា លោក គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃកម្ពុជា បានជួបជាមួយលោក Wu Jianmin អ្នកទទួលបន្ទុកការិយាល័យសម្របសម្រួលកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងចិន-កម្ពុជា។ ស្ថានទូតចិនប្រចាំកម្ពុជាបញ្ជាក់តាមរយៈហ្វេសប៊ុកនាថ្ងៃទី២៨ ខែកក្កដា ថា ភាគីទាំង ២ បានផ្លាស់ប្តូរយោបល់យ៉ាងស៊ីជម្រៅលើកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន។

ស្ថានទូតចិនបញ្ជាក់ថា៖ «ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងប្រទេសទាំង២ និងមានប្រសាសន៍ថា ភាគីកម្ពុជារីករាយបន្តពង្រឹងការចែករំលែកព័ត៌មានស្ថានភាពនិងផ្លាស់ប្តូរបទពិសោធជាមួយភាគីចិនដោយតាមរយៈការិយាល័យសម្របសម្រួលកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាង ចិន-កម្ពុជា ដើម្បីរួមគ្នាប្រយុទ្ធនិងទប់ស្កាត់បទឧក្រិដ្ឋកម្មឆ្លងដែន»៕

## កម្ពុជាចាប់បញ្ជូនក្រុមឆបោកតាមទូរស័ព្ទជិត ១០០នាក់ទៅប្រទេសថៃវិញ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១ សីហា ២០២២ដោយ deth leng

ប្រភពព័ត៌មានបានឱ្យដឹងថា អាជ្ញាធរកម្ពុជាបានចាប់បញ្ជូនក្រុមជនឆបោកតាមទូរស័ព្ទ (Call Center)ជនជាតិថៃប្រគល់ជូនសមត្ថកិច្ចថៃវិញនៅច្រកព្រំដែនអចិន្ត្រៃយ៍ ស្ថិតនៅភូមិខ្លងលឹក ស្រុកអរញ្ញ ខេត្តស្រះកែវ។ តំណាងស្នងការនគរបាលខេត្តស្រះកែ វបានមកទទួលយកពួកជនឆបោកជនជាតិថៃសរុបចំនួន ៩៤នាក់ ដែលត្រូវបានអាជ្ញាធរកម្ពុជាបញ្ជូនត្រឡប់ទៅប្រទេសថៃវិញ ដើម្បីដំណើរការកាត់ទោសនៅប្រទេសថៃ ហើយក្នុងចំណោមជនសង្ស័យជនជាតិថៃទាំងនោះ មានដីកាចាប់ខ្លួនរួចហើយចំនួន ៧៤នាក់ និងនៅមិនទាន់មានដីកាចាប់ខ្លួនចំនួន ២០នាក់ទៀត គឺសរុប ៩៤នាក់។ ពាក់ព័ន្ធនឹងករណីនេះ ក្រុមជនសង្ស័យទាំងអស់បន្ទាប់ពីសមត្ថកិច្ចធ្វើការសាកសួរបានឱ្យដឹងថា ក្រុមពួកគេទាំងអស់ សុទ្ធតែជាប់ពាក់ព័ន្ធជាមួយនឹងអំពើឆបោកតាមទូរស័ព្ទ(Call Center) និងនៅមានជាច្រើនក្រុមទៀត រួមមានទាំងជនជាតិតៃវ៉ាន់ផងដែរ៕ អត្ថបទ៖ គង់ សំអាន

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូល ខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/08/01/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង១០ និង៣០នាទី ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ និងកម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១១នាក់ ស្រី៤នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែងបណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/08/01/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃចន្ទ ៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែសីហា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ឯកឧត្តម ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឱ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៣លើក សរុបចំនួន១៦នាក់ ស្រី៧នាក់ ក្មេងស្រី២នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែងបណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ដោយមានកិច្ចសហការជាមួយសមត្ថកិច្ចកម្ពុជា ការវាយឆ្មក់នៅទូទាំងប្រទេសចាប់បានជនសង្ស័យថៃ៩៤នាក់

https://www.khmertimeskh.com/ August 2, 2022

បន្ទាប់ពីប្រតិបត្តិការរួមគ្នាដោយក្រុម Police Cyber Task Force (PCT) និងអាជ្ញាធរកម្ពុជា ដើម្បីតាមចាប់ក្រុមឆបោកតាមទូរស័ព្ទ ជនជាតិថៃចំនួន ៩៤នាក់ ត្រូវបានបង្ក្រាប និងបញ្ជូនពីរាជធានីកម្ពុជាទៅកាន់ស្រុកអរញ្ញប្រាថេត ក្នុងខេត្តស្រះកែវកាលពីម្សិលមិញ។ ក្រុមនេះសុទ្ធតែបានធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទក្នុងរាជធានីភ្នំពេញ ដោយមានចំនួន៧៤ នាក់ប្រឈមនឹងដីកាចាប់ខ្លួនដែលចេញដោយ PCT ។ អ្នកទាំងអស់ត្រូវបានចោទប្រកាន់ក្រោមច្បាប់នានារបស់កម្ពុជា មុននឹងត្រូវបញ្ជូនទៅប្រឈមមុខនឹងការចោទប្រកាន់បន្ថែមទៀតនៅប្រទេសថៃ។

នាយឧត្តមសេនីយ៍ Damrongsak Kittiprapas អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាន PCT បានចាត់មន្ត្រី PCT នគរបាលអន្តោប្រវេសន៍ និងនគរបាលភូមិភាគ២ ទទួលពួកគេ ៩៤នាក់ នៅស្រុកជិតព្រំដែន។ យោងតាមប៉ូលីស ក្រុមនេះមានទំនាក់ទំនងជាមួយក្រុមជនខិលខូចចំនួនបួននាក់ ហើយអ្នកដែលត្រូវបានបញ្ជូនទៅវិញគឺជាសមាជិកសំខាន់ៗដែលធ្វើការឱ្យក្រុមអន្ធពាលតៃវ៉ាន់។ PCT បាននិយាយថា ប៉ូលីសនឹងពិនិត្យមើលករណីនេះ ហើយនឹងចាត់ការតាមផ្លូវច្បាប់។ សេចក្តីថ្លែងការណ៍បានបន្ថែមថា អ្នកសមគំនិតជនជាតិថៃនឹងត្រូវ

បញ្ជូនទៅកាន់ប៉ុស្តិ៍ប៉ូលីសក្នុងតំបន់ ដែលបានចេញដីកាចាប់ខ្លួននៅ Tha Mai និង Muang Chanthaburi ក្នុងខេត្ត Chanthaburi ក៏ដូចជាស្ថានីយ៍ Phahon Yothin និង Bang Khen ក្នុងទីក្រុងបាងកក។

ឧត្តមសេនីយ៍ឯក Pantana Nudchanad ប្រធានក្រុមប្រតិបត្តិការ PCT 1 បាននិយាយថា មានរបាយការណ៍ចំនួន ៤៩១ នៃមនុស្សដែលត្រូវបានបោកប្រាស់ដោយក្រុមជនខិលខូចតាមរយៈការហៅទូរស័ព្ទ នៅក្នុងខែកក្កដា ដែលជាការធ្លាក់ចុះគួរឱ្យកត់សម្គាល់ពីករណីចំនួន 965 ដែលបានកត់ត្រានៅក្នុងខែមិថុនា។ "ការចាប់ខ្លួនក្រុមជនខិលខូចទាំងនេះ ត្រូវបានធ្វើឡើងជាអាទិភាពដោយលោកនាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា។ ឧត្តមសេនីយ៍ឯក Pantana បាននិយាយថា "វាជាឧក្រិដ្ឋកម្មដែលប៉ះពាល់យ៉ាងខ្លាំងដល់អាយុជីវិតមនុស្ស។ ឥឡូវនេះយើងកំពុងធ្វើការជាមួយប៉ូលីសកម្ពុជា ដើម្បីចែករំលែកព័ត៌មានអំពីឧក្រិដ្ឋជន"។ លោកបានបន្ថែមថា ក្រុមខិលខូចទាំងនេះតែងតែផ្លាស់ប្តូរយុទ្ធសាស្ត្រដើម្បីឆបោកជនរងគ្រោះ និងប៉ូលិស។

ទោះយ៉ាងណាក៏ដោយ PCT បានត្រួតពិនិត្យ និងវិភាគគ្រប់វិធីដែលពួកគេប្រើ ដើម្បីធ្វើការចាប់។ ការវាយឆ្មក់ចុងក្រោយលើក្រុមជនពាលនៅកម្ពុជាបានធ្វើឡើងនៅ៤ទីតាំង។ ទី១ គឺសណ្ឋាគារ Jing Chung នៅខេត្តព្រះសីហនុ។ ជនសង្ស័យចំនួន២១ នាក់ត្រូវបានចាប់ខ្លួនសម្រាប់គម្រោងណាត់ជួបតាមអ៊ីនធឺណិតដែលរៀបចំដើម្បីទាក់ទាញជនរងគ្រោះឱ្យចូលរួមក្នុងការវិនិយោគក្លែងក្លាយ។ ទីតាំងទី២ ជាអគារកម្ពស់៥ជាន់ ក្នុងខេត្តដដែល។ ប៉ូលិសចាប់ខ្លួនជនសង្ស័យ១៨នាក់ ដែលមានអាជីវកម្មទាក់ទងនឹងព័ត៌មានវិទ្យា ធ្វើការឆបោកតាមទូរស័ព្ទទៅប្រទេសថៃ ដើម្បីបន្លំយកប្រាក់។ ជនសង្ស័យ១០នាក់ទៀត ត្រូវបានចាប់ខ្លួននៅខេត្តព្រះសីហនុ ពាក់ព័ន្ធករណីឆបោកប្រាក់ ក្នុងការរកស៊ីខុសច្បាប់មួយទៀត។ ទីបំផុតនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ សមត្ថកិច្ចបានចាប់ខ្លួនជនសង្ស័យចំនួន ២៥នាក់ ដែលបានបន្លំខ្លួនជាបុគ្គលិកក្រុមហ៊ុន DHL Express ដើម្បីបោកប្រាស់ជនរងគ្រោះ។ អ្នកខ្លះក៏បានអះអាងថាពួកគេជាមន្ត្រីមកពីគណៈកម្មការផ្សព្វផ្សាយ និងទូរគមនាគមន៍ជាតិថៃ (NBTC)។

## ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២

## មន្ត្រីជាន់ខ្ពស់សង្គមកិច្ចៈ
## ទោះក្រសួងសម្រេចបានសមិទ្ធផលជាច្រើន តែកិច្ចការពារ និងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទេ

http://freshnewsasia.com/ 2022-08-02 12:25pm

**(បាត់ដំបង)៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបើកវគ្គបណ្តុះបណ្តាលស្តីពី «ការគ្រប់គ្រងករណីក្នុងការវិលត្រឡប់ និងការធ្វើសមាហរណកម្ម» ជូនដល់មន្ត្រីរាជការនៅខេត្តបាត់ដំបង រយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ នាសណ្ឋាគារ ក្លាស់ស៊ី & ស្ប៉ា។ ពិធីនេះបានធ្វើឡើងក្រោមវត្តមាន លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោករដ្ឋមន្ត្រី វង សូត និងមានការចូលរួមពីលោកស្រី កែវ ដាណា អភិបាលរងខេត្តបាត់ដំបង, លោក គង់ សុភណារ៉ា ទីប្រឹក្សាក្រសួង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លោក ពុំ បូរ៉ាត ទីប្រឹក្សាក្រសួង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លោកវរសេនីយ៍ទោ ម៉ី វឌ្ឍនា នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ, លោក អ៊ុ ផ្លាកទីន ប្រធានសមាគន៍ EMDR, លោក ភួង សិទ្ធ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង និងអ្នកពាក់ព័ន្ធមួយចំនួនផងដែរ។

ក្នុងនាមតំណាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោក ញឹក សុវណ្ណារ៉ា បានលើកឡើងថា ឆ្នាំ២០២០ និង២០២១នេះ ពិភពលោកប្រឈមខ្លាំងទៅនឹងការដោះស្រាយបញ្ហាជាច្រើន

ដែលជាផលប៉ះពាល់សកល មានទាំងសង្គ្រាម សេដ្ឋកិច្ចរបស់មហាអំណាចពិភពលោក ទាំងការរាតត្បាតជម្ងឺដ៏កាចសាហាវកូវីដ១៩ គ្រោះធម្មជាតិ ដែលសុទ្ធតែជាកត្តាជំរុញឱ្យសេដ្ឋកិច្ចពិភពលោកកាន់តែដុនដាប រួមទាំងសេដ្ឋកិច្ចមហាអំណាចខ្លួនឯងផង។ ជាមួយគ្នានេះដែរ លោកបានបន្តថា ទន្ទឹមនឹងផលប៉ះពាល់នេះ ភាពក្រីក្របានគ្របដណ្តប់នៅទូទាំងសាកលលោក ដែលជាសញ្ញាមិនល្អ សម្រាប់សុខុមាលភាព និងសុវត្ថិភាពរបស់មនុស្សដែលជាប្រជាជននៃប្រទេសនីមួយៗ រួមទាំងក្រុមជនទុច្ចរិតឆ្លៀតឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីកេងចំណេញពីស្ថានភាព ប្រឈមរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិក្នុងគ្រាជួបការលំបាកនេះ។

មន្ត្រីជាន់ខ្ពស់រូបនេះ បានថ្លែងថា៖ «**យើងពិតជាបានខំប្រឹងជម្នះឧបសគ្គទាំងឡាយ ដោយបានធ្វើការងារយ៉ាងសកម្មភាពព្រមៗគ្នា ដើម្បីដោះស្រាយភាពប្រឈមតាមការណែនាំរបស់រាជរដ្ឋាភិបាល ដែលសកម្មភាពខ្លះ ត្រូវមានការខ្វះចន្លោះធកល្វែង ឬមើលរំលង ដោយផ្តែកទៅលើការតម្រង់ទិស នៃបញ្ហាថ្មីៗ និងការកាត់បន្ថយចំណាយទៅលើសកម្មភាពដែលមិនចាំបាច់**»។ លោក ញឹក សុវណ្ណារ៉ា បានបញ្ជាក់ថា តែទោះបីជាយ៉ាងនេះក្តី បញ្ហាសន្តិសុខមនុស្ស សន្តិសុខសង្គម មិនអាចបណ្តែតបណ្តោយឱ្យក្លាយជាភាពច្របូកច្របល់ដោយផ្តេកផ្តួលទៅលើធនធានថវិកាបានទេ ពោលគឺត្រូវបង្កើនការយកចិត្ត ទុកដាក់ប្រកបដោយឆន្ទៈមោះមុត ដើម្បីរក្សាស្ថេរភាពនៃសុវត្ថិភាពសង្គម និងពង្រឹងកិច្ចការពារ ទប់ស្កាត់ការឆ្លៀតឱកាសគ្រប់រូបភាព។ ទោះបីក្រសួងសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏កិច្ចការពារ និងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទេជាពិសេសការផ្តល់សេវាគាំទ្រសម្រាប់ជនរងគ្រោះនៅមានកម្រិត។

វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងករណីក្នុងការវិលត្រលប់ និងសមាហរណកម្ម ដែលមានរយៈពេល៣ថ្ងៃនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធដែលជាមន្ត្រីជួរមុខរួមមាន៖ មន្ត្រីមន្ទីរសង្គមកិច្ចខេត្ត មន្ត្រីកិច្ចការនារី មន្ត្រីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីមជ្ឈមណ្ឌលការងារខេត្ត មន្ត្រី គ.ក.ន.ក មន្ត្រីសង្គមកិច្ចការិយាល័យថ្នាក់ស្រុក និងអង្គការដែលធ្វើការពាក់ព័ន្ធនឹងការងារជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងការវិលត្រឡប់ និងសមាហរណកម្ម។ វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងគោលបំណងជយពង្រឹងការវាយតម្លៃឱ្យបានកាន់តែប្រសើរឡើងអំពីភាពងាយរងគ្រោះហានិភ័យស្ថានភាពគ្រួសារ និងជំនាញផ្សេងៗ របស់អ្នកវិលត្រឡប់សំដៅបង្កើតកម្មវិធីសមាហរណកម្មប្រកបដោយ និរន្តរភាពដែលមានការគាំទ្រផ្នែកសេដ្ឋកិច្ចសង្គម ចិត្តសង្គមព្រមទាំងលើកកម្ពស់ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីបម្រើឧត្តមប្រយោជន៍ជនរងគ្រោះ។

ដើម្បីរួមចំណែកដល់ការវិលត្រឡប់ប្រកបដោយនិរន្តរភាពនៃពលករទេសន្តរប្រវេសន៍ និងអ្នករស់រានមានជីវិតនៅក្នុងតំបន់គោលដៅ សូមលើកទឹកចិត្តស្នើដល់លោក លោកស្រីទាំងអស់គ្នារួមចំណែកយ៉ាងសកម្មក្នុងការសិក្សា និងចែករំលែកចំណេះដឹង និងបទពិសោធន៍ផ្ទាល់ខ្លួនកន្លងមក អំពីការគ្រប់គ្រងករណីក្នុងការវិលត្រលប់ និងការធ្វើសមាហរណកម្ម សំដៅធានាបានការវិលត្រលប់ប្រកបដោយសុវត្ថិភាព និងនិរន្តរភាពសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាទូទាំងប្រទេស។ បន្ថែមពីនេះ លោក ញឹក សុវណ្ណារ៉ា សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីនឹងចូលរួមសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាអង្គការ IOM ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ខ្ពស់ និងបន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះនឹងត្រូវខិតខំធ្វើយ៉ាងណាដើម្បីគ្រប់គ្រងករណីក្នុងការវិលត្រលប់ និងការធ្វើសមាហរណកម្មជនរងគ្រោះប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាពទៅក្នុងក្រុមគ្រួសារ និងសហគមន៍ដើម្បីទទួលបានសេវាសមស្រប និងទទួលបាននូវសេចក្តីថ្លៃថ្នូរ សុខុមាលភាព និងសិទ្ធិរបស់ពួកគាត់៕

# បទវិចារណកថា៖ ជារឿងចៃដន្យឬចេតនាដែល Al Jazeera ចុះផ្សាយថាមន្ត្រីកម្ពុជាពាក់ព័ន្ធជាមួយអ្នកជំនួញផ្លូវងងឹតជនជាតិចិន

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២ សីហា ២០២២ដោយ deth leng

កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ សារព័ត៌មានបរទេសមួយឈ្មោះ Al Jazeera បានចេញផ្សាយរបាយការណ៍ព័ត៌មានដោយលាតត្រដាងថា មន្ត្រីរដ្ឋាភិបាលកម្ពុជាមួយចំនួនបានជាប់ពាក់ព័ន្ធជាមួយនឹងបុរសជនជាតិចិនម្នាក់ឈ្មោះ តុង លីធឹង (Dong Lecheng) ដែលជាអ្នកជំនួញដ៏ល្បីរបស់ចិន។ អ្នកជំនួញរូបនេះត្រូវគេអះអាងដែរថា ជាប់ជំពាក់នឹងសំណុំរឿងឧក្រិដ្ឋកម្មជួញដូរមនុស្ស តាមរយៈការឆបោកតាមអ៊ីនធឺណេតប្រព្រឹត្តដោយក្រុមជនជាតិចិននៅក្នុងប្រទេសកម្ពុជា។ របាយការណ៍ចេញផ្សាយជាវីដេអូមានរយៈពេលជាង៤០នាទី បានរៀបរាប់ពីការស៊ើបអង្កេតលើអំពើជួញដូរមនុស្ស កើតឡើងដោយប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណេតរបស់ជនជាតិចិននៅកម្ពុជា និងបណ្តាញរបស់ពួកគេដែលពាក់ព័ន្ធជាមួយមន្ត្រីរដ្ឋាភិបាលកម្ពុជា។ នៅក្នុងរបាយការណ៍ស៊ើបអង្កេតរបស់សារព័ត៌មានAl Jazeeraរកឃើញទៀតថា ជនរងគ្រោះដោយសារតែការបោកប្រាស់តាមអ៊ីនធឺណេតពីសំណាក់ជនជាតិចិន គឺត្រូវបានបង្ខាំងនៅអគារ China Town ក្នុងខេត្តព្រះសីហនុ។

តាម Al Jazeera លោក តុង លីធឹង បានភ្ជាប់ខ្លួនជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀត។ លោក តុង លីធឹង មានជំនួញជាច្រើននៅកម្ពុជា ក្នុងនោះលោកជាជនសំខាន់ម្នាក់ជាប់ព័ន្ធនឹងគម្រោងអគារ China Town នៅព្រះសីហនុ ហើយលោកក៏មានជំនួញជាមួយសែស្រឡាយរបស់សមាជិកព្រឹទ្ធសភាលោក កុក អាន ផងដែរ។ អ្វីដែលសំខាន់ Al Jazeera ថា កាលពីឆ្នាំ២០១៨ លោក តុង លីធឹង បានផ្តល់យន្តហោះដ៏ទំនើបមួយគ្រឿងដល់នាយករដ្ឋមន្ត្រីកម្ពុជា ដើម្បីធ្វើដំណើរទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិនៅសហរដ្ឋអាមេរិក។ ជារួម សារព័ត៌មានមួយនេះបានបញ្ចេញសាច់រឿងលម្អិតតាមរយៈការសម្ភាសប្រភពជាច្រើនមានទាំងជនជាតិខ្មែរ ជនជាតិចិន រួមនឹងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ក្នុងចេតនាចង់បានការបញ្ជាក់ថា ខេត្តព្រះសីហនុ ពិតជាមានទីតាំងបង្ខាំងមនុស្សខុសច្បាប់ប្រព្រឹត្តដោយក្រុមជនជាតិចិន ដែលមាន លោក តុង លីធឹង នៅពីក្រោយ និងចង់អះអាងថាករណីនេះពិតជាមានទាក់ទងនឹងមន្ត្រីរដ្ឋាភិបាលកម្ពុជាមួយចំនួន។ និយាយពីករណីបង្ខាំងមនុស្សនៅក្នុងខេត្តព្រះសីហនុ ធ្លាប់មានការលើកឡើងច្រើនលើកច្រើនសារមកហើយ។ អាជ្ញាធរក៏តែងចុះទៅស្រាវជ្រាវភ្លាមៗនៅពេលដែលមានសេចក្តីរាយការណ៍ ឬមានពាក្យបណ្តឹង។ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ អ្នកនាំពាក្យរដ្ឋបាលខេត្តព្រះសីហនុ និងស្នងការខេត្តព្រះសីហនុ ក៏ទើបបានធ្វើសន្និសីទកាសែតបញ្ជាក់ពីករណីថ្មីមួយ ដែលថាមានមនុស្ស១៣នាក់ត្រូវបានបង្ខាំងទុកដោយខុសច្បាប់។ ព័ត៌មាននេះទទួលបានដោយសារមានការដាក់ពាក្យបណ្តឹងទៅអភិបាលខេត្តព្រះសីហនុ លោកគួច ចំរើន ប៉ុន្តែនៅពេលចុះស្រាវជ្រាវដល់ទីតាំង មិនដូចជាអ្វីដែលបានលើកឡើងក្នុងពាក្យបណ្តឹងឡើយ។ អ្នកដាក់ពាក្យបណ្តឹងនោះក៏មិនមានប្រភពច្បាស់ការ ដឹងត្រឹមថាជាជនជាតិចិនលាក់មុខប៉ុណ្ណោះ និងមិនដឹងគេមានបំណងយ៉ាងណាឱ្យពិតប្រាកដ។

ដូច្នេះទាញភ្ជាប់ទៅនឹងអ្វីដែលសារព័ត៌មាន Al Jazeera បានចេញផ្សាយថា មានការបង្ខាំងមនុស្សទុកជួញដូរនៅក្នុងខេត្តព្រះសីហនុ អាជ្ញាធរខេត្តនេះរកមិនទាន់ឃើញមានការជួញដូរមនុស្សទ្រង់ទ្រាយធំណាមួយកើតឡើងទេ។ បើដូច្នេះតើរបាយការណ៍ព័ត៌មានរបស់ Al Jazeera ជាការពិតមែនឬយ៉ាងណា? ទោះបីជានៅក្នុងការចេញផ្សាយរបស់ Al Jazeera មានបង្ហាញពីការសម្ភាសប្រភពជាច្រើនផ្សេងៗគ្នា តែការជឿទុកចិត្តបានគឺនៅតែស្ថិតក្នុងកម្រិតមួយ។ ការចេញផ្សាយរបាយការណ៍ហាក់បង្កនូវមន្ទិលសង្ស័យ ហើយមានភាពប្រទាក់ក្រឡាជាមួយនឹងចំណាត់ការរបស់ប្រទេសលោកខាងលិចដាក់លើកម្ពុជា។ តួយ៉ាងសារព័ត៌មាននេះបានព្យាយាមលើកពីសាច់រឿងដែលថ្នាក់ដឹកនាំ និងមន្ត្រីកម្ពុជាជាប់ពាក់ព័ន្ធជាមួយជនជាតិចិន ស្របពេលទំនាក់ទំនងរវាងកម្ពុជា-ចិន កំពុងត្រូវ

បានបណ្តាប្រទេសលោកខាងលិចតាមដានមិនដាក់ភ្នែក ពិសេសគឺសហរដ្ឋអាមេរិក។ សារព័ត៌មានដដែលក៏បាន រំលេចពីការជួញដូរមនុស្សនៅកម្ពុជា ស្របពេលកម្ពុជាក៏ទើបត្រូវបានអាមេរិកបញ្ចូលក្នុងបញ្ជីខ្មៅនៃការជួញដូរ មនុស្សទាំងមិននឹកស្មានដល់។ ដូច្នេះទើបមានសំណួរចោទថា របាយការណ៍ព័ត៌មានស៊ើបអង្កេតនេះ ធ្វើឡើង ដោយត្រឹមត្រូវ មានឯករាជ្យភាព សុក្រឹតភាព ឬក៏មាននិន្នាការនយោបាយ និងមានការបង្គាប់បញ្ជាពីនរណាម្នាក់? ការដាក់ចម្ងល់ដូច្នេះ ព្រោះតែមិនមែនជាលើកទីមួយទេដែលកម្ពុជាធ្លាប់ត្រូវបានបណ្តាប្រទេសមួយចំនួនរៀបចំសេណារីយ៉ូដាក់កំហុស ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកូកប្រកាសពីចំណុចអវិជ្ជមាន អូសទាញឱ្យអន្តរជាតិមើល មកកម្ពុជាក្នុងផ្លូវមិនល្អ នៅពេលកម្ពុជាមិនព្រមធ្វើតាមការបញ្ជា ឬធ្វើឱ្យបាត់បង់ប្រយោជន៍របស់ពួកគេ។ អាមេរិក លេចធ្លោខ្លាំងជាងគេក្នុងការដាក់សម្ពាធមកលើកម្ពុជា។ ម្យ៉ាងវិញទៀត របាយការណ៍ដែលសារព័ត៌មាន Al Jazeera បានចេញផ្សាយ ត្រូវបានភាគីកម្ពុជាច្រានចោលទាំងស្រុង។

អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ បានបញ្ជាក់ប្រាប់សារព័ត៌មានក្នុងស្រុកមួយ ដោយលោក ចាត់ទុកការផ្សាយនេះជាព័ត៌មានប្រទូសរ៉ាយតែប៉ុណ្ណោះ។ លោកសង្កត់ធ្ងន់ថា ព័ត៌មានដែលចេញផ្សាយរបៀបនេះ ប្រទេសណាក៏មានដែរ ដូច្នេះត្រូវតែរួមគ្នាទប់ស្កាត់និងកម្ចាត់ឱ្យបាន។

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាលោកសុខ ឥសានវិញ ចាត់ទុកការអះអាងថា មានអ្នកជំនួញចិន ឧបត្ថម្ភយន្តហោះដល់នាយករដ្ឋមន្ត្រីកម្ពុជា ជារឿងមិនពិត។ លោកថារាជរដ្ឋាភិបាលកម្ពុជាមានលុយគ្រប់គ្រាន់ ដើម្បីចំណាយលើការធ្វើដំណើរ មិនចាំបាច់យកយន្តហោះមកពីណាជួយទេ។ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាយល់ឃើញថា អ្វីដែល Al Jazeera ចេញផ្សាយ ជាការនិយាយលម្អៀងខាងមនោគមន៍វិជ្ជា និងមានចេតនាមូល បង្កាច់កម្ពុជាតែប៉ុណ្ណោះ។ ដោយឡែកពាក់ព័ន្ធថា មានការចូលដៃចូលជើងជាមួយក្រុមទុច្ចរិត លោក សុខ ឥសាន ថារឹតតែមិនអាចទៅរួច ព្រោះរាល់លើកនៅពេលមានករណីនេះកើតឡើងរាជរដ្ឋាភិបាលកម្ពុជាតែងចាត់វិធានការជា និច្ច។ សរុបមក ការចេញផ្សាយរបាយការណ៍ព័ត៌មានដែលរសើប ហើយមានពាក់ព័ន្ធនឹងថ្នាក់ដឹកនាំប្រទេសណាមួយ គួរមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុត ព្រោះវាអាចជះឥទ្ធិពលអាក្រក់ ធ្វើឱ្យប្រទេសនោះបាត់បង់ សណ្តាប់ធ្នាប់ មានអស្ថិរភាព ឬជួបភាពចលាចលបាន។ ប្រសិនបើការចេញផ្សាយព័ត៌មានមានគោលបំណង ញុះញង់ បង្កឱ្យមានការភាន់ច្រឡំ សារព័ត៌មាននោះអាចប្រឈមនឹងចំណាត់ការផ្លូវច្បាប់។ សម្រាប់កម្ពុជា ក៏មិនគួរ ណាត្រូវបានចាត់ទុកជាទីតាំងជួញដូរមនុស្សដ៏អាក្រក់បំផុតនោះដែរ។ ក្នុងន័យធ្វើឱ្យប្រសើរឡើងនូវការលុបបំបាត់ ការជួញដូរមនុស្ស កម្លាំងមានសមត្ថកិច្ចរបស់កម្ពុជាបានចុះអនុវត្តសកម្មភាពជាប្រចាំ។ ថ្មីៗនេះរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ក៏ទើបបានប្រកាសដាក់ចេញចំណាត់ការទ្រង់ទ្រាយធំមួយទៀត គឺការធ្វើប្រតិបត្តិការត្រួតពិនិត្យលើជន បរទេសទាំងអស់ដែលរស់នៅកម្ពុជា ដើម្បីស្វែងរកមុខសញ្ញាអ្នកជួញដូរមនុស្ស និងដើម្បីស្វែងរកជនបរទេសដែល រស់នៅខុសច្បាប់។ នេះសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថា កម្ពុជាមិនឱ្យជនណាមកបង្កបញ្ហាបំផ្លាញសន្តិភាព និង ស្ថិរភាពដែលខំស្វែងរកបានយ៉ាងលំបាកនោះឡើយ។ កម្ពុជាជារដ្ឋឯករាជ្យមានសិទ្ធិជាម្ចាស់លើខ្លួនឯង គ្មាននរណាម្នាក់មកលាបពណ៌បានជាដាច់ខាត ទោះបីអ្នកនោះជាមហាអំណាចពិភពលោកក៏ដោយចុះ៕

## ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន ជួបពិភាក្សាការងារជាមួយ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃសាធារណរដ្ឋឥណ្ឌូណេស៊ី

https://news.btv.com.kh/ 2022/08/02 06:54:12 pm

ភ្នំពេញ ៖ នៅព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោកជំទាវ RETNO L.P MARSUDI រដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋឥណ្ឌូណេស៊ី នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

ក្នុងជំនួបពិភាក្សាការងារ ភាគីឥណ្ឌូណេស៊ី បានថ្លែងអំណរគុណដល់កងកម្លាំងនគរបាលជាតិកម្ពុជា ដែលបានខិតខំប្រឹងប្រែងជួយសង្គ្រោះពលរដ្ឋឥណ្ឌូណេស៊ីរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះ ភាគីទាំងពីរ ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់ និងយល់ស្របគ្នាលើការងារមួយចំនួន ដើម្បីបន្តអនុវត្ត គឺការជួយគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរគ្រប់ប្រភេទ ជាពិសេសបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យា និងជំរុញកិច្ចសហប្រតិបត្តការឲ្យកាន់តែជិតស្និទ្ធ និងស៊ីជម្រៅដោយបង្កើតយន្តការផ្លាស់ប្តូរព័ត៌មានបម្រើឲ្យការស៊ើបអង្កេតការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ការបង្កើតឲ្យមានមន្ត្រីបង្គោលដើម្បីផ្តល់ព័ត៌មាន និងគំនិតផ្តួចផ្តើមបង្កើតអនុស្សារណៈយោគយល់គ្នា (MOU) ដែលជាមូលដ្ឋានសម្រាប់បម្រើឲ្យការចាត់តាំងអនុវត្ត និងគាំទ្រឲ្យក្រុមបច្ចេកទេសកងកម្លាំងនគរបាលជាតិនៃប្រទេសទាំងពីរ។ ភាគីទាំងពីរ ក៏បានពិភាក្សាគ្នាដើម្បីស្វែងរកវិធីសាស្ត្រ និងយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ និងលុបបំបាត់ឲ្យដល់ឫសគល់នៃបណ្តាញឧក្រិដ្ឋជនជួញដូរមនុស្សទាំងនៅឥណ្ឌូណេស៊ី និងនៅប្រទេសកម្ពុជា។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានរំលឹកអំពីគុណបំណាច់របស់កងទ័ពឥណ្ឌូណេស៊ីក្នុងបេសកកម្មស្វែងរកសន្តិភាពជូនប្រទេសកម្ពុជាក្នុងទសវត្សទី៩០ផងដែរ។ ជាចុងក្រោយ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានជូនពរ លោកជំទាវ RETNO L.P MARSUDI និងសហការី ក្នុងការស្នាក់នៅកម្ពុជា សូមមានសុខភាពល្អ សប្បាយរីករាយ និងជោគជ័យក្នុងការបំពេញភារកិច្ច៕

## ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២
## រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ីប្តេជ្ញាតាមចាប់អ្នកជ្រើសរើសជនជាតិម៉ាឡេស៊ីពីក្រុមឆបោក

https://www.khmertimeskh.com/ Khmer Times August 4, 2022

លោក Dato' Sri Saifuddin Abdullah រដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ីបានមានប្រសាសន៍កាលពីយប់មិញថា លោកនឹងជួបជាមួយមន្ត្រីអនុវត្តច្បាប់ម៉ាឡេស៊ី ដើម្បីជំរុញឱ្យមានចំណាត់ការប្រឆាំងនឹងអ្នកជ្រើសរើសជនជាតិម៉ាឡេស៊ីដែលងាយរងគ្រោះ។ ថ្លែងទៅកាន់ក្រុមធុរជនម៉ាឡេស៊ីនៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា លោកបានស្វែងរកទស្សនៈរបស់សហគមន៍ធុរកិច្ច ដែលភាគច្រើនជាសមាជិកនៃសភាធុរកិច្ចម៉ាឡេស៊ី កម្ពុជា ដឹកនាំដោយប្រធានគឺ លោកឧកញ៉ា តាន់ គីម៉េង។ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការកើនឡើងនៃចំនួនប្រជាជនម៉ាឡេស៊ី ដែលបានធ្លាក់ខ្លួនជាជនរងគ្រោះ នៃអ្នកបោកប្រាស់ទាំងនេះ និងជនរងគ្រោះរបស់ពួកគេ ដែលត្រូវបានបោកបញ្ឆោតឱ្យទៅរកការងារ ដែលមានប្រាក់ខែល្អក្នុងវិស័យបដិសណ្ឋារកិច្ច រដ្ឋមន្ត្រីការបរទេសបានមានប្រសាសន៍ថា វាដល់ពេលហើយ ដើម្បីតាមដានអ្នកជ្រើសរើសដែលបានរកឃើញវិធីដ៏ប៉ិនប្រសប់ ដើម្បីដាក់នុយជនស្លូតត្រង់ និងអ្នកមិនដឹងព័ត៌មាន។ "យើងនឹងធ្វើការជាមួយភ្នាក់ងារពាក់ព័ន្ធ និងភូមិន្ទនគរបាលម៉ាឡេស៊ី ដើម្បីតាមដាន និងបង្ក្រាបអ្នកជ្រើសរើសបុគ្គលិក ហើយនេះអាចជួយរារាំងអ្នកដែលគេជ្រើសរើសថ្មីពីការដើរដោយមិនដឹងខ្លួនចូលទៅក្នុងបរិយាកាសការងារដ៏យង់ឃ្នង។

លោក Dato' Sri Saifuddin បាននិយាយថា "ខ្ញុំបានអន្តរាគមន៍ជាមួយរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១៩ នៅពេលដែលជនជាតិម៉ាឡេស៊ី ៤៧ នាក់ត្រូវបានជួយសង្គ្រោះ ដោយមានអន្តរាគមន៍ផ្ទាល់ពីនាយករដ្ឋមន្ត្រី មហាធា មហាម៉ាត់។ នៅពេលដែលវាបង្ហាញថា វានឹងក្លាយជាមេរៀនមួយ ប្រជាជនកាន់តែច្រើនត្រូវបានគេបោកបញ្ឆោតឱ្យចូលមកប្រទេសកម្ពុជា និងកន្លែងដទៃទៀតនៃពិភពលោក ទៅក្នុងសកម្មភាពខុសច្បាប់បែបនេះ" ។

ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Eldeen Husaini Mohd Hashim មានប្រសាសន៍ថា ស្ថានទូតម៉ាឡេស៊ីនៅភ្នំពេញ បានជួយសង្គ្រោះប្រជាជនម៉ាឡេស៊ីចំនួន ៤៦ នាក់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំនេះ បន្ទាប់ពី

ពួកគេត្រូវបានគេជឿថា ត្រូវបានបោកបញ្ឆោតដោយការផ្តល់ជូនការងារដែលរកបានកម្រៃខ្ពស់នៅក្រៅប្រទេស។ លោកឯកអគ្គរដ្ឋទូតបានមានប្រសាសន៍ថា "រហូតមកដល់ពេលនេះ មានជាង ៦០ករណី (ជនជាតិម៉ាឡេស៊ី ដែលត្រូវបានចោទប្រកាន់ពីបទឆបោកការងារ) ដែលកំពុងរង់ចាំចំណាត់ការបន្តទៀត។ យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរកម្ពុជា ក្នុងការសម្របសម្រួលពួកគេឱ្យត្រឡប់ទៅផ្ទះវិញ"៕

## នគរបាលអន្តោប្រវេសន៍ថៃ អនុញ្ញាតធ្វើប័ណ្ណព្រំដែនប្រថាប់ត្រាបានដល់៧ថ្ងៃវិញ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ៤ សីហា ២០២២ដោយ Sokhom Khon

នៅព្រឹកថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២នេះ ខាងភាគីនគរបាលអន្តោប្រវេសន៍របស់ថៃ បានប្រាប់ឲ្យដឹងថា ប័ណ្ណព្រំដែន Border pass ចាប់ពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២នេះតទៅ បានអនុញ្ញាតឲ្យអាជីវករ និងប្រជាពលរដ្ឋចូលទឹកដីថៃនោះ ប្តូរប្រថាប់ត្រាបានដល់៧ថ្ងៃវិញហើយ នេះបើតាមប្រភពពី chin bunna។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានប្រាប់ឲ្យដឹងថា បងប្អូនប្រជាពលរដ្ឋដែលមានបំណងធ្វើប័ណ្ណព្រំដែន (Border Pass) សូមភ្ជាប់មកជាមួយនូវឯកសាររួមមានច្បាប់ថតចម្លងតាមច្បាប់ដើម ១ អត្តសញ្ញាណប័ណ្ណថតចម្លង១ច្បាប់។ ២សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតចំនួន១ច្បាប់។ ៣ សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ចំនួន១ច្បាប់។ ៤រូបថត ៤X៦ ចំនួន ២សន្លឹក រូបថតកូន ភ្ជាប់មកជាមួយ៤X៦ ចំនួន ២សន្លឹក ករណីមានកូនរួមដំណើរជាមួយហើយ បង់សេវាចូលរដ្ឋចំនួន២០.០០០រៀលក្នុងរយះពេលកន្លះខែទើបអាចមកយកប័ណ្ណព្រំដែន(Border Pass) បាន ប័ណ្ណនេះ អាចចូលបាន២ខេត្តជាប់គ្នា គឺខេត្តស្រះកែវ និងខេត្តប្រាជីនបូរី ហើយមានរយៈពេលស្នាក់នៅ៧ថ្ងៃ ប័ណ្ណព្រំដែននេះគេតម្រូវឲ្យមកធ្វើនៅរដ្ឋបាលខេត្តបន្ទាយមានជ័យប្រក ចេញចូលតែមួយ។

លោក អ៊ុំ រាត្រី បានបញ្ជាក់ឲ្យដឹងបន្តថា ការធ្វើប័ណ្ណព្រំដែនសព្វថ្ងៃនេះមានសន្ទុះលឿនរលូនប៉ុន្តែពលរដ្ឋនៅលំបាកក្នុងករណីបញ្ជាក់អំពីលិខិតស្នាម ត្រូវថតចម្លងតាមច្បាប់ដើមហើយ បោះត្រា ប្រើពេលយូរគិតរយះពេលចាប់ពីធ្វើប័ណ្ណនេះមានបរិមាណច្រើនមានទាំងខេត្តឆ្ងាយៗក៏អាចធ្វើបានដែរឲ្យតែមានសៀវភៅមកស្នាក់នៅ ក្នុងខេត្តបន្ទាយមានជ័យដែរហើយចំណែកប័ណ្ណនេះត្រូវចំណាយពេល១៥ថ្ងៃទើបធ្វើរួចលទ្ធផលនេះមិនទាន់ឆ្លើយតបតាមសំណូមពរ និងផែនការដាក់ចុះបាននៅឡើយ។ លោក អ៊ុំ រាត្រី បានបញ្ជាក់ឲ្យដឹងទៀតថា ប័ណ្ណព្រំដែន Border Passនេះ សម្រាប់ពលរដ្ឋនៅក្នុងខេត្តបន្ទាយមានជ័យជាប់តំបន់ព្រំដែន ត្រូវរដ្ឋបាលខេត្ត ស្រះកែវនិងខេត្តប្រាជីនបូរីបាន អនុញ្ញាតិឲ្យពលរដ្ឋកម្ពុជានៅខេត្តជាប់ព្រំដែនអាចឆ្លងចេញចូលបានចំនួន២ខេត្តជាប់គ្នាគឺខេត្តស្រះកែវនិងខេត្តប្រាជីនបូរីហើយមានរយៈពេលស្នាក់នៅ៧ថ្ងៃ៕ អត្ថបទ៖ វ៉ាន់ ណាង

# ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង បានអនុញ្ញាតជូនលោកស្រី រ៉េតណូ អិល.ភី. ម៉ារស៊ូឌី ( Retno L. P. Marsudi ) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមានរដ្ឋសភា

http://nokorwatnews.com/ 05/08/2022

ភ្នំពេញ ៖ នៅរសៀលថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតជូនលោកស្រី រ៉េតណូ អិល.ភី. ម៉ារស៊ូឌី (Retno L. P. Marsudi) រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមានរដ្ឋសភា។

សម្តេចក្រឡាហោម ស ខេង បានស្វាគមន៍ចំពោះលោកស្រីរដ្ឋមន្ត្រី និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា។ សម្តេចមានប្រសាសន៍ថា សម្តេចបានទទួលព័ត៌មានអំពីគណៈប្រតិភូឥណ្ឌូនេស៊ីដឹកនាំដោយលោកស្រីរដ្ឋមន្ត្រីបានជួបពិភាក្សាការងារជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា។ សម្តេចក៏បានបង្ហាញការចូលរួមគាំទ្រលទ្ធផលនៃកិច្ចប្រជុំនោះ។ សម្តេចក្រឡាហោមក៏បានជម្រាបជូនលោកស្រីផងដែរអំពីការគាំទ្រការបន្តពង្រឹង ពង្រីកប្រតិបត្តិការរវាងកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរ ជាពិសេសលើការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដូចជាការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សជាដើម។ សម្តេចក៏បានអរគុណភាគីឥណ្ឌូនេស៊ី ដែលកន្លងមកបានផ្ញើជូនក្រសួងមហាផ្ទៃ នូវសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា ដើម្បីបង្កើតក្របខ័ណ្ឌ នៃកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃលើការងារកិច្ចសហប្រតិបត្តិការក្នុងវិស័យអនុវត្តច្បាប់។ សម្តេចក៏បានជម្រាបជូនអំពីវឌ្ឍនភាពនៃការពិនិត្យទៅលើMOUនេះ ដោយសម្តេចត្រៀមរួចជាស្រេចក្នុងការចាត់មន្ត្រីជំនាញដើម្បីជជែកពិភាក្សាសារទៅលើខ្លឹមសារជាក់ស្តែង និងធានាទៅដល់យន្តការសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាមួយឥណ្ឌូនេស៊ី។

ជាការឆ្លើយតប លោកស្រីរដ្ឋមន្ត្រីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចក្រឡាហោម ដែលតែងផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អ ជាពិសេសទៅលើការជួយគាំទ្រ និងគាំពារពលរដ្ឋឥណ្ឌូនេស៊ីដែលជួបបញ្ហាផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លោកស្រីបានក៏សម្តែងនូវសេចក្តីរីករាយដែលទទួលបាននូវព័ត៌មានអំពីបច្ចុប្បន្នភាពនៃដំណើរការធ្វើសេចក្តីព្រាង MOU និងថាឥណ្ឌូនេស៊ីត្រៀមខ្លួនជានិច្ចក្នុងការបន្តធ្វើការជាមួយក្រុមការងារជំនាញរបស់កម្ពុជាដើម្បីឈានទៅបញ្ចប់នុងចុះហត្ថលេខារវាងភាគីទាំងពីរ។ លោកស្រី រ៉េតណូ អិល.ភី. ម៉ារស៊ូឌី ក៏បានយកឱកាសនេះថ្លែងអំណរគុណសម្តេចក្រឡាហោម ដែលតែងបានយកចិត្តទុកដាក់ជួយតាមសំណូមពររបស់ភាគីឥណ្ឌូនេស៊ី ពិសេសការជួយប្រជាពលរដ្ឋឥណ្ឌូនេស៊ីដែលស្ថិតក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ ហើយបានជួបប្រទះបញ្ហាពាក់ព័ន្ធនឹងស្ថានភាពអន្តោប្រវេសន៍។

សម្តេចក្រឡាហោម ក៏បានជម្រាបជូនលោកជំទាវដែរថាសម្តេចផ្ទាល់ពិតជាគាំទ្រចំពោះការបង្កើតឲ្យមាននូវក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការផ្លូវការតាមរយៈ MOUនេះ និងសង្ឃឹមជឿជាក់ថាភាគីទាំងពីរនឹងអាចពិនិត្យលទ្ធភាពបន្ថែមនូវអ្វីដែលជាការងារចាំបាច់ និងសំខាន់សំខាន់ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ក៏ដូចជាកិច្ចសហប្រតិបត្តិការលើការងារកសាង និងបណ្តុះបណ្តាល សមត្ថភាពមន្ត្រីអនុវត្តច្បាប់ ព្រមទាំងការងារជួយគាំពារទៅវិញទៅមកដល់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរផងដែរ៕

# រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ីពិភាក្សាជាមួយនគរបាលកម្ពុជាអំពីការជួញដូរបោកបញ្ឆោតតាមបច្ចេកវិទ្យា

https://khmer.voanews.com/ 03 សីហា 2022 លាស់ លីបលីប

ភ្នំពេញ៖ រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី កាលពីថ្ងៃអង្គារ បានជួបជាមួយអគ្គស្នងការនគរបាលជាតិកម្ពុជា ដោយពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើបញ្ហាការបោកប្រាស់ កេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ីនធើណិត ឬហៅថា Scam និងការជួញដូរមនុស្ស ខណៈមានសេចក្តីរាយការណ៍ថា ជនជាតិឥណ្ឌូណេស៊ីក្លាយជាជនរងគ្រោះលើទឹកដីកម្ពុជា។ រដ្ឋមន្ត្រីមន្ត្រីការបរទេសឥណ្ឌូណេស៊ី អ្នកស្រី Retno Marsudi ដែលបានមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ដើម្បីចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ ក្នុងសប្តាហ៍នេះ ក៏បានឆ្លៀតពេលជួបពិភាក្សាជាមួយលោក នេត សាវឿន អគ្គស្នងការនគរបាលជាតិកម្ពុជា កាលពីថ្ងៃអង្គារ អំពីកិច្ចសហប្រតិបត្តិការ ការដោះស្រាយបញ្ហាកេងប្រវ័ញ្ចប្រជាជនឥណ្ឌូណេស៊ី ដោយសារក្រុមហ៊ុនបោកប្រាស់តាមអ៊ីនធើណិត និងចាត់វិធានការបង្ការការជួញដូរមនុស្ស។ នេះបើតាមសាររបស់អ្នកស្រី Retno Marsudi នៅលើប្រព័ន្ធTwitter កាលពីថ្ងៃទី២ ខែសីហា។ អ្នកស្រី Retno Marsudi បានបញ្ជាក់ថា៖ «យើងបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ ដើម្បីដោះស្រាយការកេងប្រវ័ញ្ចប្រជាជនឥណ្ឌូណេស៊ី ដោយក្រុមហ៊ុនបោកប្រាស់តាមប្រព័ន្ធអ៊ីនធើណិត និងវិធានការបង្ការការជួញដូរមនុស្ស»។ រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី ក៏បានឱ្យដឹងថា អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះជនជាតិឥណ្ឌូណេស៊ីជាង៦០នាក់ ទាក់ទងការចាញ់បោកតាមប្រព័ន្ធអ៊ីនធើណិតនៅកម្ពុជាផងដែរ។

សារព័ត៌មាន TEMPO.CO ដែលមានមូលដ្ឋាននៅទីក្រុងហ្សាការតា ចេញផ្សាយព័ត៌មានកាលពីថ្ងៃទី២ ខែសីហានេះឱ្យដឹងថា កាលពីថ្ងៃអាទិត្យ ជនជាតិឥណ្ឌូណេស៊ីទាំង៦២នាក់ ត្រូវបានអាជ្ញាធរកម្ពុជាជួយសង្គ្រោះ ដែលជាជនរងគ្រោះនៃការជួញដូរក្នុងអំពើបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធើណិត។ សារព័ត៌មាននេះឲ្យដឹងថាជនជាតិឥណ្ឌូណេស៊ីជាង១០០នាក់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍ ក្រោយត្រូវបានជួយសង្គ្រោះក្នុងប្រទេសកម្ពុជា។

លោក ឆាយ គឹមខឿន អ្នកនាំពាក្យរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រាប់វីអូអេនៅថ្ងៃពុធនេះថា ក្នុងជំនួបនោះ កម្ពុជានិងភាគីឥណ្ឌូណេស៊ីបានពិភាក្សាពីកិច្ចសហប្រតិបត្តិការរវាងគ្នាក្នុងការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ដែលនឹងធ្វើឡើងតាមរយៈការផ្លាស់ប្តូរគណៈប្រតិភូ ការបើកវគ្គសិក្សា និងសិក្ខាសាលាក្នុងការដកពិសោធន៍ ការផ្លាស់ប្តូរព័ត៌មាន និងការស្នើសុំស្រាវជ្រាវស៊ើបអង្កេតជាដើម។ លោកថ្លែងថា៖ «យើងជជែកគ្នាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ក្រាបបទឧក្រិដ្ឋឆ្លងដែន ពាក់ព័ន្ធកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងនគរបាលជាតិកម្ពុជា និងឥណ្ឌូណេស៊ី។ យើងរៀបចំឱ្យមានយន្តការ[ទំនាក់ទំនង]ក្នុងការផ្លាស់ប្តូរព័ត៌មាន...ក្នុងការបង្ក្រាបបទឧក្រិដ្ឋ [គឺមាន]តែប៉ុណ្ណឹងទេ»។ វីអូអេមិនទាន់អាចសុំការបញ្ជាក់ពីស្ថានទូតឥណ្ឌូណេស៊ីប្រចាំនៅទីក្រុងភ្នំពេញបាននៅឡើយទេ។

លោក អំ សំអាត នាយករងទទួលបន្ទុកកម្មវិធីឃ្លាំមើលនៃអង្គការលីកាដូ មើលឃើញថា បញ្ហាប្រឈមនៃការកេងប្រវ័ញ្ច និងការជួញដូរមនុស្សតាមប្រព័ន្ធអ៊ីនធើណិតនេះ គឺជាបញ្ហាមួយដែលគ្រោះថ្នាក់បំផុតសម្រាប់កម្ពុជា ពីព្រោះសហរដ្ឋអាមេរិកបានដាក់ចំណាត់ថ្នាក់លេខ៣ ដែលជាចំណាត់ថ្នាក់មិនល្អសម្រាប់កម្ពុជា។ លោកកត់សម្គាល់ថា មិនមែនមានតែជនជាតិឥណ្ឌូណេស៊ីទេដែលរងគ្រោះ គឺមានជនជាតិផ្សេងទៀត ដូចជាថៃ វៀតណាម ហ្វីលីពីន ចិនជាដើម។ នេះបើយោងទៅតាមការចេញផ្សាយតាមរយៈសារព័ត៌មាននានា។ លោកថ្លែងថា៖ «បញ្ហាទាំងអស់នេះ យើងមើលឃើញថា វាជារឿងមួយ ភាគគ្រោះថ្នាក់ និងធ្ងន់ធ្ងរទាក់ទងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មជាដើម។ អ៊ីចឹងហើយបានយើងឃើញថា ថ្មីៗនេះ សហរដ្ឋអាមេរិកបានដាក់កម្ពុជាយើងក្នុងបញ្ជីមួយមិនល្អ ចំពោះការជួញដូរមនុស្ស ហើយដាក់ចំណាត់ថ្នាក់លេខ៣ទៅទៀត»។ លោក អំ សំអាត បន្ថែមថា

កម្ពុជាត្រូវតែអនុវត្តច្បាប់អន្តោប្រវេសន៍ ក្រមព្រហ្មទណ្ឌ និងច្បាប់នានាឱ្យមានប្រសិទ្ធភាព និងត្រូវបន្ថែមយន្តការក្នុងការទប់ស្កាត់បទល្មើសនានា និងត្រូវសហការគ្នាឱ្យបានល្អជាមួយប្រទេសជិតខាង ដើម្បីធ្វើឱ្យកម្ពុជាអាចចៀសផុតពីចំណាត់ថ្នាក់នៃបញ្ជីខ្មៅរបស់សហរដ្ឋអាមេរិក និងអាចត្រឡប់ទៅទាក់ទាញអ្នកវិនិយោគ និងភ្ញៀវទេសចរបានឡើងវិញ។

កាលពីខែកក្កដា ឆ្នាំ២០២២នេះ ក្រសួងការបរទេសអាមេរិកបានចេញរបាយការណ៍ប្រចាំឆ្នាំអំពីការជួញដូរមនុស្សនៅលើពិភពលោក ដោយក្នុងនោះបានបង្ហាញថា កម្ពុជាបានធ្លាក់ចំណាត់ថ្នាក់ពីកម្រិតពីរ (Tier 2) មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំធ្វើអ្វីជាដុំកំភួន ដើម្បីកែលម្អ ហើយមិនបានបំពេញតាមបទដ្ឋានអប្បបរមាដូចដែលបានកំណត់។ របាយការណ៍នេះក៏បានលើកឡើងអំពីការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ីនធើណិត ឬហៅថាScam។

គួរបញ្ជាក់ថាកាលពីកន្លងទៅ មានសេចក្ដីរាយការណ៍ថាកម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធើណិត ដោយប្រើប្រាស់កម្លាំងបរទេស ធ្វើការនៅតាមអគារក្នុងប្រទេសកម្ពុជា រហូតមានសេចក្ដីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឲ្យមានសេរីភាព ការធ្វើទារុណកម្មនិងការជំរិតទារប្រាក់ជាដើម៕

## យោធាថៃឃាត់ពលរដ្ឋខ្មែរប្រុសស្រី១៩នាក់ចាញ់បោកមេខ្យល់ឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 04/08/2022

ប្រទេសថៃ ៖ ពលរដ្ឋខ្មែរប្រុសស្រី ១៩នាក់ ចាញ់បោកមេខ្យល់ឆ្លងដែនចូលប្រទេសថៃខុសច្បាប់ត្រូវយោធាថៃឃាត់ខ្លួន នៅវេលាម៉ោង០៤ និង ៣០ នាទី ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២។

សមត្ថកិច្ចតាមបន្ទាត់ព្រំដែនប្រាប់ថាៈ កងវរសេនាធំបញ្ជាការយោធភូមិភាគទី១២ ក្រុមការងារពិសេស កងវរសេនាធំថ្មើរជើងលេខ១១១ កម្លាំង Burapha រៀបចំកងទ័ពលោក Lt. Thor 1207 និង Lt. T.D. 1206 ដើរល្បាត និងតាមដាន ការពារ ទប់ស្កាត់ការធ្វើអន្តោរប្រវេសន៍ខុសច្បាប់ របស់ពលករខ្មែរ តាមច្រកធម្មជាតិ ព្រំដែនតំបន់បាននេនសំបួរ ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ចន្លោះច្រក ប៉ុស្តិ៍តាប្រាយ៉ា ១៩-ប៉ុស្តិ៍តាប្រាយ៉ា ២០ ដែលជាចំណុចមិនច្បាស់លាស់។ ក្រោយមកក្រុមប្រតិបត្តិការចម្រុះបានរកឃើញជនសង្ស័យមួយក្រុម ដែលគេជឿថា ជាពលករខ្មែរចំណាកស្រុក ឆ្លងដែនពីកម្ពុជាចូលប្រទេសថៃ នៅចំណុចភូមិនឿន សំបន់ រួចដើរតាមចំការ ដំឡូងមីប្រជាពលរដ្ឋ ហើយក៏បាននាំកម្លាំងចុះឡោមព័ទ្ធ និងឃាត់ខ្លួនមនុស្សសរុប ១៩នាក់ក្នុងនោះប្រុស០៧នាក់ ស្រី០៩នាក់ ក្មេងប្រុស០២នាក់ ស្រី០១នាក់)បន្ទាប់ពីការ ត្រួតពិនិត្យគ្មានលិខិតឆ្លងដែន ឬលិខិតអនុញ្ញាតការងារ នៅក្នុងប្រទេសថៃ និងពិនិត្យសីតុណ្ហភាពរាងកាយ ស្របតាមវិធានការបង្ការជំងឺកូវីដ-១៩ និងជំងឺអុតស្វា ។ ពលករទាំងអស់បានបញ្ជូនទៅកម្លាំងជម្នាញដើម្បីសួរនាំបន្ត ៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/08/04/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរ

សេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៣លើក សរុបចំនួន៤១នាក់ ស្រី១៨នាក់ ក្មេង៤នាក់ ក្មេងស្រី២នាក់ ។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២

### កម្ពុជា ឥណ្ឌូនេស៊ី ពង្រីកប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងអំពើជួញដូរមនុស្ស

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២២ ÷លោក ជួន បូណា

ភ្នំពេញ÷កម្ពុជា ឥណ្ឌូនេស៊ី ពង្រីកប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងអំពើជួញដូរមនុស្ស ដើម្បីជានាឱ្យមានសុខដុមរមនីកម្មក្នុងតំបន់ និងសកលលោក។ ក្នុងជំនួបសំដែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវ រ៉េតណូ អិល.ភី. ម៉ារស៊ូឌី (Retno L. P. Marsudi) រដ្ឋមន្ត្រីការបរ ទេសនៃសាធារណរដ្ឋឥណ្ឌូនេស៊ី នៅវិមានរដ្ឋសភា កាលពីរសៀលថ្ងៃទី៤ ខែសីហា ឆ្នាំ ២០២២ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍អំពីការគាំទ្រការបន្តពង្រឹង ពង្រីកកិច្ចសហ ប្រតិបត្តិការរវាងកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរ ជាពិសេសលើការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដូចជាការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សជាដើម។ សម្តេចក៏បានអរគុណភាគីឥណ្ឌូនេស៊ី ដែលកន្លងមកបានធ្វើជូនក្រសួងមហាផ្ទៃនូវសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា ដើម្បីបង្កើតក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃលើការងារកិច្ចសហប្រតិបត្តិការក្នុងវិស័យអនុវត្តច្បាប់។ សម្តេចក៏បានជម្រាបជូនអំពីវឌ្ឍនភាព នៃការពិនិត្យទៅលើ MOUនេះ ដោយសម្តេចត្រៀមរួចជាស្រេចក្នុងការចាត់មន្ត្រីជំនាញដើម្បីជជែកពិភាក្សាទៅលើខ្លឹមសារជាក់ ស្តែង និងជានាទៅដល់យន្ត ការសហប្រតិបត្តិការប្រកប ដោយប្រសិទ្ធភាពជាមួយឥណ្ឌូនេស៊ី។

ជាការឆ្លើយតប លោកជំទាវរដ្ឋមន្ត្រីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចក្រឡាហោម ដែលតែងផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អ ជាពិសេសទៅលើការជួយគាំទ្រ និងគាំពារពលរដ្ឋឥណ្ឌូនេស៊ីដែលជួបបញ្ហាផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លោកជំទាវ ក៏បានសំដែងនូវសេចក្តីរីករាយដែលទទួលបាននូវព័ត៌មានអំពីបច្ចុប្បន្ន ភាពនៃដំណើរការធ្វើសេចក្តី ព្រាងMOU នឹងថាឥណ្ឌូនេស៊ីត្រៀមខ្លួនជានិច្ចក្នុងការបន្តធ្វើការជាមួយក្រុមការងារជំនាញរបស់កម្ពុជាដើម្បីឈានទៅបញ្ចប់និងចុះហត្ថ លេខារវាងភាគីទាំងពីរ។ លោកជំទាវ រ៉េតណូ អិល.ភី. ម៉ារស៊ូឌី ក៏បានយកឱកាសនេះថ្លែងអំណរគុណសម្តេចក្រឡាហោម ដែលតែងបានយកចិត្តទុកដាក់ជួយតាមសំណូមពររបស់ភាគីឥណ្ឌូនេស៊ី ពិសេសការជួយប្រជាពលរដ្ឋឥណ្ឌូនេស៊ី ដែលស្ថិតក្នុងស្ថានភាព នៃជំងឺកូវីដ-១៩ ហើយបានជួបប្រទះបញ្ហាពាក់ព័ន្ធនឹងស្ថានភាពអន្តោប្រវេសន៍។

សម្តេចក្រឡាហោម ក៏បានជម្រាបជូនលោកជំទាវដែរថា សម្តេចផ្ទាល់ពិតជាគាំទ្រចំពោះការបង្កើតឱ្យមាននូវក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការផ្លូវការតាមរយៈMOUនេះនិងសង្ឃឹមជឿជាក់ថា ភាគីទាំងពីរនឹងអាចពិនិត្យលទ្ធភាពបន្ថែមនូវអ្វីដែលជាការងារចាំបាច់ និងសំខាន់ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ក៏ដូចជា

កិច្ចសហប្រតិបត្តិការលើការងារកសាង និងបណ្តុះ បណ្តាល សមត្ថភាពមន្ត្រីអនុវត្តច្បាប់ ព្រមទាំងការងារជួយគាំពារទៅវិញទៅមកដល់ប្រជាពលរដ្ឋនៃប្រទេសទាំងពីរ៕

## ក្រសួងសង្គមកិច្ច និង JICA ជួបពិភាក្សាគ្នាលើគម្រោងអភិវឌ្ឍន៍សមត្ថភាព លើការជួយជនរងគ្រោះដោយការជួញដូរមនុស្ស

http://freshnewsasia.com/ 2022-08-05 03:47pm

**(ភ្នំពេញ)៖** លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២នេះ បានដឹកនាំក្រុមមន្ត្រីនាយកដ្ឋានជំនាញ ទទួលជួបប្រជុំពិភាក្សាជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ជំនួបពិភាក្សានេះ ស្តីពី «**ការរៀបចំគម្រោងអភិវឌ្ឍន៍សមត្ថភាព លើការជួយជនរងគ្រោះដោយការជួញដូរមនុស្ស សម្រាប់ឆ្នាំ២០២២ -២០២៦**» ដែលមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី០១-០៥ ខែសីហា ឆ្នាំ២០២២ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ បន្ទាប់ពីបានជួបប្រជុំពិភាក្សាពិគ្រោះយោបល់គ្នារវាងមន្ត្រីបច្ចេកទេសរបស់ក្រសួង និងភាគីម្ចាស់ជំនួយ (JICA) បានទទួលលទ្ធផលជាផ្លែផ្កា ហើយភាគីទាំងពីរបានព្រមព្រៀងលើចំណុចជាច្រើន ដែលអាចជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបានចុះហត្ថលេខាឯកភាពគ្នា នៅរសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២២។ គម្រោងនេះ មានវិសាលភាពអនុវត្តន៍នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប៕

## លោកបណ្ឌិត អ៊ិត សំហេង អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅក្រុមហ៊ុនCPF ប្រទេសថៃ

http://freshnewsasia.com/ 2022-08-07 03:40pm

**(ប្រទេសថៃ)៖** លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ អមដំណេ◌ីរដោយឯកឧត្តម អ៊ូ ក សោភ័ណ្ឌ ឯកអគ្គរាជទូត កម្ពុជាប្រចាំប្រទេសថៃ នាព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២ បានដឹកនាំគណៈប្រតិភូរបស់ក្រសួង អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងរោងចក្រCPF(Thailand)Public Company Limited ស្ថិតនៅក្នុងខេត្តនគររាជសីម៉ា ប្រទេសថៃ។ នាឱកាសនោះ លោកបណ្ឌិត អ៊ិត សំហេង បានផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន ដែលសម្តេចទាំងពីរ តែងតែយកចិត្តទុក្ខដាក់ពីសុខទុក្ខរបស់បងប្អូនពលកររបស់យើងដែលបានកំពុងធ្វើការនៅបរទេស។

លោកបណ្ឌិត អ៊ិត សំហេង បានថ្លែងអំណរគុណដល់ក្រុមហ៊ុន CPF ដែលបានផ្តល់ឱកាសការងារ ជូនដល់ពលករកម្ពុជា ឲ្យបានបម្រើការងារនៅក្រុមហ៊ុន ទទួលបានប្រាក់ឈ្នួល ការស្នាក់នៅ និងហូបចុកបានយ៉ាងសមរម្យ ថែមទាំងយកចិត្តទុកដាក់ទៅលើបញ្ហាសុខភាពរបស់ពលករកម្ពុជាបានយ៉ាងល្អប្រសើរផងដែរ។ ទន្ទឹងនឹងនេះ លោករដ្ឋមន្ត្រី បានធ្វើការកោតសរសើរចំពោះបងប្អូនពលករខ្មែរ ដែលមានស្មារតីតស៊ូ អត់ធ្មត់ ខិតខំធ្វើការងាររកប្រាក់កម្រៃចិញ្ចឹមគ្រួសារ ជាការចូលរួមចំណែក រកចំណូលជូនជាតិ ដែលបងប្អូនពលករខ្មែរនៅថៃមានចំនួន ១,២ លាននាក់ ម្នាក់ៗក្នុងមួយខែបានផ្ញើប្រាក់ទៅផ្ទះរាប់រយដុល្លារអាមេរិក ដើម្បីផ្គត់ផ្គង់ជីវភាព ហើយបើគិត ១ឆ្នាំ បងប្អូនពលករយើងបានផ្ញើលុយទៅក្រុមគ្រួសារ ប្រមាណរាប់សិបលានដុល្លារអាម៉េរិក និងនៅពេលបងប្អូនយើង វិលត្រឡប់ទៅប្រទេសកំណើត នឹងមានចំណេះ និងជំនាញការងារ មកអភិវឌ្ឍប្រទេសផងដែរ។ លោកបណ្ឌិត អ៊ិត សំហេង ដែលជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ គូសបញ្ជាក់ថា គណៈកម្មការបានបើកយុទ្ធនាការផ្តល់ភាព

ស្របច្បាប់ ជូនបងប្អូនពលករដោយផ្តល់លិខិតធ្វើដំណើរ TD និងចេញប័ណ្ណ OCWC និងឯកសារផ្សេងទៀតដែលធានាបាននូវភាពស្របច្បាប់ក្នុងការស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ ជារួមគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ជានិច្ចជាកាល បានផ្តល់នូវការគាំពារគ្រប់បែបយ៉ាងជូនដល់បងប្អូនពលករ និងក្រុមគ្រួសារ។

លោកបណ្ឌិត បន្តថា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ កន្លងមកថ្មីៗនេះ ដែលគណបក្សប្រជាជនកម្ពុជាទទួលបានជ័យជំនះយ៉ាងត្រចះត្រចង់បំផុត ដែលក្នុងនោះក៏មានបងប្អូនពលករ និងក្រុមគ្រួសាររបស់បងប្អូន បានទៅចូលរួមបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា សបញ្ជាក់ពីការបន្តគោរពស្រលាញ់ គាំទ្រ និងជឿជាក់ មកលើការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានដឹកនាំកម្ពុជាឲ្យមានការរីកចម្រើនលើគ្រប់វិស័យ។ លោករដ្ឋមន្ត្រី ក៏បានផ្តាំផ្ញើដល់បងប្អូនពលករកម្ពុជា បន្តថែទាំសុខភាព ដោយប្រកាន់ខ្ជាប់នូវវិធានការពារពីការឆ្លងជំងឺកូវីដ-១៩ និងត្រូវចូលរួមគោរពច្បាប់របស់ប្រទេសគេឲ្យបានល្អ ជៀសវាងបង្កបញ្ហាផ្សេងៗដែលធ្វើឲ្យមានទោសទណ្ឌដល់ខ្លួន។

គួរបញ្ជាក់ជូនដែរថា រោងចក្រ CPF (Thailand) Public Company Limited. ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន C.P. Group ប្រទេសថៃ បានចាប់ដំណើរការអាជីវកម្មនៅប្រទេសថៃ តាំងពីឆ្នាំ ១៩៩៦។ រោងចក្រ CPF ជារោងចក្រផលិតសាច់មាន់គ្រប់ប្រភេទ មានទាំងសាច់មាន់ស្រស់ ទាំងអាហារឆ្អិន សម្រាប់ផ្គត់ផ្គង់ទាំងក្នុងស្រុក និងក្រៅប្រទេស បច្ចុប្បន្នក្រុមហ៊ុន CPF នៅខេត្តនគររាជសីមា មានពលករទាំងអស់សរុបចំនួន ៨ ៣៥២ នាក់ ក្នុងនោះ ពលករកម្ពុជា មានចំនួន ២ ២៧៥នាក់ (ស្រី ១ ០៩៧នាក់)៕

## ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ៖ ក្រុមហ៊ុនក្នុងប្រទេសថៃ ទទួលយកពលករកម្ពុជា ធ្វើការនៅក្នុងក្រុមហ៊ុនរបស់ខ្លួន មានប្រាក់ខែសមរម្យ និងការថែទាំលើសេវាផ្សេងៗទៀតបានល្អ

https://cen.com.kh/ Posted ByPen Srey NeatAugust 7, 2022

ប្រទេសថៃ៖ នៅក្នុងដំណើរបំពេញបេសកម្ម ចុះសួរសុខទុក្ខ និងពិនិត្យមើលស្ថានភាពរស់នៅ និងកន្លែងធ្វើការងាររបស់បងប្អូនពលករកម្ពុជា តបតាមការអញ្ជើញរបស់រោងចក្រ CPF (Thailand) Public Company Limited. ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន C.P. Group ប្រទេសថៃ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នាព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២ បានទទួលជួបពិភាក្សាការងារជាមួយ លោក CHARIN Tongsuk អភិបាលរង រួមជាមួយប្រធានមន្ទីរការងារខេត្ត និងស្នងការរបស់ខេត្តនគររាជសីម៉ា នៃប្រទេសថៃ។

នាឱកាសនោះ ក្នុងនាមអភិបាលខេត្តលោក CHARIN Tongsuk បានទទួលស្វាគមន៍ឯកឧត្តមបណ្ឌិត អ៊ិត សំហេង និងគណៈប្រតិភូយ៉ាងកក់ក្តៅបំផុត ដែលបានអញ្ជើញមកកាន់ខេត្តរបស់លោក និងបានជម្រាបជូនពីស្ថានភាពរួមរបស់ពលករកម្ពុជាដែលកំពុងធ្វើការ និងស្នាក់នៅក្នុងខេត្ត នគររាជសីម៉ា ជូនដល់គណៈប្រតិភូផងដែរ។

ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ក៏បានលើកឡើងថា តាមរយៈនៃកិច្ចព្រមព្រៀងនៃប្រទេសយើងទាំងពីរកម្ពុជា-ថៃ មកដល់ពេលនេះ គឺមានកិច្ចសហការជាមួយគ្នាបានយ៉ាងល្អគ្រប់វិស័យ។ ថ្នាក់ដឹកនាំប្រទេស ប្រជាពលរដ្ឋ និងអ្នកវិនិយោគបានធ្វើដំណើរចេញចូលប្រទេសទាំងពីរយ៉ាងមមាញឹក ក្រោយពីបើកសេដ្ឋកិច្ចប្រទេសឡើងវិញ។ ទំហំពាណិជ្ជកម្មរបស់ប្រទេសទាំងពីរ ក៏កាន់តែធំឡើងៗ នេះកើតចេញពីចំណងមិត្តភាព ដ៏រឹងមាំនៃប្រទេសយើងទាំងពីរ។ ទាក់ទងទៅនឹងកម្លាំងពលកម្ម ឯកឧត្តមរដ្ឋមន្ត្រីបញ្ជាក់ថា ប្រទេសទាំងពីរមានកិច្ចព្រមព្រៀងលើវិស័យ

កម្លាំងពលកម្ម និងការងារនេះ តាំងពីឆ្នាំ២០០៣ រហូតដល់បច្ចុប្បន្ន មានអនុស្សរណៈយោគយល់គ្នាចំនួន២ គឺវិស័យការងារ និងការផ្លាស់ប្តូរកម្លាំងពលកម្ម។ ឯកឧត្តមបណ្ឌិត បញ្ជាក់ថា កិច្ចសហប្រតិបត្តិការនេះ ពិតជាបានផ្តល់ប្រយោជន៍ទៅវិញទៅមក ដែលជាកិច្ចសហប្រតិបត្តការឈ្នះ-ឈ្នះ។ ឈ្នះរបស់កម្ពុជាគឺផ្តល់ឱកាសការងារដល់ពលកររបស់ខ្លួន ដោយទទួលបានប្រាក់ខែសមរម្យ ការថែទាំយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរ និងខាងរោងចក្រសហគ្រាស ព្រមទាំងទទួលបាននូវបទពិសោធន៍ ចំណេះជំនាញពីការងារ។ ចំពោះភាពឈ្នះរបស់ភាគីថៃ គឺទទួលបានកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ទៅលើខ្សែចង្វាក់ផលិត របស់រោងចក្រសហគ្រាសខ្លួន។

ជាមួយគ្នានេះដែរ ឯកឧត្តមរដ្ឋមន្ត្រី បញ្ជាក់ថា ពលកររបស់កម្ពុជាមានសិទ្ធិដូចពលករបរទេស និងសិទ្ធិដូចពលករថៃស្របតាមផ្លូវច្បាប់ហើយ បានថ្លែងអំណរគុណដល់អាជ្ញាធរថៃ ដែលនៅក្នុងដំណាក់កាលរាតត្បាតកូវីដ-១៩ ពលករកម្ពុជាទទួលបានការព្យាបាល និងចាក់វ៉ាក់សាំងដូចជាពលរដ្ឋថៃដែរ។ ឯកឧត្តមបណ្ឌិត ក៏អរគុណខាងក្រុមហ៊ុនដែលទទួលយកពលករកម្ពុជា បានធ្វើការនៅក្នុងក្រុមហ៊ុនរបស់ខ្លួន មានប្រាក់ខែសមរម្យ និងការថែទាំលើសេវាផ្សេងៗទៀតបានល្អ។ ម្យ៉ាងវិញទៀត កម្លាំងពលកម្មដែលមកពីកម្ពុជា ពិតជាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងពលរដ្ឋថៃ ពីព្រោះប្រទេសយើងទាំងពីរមានទំនៀមទំលាប់ ប្រពៃណី សាសនា ការរស់នៅស្រដៀងគ្នា។

លោកអភិបាលរងខេត្តនគរាជស៊ីម៉ា និងខាងតំណាងក្រុមហ៊ុន CPF បានថ្លែងអំណរគុណចំពោះឯកឧត្តមរដ្ឋមន្ត្រីដែលបានដឹកនាំគណៈប្រតិភូចុះមកពិនិត្យផ្ទាល់ពីស្ថានភាពការងារ និងការរស់នៅរបស់ពលករកម្ពុជាដែលបានកំពុងធ្វើការនៅក្នុងក្រុមហ៊ុន ហើយសង្ឃឹមថា កិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរនៅតែបន្តភាពល្អប្រសើរជាមួយនឹងគ្នាបន្ថែមទៀត៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ៖ ពលករខ្មែរនៅថៃមានចំនួន ១,២លាននាក់ មានស្មារតីតស៊ូ អត់ធ្មត់ ខិតខំធ្វើការងាររកប្រាក់កម្រៃចិញ្ចឹមគ្រួសារ

https://cen.com.kh/ Posted ByPen Srey NeatAugust 7, 2022

ប្រទេសថៃ៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នាព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២ បានដឹកនាំគណៈប្រតិភូរបស់ក្រសួង អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងរោងចក្រCPF(Thailand)Public Company Limited ស្ថិតនៅក្នុងខេត្តនគរាជសីម៉ា ប្រទេសថៃ។ នាឱកាសនោះ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន ដែលសម្តេចទាំងពីរ តែងតែយកចិត្តទុក្ខដាក់ពីសុខទុក្ខរបស់បងប្អូនពលកររបស់យើងដែលបានកំពុងធ្វើការនៅបរទេស។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានថ្លែងអំណរគុណដល់ក្រុមហ៊ុន CPF ដែលបានផ្តល់ឱកាសការងារ ជូនដល់ពលករកម្ពុជា ឲ្យបានបម្រើការងារនៅក្រុមហ៊ុន ទទួលបានប្រាក់ឈ្នួល ការស្នាក់នៅ និងហូបចុកបានយ៉ាងសមរម្យ ថែមទាំងយកចិត្តទុកដាក់ទៅលើបញ្ហាសុខភាពរបស់ពលករកម្ពុជាបានយ៉ាងល្អប្រសើរផងដែរ។

ទន្ទឹងនឹងនេះ ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើការកោតសរសើរចំពោះបងប្អូនពលករខ្មែរ ដែលមានស្មារតីតស៊ូ អត់ធ្មត់ ខិតខំធ្វើការងាររកប្រាក់កម្រៃចិញ្ចឹមគ្រួសារ ជាការចូលរួមចំណែក រកចំណូលជូនជាតិ ដែលបងប្អូនពលករខ្មែរនៅថៃមានចំនួន ១,២លាននាក់ ម្នាក់ៗក្នុងមួយខែបានផ្ញើប្រាក់ទៅផ្ទះ រាប់រយដុល្លារអាម៉េរិក ហើយបើគិត ១ឆ្នាំៗ បងប្អូនពលករយើងបានផ្ញើលុយទៅក្រុមគ្រួសារ រាប់រយលានដុល្លារអាម៉េរិក និងនៅពេលបងប្អូនយើង វិលត្រឡប់ទៅប្រទេសកំណើត នឹងមានចំណេះ និងជំនាញការងារ មកអភិវឌ្ឍប្រទេសផងដែរ។ ឯកឧត្តមរដ្ឋមន្ត្រី បានផ្តាំផ្ញើ

ដល់បងប្អូនពលករកម្ពុជា បន្តថែទាំសុខភាព ដោយប្រកាន់ខ្ជាប់នូវវិធានការពារពីការឆ្លងជំងឺកូវីដ-១៩ និងត្រូវចូលរួមគោរពច្បាប់របស់ប្រទេសគេឲ្យបានល្អ ជៀសវាងបង្កបញ្ហាដែលធ្វើឲ្យមានទោសទណ្ឌដល់ខ្លួន។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ដែលជាប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ គូសបញ្ជាក់ថា គណៈកម្មការបានបើកយុទ្ធនាការផ្តល់ភាពស្របច្បាប់ ជូនបងប្អូនពលករដោយផ្តល់លិខិតធ្វើដំណើរ TD និងចេញប័ណ្ណ OCWC និងឯកសារផ្សេងទៀតដែលជានាបាននូវភាពស្របច្បាប់ក្នុងការស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ ជារួមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជានិច្ចជាកាល បានផ្តល់នូវការគាំពារគ្រប់បែបយ៉ាងជូនដល់បងប្អូនពលករ និងក្រុមគ្រួសារ។

គួរបញ្ជាក់ជូនដែរថា រោងចក្រ CPF (Thailand) Public Company Limited. ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន C.P. Group ប្រទេសថៃ បានចាប់ដំណើរការអាជីវកម្មនៅប្រទេសថៃ តាំងពីឆ្នាំ ១៩៩៦។ រោងចក្រ CPF ជារោងចក្រផលិតសាច់មាន់គ្រប់ប្រភេទ មានទាំងសាច់មាន់ស្រស់ ទាំងអាហារឆ្អិន សម្រាប់ផ្គត់ផ្គង់ទាំងក្នុងស្រុក និងក្រៅប្រទេស បច្ចុប្បន្នក្រុមហ៊ុន CPF នៅខេត្តនគររាជសីមា មានពលករទាំងអស់សរុបចំនួន ៨ ៣៥២ នាក់ ក្នុងនោះ ពលករកម្ពុជា មានចំនួន ២ ២៧៥នាក់ (ស្រី ១ ០៩៧នាក់)៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## រដ្ឋមន្ត្រីក្រសួងការងារជួបសំណេះសំណាលជាមួយពលករខ្មែរនៅខេត្តក្នុងប្រទេសថៃ

https://www.khmertimeskh.com/ Khmer Times August 8, 2022

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង ដឹកនាំគណៈប្រតិភូចុះសួរសុខទុក្ខកម្មករកម្ពុជានៅរោងចក្រក្នុងក្រុងនគររាជសីមា ប្រទេសថៃ ដើម្បីពិនិត្យស្ថានភាពរបស់ពួកគេ។ ក្នុងអំឡុងពេលធ្វើឡើងនៅថ្ងៃទី៧ ខែសីហា លោករដ្ឋមន្ត្រី សំហេង បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន ដោយបាននិយាយថា ពួកគាត់ទាំងពីរតែងតែយកចិត្តទុកដាក់ចំពោះពលករនៅក្រៅប្រទេស។ រដ្ឋមន្ត្រីក្រសួងការងារបានថ្លែងអំណរគុណដល់ក្រុមហ៊ុនថៃដែលបានផ្តល់ឱកាសការងារដល់ពលករកម្ពុជា ក៏ដូចជាផ្តល់អាហារដល់ពួកគេ និងបានថែរក្សាសុខភាពពលករកម្ពុជាឱ្យបានល្អផងដែរ។

លោករដ្ឋមន្ត្រី សំហេង បានកោតសរសើរដល់កម្មករ-កម្មការិនីកម្ពុជា ដែលមានស្មារតីតស៊ូ ប្រឹងប្រែងធ្វើការប្រកបរបរចិញ្ចឹមជីវិត ដើម្បីបង្កើនចំណូលជាតិ។ លោកបានបន្ថែមថា ក្នុងមួយឆ្នាំៗ ពលករនៅក្រៅប្រទេសផ្ញើប្រាក់ប្រមាណ ២ពាន់លានដុល្លារ ដល់គ្រួសារ ហើយពេលពួកគេត្រឡប់មកកម្ពុជាវិញ ពួកគេបាននាំយកជំនាញដែលរៀននៅបរទេសមកជាមួយផងដែរ។ លោក សំហេង ដែលជាប្រធានគណៈកម្មការនីតិកម្ម បានគូសបញ្ជាក់ថា គណៈកម្មការបានបើកយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់កម្មករ ដោយការផ្តល់ និងចេញឯកសារធ្វើដំណើរ។ លោករដ្ឋមន្ត្រី បានណែនាំដល់កម្មករ-កម្មការិនី បន្តថែរក្សាសុខភាព ដោយប្រកាន់ខ្ជាប់នូវវិធានការ ដើម្បីការពារការរីករាលដាល និងការឆ្លងជំងឺកូវីដ-១៩ និងចូលរួមគោរពច្បាប់ប្រទេសដែលខ្លួនកំពុងធ្វើការ៕

## ពលករ១គ្រួសារត្រឡប់ពីថៃ ប្តីលាងជើងអូរក្បែរបន្ទាយទាហាន ជួបគ្រោះអកុសល

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ០៧ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ១៤:១១

ខេត្តបន្ទាយមានជ័យ ៖ បុរសជាពលករម្នាក់បានស្លាប់បាត់បង់ជីវិត ខណៈជនរងគ្រោះត្រឡប់មកពីធ្វើការនៅប្រទេសថៃជាមួយប្រពន្ធកូន ក៏បានលាងជើងអូរព្រំដែនក្បែរបន្ទាយទាហានឈុតខ្មៅត្រូវខ្សែភ្លើងឆ.ក់ បណ្តាលឱ្យស្លា.ប់កាលពីវេលាម៉ោង២ឈានចូលព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ នៅចំណុចអូរព្រំដែន ស្ថិតភូមិថាប់សេរី ឃុំថាប់សេដិត ស្រុកតាប្រាយ៉ា ប្រទេសថៃ ។ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧បានប្រាប់ថា ជនរង

គ្រោះដែលស្លា.ប់ឈ្មោះ សន ផល្លី ភេទប្រុស អាយុ៦៩ឆ្នាំ រស់នៅភូមិបឹងតាស្រី ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

តាមប្រភពពីប្រពន្ធនិងកូនរបស់ជនរងគ្រោះបានប្រាប់ថា មុនពេលកើតហេតុ ពួកគាត់ត្រឡប់ពីធ្វើការតាមបន្ទាត់ព្រំដែននៅប្រទេសថៃជាមួយប្ដីនិងប្រពន្ធកូន៣នាក់ រួមជាមួយអ្នកស្រុក ដើម្បីមកផ្ទះ ហើយមកដល់មាត់អូរ ប្ដីបានចុះលាងជើងអូរព្រំដែនក្បែរបន្ទាយឈុតខ្មៅទាហានថៃ ស្រាប់តែត្រូវខ្សែភ្លើងឆ.ក់ធ្លាក់ចូលទឹកអូរ ហើយត្រូវបានទាហានឈុតខ្មៅថៃ និងប្រជាពលរដ្ឋដែលទៅជាមួយ បាននាំគ្នាជួយសង្គ្រោះបញ្ជូនទៅមន្ទីរពេទ្យស្រុកតាប្រាយ៉ា ប្រទេសថៃ ដែរ ប៉ុន្តែជាអកុសលប្ដីរបស់គាត់បានស្លា.ប់បាត់បង់ជីវិតទៅហើយ។

កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧បានបញ្ជាក់ថា ក្រោយពីទទួលព័ត៌មានថាមានជនរងគ្រោះម្នាក់ត្រឡប់ពីធ្វើការនៅប្រទេសថៃតាមបន្ទាត់ព្រំដែនទៅព្រឹកវិលល្ងាចត្រូវខ្សែភ្លើងឆ.ក់ស្លា.ប់ ក៏បានទទួលទៅយកមកផ្ទះជនរងគ្រោះ ហើយពិនិត្យនិងសាកសួរព័ត៌មាន គឺជនរងគ្រោះត្រូវបានខ្សែភ្លើងឆ.ក់ បណ្ដាលឱ្យស្លា.ប់ពិតប្រាកដមែន ។ ក្រោយពិនិត្យរួច សមត្ថកិច្ចបានប្រគល់ស.ពជនរងគ្រោះធ្វើបុណ្យតាមប្រពៃណី ៕

## ឃាត់ខ្លួនជនជាតិថៃប្រុសស្រី៤នាក់ ដែលប្រមុងលួចឆ្លងដែនពីកម្ពុជាទៅថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៧ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ១៤:៤៦

ខេត្តបន្ទាយមានជ័យ ៖ បើតាមសេចក្ដីរាយការណ៍បានឱ្យដឹងថា ជនជាតិថៃប្រុសស្រីចំនួន៤នាក់ ដែលប្រមុងលួចឆ្លងដែនពីកម្ពុជាទៅប្រទេសថៃ ត្រូវបានឃាត់ខ្លួនប្រគល់ជូនភាគីថៃវិញ នៅវេលាម៉ោង២រសៀល ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២ នៅចំណុចអូរព្រំដែនក្បែរច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួក។ បើតាមកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ បានប្រាប់ថា ៖ នៅពេលកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧បានចេញល្បាតតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្បែរច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ក៏បានប្រទះឃើញជនជាតិថៃប្រុសស្រីចំនួន៤នាក់ ដែលបម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ក៏ត្រូវបានឃាត់ខ្លួននាំយកមកសាកសួរនៅប៉ុស្តិ៍នគរបាលការពារព្រំដែនគោកលេខ៨០៧ ប្រចាំច្រកទ្វារតំបន់ព្រំដែនបឹងត្រកួន ស្រុកថ្មពួក។

កម្លាំងនគរបាលរូបនោះបានបញ្ជាក់ថា ក្រោយឃាត់ខ្លួន ជនជាតិថៃចំនួន៤នាក់ ក្នុងស្រី១នាក់ បាននាំយកមកសាសួរ ហើយបើតាមចម្លើយ គឺពួកគាត់បានមកធ្វើការនៅកាស៊ីណូ «ហាយសូ» ក្នុងក្រុងប៉ោយប៉ែត ហើយក៏មានបំណងឆ្លងទៅប្រទេសថៃវិញគ្មានច្បាប់ តាមរយៈមេខ្យល់ខ្មែរ ដោយបានជូនមកទម្លាក់ចោលក្បែរអូរព្រំដែនដើម្បីអោយត្រឡប់ទៅវិញដោយខ្លួនឯង តែក៏ត្រូវបានកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨០៧ ឃាត់នាំយកមកសាកសួរតែម្ដង។ កម្លាំងនគរបាលរូបនោះបានបញ្ជាក់ទៀតថាជនជាតិថៃប្រុស-ស្រីទាំង៤នាក់ខាងលើរួមមាន៖ ១- ឈ្មោះ ផាន់ ផាយ៉ា ភេទប្រុស អាយុ៣០ឆ្នាំ ២- ឈ្មោះ ផា កុម ភេទប្រុស អាយុ១៩ឆ្នាំ ៣- ឈ្មោះ មុន្នី រ៉ាត់ ភេទស្រី អាយុ៣៣ឆ្នាំ និង៤- ឈ្មោះ វ៉ាក់ ណែន២ជន ភេទប្រុស អាយុ៣០ឆ្នាំ ដែលរស់នៅស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ។ ក្រោយការសាកសួរជនជាតិថៃទាំងនេះរួចហើយ ក៏បានរៀបចំឯកសារ និងប្រគល់ជូនជនជាតិថៃទាំង៤នាក់រូបនេះ ទៅឱ្យសមត្ថកិច្ចជំនាញថៃ ដើម្បីមកទទួលយកនៅច្រកទ្វារតំបន់បឹងត្រកួន ស្រុកថ្មពួក ដើម្បីទទួលទៅអនុវត្តន៍តាមនីតិវិធីនៃច្បាប់បន្តទៀត៕

# ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២

## រដ្ឋមន្ត្រីការងារណែនាំពលករខ្មែរធ្វើការនៅថៃ ត្រូវថែទាំសុខភាព និងចូលរួមគោរពច្បាប់

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៧ សីហា ២០២២ដោយ KC Virak

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានណែនាំដល់ពលករខ្មែរធ្វើការនៅប្រទេសថៃបន្តថែទាំសុខភាព ដោយប្រកាន់ខ្ជាប់នូវវិធានការពារពីការឆ្លងជំងឺកូវីដ-១៩ និងត្រូវចូលរួមគោរពច្បាប់របស់ប្រទេសគេឱ្យបានល្អ ជៀសវាងបង្កបញ្ហាផ្សេងៗដែលធ្វើឱ្យមានទោសទណ្ឌដល់ខ្លួន។ លោករដ្ឋមន្ត្រីបានណែនាំបែបនេះ ក្នុងឱកាសដែលលោកបានដឹកនាំគណៈប្រតិភូរបស់ក្រសួង អមដោយលោក អ៊ុក សោភ័ណ្ឌ ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសថៃ អញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនពលករខ្មែរដែលកំពុងធ្វើការនៅក្នុងរោងចក្រ CPF ស្ថិតនៅក្នុងខេត្តនគរាជសីមា ប្រទេសថៃ នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២២។ នាឱកាសនោះ លោករដ្ឋមន្ត្រី បានផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន ដែលសម្តេចទាំងពីរ តែងតែយកចិត្តទុកដាក់ពីសុខទុក្ខរបស់បងប្អូនពលកររបស់យើងដែលបានកំពុងធ្វើការនៅបរទេស។

លោករដ្ឋមន្ត្រីបានថ្លែងអំណរគុណដល់ក្រុមហ៊ុន CPF ដែលបានផ្តល់ឱកាសការងារ ជូនដល់ពលករកម្ពុជាឱ្យបានបម្រើការងារនៅក្រុមហ៊ុន ទទួលបានប្រាក់ឈ្នួល ការស្នាក់នៅ និងហូបចុកបានយ៉ាងសមរម្យ ថែមទាំងយកចិត្តទុកដាក់ទៅលើបញ្ហាសុខភាពរបស់ពលករកម្ពុជាបានយ៉ាងល្អប្រសើរផងដែរ។ ទន្ទឹមនឹងនេះ លោករដ្ឋមន្ត្រី បានធ្វើការកោតសរសើរចំពោះបងប្អូនពលករខ្មែរ ដែលមានស្មារតីតស៊ូ អត់ធ្មត់ ខិតខំធ្វើការងាររកប្រាក់កម្រៃចិញ្ចឹមគ្រួសារ ជាការចូលរួមចំណែក រកចំណូលជូនជាតិ ដែលពលករខ្មែរនៅថៃមានចំនួន ១,២ លាននាក់ ម្នាក់ៗក្នុងមួយខែបានផ្ញើប្រាក់ទៅផ្ទះរាប់រយដុល្លារអាមេរិក ដើម្បីផ្គត់ផ្គង់ជីវភាព ហើយបើគិត ១ឆ្នាំ បងប្អូនពលករយើងបានផ្ញើលុយទៅក្រុមគ្រួសារ ប្រមាណរាប់សិបលានដុល្លារអាមេរិក និងនៅពេលបងប្អូន វិលត្រឡប់ទៅប្រទេសកំណើត នឹងមានចំណេះ និងជំនាញការងារ មកអភិវឌ្ឍប្រទេសផងដែរ។

លោករដ្ឋមន្ត្រីបានលើកឡើងពីគណៈកម្មាធិការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានបើកយុទ្ធនាការផ្តល់ភាពស្របច្បាប់ ជូនបងប្អូនពលករដោយផ្តល់លិខិតធ្វើដំណើរ TD និងចេញប័ណ្ណ OCWC និងឯកសារផ្សេងទៀតដែលធានាបាននូវភាពស្របច្បាប់ក្នុងការស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ ជារួមគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ជានិច្ចជាកាល បានផ្តល់នូវការគាំពារគ្រប់បែបយ៉ាងជូនដល់បងប្អូនពលករ និងក្រុមគ្រួសារ។ លោករដ្ឋមន្ត្រីបានបន្ថែមថា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ កន្លងមកថ្មីៗនេះ ដែលគណបក្សប្រជាជនកម្ពុជាទទួលបានជ័យជំនះយ៉ាងត្រចះត្រចង់បំផុត ដែលក្នុងនោះក៏មានពលករ និងក្រុមគ្រួសាររបស់បងប្អូន បានទៅចូលរួមបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា សបញ្ជាក់ពីការបន្តគោរព ស្រឡាញ់ គាំទ្រ និងជឿជាក់ មកលើការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានដឹកនាំកម្ពុជាឱ្យមានការរីកចម្រើនលើគ្រប់វិស័យ។

គួរបញ្ជាក់ថា រោងចក្រ CPF មានទីតាំងនៅខេត្តនគររាជសីមា ប្រទេសថៃ មានពលករទាំងអស់សរុបចំនួន ៨ ៣៥២ នាក់ ក្នុងនោះ ពលករកម្ពុជា មានចំនួន ២ ២៧៥ នាក់ ស្រី ១ ០៩៧ នាក់៕ **អត្ថបទ៖ សំអឿន**

## រយៈពេល ១សប្តាហ៍ ដើមខែ សីហា នេះ ពលករខ្មែរចំណាកស្រុកដោយខុសច្បាប់ ១២៤នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនមកប្រគល់ឲ្យសមត្ថកិច្ចកម្ពុជាវិញ

https://gntimes.com/ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២

បាត់ដំបង៖ ប្រជាពលរដ្ឋខ្មែរ ១២៤នាក់ ដែលនាំគ្នាលួចឆ្លងដែនចូលទៅប្រទេសថៃ ជាបន្តបន្ទាប់ដោយខុសច្បាប់ ត្រូវបានទាហ៊ានឈុតខ្មៅថៃ បានចាប់ប្រមូលដើម្បីបញ្ជូនមកស្រុកកំណើតវិញ ខណៈពួកគេបានទៅតាមមេខ្យល់ដោយប្រថុយប្រថានគ្មានច្បាប់ទម្លាប់ចូលទៅធ្វើការនៅប្រទេសថៃ ។

បើតាមការបញ្ជាក់ពីកម្លាំងការពារតំបន់ព្រំដែនបានឲ្យដឹងថា ពលករដែលសមត្ថកិច្ចភាគីថៃ បានចាប់បញ្ជូនមកស្រុកកំណើតវិញខាងលើនេះ គឺភាគីថៃធ្វើឡើងក្នុងរយៈពេល ៧ថ្ងៃ ចាប់តាំងពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០២២ កន្លងមកនេះ ខណៈដែលពួកគេធ្វើចំណាកស្រុកដោយខុសច្បាប់នៅប្រទេសថៃសរុប ១២៤នាក់ ក្នុងនោះពលករបុរស ២៨នាក់ ស្ត្រីចំនួន ៥១នាក់ និងក្មេងប្រុសស្រី ៤៥នាក់ ។ ប្រភពដដែលបានបញ្ជាក់បន្តថា ជាទូទៅពលករដែលបានលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ច្រើនធ្វើឡើងនៅពេលយប់ ជ្រៅតាមច្រករបៀងនានានៅក្នុងភូមិសាស្ត្ររបស់ស្រុកសំពៅលូន ខេត្តបាត់ដំបង ទើបកម្លាំងមានការឆក់ល្វែងខ្លះ ។

ក្រុមគ្រូពេទ្យប្រាប់ថា សម្រាប់ពលករទាំងអស់ខាងលើ ក្រោយសហការទទួលពីភាគីទាហានថៃក្រុមគ្រូពេទ្យបានពិនិត្យធ្វើតេស្តជាលទ្ធផលអវិជ្ជមាននូវជំងឺកូវីដ-១៩ រួចហើយអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់មូលដ្ឋានរៀងៗខ្លួនវិញបន្ទប់ពីសមត្ថកិច្ចធ្វើ ការណែនាំអប់រំរួចមក ៕ ដោយ៖ សួន សុខហៃ

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូល ខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/08/08 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃចន្ទ ១១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៨ខែសីហា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០២លើក សរុបចំនួន១៤នាក់ ស្រី៧នាក់ ក្មេងស្រី១នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ ផ្សព្វផ្សាយ ផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

http://nokorwatnews.com/ 09/08/2022

ភ្នំពេញ៖ បើយោងតាមនាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងមហាផ្ទៃ បានបញ្ជាក់អោយដឹងថា, ទីស្តីការក្រសួងមហាផ្ទៃ ៖ នារសៀលថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ ផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដោយមានការអញ្ជើញចូលរួមពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ, រដ្ឋលេខាធិការប្រចាំការ, រដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ, គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា, អគ្គស្នងការដ្ឋាននគរបាលជាតិ អភិបាលរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត។

សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍បញ្ជាក់ថា ការងារប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ពិតជាមានសារៈសំខាន់ ដើម្បីការពារសិទ្ធិមនុស្ស ព្រមទាំងទាក់ទងទៅនឹងការងារអំពើប្រយុទ្ធប្រឆាំង និងទប់ស្កាត់អាវុធមហាប្រល័យ។ សម្តេច បន្តថា ការងារទាំងនេះ ក្រុមការងារធ្វើការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងទទួលបានលទ្ធផលជាបន្តបន្ទាប់ ទោះបីជួបបញ្ហាមួយចំនួនក៏ដោយ។ សម្តេចក្រឡាហោម បានបន្ថែមថា តាមការវាយតម្លៃរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នាពេលកន្លងទៅនេះ បានទម្លាក់ប្រទេសកម្ពុជាដល់ចំណាត់ថ្នាក់លេខ៣ ទាក់ទងទៅនឹងអំពើជួញដូរមនុស្ស។ សម្តេច ក៏ចាត់ទុកថា ទាំងនេះក៏ជាមូលដ្ឋានមួយសម្រាប់កម្ពុជា បន្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

នាឱកាសនោះដែរ លោក នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តប្រវេសន៍ បានអានសេចក្តីព្រាង ស្តីពីផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធ ប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ថា រហូតដល់បច្ចុប្បន្ន រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាចិត្តយ៉ាងមុតមាំ ប្រកបដោយឆន្ទៈមោះមុត ក្នុងការតស៊ូប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មភេទ ជាពិសេសលើស្ត្រី និងកុមារ ដើម្បីការពារជោគវាសនាប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាជនបរទេសដែលរស់នៅព្រះរាជាណាចក្រកម្ពុជា មិនឱ្យធ្លាក់ទៅក្នុងគ្រោះមហន្តរាយដោយអំពើទាសភាពសម័យ ថ្មីនេះបានឡើយ។

លោក បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា ដោយមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជាសេនាធិការ បានដាក់ចេញនូវបណ្តាគោលការណ៍ ផែនការ និងវិធានការជាអាទិភាព ព្រមទាំងដឹកនាំអនុវត្ត កិច្ចការនេះទទួលបាននូវលទ្ធផលផ្លែផ្កាជាច្រើន គួរជាទីមោទនៈ ដែលក្នុងនោះបានលើកកម្ពស់ការយល់ដឹង របស់សាធារណជនគ្រប់ស្រទាប់ ឱ្យបានជ្រួតជ្រាបអំពីគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស កលល្បិចជនល្មើស ព្រមទាំងបានបើកកិច្ចប្រតិបត្តិការយ៉ាងសកម្មក្នុងការបង្ក្រាបអំពើជួញដូរមនុស្សជាច្រើនករណី រំដោះជនរងគ្រោះច្រើនពាន់នាក់ និងបានឧបត្ថម្ភ គាំទ្រក្នុងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដោយជោគជ័យ។

លើសពីនេះ លោក អគ្គនាយកដ្ឋានអន្តប្រវេសន៍ បានលើកឡើងទៀតថា ផ្តើមពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងការធ្វើពលិកម្មយ៉ាងសកម្មរបស់ក្រសួង/ស្ថាប័នមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ បានញ៉ាំងឱ្យអំពើល្មើសទាំងនេះ ត្រូវបានកាត់បន្ថយ

និងធ្វើឱ្យសង្គមកម្ពុជា មានសុខសុវត្ថិភាព សន្តិសុខ មានការរីកចម្រើន មានភាពស៊ីវិល័យសមស្របតាមគន្លងប្រពៃណី និងទំនៀមទម្លាប់ដ៏ថ្លៃថ្នូររបស់ជាតិខ្មែរ ប្រជាពលរដ្ឋមានជីវភាពសមរម្យ ដោយបានចៀសផុតពីហានិភ័យ និងគ្រោះថ្នាក់ ដែលបង្កដោយអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងជួញដូរផ្លូវភេទជាបន្តបន្ទាប់៕

## ប្រទេសឥណ្ឌូនេស៊ី និងកម្ពុជាសហការគ្នាក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ជាពិសេសអ្នកដែលត្រូវបានគេបោកបញ្ឆោតតាមអ៊ីនធឺណិត

https://www.khmertimeskh.com/ Khmer Times August 9, 2022

រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ីលោកស្រី Retno Marsudi បានជួបជាមួយអគ្គស្នងការនគរបាលជាតិកម្ពុជាលោក នេត សាវឿន នៅរាជធានីភ្នំពេញ នៅថ្ងៃទី២ ខែសីហា ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការជួញដូរមនុស្ស។ នៅក្នុងសេចក្តីប្រកាសព័ត៌មានដែលចុះផ្សាយដោយក្រសួងការបរទេសឥណ្ឌូនេស៊ីនៅថ្ងៃដដែលនោះ លោកស្រី Marsudi បានសង្កត់ធ្ងន់ថា កិច្ចសហប្រតិបត្តិការរវាងឥណ្ឌូនេស៊ី និងកម្ពុជា ក្នុងការទប់ស្កាត់ការជួញដូរមនុស្សត្រូវតែបង្កើនឡើង។

ជាការឆ្លើយតបទៅនឹងសំណើរបស់លោកស្រី Marsudi លោក នេត សាវឿន បាននិយាយថា ប៉ូលីសកម្ពុជាបានសន្យាថានឹងសហការយ៉ាងពេញលេញជាមួយភ្នាក់ងារពាក់ព័ន្ធរបស់ប្រទេសឥណ្ឌូនេស៊ី។ ក្នុងជំនួបនោះ មន្ត្រីទាំងពីរក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ និងវិធានការទប់ស្កាត់ករណីបែបនេះមិនឱ្យកើតឡើងវិញម្តងទៀត។

ពួកគេក៏បានឯកភាពថា ក្រុមបច្ចេកទេសនៃកងកម្លាំងនគរបាលនៃប្រទេសទាំងពីរនឹងបើកកិច្ចប្រជុំនាពេលឆាប់ៗនេះ ដើម្បីពិភាក្សាលើបញ្ហាជាច្រើន រួមទាំងកិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេតរួមគ្នា ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងកម្លាំងនគរបាលប្រទេសទាំងពីរស្តីពីការដោះស្រាយ និងប្រឆាំងការជួញដូរមនុស្ស។ កិច្ចប្រជុំនេះធ្វើឡើងបន្ទាប់ពីប៉ូលីសកម្ពុជាបានដោះលែងពលករឥណ្ឌូនេស៊ីចំនួន ៥៥ នាក់ ក្នុងចំណោម ៦២ នាក់ ដែលជាជនរងគ្រោះនៃការឆបោកការងារ ហើយត្រូវបានឃុំខ្លួននៅប្រទេសកម្ពុជាកាលពីចុងខែកក្កដា៕ *VNA*

## ប៉ូលិសថៃឆ្មក់ចាប់ក្រុមថតភាពយន្តអាសអាភាស ពេលកំពុងប្រតិបត្តិការនៅលើគ្រែ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ៩ សីហា ២០២២ដោយ Sonya

នៅថ្ងៃទី៧ ខែសីហា សមត្ថកិច្ចថៃបានបើកប្រតិបត្តិការឆ្មក់ចូលចាប់ខ្លួនក្រុមថតភាពយន្តអាសអាភាសមួយក្រុម នៅក្នុងផ្ទះវីឡាមានអាងទឹកប្រណីតមួយ ស្ថិតក្នុងស្រុកសាត់ហីប ខេត្តឈុនប៊ូរី រួមមានជនសង្ស័យចំនួន ៤ នាក់ ក្នុងនោះមានជនជាតិចិនចំនួន ២នាក់ និងជនជាតិថៃចំនួន ២នាក់ជាតួសម្តែង (ប្រុស-ស្រី) ព្រមជាមួយនឹងឧបករណ៍វត្ថុតាង មានកាមេរ៉ាសម្រាប់ថតរូប ឧបករណ៍បំភ្លឺ និងឧបករណ៍ផ្សេងទៀតសម្រាប់ថតឈុតអាសអាភាស (រឿងស៊ិច)។ សមត្ថកិច្ចបានរកឃើញថា ជនជាតិចិនទាំងនេះ បានមកថតភាពយន្តអាសអាភាសនៅតំបន់ប៉ាតាយ៉ា និងក្រុងបាងកក ពោលគឺពួកគេត្រូវការអ្នកសម្តែង (តួប្រុស-ស្រី) ជាជនថៃចូលរួមថតវីដេអូអាសអាភាសនេះដើម្បីផ្សព្វផ្សាយតាមរយៈគេហទំព័រ ឬប៉ុស្តិ៍ទូរទស្សន៍ចិន។ បន្ទាប់ពីសមត្ថកិច្ចបានសួរចម្លើយ ជនសង្ស័យបានសារភាពថា ក្រុមជនជាតិចិនទាំងនេះ ទើបតែបានចាប់ផ្តើមថតភាពយន្តអាសអាភាសនេះជាលើកទី១ គឺនៅថ្ងៃទី៤

ខែសីហា ឆ្នាំ២០២២កន្លងមក ក្នុងគោលបំណងដើម្បីរៀបចំផ្សព្វផ្សាយតាមរយៈគេហទំព័រមួយ រហូតដល់ត្រូវបានសមត្ថកិច្ចចាប់ខ្លួននេះតែម្តង។

ជនជាប់ចោទទាំង ៤នាក់ ម្នាក់ឈ្មោះ លី អាយុ ៣៣ឆ្នាំ ជនជាតិចិន មានមុខងារជាអ្នកថតរូប និងឈ្មោះ អាជុង អាយុ ២៤ឆ្នាំជនជាតិចិនជាអ្នកបកប្រែ និងជាអ្នកស្វែងរកតួសម្តែង (ប្រុស-ស្រី) ជាជនជាតិថៃ។ ជនជាតិថៃម្នាក់ឈ្មោះ អេ អាយុ ២០ឆ្នាំជាតួប្រុស ទទួលបានប្រាក់ឈ្នួល ៦០០០បាតក្នុងមួយថ្ងៃ ខណៈតារាស្រី ឈ្មោះ ប៊ី អាយុ ២៤ឆ្នាំ ជាតួស្រី ទទួលបានប្រាក់ឈ្នួល ២០,០០០បាតក្នុងមួយថ្ងៃ៕ **ប្រែសម្រួល៖ គង់ សំអាន**

## រដ្ឋបាលខេត្តកំពង់ឆ្នាំង បានប្រជុំពិគ្រោះយោបល់ លើការរៀបចំផែនការកិច្ចការពារកុមាររយៈពេល ៣ ឆ្នាំ ២០២៣-២០២៥

https://www.rasmeinews.com/ AUG 10, 2022

**ដោយៈទេពកង្រី / កំពង់ឆ្នាំងៈ** រដ្ឋបាលខេត្តកំពង់ឆ្នាំង បានបើកកិច្ចប្រជុំមួយ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ នេះ នៅសាលប្រជុំសាលាខេត្ត ដើម្បីពិគ្រោះយោបល់ លើការរៀបចំផែនការកិច្ចការពារកុមារក្នុងខេត្តរយៈពេល ៣ ឆ្នាំ ចាប់ពីឆ្នាំ២០២៣ ដល់ ២០២៥ ក្រោមអធិបតីភាពលោក អម សុភា អភិបាលរងខេត្តកំពង់ឆ្នាំង។ បន្ទាប់ពីការចូលរួមផ្តល់មតិ របស់តំណាងក្រសួងពាក់ព័ន្ធ និងតំណាងអង្គការជាដៃគូ លើការងារមួយចំនួន ដែលទាក់ទងទៅនឹងកិច្ច ការពារកុមាររួចមក លោកស្រី តុង ណារីប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត បានមានប្រសាសន៍បើកអង្គប្រជុំនោះថាៈ កុមារ គឺជាទំពាំងស្នងឫស្សី សម្រាប់បន្តវេនទៅថ្ងៃអនាគត ហើយចាប់តាំងពីប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីសិទ្ធិកុមារ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានសមិទ្ធផលជាច្រើន គួរឱ្យកត់សម្គាល់ រួមទាំងការផ្តល់សច្ចាប័នលើលិខិតតូបករណ៍អន្តរជាតិ ការបង្កើតច្បាប់ជាតិ លិខិតបទដ្ឋាន គតិយុត្ត ផែនការយុទ្ធសាស្ត្រ និងផែនការជាតិពាក់ព័ន្ធនិងកុមារ។

លោកស្រី បានបន្តថាៈ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ បានធ្វើឲ្យមានសុខសន្តិភាពពេញលេញ ធ្វើឲ្យស្ថានភាពសង្គម មានលក្ខណៈល្អប្រសើរ កុមារ ត្រូវបានលើកស្ទួយ និងគោរពសិទ្ធិជាមូលដ្ឋានទាំងបួន មានលក្ខណៈល្អប្រសើរជាលំដាប់។ ដោយឡែក កុមារនៅខេត្តកំពង់ឆ្នាំង ក៏ដូចជាកុមារទូទាំងប្រទេសដែរ ត្រូវបានរាជរដ្ឋាភិបាល ជំរុញការយកចិត្តទុកដាក់ថែទាំ ការពារ ពិសេសពីថ្នាក់ដឹកនាំខេត្ត គណៈកម្មាធិកាពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខេត្ត ក្រុង ស្រុក មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ស្ថាប័នពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដោយភាពទទួលខុសត្រូវតាមបណ្តាមូលដ្ឋាន សហគមន៍រៀងៗខ្លួន ប៉ុន្តែ កុមារមួយចំនួន កំពុងស្ថិតក្នុងស្ថានភាពលំបាករងគ្រោះ និងងាយរងគ្រោះ ដែលបណ្តាលមកពីកត្តាជីវភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចពលកម្ម ការរងផលប៉ះពាល់ដោយ ជំងឺកូវីដ១៩ ការកេងប្រវ័ញ្ចផ្លូវភេទ គ្រោះថ្នាក់ដោយប្រការផ្សេងៗ ដូចជាគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ធម្មជាតិ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានជាដើម។

លោកស្រី បានស្នើឲ្យសមាជិក សមាជិកាទាំងអស់ ត្រូវយកចិត្តទុកដាក់ស្តាប់នូវការធ្វើបទបង្ហាញសង្ខេបខ្លឹមសារ នៃផែនការកិច្ចការពារកុមារ ផ្តោតលើការថែទាំជំនួស និងអំពើហិង្សាលើកុមារ និងសូមឱ្យសមាជិក សមាជិកាទាំងអស់ ទទួលយកផែនការនេះទៅអនុវត្តនៅមូលដ្ឋានរៀងៗខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ៕

# របាយការណ៍៖ អំពើហិង្សាផ្លូវភេទនិងការរំលោភសេពសន្ថវៈ លើស្ត្រីជនជាតិដើមភាគតិចកើនឡើង

https://khmer.voanews.com/ 09 សីហា 2022កាន់ វិច្ឆិកា

ភ្នំពេញ៖ ករណីអំពើហិង្សាផ្លូវភេទ និងការរំលោភសេពសន្ថវៈលើស្ត្រីជនជាតិដើមភាគតិចកំពុងកើនឡើង ដោយសារចន្លោះប្រហោងក្នុងការអនុវត្តច្បាប់មានភាពមិនប្រក្រតី ហើយចំណេះដឹងនិងការទទួលបានព័ត៌មានរបស់ស្ត្រីជនជាតិដើមភាគតិចនៅមានកម្រិត។ នេះបើតាមរបាយការណ៍ និងសង្គមស៊ីវិលដែលផ្តើការផ្តោតលើសិទ្ធិស្ត្រី។

របាយការណ៍ស្តីអំពី «អំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិចក្នុងខេត្តចំនួនបីនៃប្រទេសកម្ពុជាឆ្នាំ ២០២០» ដែលមានកម្រាស់ ៧៦ ទំព័រនេះ ត្រូវបានសហការស្រាវជ្រាវដោយសមាគមស្ត្រីជនជាតិដើមភាគតិចកម្ពុជា អង្គការជនជាតិដើមភាគតិចកម្ពុជា អង្គការក្លាហាន និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (UNOHCHR)។

នាយិកាអង្គការក្លាហាន កញ្ញា បុណ្យ រចនា ប្រាប់ VOA ថា របាយការណ៍បានរកឃើញថា ស្ត្រីជនជាតិដើមភាគតិចរងការរំលោភសេពសន្ថវៈ និងការប្រើហិង្សាផ្អែកលើយេនឌ័រ ចំនួន ២៣ ករណី។ ចំនួននេះមានការកើនឡើង បើធៀបនឹងឆ្នាំ ២០១៥ ដោយសារការអនុវត្តច្បាប់នៅមានកម្រិត ហើយអាជ្ញាធរមូលដ្ឋានមិនមានភាពសកម្មគ្រប់គ្រាន់ ស្របពេលមានផលលំបាកក្នុងការទំនាក់ទំនង និងការប្រើភាសារវាងស្ត្រីជនជាតិដើមភាគតិច និងអាជ្ញាធរពាក់ព័ន្ធទទួលបន្ទុកគាំពារសិទ្ធិស្ត្រី។ កញ្ញាបានថ្លែងប្រាប់វីអូអេថា៖ «ស្ថានភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងសង្គមកម្ពុជា អត់មានការថយចុះទេ បើទោះបីជា យើងឃើញមានគោលនយោបាយជាតិ ឬក៏ផែនការជាតិ ឬក៏ច្បាប់ដែលបានដាក់ចេញក្នុងការទប់ស្កាត់ក៏ដោយ។ ដោយសារតែការអនុវត្តច្បាប់របស់យើងនៅមានភាពមិនប្រក្រតី ហើយនៅមានភាពខ្វះចន្លោះ ហើយដាច់ដោយដុំទៀត។ ហើយមួយទៀតមន្ត្រីដែលទទួលបន្ទុកនៅតាមមូលដ្ឋានហ្នឹង គាត់នៅមានទស្សនៈមួយ ដែលដូចលើកឡើងក្នុងរបាយការណ៍អ៊ីចឹង គឺនៅតែចាប់បង្ខំជនរងគ្រោះឱ្យទទួលខុសត្រូវនូវហេតុការណ៍ដែលបានកើតឡើង»។

កញ្ញា រចនា បានរៀបរាប់បន្ថែមថា ក្នុងឆ្នាំ ២០១៥ មិនមានការចងក្រងទិន្នន័យជាក់លាក់នោះទេ ប៉ុន្តែការរកឃើញថា មានការកើនឡើងនូវការប្រើហិង្សាផ្អែកលើយេនឌ័រ និងការរំលោភផ្លូវភេទនេះ គឺត្រូវបានកត់សម្គាល់តាមរយៈការផ្សព្វផ្សាយលើបណ្តាញសង្គមនិងសារព័ត៌មាន។ កញ្ញាថ្លែងថា៖ «អ្វីដែលយើងអាចនិយាយបានហ្នឹង គឺថានៅក្នុងចំណោមសហគមន៍ស្ត្រីជនជាតិដើមភាគតិច ដែលគាត់រស់នៅផ្ទាល់ ឬក៏ធ្វើការផ្ទាល់ក្នុងសហគមន៍ហ្នឹង គឺជាការចាប់អារម្មណ៍របស់គាត់ផ្ទាល់ថា នៅក្រោយឆ្នាំ ២០១៥ ហ្នឹង គឺមានករណីហិង្សាផ្លូវភេទហ្នឹងកើនឡើងអ៊ីចឹងហើយទើបគាត់ចាប់ផ្តើមធ្វើការចងក្រងទិន្នន័យទាំងអស់ហ្នឹង»។

របាយការណ៍នេះ ធ្វើឡើងឡើងដោយមានការធ្វើបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធចំនួន ៥៤ នាក់ ក្នុងខេត្តចំនួនបី គឺខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង ដែលពួកគេគឺជាជនរងគ្រោះ សាច់ញាតិជនរងគ្រោះ និងអាជ្ញាធរ។ ក្នុងនោះអ្នកស្រាវជ្រាវរកឃើញថា ករណីរំលោភសេពសន្ថវៈ និងការប្រើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិច មានចំនួន ២៣ ករណី។

កញ្ញា បុណ្យ រចនា បានថ្លែងបន្ថែមថា តួលេខនេះគ្រាន់តែរកឃើញក្នុងខេត្តចំនួនបីប៉ុណ្ណោះ ប៉ុន្តែនៅតាមបណ្តាខេត្តជាង ១០ ផ្សេងទៀត ក៏កើតមានបញ្ហាស្រដៀងគ្នានេះផងដែរ។ នាយិកាអង្គការក្លាហានរូបនេះពន្យល់បន្ថែមទៀតថា ដើម្បីទប់ស្កាត់ និងដោះស្រាយករណីរំលោភសេពសន្ថវៈ និងការប្រើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិច លុះត្រាតែរដ្ឋាភិបាលត្រូវបង្កើតឱកាសសម្រាប់មន្ត្រីមូលដ្ឋាន ស្វែងយល់អំពីបរិបទសង្គម និង

ប្រពៃណីរបស់ជនជាតិដើមភាគតិច ហើយជំរុញការអប់រំផ្សព្វផ្សាយនៃឫសគល់អំពីបញ្ហាហិង្សាលើស្ត្រី និងពង្រឹងការអនុវត្តច្បាប់ ព្រមទាំងបង្កើតកញ្ចប់ថវិកា និងធនធានមនុស្សក្នុងការដោះស្រាយបញ្ហាទាំងនោះ។ នាពេលបច្ចុប្បន្ននេះ ជនជាតិដើមភាគតិចនៅកម្ពុជាមានចំនួន ២៤ ក្រុមផ្សេងៗគ្នា ដែលមានចំនួនសរុប ២៥០.០០០ នាក់ ទៅ ៤០០.០០០នាក់ ឬ ២% ទៅ ៣% នៃចំនួនប្រជាជនកម្ពុជាសរុបប្រមាណ ១៦លាននាក់។ ក្នុងនោះស្ត្រីជនជាតិដើមភាគតិចមានប្រមាណជា ៥១%។ នេះបើតាមរបាយការណ៍ស្តីអំពីអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិចក្នុងខេត្តចំនួនបី គឺខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។ ទន្ទឹមនឹងការផ្សព្វផ្សាយរបាយការណ៍ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ព្រមទាំងជនជាតិដើមភាគតិចប្រមាណជា ១០០ នាក់ បានប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោក លើកទី ២៨ ក្រោមប្រធានបទ «តួនាទីស្ត្រីជនជាតិដើមភាគតិចក្នុងការអភិរក្ស និងការផ្ទេរចំណេះដឹងប្រពៃណី» ផងដែរ។

អ្នកស្រី រម៉ាស់ សារ៉ន តំណាងស្ត្រីជនជាតិដើមភាគតិច លើកឡើងថា របាយការណ៍នេះមានសារៈសំខាន់ណាស់សម្រាប់ឱ្យអ្នកពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់ និងដោះស្រាយករណីហិង្សាផ្អែកលើយេនឌ័រ និងការរំលោភសេពសន្ថវៈលើស្ត្រីជនជាតិដើមភាគតិច។ អ្នកស្រី រម៉ាស់ សារ៉ន ថ្លែងថា៖ «ខ្ញុំគិតថា របាយការណ៍ទាក់ទងនឹងអំពើហិង្សាលើយេនឌ័រលើស្ត្រីជនជាតិដើមភាគតិចនេះ មានសារៈសំខាន់មែនទែន ដើម្បីគ្រប់ភាគីទាំងអស់ចាប់ផ្តើមចូលរួមចំណែកក្នុងការដោះស្រាយ ក៏ដូចជាយកលទ្ធផលដែលបានរកឃើញក្នុងរបាយការណ៍នេះ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍ ក៏ដូចជាផែនការសកម្មរបស់ខ្លួន ក្នុងការចូលរួមចំណែកដោះស្រាយបញ្ហានេះ»។ អ្នកស្រីថ្លែងបន្ថែមថា ប្រសិនបើមិនមានការស្រាវជ្រាវ ឬចងក្រងតួលេខអំពីការប្រើហិង្សា និងការរំលោភសេពសន្ថវៈនេះទេ នោះស្ត្រីជនជាតិដើមភាគតិច នឹងបាត់បង់ឱកាសក្នុងការរៀនសូត្រ និងធ្វើការងារ។

អគ្គនាយិការងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមរបស់ក្រសួងកិច្ចការនារី អ្នកស្រី ស ស៊ីណែត លើកឡើងថា របាយការណ៍នេះមិនមានតួលេខជាក់លាក់អំពីការកើនឡើងនៃការប្រើហិង្សា និងរំលោភសេពសន្ថវៈ ហេតុនេះមិនទាន់អាចបញ្ជាក់ថាពិតជាមានការកើនឡើង ឬថយចុះនៅឡើយ។ អ្នកស្រីថ្លែងបន្ថែមដោយទទួលស្គាល់ថា អាជ្ញាធរដែលអនុវត្តការងារនៅមូលដ្ឋានមានផ្នត់គំនិតរើសអើងស្ត្រីជនជាតិដើមភាគតិច ហើយវិធីសាស្ត្រក្នុងការទំនាក់ទំនងនៅមានកម្រិតដោយសារបញ្ហាភាសា និងអាចដោយសារជនជាតិដើមភាគតិចមួយចំនួន នៅប្រកាន់ប្រពៃណីទំនៀមទម្លាប់មិនឱ្យអ្នកដទៃជ្រៀតជ្រែកជាដើម។ ទោះយ៉ាងណាក្តី អ្នកស្រីថ្លែងថា ក្រសួងកិច្ចការនារីបាន និងកំពុងទប់ស្កាត់ និងដោះស្រាយបញ្ហាទាំងនេះតាមរយៈការប្រមូលឯកសាររៀងរាល់ ៥ ឆ្នាំម្តង និងបន្ថែមផែនការសកម្មភាពនិងយុទ្ធសាស្ត្រជាច្រើនទៀត។ អ្នកស្រី ស ស៊ីណែត ប្រាប់វីអូអេនៅថ្ងៃអង្គារនេះថា៖«យើងរៀបចំ policy [គោលនយោបាយ] មានទាំងពីយុទ្ធសាស្ត្រនារីរតនៈទី ៥ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី មានទាំងពីផែនការសកម្មភាពស្តីពីការបង្ការការរៀបអាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់»។ អ្នកស្រី ស ស៊ីណែត ថ្លែងទៀតថា រាល់សកម្មភាព និងយុទ្ធសាស្ត្រដែលចេញដោយក្រសួងកិច្ចការនារី ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ទប់ស្កាត់ និងប្រាប់ពីផលប៉ះពាល់ដើម្បីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច ព្រមទាំងឱកាសផ្សេងៗដល់ក្មេងស្រី និងស្ត្រីជនជាតិដើមភាគតិច៕

# ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២

## ព្រឹកនេះ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល រៀបចំសន្និសីទសារព័ត៌មាន ស្តីពី "ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា"

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១២ សីហា ២០២២ដោយ sopheak khoun

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៅព្រឹកថ្ងៃទី ១២ ខែសីហានេះ នឹងរៀបចំសន្និសីទសារព័ត៌មាន ស្តីពី "ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា" នៅទីស្តីការគណៈរដ្ឋមន្ត្រី។ វាគ្មិនកិត្តិយស ដែលនឹងអញ្ជើញចូលរួម រួមមាន៖ តំណាងមកពីក្រសួងមហាផ្ទៃ, ក្រសួងយុត្តិធម៌, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, និងអង្គការដៃគូ។

សន្និសីទសារព័ត៌មាននេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីឆ្លើយតបឲ្យទាន់សភាពការណ៍ ដែលសហរដ្ឋអាមេរិក បានសរសេរក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពី ការជួញដូរមនុស្សនៅលើពិភពលោក របស់ក្រសួងការបរទេសអាមេរិក ដែលដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ ៣ ស្មើនឹងកម្ពុជា មិនបានធ្វើអ្វីសោះដែលជារឿងមិនពិត ជាហេតុផលនៃការដាក់ទណ្ឌកម្មថែមទៀត គឺជារឿងអយុត្តិធម៌មិនអាចទទួលយកបាន។ សេចក្តីជូនដំណឹង របស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល បានលើកឡើងថា កន្លងមក រាជរដ្ឋាភិបាល ដៃគូជាតិ និងអន្តរជាតិ បានឲ្យដឹងច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទទួលបានលទ្ធផលជាច្រើន។

ក្រសួងការបរទេសអាមេរិក កាលពីអំឡុងខែកក្កដាកន្លងទៅនេះ បានចេញរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការជួញដូរមនុស្សនៅលើពិភពលោក ហើយក្នុងនោះ ក៏មានប្រទេសកម្ពុជាផងដែរ។ របាយការណ៍នេះ បានទម្លាក់កម្រិតកម្ពុជាពីចំណាត់ថ្នាក់ទី២ មកចំណាត់ថ្នាក់ទី៣ ដែលជាចំណាត់ថ្នាក់ទាបមួយ ពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ កាលពីថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០២២កន្លងទៅនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួងមហាផ្ទៃ។

នៅក្នុងឱកាសនោះ សម្តេចក្រឡាហោម ស ខេង បានគូសបញ្ជាក់ជូនអង្គប្រជុំអំពីការវិវត្តន៍ថ្មីៗ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។ ក្នុងនោះសម្តេច ក៏បានមានប្រសាសន៍ដល់ការដាក់ចំណាត់ថ្នាក់របស់ក្រសួងការបរទេសអាមេរិកមកលើកម្ពុជាថា ជាប្រទេសគ្មានឆន្ទៈប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផងដែរ។ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ទៀតថា រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការ បានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងថាទោះជាភាគីអាមេរិកដាក់ចំណាត់ថ្នាក់បែបណាក៏ដោយ ក៏កម្ពុជាចាត់ទុកចំណាត់ថ្នាក់នេះជាមូលដ្ឋានមួយ ក្នុងការបន្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ខ្លួនដែរ៕ អត្ថបទ៖ ឃួន សុភ័ក្រ

## លោក ប៉ែន ពេជ្រសាលី ជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមអំពី«ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ក្នុងករណីជួញដូរមនុស្ស ដល់ក្រុមគ្រូបង្គោលកម្មវិធីជំនាញអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ

http://nokorwatnews.com/ 12/08/2022

ភ្នំពេញ៖ លោក ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ អញ្ជើញចូលរួមជាគណៈអធិបតី និងជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមអំពី «ច្បាប់ស្តីពីការជួយគ្នាទៅ

វិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ»ក្នុងករណីជួញដូរមនុស្ស ដល់ក្រុមគ្រូបង្គោលកម្មវិធីជំនាញអាស៊ាន ស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ។

សូមបញ្ជាក់ថា, នៅថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២មុ្សិលមុិញ នេះ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី លោករដ្ឋមន្រ្តីក្រសួងយុត្តិធម៌ លោក ប៉ែន ពេជ្រសាលី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអេយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្រ្តាលីដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា បានអញ្ជើញចូលរួមជាគណៈអធិបតី តំណាងក្រសួងយុត្តិធម៌ និងជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមអំពី«ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ»ក្នុងករណីជួញដូរមនុស្ស ដល់ក្រុមគ្រូបង្គោលកម្មវិធីជំនាញអាស៊ាន ស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ ២០២២ នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ដែលសហការរៀបចំដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងកម្មវិធីអាស៊ាន-អូស្រ្តាលីប្រឆាំងការជួញដូរមនុស្ស។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងសមត្ថភាពបន្ថែមដល់ក្រុមគ្រូបង្គោលកម្មវិធីជំនាញអាស៊ាន ស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរដែលបានទទួលការបណ្តុះបណ្តាលក្រោមកម្មវិធីអូស្រ្តាលី-អាស៊ីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ក្នុងកម្មវិធីនេះ លោកអគ្គនាយក បានចូលរួមជាគ្រូឧទ្ទេសក្នុងការធ្វើបទបង្ហាញបណ្តុះបណ្តាលអំពីច្បាប់ ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ ដល់ក្រុមគ្រូបង្គោលដើម្បីទទួលបានចំណេះដឹងអំពីនីតិវិធីក្នុងការរៀបចំសំណើ សុំជំនួយ អនុវត្តសំណើ សុំជំនួយ ឆ្លើយតបសំណើសុំជំនួយទៅកាន់រដ្ឋបរទេស ក្នុងនាមជាអាជ្ញាធរអនុវត្តសំណើ រួមទាំងយល់ដឹងអំពីសមត្ថកិច្ចតួនាទីរបស់អាជ្ញាធរកណ្តាល និងការបង្កក ការចាប់យក និងការរឹបអូស ៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/08/11/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១០ និង០០នាទី ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡែស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង–ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) និងកម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុប ចំនួន១៦នាក់ ស្រី៣នាក់ ។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២

## លោកស្រី ជូ ប៊ុនអេង ៖ កម្ពុជា បាននិងកំពុងរិះរកគ្រប់វិធានការ ដើម្បីឆ្លើយតបឲ្យទាន់ពេល ទៅលើបញ្ហាជួញដូរមនុស្ស

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១២ សីហា ២០២២ដោយ sopheak khoun

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងតែរិះរកគ្រប់វិធានការ ដើម្បីឆ្លើយតបឲ្យបានទាន់ពេល ទៅលើបញ្ហាជួញដូរមនុស្ស ដើម្បីកាត់បន្ថយភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ខណៈអំពើជួញដូរមនុស្ស បាននិងកំពុងកើតឡើងយ៉ាងកក្រើក នៅទូទាំងពិភពលោក។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មានស្តីពី «ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា» នៅព្រឹកថ្ងៃទី ១២ ខែសីហានេះថា អំពើជួញដូរមនុស្ស បាននិងកំពុងកើតឡើងយ៉ាងកក្រើក នៅទូទាំងពិភព លោក ដែលជាវិបត្តិសកលមួយ ហើយទោះជាប្រទេសតូច ឬក៏ធំ ក៏ទទួលរងនូវអំពើជួញដូរមនុស្សនេះ ពីព្រោះវាជាឧក្រិដ្ឋកម្មឆ្លងដែន និងមានបណ្តាញចាត់តាំងថែមទៀត។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានថ្លែងថា ការទប់ស្កាត់ ឬលុបបំបាត់អំពើជួញដូរមនុស្សនេះ មិនអាចនរណាម្នាក់ ធ្វើបានតែឯងនោះទេ។ លោកស្រី ជូ ប៊ុងអេង ថា «ទោះបីរាជរដ្ឋាភិបាល ឬក៏សកលលោក ដែលខំប្រឹងបង្កើតនូវច្បាប់ នូវគោលនយោបាយ បទដ្ឋាន អនុសញ្ញា កតិកាសញ្ញា ជាបន្តបន្ទាប់ តែយើងធ្វើក្រោយពេលដែលរឿងវាកើតទេ គឺយើងខិតខំជំរុញស្ថានភាព ដើម្បីវត់ឲ្យទាន់ទៅស្ទាត់មុខ ប៉ុន្តែមានពេលខ្លះ យើងដឹងហើយថា កលល្បិចជនល្មើស តើវាការបត់បែនប៉ុណ្ណា?»។

អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា មិនអះអាងថា ជាប្រទេសដែលសក្តានុពលខ្ពស់ នៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឥតខ្ចោះនោះដែរ ហើយក៏មិនមែនមានន័យថា អ្វីដែលកម្ពុជាធ្វើសុទ្ធតែល្អត្រឹមត្រូវ ឬសុទ្ធតែមានប្រសិទ្ធភាពនោះដែរ។ លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា «ពីព្រោះយើងដឹងហើយថា វានៅតែកើតមានៗ នូវអំពើជួញដូរមនុស្ស អញ្ចឹងហើយដែលរាជរដ្ឋាភិបាល បាននិងកំពុងតែរិះរកគ្រប់វិធានការ ដើម្បីឆ្លើយតបឲ្យបានទាន់ពេល ពីព្រោះយើងចង់កាត់បន្ថយភាពរងគ្រោះ របស់ប្រជាពលរដ្ឋ»។ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានលើកឡើងទៀតថា នាពេលបច្ចុប្បន្ននេះ វិទ្យាសាស្ត្រកាន់តែទំនើប ហើយល្បិចកលរបស់ឧក្រិដ្ឋជនជួញដូរមនុស្ស ក៏កាន់តែជឿនលឿនណាស់ដែរ។ ត្រង់ចំណុចនេះ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ថា «ពីព្រោះបើយើងប្រើវិទ្យាសាស្ត្រ យើងប្រើព័ត៌មានវិទ្យាសម្រាប់ធ្វើការបង្ក្រាប អំពើជួញដូរមនុស្ស តែកុំភ្លេចជនល្មើសក៏គេចេះប្រើដែរ ហើយមានពេលខ្លះ គេមានភាពវៃឆ្លាតជាងយើងទៅទៀត ពីព្រោះគេត្រៀមលក្ខណៈនៅក្នុងការធ្វើឧក្រិដ្ឋកម្មនេះ»៕ អត្ថបទ៖ ឃួន សុភ័ក្រ

## កម្ពុជា ត្រៀមបើកប្រតិបត្តិការពិសេសដើម្បីស្រាវជ្រាវរុករក និងបង្ក្រាបករណីជួញដូរមនុស្ស នៅទូទាំងប្រទេស

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១២ សីហា ២០២២ដោយ sopheak khoun

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអះអាងថា នាពេលខាងមុខ នឹងមានប្រតិបត្តិការពិសេសមួយនៅទូទាំងប្រទេស ដើម្បីស្រាវជ្រាវរុករក និងបង្ក្រាបករណីជួញដូរមនុស្ស នៅលើទឹកនៃព្រះរាជាណាចក្រកម្ពុជា។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន ស្ដីពី «ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា» នៅព្រឹកថ្ងៃទី ១២ ខែសីហានេះថា រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងរៀបចំផែនការប្រតិបត្តិការពិសេស ដើម្បីស្រាវជ្រាវរុករកករណីជួញដូរមនុស្ស ដែលមាននៅលើទឹកនៃព្រះរាជាណាចក្រកម្ពុជា។ លោកស្រី ជូ ប៊ុនអេង បានថ្លែងថា «រហូតដល់បច្ចុប្បន្ននេះ យើងបាននិងកំពុងតែរៀបចំនូវផែនការប្រតិបត្តិការពិសេស សម្រាប់ការស្រាវជ្រាវរកនូវស្ថានភាព ដែលលាក់កំបាំងក្នុងរឿងជួញដូរមនុស្ស ដែលមាននៅលើទឹកដីកម្ពុជាហ្នឹងហើយ ប្អូនៗអ្នកសារព័ត៌មាន គង់តែទទួលបានលទ្ធផលទេ ថាធ្វើយ៉ាងម៉េច? តែសុំទោសពេលដែលយើងប្រតិបត្តិការ មិនមែនជាពេលវេលាដែលត្រូវចង្អុលបង្ហាញថា កន្លែងនេះមានជនល្មើស កន្លែងនេះមានបទល្មើសទេ ពីព្រោះយើងមានពេលខ្លះគេហៅថា ជាគេហៅថា វិធីសាស្ត្រ ឬក៏នីតិវិធីនៅក្នុងការបង្ក្រាប យើងអត់វៃស្មៅបង្អើលពស់ទេ យើងគ្រាន់តែប្រាប់ថា យើងមានកិច្ចប្រតិបត្តិការទូទាំងប្រទេស»។

អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបញ្ជាក់ទៀតថា រាជរដ្ឋាភិបាលកម្ពុជា បានគិតគូរអំពីបញ្ហាជួញដូរមនុស្សនេះជាយូរណាស់មកហើយ តាំងពីពេលទទួលបានព័ត៌មានថា មានករណីជួញដូរមនុស្សនេះកើតឡើងនៅកម្ពុជា គឺអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់ និងបង្ក្រាបបញ្ហានេះ៕ អត្ថបទ៖ យួន សុភ័ក្រ

## មន្ត្រីជាន់ខ្ពស់នគរបាលជាតិ បង្ហាញលេខទូរស័ព្ទ Hotline ដើម្បីឲ្យពលរដ្ឋ និងអ្នកពាក់ព័ន្ធរាយការណ៍ជុំវិញករណីជួញដូរមនុស្ស

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១២ សីហា ២០២២ដោយ sopheak khoun

មន្ត្រីជាន់ខ្ពស់នគរបាលជាតិ បានបង្ហាញអំពីលេខទូរស័ព្ទទាន់ហេតុការណ៍ (Hotline) និងទំព័រហ្វេសប៊ុករបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ដើម្បីឲ្យប្រជាពលរដ្ឋ អ្នកសារព័ត៌មាន ក៏ដូចជាអ្នកពាក់ព័ន្ធរាយការណ៍ព័ត៌មានជុំវិញករណីជួញដូរមនុស្ស ដើម្បីឲ្យមានការបង្ក្រាបទាន់ពេលវេលា។

លោកស្រីនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរង អគ្គស្នងការដ្ឋាននគរបាលជាតិ បានមានប្រសាសន៍ក្នុងសន្និ សីទសារព័ត៌មាន ស្ដីពី «ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា» នាព្រឹកថ្ងៃទី ១២ ខែសីហានេះថា អគ្គស្នងការដ្ឋាននគរបាលជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ តែងតែខិតខំប្រឹងបង្ក្រាបបទល្មើសជួញដូរមនុស្សជាបន្តបន្ទាប់ ទោះបីប្រទេសជាតិស្ថិតក្នុងវិបត្តិនៃជំងឺកូវីដ-១៩ ឬក៏ជួបបញ្ហាប្រឈមអ្វីក៏ដោយ។ ក្នុងនោះដែរ លោកស្រីនាយឧត្តមសេនីយ៍ យក់ សុខា ក៏បានបង្ហាញអំពីលេខទូរស័ព្ទទាន់ហេតុការណ៍ (Hotline) និងទំព័រហ្វេសប៊ុកដើម្បីទទួលព័ត៌មានជុំវិញករណីជួញដូរមនុស្ស ផងដែរ។ លោកស្រីអគ្គស្នងការរង បានថ្លែងថា «Hotline របស់នាយកដ្ឋានយើងមានមួយទៀត គឺHotline ១២៨៨ ដែលHotline របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ហើយនៅពេលដែលយើងបង្ការថា ប្រសិនបើមានការទូរស័ព្ទមក Hotline ហ្នឹងវាមានច្រើន ហើយវាមានការរអាក់រអួល គឺយើងមានហ្វេសប៊ុកផេករបស់នាយកដ្ឋានថែមទៀត ដើម្បីលោកអាចផ្ញើព័ត៌មាន ដើម្បីយើងបានដឹង យើងសហការគ្នាស្រាវជ្រាវ ហើយនិងប្រសិនជារបស់ថ្នាក់ក្រោមជាតិ យើងនឹងចាត់ចំណាត់ការភ្លាម ដើម្បីបើកការស្រាវជ្រាវ»។

លោកស្រីនាយឧត្តមសេនីយ៍ យក់ សុខា បានអំពាវនាវឲ្យមានការចូលរួមពីប្រជាពលរដ្ឋ អ្នកសារព័ត៌មាន និងអ្នកពាក់ព័ន្ធទាំងអស់ ជាមួយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈការផ្ដល់ព័ត៌មានអំពីការជួញដូរមនុស្សនេះ ដើម្បីអាចបង្ការទប់ស្កាត់ និងចុះបង្ក្រាបបានទាន់ពេលវេលា៕ អត្ថបទ៖ យួន សុភ័ក្រ

# កម្ពុជាអះអាងពីកិច្ចខិតខំប្រឹងប្រែង ខណៈការជួញដូរមនុស្សធ្លាក់ក្នុងបញ្ជីខ្មៅ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 12/08/2022 - 08:33

អ្នកជំនាញខាងប្រឆាំងការជួញមនុស្សរបស់ក្រសួងមហាផ្ទៃ អះអាងថា កម្ពុជាមិនព្រងើយកន្តើយចំពោះបញ្ហានេះទេ ហើយថាកម្ពុជាកំពុងខិតខំជំរុញគោលនយោបាយ ទេសន្តប្រវេសន៍ទៅតាមសហគមន៍ និងសាលារៀន ទាក់ទងនឹងបញ្ហាជួញដូរមនុស្សនេះ។ នេះជាការឆ្លើយតបទៅនឹងរបាយការណ៍របស់សហរដ្ឋអាមេរិកដែលទម្លាក់កម្ពុជាទៅក្នុងចំណាត់ថ្នាក់ទី៣ ឬបញ្ជីខ្មៅនៃការជួញដូរមនុស្សឆ្នាំ២០២២។

នៅក្នុងសន្និសិទនៅថ្ងៃសុក្រនេះ ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជាលោកស្រី ជូ ប៊ុនអេង គូសបញ្ជាក់ថា ក្នុងរបាយការណ៍ថ្មីចុងក្រោយនេះ គឺមានជនរងគ្រោះ១៥៧៧នាក់ ត្រូវបានជួយសង្គ្រោះ ខណៈសមត្ថកិច្ចបានកសាងពាក្យបណ្តឹងទៅតុលាការបាន៥៣៨ករណី។ តែលោកស្រីទទួលស្គាល់ថា បទល្មើសថ្មីៗ ទាក់ទងនឹងការជួញដូរមនុស្ស នៅតែកើតមាន តាមរយៈការប្រើប្រាស់ទឹកដីកម្ពុជា។ កម្ពុជាដែលធ្លាក់ទៅក្នុងចំណាត់ថ្នាក់ទី៣ ឬបញ្ជីខ្មៅក្នុងរបាយការណ៍ជួញដូរមនុស្សប្រចាំឆ្នាំ២០២២ របស់សហរដ្ឋអាមេរិក ដោយសារតែការទប់ស្កាត់បទល្មើសជួញដូរមនុស្ស មិនទាន់មានប្រសិទ្ធិភាព។ បើតាមអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺកម្ពុជាមិនបដិសេធនឹងរបាយការណ៍របស់សហរដ្ឋអាមេរិកបែបនេះទេ តែថាលោកស្រីស្លុតចិត្តនៅពេលឃើញការផ្សព្វផ្សាយបែបនេះពាសពេញពិភពលោក ទោះបីជាប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានព្យាយាមធ្វើការងារ និងបង្កើនកិច្ចសហប្រតិបត្តិការ ដើម្បីទប់ស្កាត់ការជួញដូរមនុស្សក៏ដោយ។

ទោះជាយ៉ាងណា លោកស្រី ជូ ប៊ុនអេង អះអាងថា កម្ពុជាមិនព្រងើយកន្តើយចំពោះបញ្ហានេះទេ ហើយថាកម្ពុជាកំពុងខិតខំប្រឹងប្រែងជំរុញគោលនយោបាយទេសន្តប្រវេសន៍ទៅតាមសហគមន៍ និងសាលារៀន ទាក់ទងនឹងបញ្ហាជួញដូរមនុស្សនេះ។ ក៏ប៉ុន្តែ នៅក្នុងរបាយការណ៍ កាលពីចុងខែកក្កដា សហរដ្ឋអាមេរិក បានកត់សំគាល់ថាកម្ពុជាមិនបានបំពេញតាមស្តង់ដារអប្បរមា និងមិនបានខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅឡើយ។ បញ្ហានេះបូករួមទាំងផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ និង អំពើពុករលួយជាប្រព័ន្ធ បានបន្តរាំងដល់ប្រតិបត្តិការពង្រឹងច្បាប់ ទំនួលខុសត្រូវអ្នកជួញដូរ និងការផ្តល់សេវាជួយជនរងគ្រោះ។ នេះបើតាមរបាយការណ៍ដដែល។

បើទោះបីជាមានការចាប់ខ្លួន និងកាត់ទោស ជនជួញដូរមនុស្សជាបន្តបន្ទាប់ ក៏ប៉ុន្តែរបាយការណ៍របស់សហរដ្ឋអាមេរិក បានលើកឡើងថា រដ្ឋាភិបាលមិនបានបង្ហាញរបាយការណ៍ស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយនោះទេ។ ជាក់ស្តែងក្នុងឆ្នាំ២០២១ មានសេចក្តីរាយការណ៍ថា អាជ្ញាធរបានចាប់ខ្លួនជនសង្ស័យជួញដូរមនុស្សចំនួន ៣៧០នាក់ ដែលក្នុងនោះមាន មេខ្យល់ ៣២២នាក់ ក៏ប៉ុន្តែរដ្ឋាភិបាលមិនបានរាយការណ៍បច្ចុប្បន្នភាព អំពីការចាប់ខ្លួនទាក់ទងទៅនឹងបទល្មើសជួញដូរមនុស្សទេ៕

# លោកស្រី ជូ ប៊ុនអេង៖ រាជរដ្ឋាភិបាលកម្ពុជាមិនបានព្រងើយកន្តើយចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សទេ

https://www.postkhmer.com/ មុំ គន្ធា | Publication date 12 August 2022 | 14:57 ICT

មន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃបានបញ្ជាក់ថា កម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ណាស់នៅក្នុងការការពារជនរងគ្រោះ ដោយការជួញដូរមនុស្ស បើទោះបីជាជនរងគ្រោះជាជនជាតិកម្ពុជាជាជនបរទេសក៏ដោយ គឺវិសាលភាពនៃច្បាប់របស់ប្រទេសកម្ពុជា នៅតែទទួលខុសត្រូវចំពោះអ្នកដែលស្ថិតក្នុងដែននៃប្រទេសកម្ពុជា និងទៅលើប្រជាជនកម្ពុជាទោះបីជាស្ថិតនៅទីណាក៏ដោយ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានថ្លែងឡើងដូចនេះ ក្នុងសន្និសីទសារព័ត៌មានស្តីពី «ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា» ដែលរៀបចំឡើងដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១២ ខែសីហានេះ។ លោកស្រីមានប្រសាសន៍ថា៖ «ប្រទេសកម្ពុជា ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាមិនបានព្រងើយកន្តើយចំពោះកិច្ចខិតខំប្រឹងប្រែងនូវក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សទេ ដោយយើងរិះរកគ្រប់មធ្យោបាយ និងបានធ្វើយុទ្ធនាការអន្តរសាសនា ដោយរួមគ្នាក្នុងការធ្វើឱ្យអំពើជួញដូរមនុស្សនៅកម្ពុជាត្រូវបានកាត់បន្ថយ ឬសាបរលាប និងការងារជាច្រើនទៀតពាក់ព័ន្ធនឹងការជួញដូរមនុស្សនេះ»។ ជាមួយគ្នានោះដែរ លោកស្រីក៏បានលើកឡើងផងដែរ ដែលកម្ពុជាកំពុងរៀបចំបង្កើតនូវផែនការប្រតិបត្តិការពិសេស ក្នុងការស្រាវជ្រាវរកនូវការលាក់កំបាំងករណីជួញដូរមនុស្សនៅទូទាំងប្រទេសកម្ពុជា ដែលប្រតិបត្តិការនេះអាចនឹងចាប់ផ្តើមអនុវត្តនាពេលឆាប់ៗខាងមុខនេះ។

នៅឆ្នាំ ២០២១ គឺជាឆ្នាំដែលកម្ពុជាបង្ក្រាបបានច្រើនជាងឆ្នាំណាទាំងអស់ ថ្វីដ្បិតតែជាអំឡុងពេលដែលកម្ពុជាកំពុងប្រយុទ្ធនឹងជំងឺកូវីដ ១៩ ក៏ដោយ ដែលឆ្នាំ ២០២១ គឺជាការបង្ក្រាបដើម្បីបង្ការការទប់ស្កាត់។ បើតាមលោកស្រី ជូ ប៊ុនអេង ក្នុងឆ្នាំ ២០២១ បង្ក្រាបករណីជួញដូរមនុស្សបានចំនួន ៣៥៩ ករណី កើនឡើងទ្វេដងជាងឆ្នាំ ២០១៩ ដែលមានតែ ១៥៥ ករណី។ កម្ពុជាក៏បានជួយសង្គ្រោះជនរងគ្រោះ ១៥៧៧ នាក់ ខណៈឆ្នាំ ២០១៩ មានតែ ៤៦៧ នាក់ និងបានកសាងសំណុំរឿងទៅតុលាការបានចំនួន ៥៣៨ ករណី ខណៈឆ្នាំ ២០១៩ មានចំនួន ១៩៣ ករណី។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ថា៖ «កម្ពុជាមិននៅស្ងៀមនោះទេលើការងារទប់ស្កាត់ ការបង្ក្រាប និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តែយើងឈឺចាប់នៅពេលដែលនៅតែមានសកម្មភាពថ្មីៗរបស់ជនល្មើសកើតមានឡើងលើទឹកដីកម្ពុជា ពីព្រោះយើងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីការពារប្រជាពលរដ្ឋមិនឱ្យរងគ្រោះដោយអំពើជួញដូរមនុស្សក៏ដោយ តែទីបំផុតគេនៅតែយកទឹកដីកម្ពុជា ដើម្បីយកមកធ្វើបទល្មើសឱ្យយើងប្រឈមជាមួយនឹងបទល្មើសនេះទាល់តែបាន»។ ចំណុចនេះដែរ លោកស្រីបានលើកឡើងដែរថា អ្វីដែលកម្ពុជារកឃើញគឺនៅក្នុងអំឡុងខែមិថុនា ឬខែកក្កដា ដែលវាផុតកំណត់ពីការវាយតម្លៃទៅហើយ ដែលលោកស្រីមិនដឹងថាតើការងារនេះ ឬបញ្ហានេះត្រូវផ្ទួបផ្សំជាមួយនឹងការវាយតម្លៃឆ្នាំមុននោះទេ។

លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា៖«យើងមិនប្រកែកទេ នៅពេលដែលគេសួរថាទទួលយកបានទេ? មានអីប្រកែកបើផ្សព្វផ្សាយទូទាំងពិភពលោកហើយហ្នឹង។ យើងទទួលយកប៉ុន្តែយើងក៏ត្រូវរិះរកគ្រប់មធ្យោបាយក្នុងការឆ្លើយតបទៅវិញផងដែរ ព្រោះយើងទទួលស្គាល់ដែរថាកម្ពុជាមិនមែនជាប្រទេសដែលមានសក្តានុពលគ្រប់គ្រាន់នៅក្នុងប្រឆាំងបទល្មើសគ្រប់បែបយ៉ាងនោះទេ ប៉ុន្តែយើងចាត់ទុកការប្រឆាំងបទល្មើសជាអាទិភាពទី ១ ដោយសារយើងចង់ឱ្យកម្ពុជាមានសុវត្ថិភាព និងសុខសន្តិភាព សម្រាប់មនុស្សគ្រប់គ្នា»។ លោកស្រីថា បច្ចុប្បន្ននេះកម្ពុជាបានបង្កើតផែនការប្រតិបត្តិការ ពិសេសសម្រាប់ការស្រាវជ្រាវរកនូវស្ថានភាពការលាក់កំបាំងករណីជួញដូរមនុស្សនៅទូទាំងប្រទេស ដែលនឹងធ្វើឡើងក្នុងពេលខាងមុខនេះ។ នាឱកាសនោះដែរ លោកស្រីក៏បានលើកឡើងដែរថា កម្ពុជាមិនដែលបដិសេធចំពោះការបង្ក្រាបបទល្មើសនេះទេ ហើយកម្ពុជាក៏បានព្យាយាមធ្វើការទំនាក់ទំនងជាមួយបណ្តាប្រទេសពាក់ព័ន្ធ ហើយប្រទេសដែលធ្វើការជាមួយនឹងកម្ពុជាបានដឹង និងសប្បាយចិត្ត ដោយសារកម្ពុជាបានបើកទូលាយឱ្យសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធធ្វើការជាមួយគ្នា ដើម្បីសង្គ្រោះប្រជាពលរដ្ឋរបស់គាត់។

គួរបញ្ជាក់ផងដែរថា កាលពីពេលថ្មីៗកន្លងទៅនេះ ក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការជួញដូរមនុស្សនៅលើពិភពលោករបស់ក្រសួងការបរទេសអាមេរិក បានដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ ៣ ក្នុងការបង្ក្រាបការជួញដូរមនុស្សដែលវាជារឿងមិនពិត និងជារឿងអយុត្តិធម៌សម្រាប់កម្ពុជា៕

## មន្ត្រីក្រសួងយុត្តិធម៌ ៖ ទោះបីចំណាត់ថ្នាក់កម្ពុជាយ៉ាងណា ក៏ការងារប្រឆាំងការជួញដូរមនុស្សនៅតែបន្តយ៉ាងសកម្ម

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១២ សីហា ២០២២ដោយ sopheak khoun

មន្ត្រីជាន់ខ្ពស់ក្រសួងយុត្តិធម៌ បញ្ជាក់ថា បើទោះបីជាចំណាត់ថ្នាក់កម្ពុជាទទួលបានយ៉ាងណាក៏ដោយ តែបេសកកម្មសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជានៅតែបន្ត ដរាបណាការងារមួយនេះមិនទាន់សម្រេចតាមគោល ដៅរបស់ខ្លួន។ លោក កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បញ្ជាក់បែបនេះ នៅក្នុងសន្និសីទសារព័ត៌មាន នៅថ្ងៃទី ១២ ខែសីហានេះ នាទីស្តីការគណៈរដ្ឋមន្ត្រី។

លោក កេង សុម៉ារិទ្ធ លើកឡើងថា បើទោះបីនៅក្នុងឆ្នាំនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ ៣ ដែលវាយតម្លៃដោយសហរដ្ឋអាមេរិកក៏ដោយ តែជានិច្ចកាលរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសសម្តេចក្រឡាហោម ស ខេង ក្នុងនាមជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺតែងតែយកចិត្តទុកដាក់ខ្ពស់ប្រកបដោយឆន្ទៈមោះមុត និងការប្តេជ្ញាចិត្តក្នុងការបំពេញការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយបទល្មើសជាបន្តបន្ទាប់។

លោករដ្ឋលេខាធិការ សង្កត់ធ្ងន់ថា ការខិតខំរបស់កម្ពុជាលើការងារប្រឆាំងអំពើជួញដូរមនុស្សនេះ គឺមិនមែនដើម្បីតែចំណាត់ថ្នាក់ទេ បើទោះបីចំណាត់ថ្នាក់កម្ពុជា ទទួលបានយ៉ាងណាក៏ដោយ ក៏បេសកកម្មមួយនេះនៅតែបន្តដដែល ពោលគឺដរាបណាមិនទាន់បានសម្រេចគោលដៅដែលខ្លួនចង់បាន។ លោកបន្តថា ក្នុងនាមជារដ្ឋមួយ គឺកម្ពុជាមានកាតព្វកិច្ចការពារឧត្តមប្រយោជន៍ជាតិ និងការធានាការពារសិទ្ធសេរីភាពរបស់ពលរដ្ឋ និងជនបរទេសទាំងឡាយដែលរស់នៅកម្ពុជា កុំឲ្យក្លាយជាជនរងគ្រោះដោយសារការជួញដូរ។ ជាមួយគ្នានេះ លោក កេង សុម៉ារិទ្ធ បញ្ជាក់ដែរថា ក្រសួងយុត្តិធម៌ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញ និងការពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា គឺក្រសួងបានយកចិត្តទុកដាក់យ៉ាងមោះមុត និងយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់ នៅក្នុងកិច្ចការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ផងដែរ៕ អត្ថបទ៖ ជឿន វ៉ាន់សុង

## រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://freshnewsasia.com/ 2022-08-12 04:37pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (គ.ជ.ប.ដ) បានបញ្ជាក់អំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងប្រទេស សំដៅធ្វើឲ្យការងារកាន់តែមានវឌ្ឍនភាពល្អប្រសើរបន្ថែមទៀត។ ការប្តេជ្ញានេះ បានធ្វើឡើងស្របពេលដែលសហរដ្ឋអាមេរិក បានទម្លាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជាពីលេខ២ មកនៅត្រឹមលេខ៣ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដែលជាចំណាត់ថ្នាក់មួយស្មើនឹងកម្ពុជា មិនបានធ្វើអ្វីសោះលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងសន្និសីទសារព័ត៌មានរបស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៅព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២នេះ ក្រោមប្រធានបទ «ស្ថានភាពការជួញដូរមនុស្សនៅកម្ពុជា» លោកស្រី ជូ ប៊ុនអេង បានអះអាងថា រាជរដ្ឋាភិបាលកម្ពុជាទទួលយកចំពោះចំណាត់ថ្នាក់នេះ ដើម្បីជុះខាតបន្ថែមទៀតនូវអ្វីដែលខ្វះខាត។

លោកស្រី ជូ ប៊ុនអេង បានថ្លែងយ៉ាងដូច្នេះថា **«យើងកំពុងធ្វើការងារយ៉ាងស្រួចស្រាវ ហើយការងារនេះយើងអត់មានបណ្តែតបណ្តោយទេ រហូតដល់បច្ចុប្បន្ននេះយើងបាននិងកំពុងតែរៀបចំនូវផែនការប្រតិបត្តិការពិសេសសម្រាប់ការស្រាវជ្រាវរកនូវស្ថានភាពដែលលាក់កំបាំង ក្នុងរឿងជួញដូរមនុស្សដែលមាននៅលើទឹកដីកម្ពុជានេះហើយ**

[...] **រាជរដ្ឋាភិបាលមិនដែលប្រងើយកន្តោយចំពោះការឆ្លើយតបអំពើជួញដូរមនុស្សនោះទេ»។** មន្ត្រីជំនាញរូបនេះលើកឡើងទៀតថា បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាមិនបានធ្វើការងារនេះលើបញ្ហាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតែម្នាក់ឯងនោះទេ ពោលបានព្យាយាមពង្រីកកិច្ចសហប្រតិបត្តិការឲ្យបានទូលំទូលាយ មិនមែនត្រឹមតែក្នុងរាជរដ្ឋាភិបាលនោះទេ ទាំងអង្គការដៃគូជាតិ និងអន្តរជាតិថែមទៀតផង ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលា និងទាន់សភាពការណ៍។ ជាមួយនឹងការទទួលយកនូវការដាក់ចំណាត់ថ្នាក់នេះ លោកស្រីអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ហាក់បានសម្តែងនូវការអន់ចិត្តចំពោះរដ្ឋាភិបាលអាមេរិក ដែលបានរកឃើញនូវអ្វីដែលជាការខ្វះខាតរបស់កម្ពុជា ប៉ុន្តែមិនបានរាយការណ៍ត្រង់មកកាន់រាជរដ្ឋាភិបាលនោះទេ ផ្ទុយទៅវិញបែរជាចេញផ្សាយនូវរបាយការណ៍ជាសាធារណៈតែម្តង។ លោកស្រីបានចាត់ទុកថា នេះប្រៀបដូចជាការដុតឲ្យខ្លោច រោលឲ្យឆៅ។

យ៉ាងណាមិញលោកស្រី ជូ ប៊ុនអេង ក៏បានបង្ហាញនូវអ្វីដែលជាយុទ្ធសាស្ត្រចំនួន៤យ៉ាងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញដោយអនុវត្តលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ដែលបណ្តាប្រទេសផ្សេងៗជាច្រើននៅលើពិភពលោកបានប្រើប្រាស់ដូចគ្នា។

*__ទី១៖__ ការងារបង្ការទប់ស្កាត់

*__ទី២៖__ កិច្ចការពារជនរងគ្រោះ

*__ទី៣៖__ ការអនុវត្តច្បាប់ ឬយុត្តិធម៌ព្រហ្មទណ្ឌ

*__ទី៤៖__ កិច្ចសហប្រតិបត្តិការរៀបចំ ឬអនុវត្តច្បាប់នានា។

លោកស្រីបានបន្ថែមថា ក្រៅពីយុទ្ធសាស្ត្រទាំង៤នេះ រាជរដ្ឋាភិបាលក៏បានបែងចែកក្រុមយន្តការចំនួន៦ក្រុម ដែលមានសមាសភាពចូលរួមចម្រុះ រួមជាមួយអង្គការដៃគូផងដែរ ក្នុងនោះរួមមាន ក្រុមការងារបង្ការទប់ស្កាត់, ក្រុមការងារអនុវត្តច្បាប់, ក្រុមការពារជនរងគ្រោះ, ក្រុមការងារកិច្ចការយុត្តិធម៌, ក្រុមការងារទេសន្តប្រវេសន៍ និងក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ។

សូមជម្រាបថា ក្រសួងការបរទេសអាមេរិក កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ បានផ្សព្វផ្សាយរបាយការណ៍ ឆ្នាំ២០២២ ស្តីពីការជួញដូរមនុស្ស។ ក្នុងបាយការណ៍នោះ គឺអាមេរិក បានដាក់កម្ពុជា វៀតណាម តំបន់ម៉ាកាវ របស់ចិន និងប្រទេសផ្សេងទៀត ពីបញ្ជីស្ថិតក្រោមការឃ្លាំមើលនៅកម្រិត២ ទៅកម្រិត៣ ដែលគេស្គាល់ជាទូទៅថា បញ្ជីខ្មៅ ដែលជាកម្រិតដ៏អាក្រក់។ អាមេរិកចោទប្រកាន់ថា កម្ពុជា និងប្រទេសទាំងនោះ មានកិច្ចខិតខំតិចតួច និងមិនបានគោរពតាមស្តង់ដារនៃការលុបបំបាត់ការជួញដូរមនុស្ស៕

# ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

## កម្ពុជា ស្នើអាមេរិកប្រាប់ពីកង្វល់របស់ខ្លួន លើករណីជួញដូរមនុស្ស ដើម្បីកែលម្អ ជាជាងយកទៅផ្សព្វផ្សាយ

https://www.btv.com.kh/ 2022/08/12 02:45:46 pm

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានស្នើទៅអាមេរិក ក្នុងនាមជាប្រទេសមានកិច្ចសហប្រតិបត្តិរួមគ្នា ប្រាប់ពីកង្វល់របស់ខ្លួនមកកាន់ម្ពុជា លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីធ្វើការរួមគ្នាកែលម្អ ជាជាងយកទៅផ្សព្វផ្សាយដុតឲ្យខ្លោចរោចឲ្យឆៅ ។

ក្នុងសន្និសីទសារព័ត៌មានស្តីពី ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា រៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ លោកជំទាវ ជូ ប៊ុនអេង មានប្រសាសន៍ថា អំពើជួញដូរមនុស្សកំពុងកក្រើកមានភាពស្មុគស្មាញ ព្រោះជាបញ្ហាសកល ដែលកើតឡើងទាំងនៅក្នុងប្រទេសតូច និងប្រទេសធំ ហើយមិនអាចប្រទេសណាមួយធ្វើតែម្នាក់ឯងបាននោះទេ ។ លោកជំទាវ បានបន្តថា ចំពោះកម្ពុជាបានយកចិត្តទុកដាក់ខ្លាំងណាស់ លើការងារប្រយុទ្ធប្រឆាំង តាមរយៈការអនុវត្តនូវគោលការណ៍ចំនួន ដែលប្រទេសក្នុងពិភពលោកធ្វើដូចគ្នា ក្នុងនោះ គឺការទប់ស្កាត់ ការបង្ក្រាប ការដាក់ទោសលើជនល្មើស និងការធ្វើកិច្ចសហប្រតិបត្តិជាមួយប្រទេសដៃគូនានា ។

លោកជំទាវ ជូ ប៊ុនអេង បន្ថែមថា ទោះបីជាកម្ពុជា និងដៃគូបានខិតខំទប់ស្កាត់ បង្ក្រាបបទល្មើសអំពើជួញដូរមនុស្សជាបន្តបន្ទាប់ ប៉ុន្តែជនល្មើសនៅឆ្លៀតឱកាស ក្នុងការប្រព្រឹត្តិ ហើយក្នុងនាមជាប្រទេសជាដៃគូរ បើមានកង្វល់អ្វីលើអំពើជួញដូរមនុស្សនៅកម្ពុជាគួរប្រាប់ផ្ទាល់ ដែលវាល្អប្រសើរជាងយកទៅផ្សព្វផ្សាយ ព្រោះកម្ពុជាមិនដែលព្រងើយកន្តើយនោះឡើយ លើបញ្ហាជួញដូរមនុស្ស និងទទួលយកនូវកិច្ចសហប្រតិបត្តិការ ។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃរូបនេះ បានបញ្ជាក់ថា កាលពីឆ្នាំ២០២១ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងអង្គការដៃគូ បានចុះផ្សព្វផ្សាយអប់រំពីបញ្ហាអំពើជួញដូរមនុស្ស ទៅប្រជាពលរដ្ឋបានជាង ៦លាននាក់ ជួយរំដោះពលរដ្ឋរងគ្រោះដោយអំពើជួញដូរមនុស្សជាង ១០០០នាក់ បានបញ្ជូនករណីល្មើសទៅតុលាការចំនួនជាង ៥០០ករណី ខណៈបច្ចុប្បន្នពលរដ្ឋខ្មែរ កំពុងធ្វើការចំណាក់ស្រុកទៅក្រៅប្រទេសមានជាង ១លាននាក់ ។

គួរបញ្ជាក់ថា កាលពីពេលថ្មីៗនេះ សហរដ្ឋអាមេរិក បានដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ៣ នៃការជួញដូរមនុស្ស ដែលការដាក់ចំណាត់ថ្នាក់មិនល្អនេះ ត្រូវបានមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា លើកឡើងថា ជាការផ្តល់ភាពអយុត្តិធម៌ ដល់ការខិតខំប្រឹងប្រែងរបស់កម្ពុជា និងដៃគូផ្សេងៗ ៕ អត្ថបទ៖ បាន សុខរិទ្ធិ

## មន្ត្រី៖ តុលាការកម្ពុជាកាត់ក្តីយ៉ាងម៉ឺងម៉ាត់រាល់អំពើជួញដូរមនុស្ស និងការផ្តន្ទាទោសជនល្មើស

https://www.btv.com.kh/ 2022/08/12 03:44:05 pm

ភ្នំពេញ៖ ឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ថ្លែងថា រាល់ករណីអំពើជួញដូរមនុស្ស គឺតុលាការកម្ពុជា បានកាត់ក្តីយ៉ាងម៉ឺងម៉ាត់ និងយកចិត្តទុកដាក់បំផុត រួមទាំងបានផ្តន្ទាទោសចំពោះជនល្មើស ហើយរាល់នីតិវិធី ធ្វើឡើយតាមដំណាក់កាល ។ ក្នុងសន្និសីទសារព័ត៌មានស្តីពី ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម កេង សុម៉ារិទ្ធ មានប្រសាសន៍ថា ក្រសួងយុត្តិធម៌ មិនអាចស្នើសុំឲ្យស្ថាប័នតុលាការ ដាក់ទោសទណ្ឌលើបុគ្គលណាមួយ ក្នុងកម្រិតធ្ងន់ ឬកម្រិតស្រាលបាននោះទេ ដែលនោះជាឯករាជ្យភាពរបស់តុលាការ ។ ឯកឧត្តមបានបន្តថា ប៉ុន្តែក្រសួងយុត្តិធម៌បានយកចិត្តទុកដាក់ណែនាំ ដោយស្នើសុំនូវកិច្ចសហការ និងជំរុញការអនុវត្តទៅលើការបង្ក្រាប ការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងការផ្តន្ទាទោស ដែលត្រូវអនុវត្តឲ្យម៉ឺងម៉ាត់បំផុត ចំពោះករណី ឬរឿងក្តីទាំងឡាយណា ដែលបានបញ្ជូនមកតុលាការ ។

រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានបន្ថែមថា កន្លងមកមានសំណុំរឿងជាច្រើន ដែលបានកសាងជាទិន្នន័យ ហើយធ្វើការរាយការណ៍ជាប្រចាំ ឃើញថាស្ថាប័នតុលាការ រាប់ទាំងដំណាក់កាលព្រះអយ្យការ ដំណាក់កាលស៊ើបសួរ ដំណាក់កាលជំនុំជម្រះ គឺយកចិត្តទុកដាក់ខ្ពស់ទាំងលើចំណាត់ការនៃរឿងក្តីទាំងអស់នេះ ទាំងអនុវត្តតាមច្បាប់នីតិវិធីជាធរមានយ៉ាងម៉ឺងម៉ាត់ រហូតឈានដល់ការផ្តន្ទាទោស ចំពោះជនល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ដែល

ការកាត់ទោសនេះ គឺជាការបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់ ដោយប្រព័ន្ធតុលាការកម្ពុជា ។ ឯកឧត្តម កេង សុម៉ារិទ្ធ បានបញ្ជាក់ថា ក្នុងឆមាសទី១ ឆ្នាំ២០២២ នៅស្ថាប័នអយ្យការទទួលបានសំណុំរឿងចំនួន១៩៥រឿង ពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុងនោះចំនួន១៥៣រឿង បានចាត់ការរួចរាល់ នៅសល់ចំនួន ៤២រឿងទៀត កំពុងបន្តនីតិវិធី ។ នៅក្នុងដំណាក់កាលស៊ើបសួរ ទទួលបានចំនួន ១៧៨សំណុំរឿង ដំណាក់កាលជំនុំជម្រះទទួលបាន ២៨០សំណុំរឿង ៕ អត្ថបទ ៖ បាន សុខរិទ្ធ

## លោកជំទាវ ជូ ប៊ុនអេង៖ ម្នាក់ៗត្វាក់ខ្លួនហើយ ក្រោយអាមេរិកទំលាក់ចំណាត់ថ្នាក់

https://kbn.news/ August 12, 2022

ភ្នំពេញ៖ «ទើបតែពេលនេះភ្ញាក់ទាំងអស់គ្នាហើយ ថាតើអំពើជួញដូរមនុស្សវាមានសារៈសំខាន់ប៉ុណ្ណា បើយើងមិនប្រឆាំងតបតតើវាមានរឿងអីកើតឡើង ហើយបើសិនជាយើងធ្វើក៏វាមានរឿងអីកើតឡើង»។ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងយ៉ាងដូច្នេះក្នុងសន្និសីទកាសែតរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលនៅព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២នេះ។

បើតាមលោកជំទាវ ជូ ប៊ុនអេង ការអះអាងខាងលើនេះ គឺបន្ទាប់ពីលោកជំទាវ សង្កេតឃើញថា«ច្បុប្បន្ននេះ អំពើជួញដូរមនុស្សវាក្លាយជាបរិបទសាកលដែលកន្លងមកមានស្ថានភាពឬមួយផ្នែកខ្លះ ក្រុមខ្លះ គឺគាត់មិនសូវយកចិត្តទុកដាក់ថាអំពើជួញដូរមនុស្សហ្នឹងវាមានរឿងអីដែលសំខាន់ទ។ អ៊ីចឹងបានជាយើងហាក់ដូចជាមើលរំលើងនូវសកម្មភាព និងលទ្ធផលដែលយើងខិតខំប្រឹងប្រែង»។ក្រសួងការបរទេសសហរដ្ឋអាមេរិក បានទំលាក់ចំណាត់ថ្នាក់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកម្ពុជាដក់កម្រិតទាបបំផុត ដែលមានន័យថាកម្ពុជាជាប្រទេសគ្មានឆន្ទៈទាល់តែសោះក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានថ្លែងទទួលយកការវាយតម្លៃនេះមកធ្វើជារបៀបវារៈបន្ថែមក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលរាជរដ្ឋាភិបាលនិងកំពុងប្រឹងប្រែង ក៏ប៉ុន្តែបានសម្តែងការអាក់អន់ស្រពន់ចិត្តខ្លះដែរចំពោះចំណាត់ថ្នាក់នេះ។

កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការប្រតិបត្តិការបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តមប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សម្តេចមានប្រសាន៍ថា រាជរដ្ឋាភិបាលកម្ពុជាដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការ បានខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងថាទោះជាភាគីអាមេរិកដាក់ចំណាត់ថ្នាក់បែបណាក៏ដោយ ក៏កម្ពុជាចាត់ទុកចំណាត់ថ្នាក់នេះជាមូលដ្ឋានមួយក្នុងការបន្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ខ្លួនដែរ។

ផ្តើមពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងការធ្វើពលីកម្មយ៉ាងសកម្មរបស់ក្រសួង ស្ថាប័នមាន សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម និងអាជីវកម្មផ្លូវភេទ បានញ៉ាំងឱ្យអំពើល្មើសទាំងនេះកាត់បន្ថយ និងធ្វើឲ្យសង្គមកម្ពុជា មានសុខសុវត្ថិភាព សន្តិសុខ មានការវិវត្តរីកចម្រើន មានភាពស៊ីវិល័យសមស្របតាមគន្លងប្រពៃណី និងទំនៀមទម្លាប់ដ៏ថ្លៃថ្នូររបស់ជាតិ ខ្មែរ ប្រជាពលរដ្ឋមានជីវភាពសមរម្យដោយបានចៀសផុតពីហានិភ័យ និងគ្រោះថ្នាក់ដែលបង្កដោយអំពើ ជួញដូរមនុស្ស ជួញដូរពលកម្ម និងជួញដូរផ្លូវភេទជាបន្តបន្ទាប់។ យ៉ាងណាក៏ដោយ កម្ពុជានៅមានសេសសល់បញ្ហាប្រឈមដោយអន្លើដែលបង្កឡើងដោយ

មហិច្ឆតារបស់ឧក្រិដ្ឋជន រួមទាំងកត្តាសត្យានុម័តិ អត្តនោម័តិ កត្តាសេដ្ឋកិច្ច និងកត្តានយោបាយផងដែរ ហើយបញ្ហាទាំងអស់នេះ បានជះឥទ្ធិពលដល់កិត្យានុភាពជាតិ ប៉ះពាល់ដល់គោលនយោបាយជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ថែមទាំងបង្កឱ្យមានផលប៉ះពាល់ដល់សិទ្ធិ សុខុមាលភាព និងជីវភាព ជាក់ស្តែង របស់ប្រជាពលរដ្ឋមួយចំនួនទៀតផង។

ដើម្បីជំរុញឱ្យបានខ្លាំងក្លាថែមទៀតនូវសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវផែនការប្រតិបត្តិការ មានខ្លឹមសារសំខាន់ៗពាក់ព័ន្ធនឹងការងារផ្សព្វផ្សាយអប់រំ ការអនុវត្តវិធានការរដ្ឋបាល ការអនុវត្តវិធានការច្បាប់ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ នេះបើតាមខ្លឹមសារចេញផ្សាយលើទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម ស ខេង។

សូមបញ្ជាក់ថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឱ្យដឹងថា ក្នុងឆ្នាំ២០២១ មានជនសង្ស័យចំនួន ៤០០នាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្សចំនួន២៣៥ករណី។ ចំនួននេះកើនឡើងយ៉ាងខ្លាំងរហូតដល់ទៅចំនួន១៩១ករណីបន្ថែមទៀត បើប្រៀបធៀបនឹងបទល្មើសដែលត្រូវបានបង្ក្រាបក្នុងឆ្នាំ២០២០ មានតែ ៤៤ករណីប៉ុណ្ណោះ។ ចំណាត់ថ្នាក់ទាបលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអាចឱ្យកម្ពុជាទទួលរងទណ្ឌកម្មផ្សេងៗពីភាគីអាមេរិក និងក្រុមសម្ព័ន្ធមិត្ត ៕

## កម្ពុជាប្តេជ្ញាបង្ក្រាបការជួញដូរមនុស្ស

https://www.khmertimeskh.com/ Khmer Times August 13, 2022

មន្ត្រីជាន់ខ្ពស់មួយរូបបាននិយាយកាលពីថ្ងៃសុក្រថា ប្រទេសកម្ពុជាបានបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដោយបានដោះស្រាយចំនួន ៣៥៩ករណី ក្នុងឆ្នាំ២០២១ ដែលជាការកើនឡើងគួរឱ្យកត់សម្គាល់ពីចំនួន ១៥៥ករណី ក្នុងឆ្នាំ២០២០។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា ដោយសាររដ្ឋាភិបាលកំពុងមមាញឹកប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ឧក្រិដ្ឋជនមួយចំនួនបានព្យាយាមរត់ពន្ធមនុស្សឆ្លងព្រំដែនកាលពីឆ្នាំមុន។ មន្ត្រីរូបនេះបាននិយាយក្នុងសន្និសីទសារព័ត៌មានដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលថា "ឆ្នាំ២០២១ គឺជាឆ្នាំដែលយើងបានកត់ត្រាចំនួនខ្ពស់បំផុតនៃការបង្ក្រាបករណីជួញដូរមនុស្ស"។ លោកស្រីបានបន្ថែមថា "នេះឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការខិតខំប្រឹងប្រែងឥតឈប់ឈររបស់យើង ដើម្បីការពារ និងជួយសង្គ្រោះមនុស្សពីការជួញដូរមនុស្សគ្រប់ទម្រង់"។ លោកស្រី ជូ ប៊ុនអេង ដែលជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សផងដែរនោះ មានប្រសាសន៍ថា នៅឆ្នាំ២០២១ មានជនសង្ស័យជួញដូរមនុស្សចំនួន ៥៣៨នាក់ ត្រូវបានបញ្ជូនទៅតុលាការ ខណៈជនរងគ្រោះចំនួន ១,៥៧៧ នាក់ត្រូវបានសង្គ្រោះ។ លោកស្រីបានបញ្ជាក់ជាថ្មីថា រដ្ឋាភិបាលប្តេជ្ញាលុបបំបាត់រាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ៕ *ស៊ីនហួ*

## ឆ្នាំ២០២១ កម្ពុជាបង្ក្រាបអំពើជួញដូរមនុស្សជាង ៣៥០ករណី និងសង្គ្រោះជនរងគ្រោះជាង១៥០០នាក់

https://btv.com.kh/ 2022/08/13 12:44:07 pm

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង បានឱ្យដឹងថា ក្នុងឆ្នាំ២០២១ កម្ពុជាបង្ក្រាបបទល្មើសជួញដូរ មនុស្សបានជាង ៣៥០ករណី ដែលការបង្ក្រាបនេះ បានច្រើនជាងឆ្នាំណាៗទាំងអស់ និងបានជួយ សង្គ្រោះជនរងគ្រោះចំនួនជាង ១៥០០នាក់ ។ ក្នុងសន្និសីទសារព័ត៌មាន ស្តីពីស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា កាលពីថ្ងៃទី១២ ខែសីហា ម្សិលមិញ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា នៅឆ្នាំ២០២១ ក្នុងដំណាក់កាល ដែលកំពុងមានការឆ្លងរាលដាល នៃជំងឺ កូវីដ-១៩ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សមត្ថកិច្ចពាក់ព័ន្ធ និងអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយពីករណីជួញដូរមនុស្ស ទៅដល់ប្រជាពលរដ្ឋចំនួនជាង ១២ម៉ឺន៨០០០លើក ស្មើមនុស្ស ជាង៦លាននាក់ ។

លោកជំទាវ បានបន្តថា នៅក្នុងឆ្នាំ២០២១ ការបង្ក្រាបបទល្មើសជួញដូរមនុស្ស បានរហូតដល់ ៣៥៩ករណី និងបានបញ្ជូនជនសង្ស័យជាច្រើននាក់ទៅតុលាការ ចាត់ការតាមនីតិវិធីច្បាប់ ខណៈ ឆ្នាំ២០១៩ បង្ក្រាបបានត្រឹម១៥៥ករណី គឺកើនឡើងទ្វេដង ហើយបានសង្គ្រោះជនរងគ្រោះរហូតដល់១ ៥៧៧នាក់ ដែលកាលពីឆ្នាំ២០១៩ គឺសង្គ្រោះបានត្រឹម ៤៦៧នាក់ ។ ក្នុងសន្និសីទនេះដែរ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ បានលើកឡើង ថា ប្រសិនបើពលរដ្ឋ ចង់រាយការណ៍ព័ត៌មានពាក់ព័ន្ធការជួញដូរមនុស្ស ដើម្បីឲ្យមានការបង្ក្រាបទាន់ពេលវេលា អាចទាក់ទង «Hotline របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស គឺ (១២៨៨) ហើយនៅពេល ដែលទូរស័ព្ទទៅ Hotlineនេះ មានការរអាក់រអួល គឺនៅមានហ្វេសប៊ុកផេករបស់នាយកដ្ឋានថែមទៀត ដែលអាចធ្វើព័ត៌មានចូល ដើម្បីសហការគ្នាស្រាវជ្រាវ ៕ អត្ថបទ៖ បាន សុខរិទ្ធិ

## ឧក្រិដ្ឋជនផ្លូវភេទជនជាតិកាណាដា ត្រូវចាប់ខ្លួននៅកម្ពុជាពីបទរំលោភផ្លូវភេទលើកុមារ

https://www.khmertimeskh.com/ Khmer Times August 14, 2022

អង្គភាពការពារកុមារ ដែលជាក្រុមស៊ើបអង្កេតមួយ សហការជាមួយក្រសួងមហាផ្ទៃកម្ពុជា ដែលទទួលបានមូលនិធិដោយអង្គការមិនរកប្រាក់ចំណេញ Cambodian Children's Fund មានប្រសាសន៍ថា Andrew David Eyre អាយុ៤៣ឆ្នាំ ត្រូវបានចាប់ខ្លួននិងចោទប្រកាន់កាលពីសប្តាហ៍មុនពីបទរំលោភផ្លូវភេទកុមារនិងបំពានធ្ងន់ធ្ងរ។ លោក James McCabe នាយកអង្គភាពបាននិយាយថា ការចោទប្រកាន់នេះ ជាប់ពាក់ព័ន្ធនិងជនរងគ្រោះខ្មែរចំនួន៨នាក់ មានអាយុពី៨ ទៅ ១២ឆ្នាំ។ RCMP បានប្រាប់ CBC News ថាខ្លួនក៏កំពុងស៊ើបអង្កេត Eyre ផងដែរ។ លោក Sgt Caroline Duval បានសរសេរនៅក្នុងអ៊ីមែល ថា "មន្ត្រីទំនាក់ទំនងរបស់ RCMP នៅប្រទេសថៃ និងមជ្ឈមណ្ឌលឧក្រិដ្ឋកម្មកេងប្រវ័ញ្ចកុមារជាតិកំពុងពិនិត្យមើលបន្ថែមទៀត លើសកម្មភាពរបស់ Eyre នៅក្នុងប្រទេសកាណាដា និងនៅបរទេស" ។ «លើសពីនេះ មន្ត្រីទំនាក់ទំនងកំពុងជួយក្រុមស៊ើបអង្កេតនៅកម្ពុជា»។ Eyre យោងទៅតាមទំព័រ LinkedIn ដែលផ្តល់នឹងការពិពណ៌នារបស់គាត់ មានទំនាក់ទំនងការងារ ការអប់រំ និងការស្ម័គ្រចិត្តជាមួយ Burnaby ។ Cpl. Alexa Hodgins ជាមួយ Burnaby RCMP បានប្រាប់ CBC នៅក្នុងអ៊ីមែលថា Mounties "មានឯកសារពីមុនជាមួយ Andrew Eyre ក្នុងឆ្នាំ២០១៨ ដែលគាត់ត្រូវបានកាត់ទោសពីបទល្មើសទាក់ទងនឹងផ្លូវភេទ" ។

សេវាអយ្យការ B.C. Prosecution Service នឹងមិនធ្វើអត្ថាធិប្បាយលើការផ្តន្ទាទោសពីមុនណាមួយឡើយ ហើយការតាមដានសំណួរទៅកាន់ RCMP មិនបានទទួលការឆ្លើយតបភ្លាមៗទេ។ McCabe និយាយថា អ្នកស៊ើបអង្កេតនៅកម្ពុជាគ្រោងនឹងដាក់សំណាញ់យ៉ាងទូលំទូលាយរុករកសកម្មភាពរបស់ Eyre នៅក្នុងភូមិដាច់ស្រយាល ដែលគាត់បានទៅ នៅក្នុងប្រទេស។ យោងតាមលោក McCabe Eyre ត្រូវបានគេចោទប្រកាន់ថាបានទៅលេងសហគមន៍ដាច់ស្រយាលមួយក្នុងខេត្តកណ្តាល ដែលមានចម្ងាយ ៧៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ លោកបានអះអាងថាជាគ្រូពេទ្យ និងបានពិនិត្យកុមារជាច្រើននាក់។ អំឡុងពេលនៃការពិនិត្យទាំងនេះគឺជាពេលដែលបទល្មើសត្រូវបានគេចោទថាបានកើតឡើង។ McCabe បាននិយាយថាសុខុមាលភាព និងស្ថានភាពរបស់កុមារកំពុងត្រូវបានត្រួតពិនិត្យ។

អង្គភាពការពារកុមារ និងមូលនិធិកុមារកម្ពុជា បានពណ៌នាលោក Eyre ជាមេចុងភៅ។ ទំព័រ LinkedIn គឺត្រូវគ្នានឹងឈ្មោះរបស់គាត់ បទពិសោធន៍ការងារធ្វើម្ហូប ពេលវេលាដែលបានចំណាយក្នុងប្រទេសកម្ពុជា និងអាយុប្រហាក់ប្រហែល។ គេហទំព័រនេះរាយឈ្មោះ Eyre ដែលបច្ចុប្បន្នកំពុងធ្វើការនៅទីក្រុងភ្នំពេញ បន្ទាប់ពីអ្នកធ្វើការនៅក្នុងប្រទេសចិន និងភោជនីយដ្ឋានជាច្រើនក្រុមហ៊ុនម្ហូបអាហារ និងទីលានវាយកូនហ្គោលនៅ B.C.។ គេហទំព័រនេះក៏រាយឈ្មោះគាត់ជាអ្នកស្ម័គ្រចិត្តជាមួយព្រះវិហារ Willingdon នៅ Burnaby ។ អាចារ្យម្នាក់នៅទីនោះបានប្រាប់ CBC ថាគាត់នឹកឃើញ Eyre ពីប៉ុន្មានឆ្នាំមុន ប៉ុន្តែវាមិនច្បាស់ថាជាគាត់ ប្រសិនបើ Eyre ជាអ្នកស្ម័គ្រចិត្ត។ ទោះបីជាគាត់បានឮថាគាត់អត់ដែលមានបញ្ហាអ្វីនោះទេ។ គេហទំព័រ LinkedIn ក៏រាយឈ្មោះ Eyre ជាគ្រូបង្រៀនធ្វើម្ហូបស្ម័គ្រចិត្តនៅសាលាមធ្យមសិក្សា Burnaby Central ។ បញ្ជីឈ្មោះគ្រូបង្រៀនរបស់ B.C. មិនបានចុះបញ្ជីនរណាម្នាក់ដែលមានឈ្មោះរបស់គាត់ថាមានអាជ្ញាប័ណ្ណគ្រូបង្រៀនទេ ហើយក៏មិនមានប្រវត្តិនៃវិន័យសម្រាប់អ្នកដែលមានឈ្មោះរបស់គាត់ដែរ។ រហូតមកដល់ពេលនេះ CBC មិនអាចទទួលបានការឆ្លើយតបពីសាលា Burnaby ទេ។

**កង្វល់សិទ្ធិមនុស្ស**ការចោទប្រកាន់ប្រឆាំងលោកEyreនៅកម្ពុជាមិនត្រូវបានបង្ហាញសក្ខីកម្មនៅតុលាការទេ។ McCabe និយាយថា Eyre នៅតែស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ បើត្រូវកាត់ទោសពីបទរំលោភផ្លូវភេទកុមារមានស្ថានទម្ងន់ទោស គាត់អាចនឹងជាប់ពន្ធនាគារពី ៧ ទៅ ១៥ឆ្នាំ។ បទរំលោភបំពានមានចាប់ពីការផាកពិន័យដល់ដាក់ពន្ធនាគាររហូតដល់បីឆ្នាំ។ McCabe និយាយថា Eyre ត្រូវបានគេផ្តល់មេធាវីម្នាក់ ហើយនឹងទទួលបានការកាត់ក្តីដោយយុត្តិធម៌ រួមទាំងការទទួលបានជំនួយផ្នែកកុងស៊ុលផងដែរ។ លោក McCabe បាននិយាយថា "គាត់នឹងទទួលបានសិទ្ធិក្រោមប្រព័ន្ធតុលាការ ដែលជាប្រព័ន្ធដ៏រឹងមាំ" ដោយបន្ថែមថា Eyre មិនបានផ្តល់ការពន្យល់ណាមួយសម្រាប់សកម្មភាពដែលត្រូវបានចោទប្រកាន់របស់គាត់នោះទេ។ Global Affairs Canada និយាយថា ខ្លួនដឹងពីជនជាតិកាណាដាម្នាក់ដែលត្រូវបានឃុំខ្លួនក្នុងប្រទេសកម្ពុជា ហើយកំពុងប្រមូលព័ត៌មានបន្ថែម។ *cbc.ca*

## តៃប៉ិឃាត់ខ្លួនប្តីប្រពន្ធពីបទជ្រើសរើសបុគ្គលិក និងបញ្ជូនអ្នកស្វែងរកការងារជាង១០០នាក់ឱ្យក្រុមឆបោកនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 14, 2022

នគរបាលបានឃាត់ខ្លួនប្តីប្រពន្ធ Taoyuan ដែលជាប់សង្ស័យថាបានឃុបឃិតគ្នាជាមួយក្រុមជួញដូរមនុស្ស និងអ្នកបោកប្រាស់ការងារនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ កាលពី ២ខែមុន ដែលបានបញ្ជូនអ្នកស្វែងរកការងារធ្វើជនជាតិតៃវ៉ាន់ជិត ១០០ នាក់មកកម្ពុជា។ នៅក្នុងសន្និសីទសារព័ត៌មាននៅទីក្រុងតៃប៉ិកាលពីម្សិលមិញ

ការិយាល័យស៊ើបអង្កេតឧក្រិដ្ឋកម្មបានបង្ហាញរបស់របរដែលរឹបអូសពីប្ដីប្រពន្ធ រួមទាំងលិខិតឆ្លងដែនរបស់ជនរងគ្រោះរបាយការណ៍ចាក់វ៉ាក់សាំង COVID-19ក្លែងបន្លំ ទូរសព្ទដៃ ឯកសារធនាគារ មូលប្បទានប័ត្រ និងសាច់ប្រាក់។ បុរសនោះមានឈ្មោះថា Tsai និងមិត្តស្រីរបស់គាត់ឈ្មោះ Tsan ត្រូវបានចាប់ខ្លួនកាលពីខែមុន បន្ទាប់ពីនគរបាលនៅអាកាសយានដ្ឋានអន្តរជាតិ Taoyuan របស់តៃវ៉ាន់បានឃាត់ខ្លួនអ្នកស្វែងរកការងារចំនួនបួននាក់ មិនឱ្យឡើងយន្តហោះមកទីក្រុងភ្នំពេញ នេះបើយោងតាមលោក Dustin Lee មន្ត្រីការិយាល័យកិច្ចការឧក្រិដ្ឋកម្មអន្តរជាតិ។

លោក Lee បាននិយាយថា នគរបាលបានឃុំខ្លួន Tsai នៅអាកាសយានដ្ឋាន បន្ទាប់ពីគាត់បានទម្លាក់មនុស្ស ៤នាក់។ លោកបានបន្ថែមថា សមាជិកគ្រួសារនៃអ្នកស្វែងរកការងារបានជូនដំណឹងដល់នគរបាលអំពីផែនការរបស់ពួកគេ។ លោក Lee បាននិយាយថា ក្រោយមក Tsan ត្រូវបានឃុំខ្លួននៅក្នុងការិយាល័យដែលគាត់នៅជាមួយTsai ដោយបន្ថែមថា ប្ដីប្រពន្ធទាំងពីរប្រឈមមុខនឹងការចោទប្រកាន់ពីបទឆបោក និងជួញដូរមនុស្ស។ លោក Lee បាននិយាយថា ក្រោយមកនគរបាលបានឃាត់អ្នកស្វែងរកការងារបីនាក់ទៀត មិនឱ្យឡើងយន្តហោះមកប្រទេសកម្ពុជា ដោយបន្ថែមថា ពួកគេទំនងជាក៏ត្រូវបានជ្រើសរើសដោយក្រុមជួញដូរមនុស្សដែលមានមូលដ្ឋាននៅប្រទេសកម្ពុជាផងដែរ។ លោក Lee បាននិយាយថា ក្រុមអ្នកស៊ើបអង្កេតសង្ស័យថា Tsai បានដឹកជញ្ជូនជនជាតិតៃវ៉ាន់ជិត១០០នាក់ទៅកាន់អាកាសយានដ្ឋានជាផ្នែកនៃប្រតិបត្តិការនេះ ដោយផ្អែកលើប្រាក់ប្រហែល ២លានដុល្លារតៃវ៉ាន់ (៦៦,៧៣៣ដុល្លារ) ដែលគាត់ត្រូវបានគេចោទប្រកាន់ថាបានទទួលសម្រាប់សេវាកម្មរបស់គាត់ពីមេក្លោងឆបោក។

នគរបាលបាននិយាយថា ក្រុមនេះត្រូវបានគេសង្ស័យថាបានកំណត់គោលដៅលើជនជាតិតៃវ៉ាន់តាមរយៈការផ្សាយពាណិជ្ជកម្មនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដែលសន្យាជាមួយអ្នកស្វែងរកការងារ ថានឹងទទួលបានប្រាក់ខែខ្ពស់នៅក្នុងកាស៊ីណូ និងសណ្ឋាគារក្នុងប្រទេសកម្ពុជា។ នគរបាលបាននិយាយថា ទោះជាយ៉ាងណាក៏ដោយសមាជិកក្រុមឆបោកក្នុងស្រុក ក្នុងស្រុកត្រូវបានចោទប្រកាន់ថាបានយកលិខិតឆ្លងដែនរបស់អ្នកស្វែងរកការងារធ្វើ និងឯកសារផ្ទាល់ខ្លួនផ្សេងទៀតនៅពេលដែលពួកគេមកដល់ប្រទេសកម្ពុជា ដែលជាកន្លែងដែលពួកគេត្រូវបានបង្ខំឱ្យធ្វើការសម្រាប់ប្រតិបត្តិការឆបោកតាមទូរស័ព្ទដែលផ្ដោតគោលដៅលើអ្នកនិយាយភាសាចិនកុកងឺ។

លោក Lee បាននិយាយថា Tsai និង Tsan ត្រូវបានគេចោទប្រកាន់ថាទទួលខុសត្រូវចំពោះប្រតិបត្តិការក្រុមឆបោកនៅតៃវ៉ាន់ រួមទាំងការផ្ដល់ព័ត៌មាន និងការបង់ប្រាក់ជាមុនដល់មនុស្សដែលចាប់អារម្មណ៍លើការងារដែលបានផ្សព្វផ្សាយ ការស្នើសុំលិខិតឆ្លងដែន និងការកក់សំបុត្រយន្តហោះ និងបន្ទប់សណ្ឋាគារមុនពេលពួកគេធ្វើដំណើរ។ លោក Lee បាននិយាយថា អ្នកស្វែងរកការងារដែលត្រូវបានឃាត់ខ្លួននៅអាកាសយានដ្ឋានមិនស្គាល់ឈ្មោះក្រុមហ៊ុនដែលពួកគេត្រូវធ្វើការនៅប្រទេសកម្ពុជា ហើយក៏មិនដឹងថាពួកគេនឹងត្រូវជួលសម្រាប់ការងារអ្វីដែរ។ លោកបានបន្ថែមថា អ្នកបោកប្រាស់មិនបានសួររកគុណវុឌ្ឍិទេ ដែលធ្វើឲ្យការផ្ដល់ជូនមានភាពទាក់ទាញដល់អ្នកដែលគ្មានជំនាញវិជ្ជាជីវៈ។ លោក Lee បាននិយាយថា មន្ត្រីបានប្រាប់ពលរដ្ឋទាំងនោះថា ពួកគេត្រូវបានឃាត់មិនឱ្យឡើងយន្តហោះគឺដោយសារ ពួកគេបានធ្លាក់ខ្លួនរងគ្រោះក្នុងក្រុមឆបោក ហើយថាពួកគេទំនងជាប្រឈមមុខនឹងការរំលោភបំពាននៅក្នុងប្រទេសកម្ពុជា។

ករណីដោយឡែកមួយទៀត ប៉ូលីសក្រុង Kaohsiung បាននិយាយថា ពួកគេបានឃាត់បុរសម្នាក់ឈ្មោះ Cheng និងមិត្តស្រីរបស់គាត់ ឈ្មោះ Wang មិនឱ្យធ្វើដំណើរមកប្រទេសកម្ពុជា ដែលពួកគេសង្ស័យថា ពួកគេនឹងក្លាយជាជនរងគ្រោះដោយសារគម្រោងស្រដៀងគ្នានេះ។ ឪពុកម្ដាយរបស់ Wang បានជូនដំណឹងដល់នគរបាលថានាង និងមិត្តប្រុសរបស់នាង មានគម្រោងទៅធ្វើការនៅទីនោះ ហើយនគរបាលបានបន្ថែមថា ពួកគេត្រូវបានគេសន្យាថា ទទួលបានការងារខ្ពស់ ហើយសំបុត្រយន្តហោះរបស់ពួកគេត្រូវបានបង់ដោយភាគីទីបី។ នគរបាលបាន

និយាយថា Cheng បានប្រាប់ពួកគេថាគាត់គឺជាពលករ ដែលគ្មានការងារធ្វើស្ថិតស្ថេរ។ នគរបាលបានដកស្រង់សម្តីគាត់ថា "គេផ្តល់ការងារឱ្យគាត់លើប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយអះអាងថា ពេលអ្នកមកដល់ស្រុកខ្មែរ ខ្ញុំមានមិត្តភក្តិមើលថែអ្នកគ្រប់យ៉ាង"។ *Taipei Times*

## ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២

### សមត្ថកិច្ចការពារព្រំដែនកម្ពុជានិងថៃ រួមគ្នាទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៤ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ១០:៤៤

ខេត្តបន្ទាយមានជ័យ ៖ លោកវរសេនីយ៍ឯក សូ ចាន់ណារី មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៩១១ អមដំណើរដោយលោកមេបញ្ជាការរង នាយ នាយរង និងមន្ត្រីនគរបាលប៉ុស្តិ៍ការពារព្រំដែនព្រៃគប់ និងប៉ុស្តិ៍ការពារព្រំដែនដើមកកោះ សរុបចំនួន១៥នាក់ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២នេះ បានជួបប្រជុំជាមួយទាហានឈុតខ្មៅថៃ វរសេនាធំលេខ១២ ចំនួន០៧នាក់ ដឹកនាំដោយលោកវរសេនីយ៍ឯក ភិយ៉ានេតផាតាឡាក់ សាត វ៉ាតាវង្ស មេបញ្ជាការ និងលោកវរសេនាតូចឯក ណាតាផុង មាំម៉ាឡាក់ មេបញ្ជាការរងប្រចាំស្រុកតាប្រាយ៉ា និងមន្ត្រីនៅចំណុចមុខភូមិសាស្ត្រគោលដៅ (ប៉ុស្តិ៍ព្រៃគប់ចាស់) ស្ថិតភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ។ លោកវរសេនីយ៍ឯក សូ ចាន់ណារី បានលើកឡើងថា ៖ តាមការណាត់ជួបទ្វេភាគីនៅក្នុងជំនួបនោះ ភាគីទាំង០២ បានលើកយក០៣ចំណុចគឺ ៖

១- រួមគ្នាទប់ស្កាត់ប្រជាពលរដ្ឋទាំងសងខាងមិនឲ្យចូលកា.ប់ឆ្ការព្រៃ សាងសង់សំណង់ អាស្រ័យផលនៅក្នុងតំបន់ព្រំដែនមិនទាន់ច្បាស់លាស់ឡើយ ។

២- រួមគ្នាទប់ស្កាត់បទល្មើសឆ្លងដែនដោយខុសច្បាប់ ។

៣- បង្កើនកិច្ចសហប្រតិបត្តិការ និងផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក រាល់ហេតុការណ៍កើតឡើងនៅតាមបន្ទាត់ព្រំដែន ៕

### សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/08/13/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១១ និង ០០នាទី ថ្ងៃសៅរ៍ ១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័កព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង–ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១២នាក់ ស្រី៥នាក់ក្មេងប្រុស១

នាក់។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្កែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## បទយកការណ៍៖ការប្រយុទ្ធនឹងការជួញដូរមនុស្សនៅកម្ពុជាត្រូវការកិច្ចសហប្រតិបត្តិពីបណ្ដាប្រទេសពាក់ព័ន្ធ

https://www.khmertimeskh.com/ តាំង វីនិត្យ និង យឹម ស្រីលីន August 15, 2022

ការជួញដូរមនុស្ស ដែលកំណត់ថាជាការប្រើប្រាស់កម្លាំងបាយ ការក្លែងបន្លំ ឬការបង្ខិតបង្ខំ ដើម្បីទទួលបានការងារប្រភេទណាមួយ ឬសកម្មភាពផ្លូវភេទបែបពាណិជ្ជកម្ម មិនមែនជាបញ្ហាថ្មីសម្រាប់ប្រទេសកម្ពុជាទេ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះហាក់ដូចជាឈានដល់កម្រិតកំពូលនាពេលថ្មីៗនេះ បន្ទាប់ពីកម្ពុជាត្រូវបានអន្តរជាតិរិះគន់ចំពោះសមត្ថភាពរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងទម្រង់ឧក្រិដ្ឋកម្មនេះ។

កាលពីខែកក្កដា ស្ថានទូតអាមេរិកប្រចាំកម្ពុជាបានទម្លាក់ចំណាត់ថ្នាក់របស់កម្ពុជាពីលំដាប់ទី ២ មកកម្រិតទី ៣ នៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០២២ របស់ខ្លួន ដែលមានន័យថា កម្ពុជាបានធ្លាក់ទៅក្នុងបញ្ជីខ្មៅ ដែលប្រឈមនឹងការទទួលរងទណ្ឌកម្មពីសហរដ្ឋអាមេរិក បើទោះបីជារដ្ឋបាលតែងតែលើកលែងការដាក់ទណ្ឌកម្មចំពោះប្រទេសជាមិត្តដែលសន្យាថានឹងមានការកែលម្អក៏ដោយ។ អ្នកសរសេររបាយការណ៍បាននិយាយថា រដ្ឋាភិបាលកម្ពុជាបានបរាជ័យក្នុងការផ្តល់សេវាការពារគ្រប់គ្រាន់សម្រាប់ជនរងគ្រោះក្នុងប្រទេស ឬក្រៅប្រទេស ហើយពឹងផ្អែកខ្លាំងលើម្ចាស់ជំនួយបរទេស និងអង្គការក្រៅរដ្ឋាភិបាលក្នុងក ារផ្តល់ការគាំទ្រដែលមានតម្រូវការច្រើន។ របាយការណ៍នេះថ្លែងថា៖ «កម្ពុជាមិនទាន់បំពេញបានពេញលេញនូវស្តង់ដារអប្បបរមាសម្រាប់ការលុបបំបាត់ការជួញដូរ ហើយមិនបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើដូច្នេះទេ សូម្បីតែមានផលប៉ះពាល់នៃជំងឺរាតត្បាត កូវីដ-១៩ លើសមត្ថភាពប្រឆាំងការជួញដូររបស់ខ្លួន ដូច្នេះហើយ កម្ពុជាត្រូវបានទម្លាក់ចំណាត់ថ្នាក់ទៅចំណាត់ថ្នាក់ទី ៣»។ ការទម្លាក់ចំណាទបានបង្កជាភាពចម្រូងចម្រាស់ ខណៈដែលមន្ត្រីពាក់ព័ន្ធកម្ពុជាបាននិងកំពុងសម្តែងការខកចិត្តចំពោះរបាយការណ៍របស់ស្ថានទូតសហរដ្ឋអាមេរិក អំពីស្ថានភាពជួញដូរមនុស្សនៅក្នុងប្រទេសដោយអះអាងថារបាយការណ៍នេះបានវាយតម្លៃតិចតួចដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មនេះ។ ជាមួយគ្នានេះដែរ អង្គការសិទ្ធិមនុស្សក្នុងស្រុក ភាគច្រើនគាំទ្រការវាយតម្លៃ ដោយហៅវាថាជាការឆ្លុះបញ្ចាំងអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ការវាយតម្លៃរបស់ស្ថានទូតអាមេរិកបានធ្វើឡើងបន្ទាប់ពីមានរបាយការណ៍ជាច្រើនខែ នៃករណីជនបរទេសត្រូវបានបោកប្រាស់ដោយក្រុមប្រតិបត្តិករខុសច្បាប់នៅក្នុងប្រទេសដែលភាគច្រើនបានកើតឡើងនៅក្នុងក្រុងព្រះសីហនុដែលជាមជ្ឈមណ្ឌលវិនិយោគរបស់ចិននៅកម្ពុជា។

កាសែតខ្មែរថាមស៍ ដែលបានស៊ើបអង្កេតយ៉ាងទូលំទូលាយទៅលើករណីទាំងនោះ និងរាយការណ៍អំពីប្រតិបត្តិការជួយសង្គ្រោះ បានរកឃើញថា ដំណើរការប្រតិបត្តិការនេះពាក់ព័ន្ធនឹងអ្នកបោកប្រាស់ដែលផ្តល់ឲ្យជនរងគ្រោះដែលរហូតមកដល់ពេលនេះរួមមានជនជាតិចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ និងវៀតណាមថ្មីៗនេះ នូវប្រាក់ខែខ្ពស់ និងអត្ថប្រយោជន៍ការងារជាច្រើនក្នុងការអូសទាញពួកគេចូលប្រទេសកម្ពុជា។ នៅពេលដែលជនរងគ្រោះមកដល់ ពួកគេត្រូវបានក្រុមឧក្រិដ្ឋជនចាប់បង្ខាំង និងបង្ខំឱ្យធ្វើការក្នុងប្រតិបត្តិការខុសច្បាប់ដោយរងការគំរាមកំហែង ខណៈដែលអ្នកខ្លះដែលត្រូវបានជួយសង្គ្រោះបាននិយាយថា ពួកគេត្រូវបានគេគេបំពានលើរាងកាយ។

កាលពីខែមីនាកន្លង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានប្រកាសថា ក្រសួងរបស់លោកប្តេជ្ញាបញ្ចប់ឧក្រិដ្ឋកម្មទាំងអស់ រួមទាំងការបោកប្រាស់គ្រប់ប្រភេទនៅខេត្តព្រះសីហនុ ដែល «កំពុងបំផ្លាញកេរ្តិ៍ឈ្មោះរបស់ព្រះ

រាជាណាចក្រកម្ពុជា»នៅមុនការបោះឆ្នោតឃុំសង្កាត់នៅខែមិថុនា។ ទោះបីជាយ៉ាងណាក៏ដោយ ករណីនៅតែត្រូវបានរាយការណ៍ថា កំពុងតែបន្តកើតមាន។ ទាំងនេះបង្ហាញថា ទម្រង់ថ្មីនៃទាសភាពសម័យទំនើប ដែលពឹងផ្អែកលើអុ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ប្រតិបត្តិការ ឥឡូវនេះកំពុងគ្របដណ្តប់លើការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា ដែលរហូតមកដល់ពេលនេះហាក់ដូចជាបានប្រែក្លាយពីប្រទេសនាំចេញទៅជាប្រទេសគោលដៅសម្រាប់ឧក្រិដ្ឋកម្ម។ ហើយដោយសារបទល្មើសបែបនេះមានជាប់ពាក់ព័ន្ធនឹងប្រទេសជាច្រើន ក្រុមមន្ត្រីរបស់កម្ពុជាដែលទទួលបន្ទុកលើប្រធានបទនេះបានលើកឡើង កម្ពុជាមិនគួរទទួលខុសត្រូវតែម្នាក់ឯងក្នុងការប្រយុទ្ធនឹងវានោះទេ។

តម្រូវការនៃសហប្រតិបត្តិការលក្ខណៈអន្តរជាតិ ទោះបីជារងការរិះគន់យ៉ាងខ្លាំងក៏ដោយ ក៏ស្ថិតិបានបង្ហាញថា ប្រទេសកម្ពុជាបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ យោងតាមក្រសួងមហាផ្ទៃ ប្រទេសកម្ពុជាបានបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដោយបានដោះស្រាយចំនួន ៣៥៩ ករណីក្នុងឆ្នាំ ២០២១ ដែលកើនឡើងគួរឱ្យកត់សម្គាល់ពីចំនួន ១៥៥ ករណីក្នុងឆ្នាំ ២០២០។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សបាននិយាយថា៖ «ឆ្នាំ២០២១ គឺជាឆ្នាំដែលយើងបានកត់ត្រាចំនួនការបង្ក្រាបករណីជួញដូរមនុស្សខ្ពស់បំផុត»។ លោកស្រីបន្ថែមថា៖ «ទោះជាយ៉ាងនេះក្តី ឆ្នាំនេះគឺជាឆ្នាំដ៏អាក្រក់បំផុតសម្រាប់ប្រទេសកម្ពុជា ទាក់ទងនឹងការជួញដូរមនុស្ស ដែលជាការឈឺចាប់សម្រាប់ប្រទេសកម្ពុជា ដោយសារថាយើងបានខិតខំយ៉ាងខ្លាំងដើម្បីប្រយុទ្ធនឹងវា»។

បន្ថែមពីលើនេះ លោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានមានប្រសាសន៍កាលពីសប្តាហ៍មុនថា ដោយមិនគិតពីសហរដ្ឋអាមេរិក កម្ពុជានឹងប្រើប្រាស់ចំណាត់ថ្នាក់នេះជាមូលដ្ឋានសម្រាប់បន្តការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ លោកបានមានប្រសាសន៍ថា៖ «រដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងពាណិជ្ជកម្មផ្លូវភេទ ជាពិសេសកុមារ និងស្ត្រីកម្ពុជា ក៏ដូចជាជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា»។ ប៉ុន្តែ ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃទម្រង់ថ្មីនៃទាសភាពសម័យទំនើបនៅក្នុងកម្ពុជា ក្រុមមន្ត្រីកម្ពុជាបានលើកឡើងថា វាហាក់បីដូចជាមិនត្រឹមត្រូវនោះឡើយសម្រាប់កម្ពុជាក្នុងការដោះស្រាយវាតែម្នាក់ឯងនោះទេ។

លោកស្រី ជូ ប៊ុនអេង បានលើកឡើងថា ខណៈពេលដែលរបាយការណ៍របស់ស្ថានទូតសហរដ្ឋអាមេរិក ស្តីពីការជួញដូរមនុស្សធ្វើឱ្យខូចកេរ្តិ៍ឈ្មោះកម្ពុជា វាក៏ជាការអាម៉ាស់ផងដែរសម្រាប់ប្រទេសដែលពលរដ្ឋត្រូវបានជួញដូរចូលមកក្នុង កម្ពុជា។ លោកស្រីបាននិយាយថា៖ «ប្រទេសទាំងអស់គួរតែចូលរួម។ សម្រាប់ប្រទេសកម្ពុជា យើងកំពុងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម ប៉ុន្តែគ្រប់គ្នាដឹងថាឧក្រិដ្ឋជននឹងមិនមកប្រាប់យើងដោយផ្ទាល់អំពីប្រតិបត្តិការរបស់ពួកគេនោះទេ»។ លោកស្រីបន្តថា៖ «ឧក្រិដ្ឋកម្មកំពុងកើតឡើង ហើយយើងបង្ក្រាបពួកវានៅពេលយើងដឹងពីពួកវា ប៉ុន្តែជនល្មើសតែងតែមានមធ្យោបាយ និងរកវិធីថ្មីដើម្បីគេចពីយើង»។ ទោះជាយ៉ាងណាក៏ដោយ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្នុងតំបន់នាពេលបច្ចុប្បន្ន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅកម្ពុជា ហាក់នៅមានកម្រិតខ្លាំង។ ជាឧទាហរណ៍ កាសែត បាងកកប៉ុស្តិ៍កាលពីដើមខែនេះ បានរាយការណ៍ថា ជនជាតិថៃចំនួន ៩៤ នាក់ ដែលបានសហការ ឬធ្វើការជាមួយក្រុមអ្នកបោកប្រាស់នៅទីក្រុងភ្នំពេញត្រូវបានអាជ្ញាធរកម្ពុជានិរទេសត្រឡប់ទៅប្រទេសថៃវិញ ដើម្បីប្រឈមមុខនឹងយុត្តិធម៌។ ទោះជាយ៉ាងណា មន្ត្រីពាក់ព័ន្ធមួយចំនួន រួមទាំងប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ដែលត្រូវបានទាក់ទងសុំការអត្ថាធិប្បាយដោយកាសែត ខ្មែរថាមស៍ បានលើកឡើងថា មិនបានដឹងពីរឿងនេះនោះឡើយ។

នៅពេលត្រូវសួរថា តើក្របខណ្ឌដាក់លាក់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សមានដែរឬទេនោះ លោកស្រី ជូ ប៊ុនអេង បានថ្លែងថាវានៅតែស្ថិតក្នុង «ការអភិវឌ្ឍ» ប៉ុន្តែនឹងបង្កើតលទ្ធផលឆាប់ៗ។ លោកស្រីបានបន្តថា៖ «ទន្ទឹមនឹងនេះ យើងបាននិងកំពុងធ្វើការបង្ក្រាបរាល់ករណីដែលយើងបានកំណត់ដោយការធ្វើការជាមួយមន្ត្រីនៃប្រទេសពាក់ព័ន្ធ។ ប្រទេសមួយ ចំនួន ដូចជាប្រទេសឥណ្ឌូនេស៊ីបានសម្តែងអំណរគុណចំពោះពួកយើងចំពោះការជួយសង្គ្រោះពលរដ្ឋរបស់ពួកគេ»។ យ៉ាងណាក៏ដោយ លោកស្រី ជូ ប៊ុនអេង អះអាងថា ខណៈជាមួយគ្នានេះ មានប្រទេសមួយចំនួន ដែលលោកស្រីបដិសេធមិនបញ្ចេញឈ្មោះ « ដើម្បីការពារភាពតានតឹងផ្នែកនយោបាយ» បានដាក់ទំនួលខុសត្រូវស្ទើរតែទាំងស្រុងមកលើកម្ពុជាចំពោះពលរដ្ឋរបស់ខ្លួន ដែលបានរងគ្រោះដោយសារការជួញដូរដែលប្រព្រឹត្តដោយឧក្រិដ្ឋជននៅកម្ពុជា។ លោកស្រីបាននិយាយថា៖« យើងបានទទួលស្គាល់ថាមានចន្លោះប្រហោងមួយចំនួននៅក្នុងប្រតិបត្តិការរបស់យើង ប៉ុន្តែការចោទប្រកាន់មួយចំនួនដោយប្រទេសទាំងនោះគឺគ្មានមូលដ្ឋានទេ ឧទាហរណ៍ដោយពឹងផ្អែកលើចំនួនពលរដ្ឋរបស់ពួកគេដែលមិនអាចត្រឡប់ទៅប្រទេសរបស់ពួកគេវិញ»។ ជាមួយគ្នានោះដែរ ក៏មានឧទាហរណ៍ដែលជនបរទេសមួយចំនួនដែលក្លែងខ្លួនជាជនរងគ្រោះដោយគ្រាន់តែដើម្បីប្រយោជន៍ខ្លួនផ្ទាល់ខ្លួន។

បុរសជនជាតិចិនម្នាក់បាននិយាយថា គាត់ជាជនរងគ្រោះនៃការបោកប្រាស់ការងារ ហើយត្រូវបានល្បួងឱ្យចូលមកកម្ពុជា ហើយត្រូវបានគេបង្ខំបូមឈាមពីគាត់ម្តងហើយម្តងទៀត អស់រយៈពេលប្រាំមួយខែ ដែលជាការកុហកមួយដែល គាត់ និងជនរួមជាតិរបស់គាត់ប៉ុន្មាននាក់បានបង្កើត ដើម្បីគេចពីការចោទប្រកាន់ពីអន្តោប្រវេសន៍ខុសច្បាប់។ ពេលនេះគាត់ និងជនផ្សំគំនិតកំពុងប្រឈមនឹងការចោទប្រកាន់នៅតុលាការ។ ឧទាហរណ៍មួយទៀតគឺស្ត្រីជនជាតិថៃអាយុ ២៥ ឆ្នាំម្នាក់ដែលកាលពីថ្ងៃទី ៩ ខែមីនាបានរាយការណ៍ទៅប៉ូលីសថៃថា នាងត្រូវបានទាក់ទាញឱ្យមកខេត្តព្រះសីហនុឱ្យធ្វើការនៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទខុសច្បាប់ដោយក្រុមជនជាតិចិនដែលបានបូមឈាមរបស់នាងជាច្រើនដង ព្រមទាំងចង់វះយកគ្រឿងក្នុងនាងថែមទៀតផង។ ជាមួយនឹងសាច់រឿងដែលពោរពេញដោយការគួរឱ្យសង្ស័យ ក្រោយមកនាងបានសារភាពប្រាប់ប៉ូលីសថា នាងបានប្រឌិតរឿងនេះ ហើយត្រូវបានតុលាការខេត្តស្រះកែវ កាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ ។

លោកស្រី ជូ ប៊ុនអេង បាននិយាយថា៖«ខ្ញុំសង្ឃឹមថាប្រទេសនានានឹងធ្វើការបន្ថែមទៀតលើកិច្ចសហប្រតិបត្តិការជាមួយយើងក្នុងការដោះស្រាយបញ្ហាជាជាងការផ្តោតលើការផ្សព្វផ្សាយព័ត៌មាន។ ការផ្សព្វផ្សាយព័ត៌មានដល់ពិភពលោកទាំងមូល ដែលវាយប្រហារប្រទេសកម្ពុជាដែលកំពុងខិតខំធ្វើការបង្ក្រាបគឺមិនមានផលប្រយោជន៍នោះទេ»។ យ៉ាងណាក៏ដោយ ប្រទេសមួយចំនួនបានបង្ហាញកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនិងការជួញដូរមនុស្ស។

ជាឧទាហរណ៍ ម៉ាឡេស៊ីបានប្តេជ្ញាបន្តការប្រយុទ្ធប្រឆាំងនឹងទាសភាពសម័យទំនើបជារួម ដើម្បីឲ្យជនរងគ្រោះអាចទទួលបានការការពារ នេះបើតាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោកHamzah Zainudin ក្នុងខែមករាឆ្នាំនេះ។ លោក Zainudin បានប្រាប់ Free Malaysia Today ថា ការជួញដូរមនុស្ស និងពលកម្មដោយបង្ខំ គឺជាបញ្ហាឆ្លងព្រំដែន ដែលកើតឡើងនៅក្នុងប្រទេសជាច្រើន មិនថាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍនោះទេ។ លោកបានថ្លែងថា៖ «ដូច្នេះហើយបានជាខ្ញុំមកជាមួយមន្ត្រីជាន់ខ្ពស់ដើម្បីដោះស្រាយបញ្ហាផ្លូវច្បាប់ហើយក្នុងពេលជាមួយគ្នាដើម្បីប្រាប់សមភាគីរបស់យើងអំពីអ្វីដែលយើងកំពុងធ្វើ»។ ជាមួយគ្នានេះ លោក Eldeen Husaini Mohd Hashim ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំនៅកម្ពុជា បានជំរុញឱ្យប្រជាជនម៉ាឡេស៊ីមានការសង្ស័យ នៅពេលដែលពួកគេឃើញការផ្សាយពាណិជ្ជកម្មជ្រើសរើសការងារដែលសន្យាថានឹងទទួលបានប្រាក់កម្រៃខ្ពស់និងអត្ថប្រយោជន៍មិនគួរឱ្យជឿនៅក្រៅប្រទេស។ ឯកអគ្គរដ្ឋទូត Eldeen បានប្រាប់ Bernama ដែលជាទីភ្នាក់ងារព័ត៌មានរដ្ឋាភិបាលម៉ា

ឡេស៊ី អាជ្ញាធរបានរកឃើញជនជាតិម៉ាឡេស៊ីជាច្រើននាក់ជាប់គាំងក្នុងកម្ពុជា បន្ទាប់ពីត្រូវបានបោកប្រាស់ដោយក្រុមប្រតិបត្តិការខុសច្បាប់។ លោកបានថ្លែងថា៖ «យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធរពាក់ព័ន្ធដើម្បីអាចជួយពួកគេឲ្យត្រឡប់មកផ្ទះវិញ។ ទោះជាយ៉ាងនេះក្តី ដំណើរការក្នុងការរកដោះស្រាយសំណុំរឿងខុសគ្នានិងត្រូវការពេលវេលា»៕

## អង្គការសិទ្ធិមនុស្ស ទាមទារសំណងលើការរំលោភបំពានពលករចំណាកស្រុក

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៥ សីហា ២០២២ដោយ Dy Bunnara

អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានអំពាវនាវឱ្យ FIFA និងកាតា ធ្វើឱ្យប្រសើរឡើងនូវសំណងរបស់ប្រទេសចំពោះ "ការរំលោភបំពាន" ពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ។ ក្រុមសកម្មជនបានទទូចថា "កម្មវិធីសំណងដ៏ទូលំទូលាយ" គួរតែត្រូវបានបង្កើតឡើង "សម្រាប់កម្មករដែលបានទទួលគ្រោះថ្នាក់ធ្ងន់ធ្ងរ រួមទាំងការស្លាប់ របួស និងការលួចកាត់ប្រាក់ឈ្នួល" អំឡុងពេលពួកគេធ្វើការលើគម្រោងទាក់ទងនឹងការប្រកួតបាល់ទាត់ពិភពលោក ដូចជាកីឡដ្ឋាន ការដឹកជញ្ជូន និងសណ្ឋាគារ។ វាមិនបានបញ្ជាក់ថា តើត្រូវបង់ប៉ុន្មានទៅអ្នកដែលពាក់ព័ន្ធនោះទេ។

ប្រទេសកាតា បានប្រឈមមុខនឹងការត្រួតពិនិត្យយ៉ាងខ្លាំងក្លាចាប់តាំងពីការទទួលបានសិទ្ធិធ្វើម្ចាស់ផ្ទះ FIFA World Cup ឆ្នាំ២០២២ សម្រាប់ច្បាប់ការងាររបស់ខ្លួន និងការយកចិត្តទុកដាក់លើពលករចំណាកស្រុករាប់សែននាក់ ដែលបានជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាតម្រូវការសម្រាប់ព្រឹត្តិការណ៍បែបនេះ។ ខណៈពេលដែលអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានទទួលស្គាល់ថាប្រព័ន្ធសំណងជាច្រើនត្រូវបានណែនាំដើម្បីកាត់បន្ថយបញ្ហាទាំងនេះ ប៉ុន្តែវាបែជាត្រូវបានអះអាងថា មិនមានសារសំខាន់គ្រប់គ្រាន់ដើម្បីគ្របដណ្តប់ក្នុងការជួយកម្មករទាំងអស់ពីការរំលោភបំពាននោះទេ។

លោក Michael Page អនុប្រធានមជ្ឈិមបូព៌ានៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយថា «ប្រទេសកាតាបានផ្តល់សំណងដល់កម្មករចំណាកស្រុកមួយចំនួនដែលបានប្រឈមមុខនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែ កម្មវិធីទាំងនេះត្រូវបានបង្កើតឡើងយឺតពេល ហើយនៅតែមានការងារមួយចំនួនធំដែលកំពុងស្ថិតដំណើរការនៅឡើយ។ វាមានសារៈសំខាន់ណាស់សម្រាប់ FIFA និងកាតា ក្នុងការប្តេជ្ញាចិត្តជាសាធារណៈ ទៅលើការផ្តល់សំណងដល់កម្មករ និងក្រុមគ្រួសាររបស់ពួកគេដែលបានរងគ្រោះថ្នាក់ធ្ងន់ធ្ងរ ខណៈពេលដែលពួកគេនេះហើយជាអ្នកធ្វើឱ្យការប្រកួតបាល់ទាត់ពិភពលោកអាចប្រព្រឹត្តទៅបាន»។

របាយការណ៍របស់ Guardian បានលើកឡើងថា កម្មករជាង ៦,៥០០នាក់ មកពីប្រទេសឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដែស នេប៉ាល់ និងស្រីលង្កា បានស្លាប់នៅក្នុងប្រទេសនេះ ចាប់តាំងពីប្រទេសកាតា បានទទួលសិទ្ធរៀបចំ World Cup តាំងពីឆ្នាំ២០១០។ ៣៧នាក់នៃការស្លាប់ទាំងនេះ ត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងការសាងសង់កីឡដ្ឋានសម្រាប់ការប្រកួត។ យោងតាមអង្គការឃ្លាំមើលសិទ្ធិមនុស្ស អាជ្ញាធរកាតាមិនបានស៊ើបអង្កេតមូលហេតុនៃការស្លាប់របស់កម្មកររាប់ពាន់នាក់នោះទេ ហើយបានបញ្ជាក់ថាមូលហេតុនៃការស្លាប់របស់ពួកគេគឺមកពី "មូលហេតុធម្មជាតិ"។ សម្ព័ន្ធនៃអង្គការចំនួន១០ រួមទាំងអង្គការលើកលែងទោសអន្តរជាតិ បានជំរុញកាលពីខែឧសភាឱ្យ FIFA ប្តេជ្ញាបង់ប្រាក់ចំនួន ៤៤០លានដុល្លារ ដល់ពលករចំណាកស្រុកដែលបានជួបប្រទះ "ការរំលោភសិទ្ធិមនុស្សក្នុងកម្រិតគ្រោះថ្នាក់" ដែលទាក់ទងនឹងការប្រកួតបាល់ទាត់ពិភពលោក។ ការប្រកួតបាល់ទាត់ពិភពលោក (FIFA World Cup 2022) នៅប្រទេសកាតា នឹងចាប់ផ្តើមនៅថ្ងៃទី២០ ខែវិច្ឆិកា បន្ទាប់ពីការផ្លាស់ប្តូរកាលបរិច្ឆេទចុងក្រោយមកប្រកួតមុន១ថ្ងៃ ពី FIFA ហើយគ្រោងនឹងបញ្ចប់នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២២៕ អត្ថបទ៖ មន្នីរ័ត្ន

## សហរដ្ឋអាមេរិក៖ ប៉ូលិស FBI ជួយសង្គ្រោះអនីតិជន ១២១នាក់ ពីការជួញដូរផ្លូវភេទ និង មនុស្ស នៅទូទាំងប្រទេស

http://freshnewsasia.com/ 2022-08-16 09:04am

**(វ៉ាស៊ីនតោន)៖** ប៉ូលិសអាមេរិក FBI នៅថ្ងៃចន្ទសប្តាហ៍នេះបានប្រកាសពីលទ្ធផល នៃប្រតិបត្តិការប្រយុទ្ធប្រឆាំងការជួញដូរផ្លូវភេទនៅទូទាំង ប្រទេស ដោយបង្ហាញថាអនីតិជន ៨៤នាក់ជាជនរងគ្រោះនៃការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទត្រូវបានកំណត់អត្តសញ្ញាណ និងរកឃើញ។ នេះបើតាមការដកស្រង់ចេញផ្សាយពីសារព័ត៌មាន Fox News នៅថ្ងៃអង្គារ ទី១៦ ខែសីហា ឆ្នាំ២០២២។ បើតាមសេចក្តីថ្លែងការណ៍មួយចេញផ្សាយដោយក្រសួងយុត្តិធម៌អាមេរិក កុមារបាត់ខ្លួនចំនួន ៣៧នាក់ផ្សេងទៀត ត្រូវបានកំណត់ទីតាំង និងរកឃើញ កំឡុងប្រតិបត្តិការមានឈ្មោះថា «ប្រតិបត្តិការទូទាំងប្រទេស ឬ Operation Cross Country» របស់ប៉ូលិស FBI។ លើសពីនេះទៅទៀត បន្ថែមពីលើការកំណត់អត្តសញ្ញាណ និងទីតាំងជនរងគ្រោះទាំង១២១នាក់ខាងលើ FBI និងអាជ្ញាធរជាដៃគូក៏បានរកឃើញ មនុស្សពេញវ័យ ១៤១នាក់ ដែលជាជនរងគ្រោះនៃការជួញដូរមនុស្សផងដែរ ខណៈ FBI បានកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនសង្ស័យ ៨៥នាក់ ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងជួញដូរមនុស្ស៕

## ក្រុងតៃប៉ិប៉ាន់ស្មានថាមានជនរងគ្រោះពីការជួញដូរមនុស្សចន្លោះពី២,០០០ទៅ៥,០០០នាក់នៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 16, 2022

នគរបាលតៃប៉ិបាននិយាយថា ចំនួនជនរងគ្រោះដែលបានបាត់ខ្លួន និងត្រូវបានជួញដូរច្រើននាក់ សង្ស័យថានៅកម្ពុជា បន្ទាប់ពីការស៊ើបអង្កេតផ្អែកលើកំណត់ត្រាជើងហោះហើររបស់ទីភ្នាក់ងារនគរបាលជាតិ (NPA) ដែលបានរកឃើញជនជាតិតៃវ៉ាន់ប្រហែល ១,០០០នាក់ ដែលបានធ្វើដំណើរមកកម្ពុជារៀងរាល់ខែ ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ប៉ុន្តែជាមធ្យមមានប្រហែលជា១០០នាក់ប៉ុណ្ណោះដែលត្រឡប់ទៅផ្ទះវិញ។ ទីក្រុងតៃប៉ិបានប៉ាន់ប្រមាណថា ជនរងគ្រោះពីការជួញដូរមានចន្លោះពី ២,០០០ ទៅ ៥,០០០នាក់ស្ថិតនៅកប្រទេសកម្ពុជា ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ប៉ុន្តែបានបន្ថែមថាចំនួនអាចខ្ពស់ជាង ឬទាបជាងនេះ ដោយសារតែមានចំណុចមិនច្បាស់លាស់នៅក្នុងទិន្នន័យ។

អ្នកនាំពាក្យខុទ្ទកាល័យលោក Lo Ping-cheng បានប្រាប់អ្នកសារព័ត៌មានថា ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើងដោយនាយកប្រតិបត្តិ Yuan ដើម្បីដោះស្រាយបញ្ហានេះ ខណៈដែលលោក Wallace Chow ប្រធាននាយកដ្ឋានកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិករបស់ក្រសួងការបរទេសបាននិយាយថា ក្រសួងរបស់លោកបានទទួល របាយការណ៍នៃករណីស្រដៀងគ្នានេះចាប់តាំងពីខែមិថុនាឆ្នាំមុន។ លោក Chow បាននិយាយថា ចំនួនអ្នកធ្វើដំណើរជនជាតិតៃវ៉ាន់មកកម្ពុជាចាប់ពីខែមករាឆ្នាំនេះ មានចំនួនលើសពី ៦,៤០០នាក់ ដោយចំនួននេះខ្ពស់ខុសប្រក្រតី។

ក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃទី១២ ខែសីហា ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សបាននិយាយថា រដ្ឋាភិបាលកំពុងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ហើយឧក្រិដ្ឋជនកំពុងទាញយកផលប្រយោជន៍ពីការខ្វះចន្លោះប្រហោងដើម្បីរត់ពន្ធមនុស្សសម្រាប់បំរើប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។ "មនុស្សរាប់រយនាក់ត្រូវបានជួយសង្គ្រោះក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ បន្ទាប់ពីពួកគេត្រូវបានបង្ខំឱ្យធ្វើការរយៈពេល១២ម៉ោងក្នុងមួយថ្ងៃ" លោកស្រីបានបន្តថា៖ "អ្វីដែល

យើងបានឃើញគឺថា ទោះបីជាយើងបានធ្វើអ្វីៗជាច្រើនក៏ដោយ ក៏នៅមានចន្លោះប្រហោងដែលធ្វើអោយបញ្ហានេះបន្តកើតឡើង»។ "ជនល្មើសមិននៅមួយកន្លែងទេ ហើយពួកគេតែងតែរង់ចាំមើលឱកាសណាមួយដែលពួកគេអាចធ្វើសកម្មភាព ដូច្នេះយើងត្រូវតែតាមប្រម៉ាញ់ពួកវា"។ លោកស្រីបានបន្តថា រដ្ឋាភិបាលមានការភ្ញាក់ផ្អើល ហើយបានបញ្ជាក់ម្តងទៀតនូវការអះអាងថា ការទម្លាក់ចំណាត់ថ្នាក់របស់ខ្លួនទៅ Tier-3 ដែលជាចំណាត់ថ្នាក់ទាបបំផុតដោយក្រសួងការបរទេសសហរដ្ឋអាមេរិក "... គឺជាភាពអយុត្តិធម៌" ហើយ "នេះធ្វើឱ្យយើងខកចិត្តព្រោះ វាមិនស័ក្តិសមនឹងការព្យាយាមរបស់យើងទេ»។ លោកស្រី ប៊ុនអេង បានបន្ថែមថា "ខ្ញុំសូមជម្រាបជូនថា មិនមែនគ្រប់ករណីទាំងអស់សុទ្ធតែជាការជួញដូរមនុស្សនោះទេ ហើយយើងបានធ្វើការបង្ក្រាបលើករណីជាច្រើនដោយមានកិច្ចសហការពីប្រទេសពាក់ព័ន្ធ។ លោកស្រីក៏បានស្នើឲ្យអ្នកសារព័ត៌មាន ធ្វើការសហការបន្ថែមទៀត ក្នុងការជួយអាជ្ញាធរក្នុងការដោះស្រាយបញ្ហានេះ។

តាមរយៈការស៊ើបអង្កេតរបស់ខ្មែរថាមស៍លើប្រតិបត្តិការនៃក្រុមបោកប្រាស់នេះ បានរកឃើញថា ជនឆបោកបានល្បួងជនរងគ្រោះ ដោយផ្តល់ការងារដែលមានប្រាក់ខែល្អ ដោយជនរងគ្រោះទាំងនោះមិនបានសិក្សា ឬដឹងពីហានិភ័យនោះទេ។ ប្រទេសថៃ និងឥណ្ឌូណេស៊ី ហើយឥឡូវនេះតែប៉ុន្មានក៏បានចាប់ផ្តើមដោះស្រាយបញ្ហាឆបោកនេះ និងបន្តកិច្ចខិតខំប្រឹងប្រែងប្រកបដោយចីរភាព និងរួមគ្នាក្នុងការកំណត់អត្តសញ្ញាណ និងបង្ក្រាបអ្នកឆបោក នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយ ប៉ុន្តែមិនអាចការពារក្មេងជំទង់ និងយុវជនពីការធ្លាក់ចូលអន្ទាក់ក្រុមទាំងនេះ ដោយត្រូវបានលក់ជាទាសករការងារពីមួយកន្លែងទៅមួយកន្លែង។ ប្រទេសម៉ាឡេស៊ី ក៏បានបញ្ជាក់ផងដែរថា ខ្លួនបានប្តេជ្ញាចិត្តតាមចាប់ក្រុមឆបោក ដែលក្រុមនេះត្រូវចំណាយប្រាក់ចន្លោះពី ២,០០០ ទៅ ៤,០០០ ដុល្លារសម្រាប់ការទទួលបានជនរងគ្រោះម្នាក់។ "ជាធម្មតាជនរងគ្រោះត្រូវបានផ្តល់សេវាលំដាប់ផ្កាយប្រាំសម្រាប់រយៈពេលពីរបីថ្ងៃនៅពេលដែលពួកគេមកដល់ប្រទេសកម្ពុជាមុនពេលជីវិតរបស់ពួកគេធ្លាក់ចូលឋាននរក។ ប្រភពនគរបាលដែលជិតស្និទ្ធនឹងកិច្ចការងារនេះ បានប្រាប់កាសែតថា នេះគឺជាការឆបោករបស់ក្រុមបោកប្រាស់ដើម្បីបញ្ចុះបញ្ចូលជនរងគ្រោះអោយធ្លាក់ទៅក្នុងអន្ទាក់របស់ពួកគេ៕ *UCA, Taipei Times/Khmer Times*

## ទីភ្នាក់ងារជំនួយអាមេរិក USAID ប្រកាសការគាំទ្រថ្មីមួយ ដើម្បីប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

https://cen.com.kh/ Posted ByPen Srey NeatAugust 16, 2022

ភ្នំពេញៈ ទីភ្នាក់ងារជំនួយអាមេរិក USAID នៅថ្ងៃទី១៦ ខែសីហា នេះ បានប្រកាសគំនិតផ្តួចផ្តើមថ្មីមួយដើម្បីគាំទ្រដល់វិស័យយុត្តិធម៌នៅកម្ពុជាក្នុងការស៊ើបអង្កេត និងកាត់ទោសឧក្រិដ្ឋកម្មជួញដូរមនុស្ស។ គំនិតផ្តួចផ្តើមថ្មីនេះ ដែលនឹងគ្រប់គ្រងដោយអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ ( International Justice Mission – IJM ) គឺជាផ្នែកមួយនៃគម្រោង ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (Cambodia Counter Trafficking in Persons – CTIP ) របស់ទីភ្នាក់ងារជំនួយអាមេរិក USAID ដែលអនុវត្តដោយអង្គការ វីនរ៉ក់ អន្តរជាតិ ( Winrock International ) ។ គម្រោង CTIP សហការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន និងអង្គការសង្គមស៊ីវិលដើម្បីការពារប្រជាជនកម្ពុជាពីអំពើជួញដូរមនុស្ស។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ទីភ្នាក់ងារជំនួយអាមេរិក USAID នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២។ភារធារីស្ថានទូតអាមេរិកប្រចាំនៅកម្ពុជាលោក Benjamin Wohlauer បានមានប្រសាសន៍បញ្ជាក់ថា "ការងាររបស់យើងលើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងភាពជាដៃគូជាមួយនឹងអង្គការ IJM នឹងជួយសម្រាលការឈឺចាប់របស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងយកជនល្មើសមកកាត់ទោសតាមច្បាប់។ យើងមានមោទកភាពក្នុងការជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុ

ជា ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។ អង្គការ IJM នឹងបំពេញបន្ថែមលើគម្រោង CTIP ដោយសហការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យសេវានិងការការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស មានភាពប្រសើរឡើង។”នៅក្នុងសេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ថា សហរដ្ឋអាមេរិក បន្តសហការជាមួយនឹងភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងឃ្លាំមើលសូចនាករនៃអំពើជួញដូរមនុស្សដែលពាក់ព័ន្ធនឹងការជ្រើសរើសពលករឯកជន ក៏ដូចជាកាត់ទោសឧក្រិដ្ឋជន ការពារជនរងគ្រោះ និងទប់ស្កាត់អំពើជួញដូរមនុស្ស៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

## អន្តរាគមន៍នគរបាលបង្ក្រាបឥណ្ឌូនេស៊ី ទប់ស្កាត់ការជួញដូរមនុស្ស២១២នាក់មកកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 17, 2022

ក្រុមស៊ើបអង្កេតនគរបាលបង្ក្រាបមកពីនគរបាលស៊ូម៉ាត្រាខាងជើង ត្រូវបានបញ្ជូនទៅកាន់ទីក្រុងហ្សាកាតា ដើម្បីតាមដាន និងបង្ក្រាបក្រុមហ៊ុនជ្រើសរើសបុគ្គលិកពាក់ព័ន្ធនឹងការជួញដូរពលករឥណ្ឌូនេស៊ីចំនួន២១២ នាក់មកកម្ពុជា។ ការប៉ុនប៉ងរបស់ក្រុមហ៊ុនជ្រើសរើសបុគ្គលិក ត្រូវបានគេរាយការណ៍ថាបានត្រូវបានទប់ស្កាត់កាលពីថ្ងៃសុក្រសប្តាហ៍មុននៅក្នុងប្រតិបត្តិការរួមគ្នាមួយដែលបានធ្វើឡើងដោយមន្ត្រីអន្តោប្រវេសន៍ នគរបាល និងទីភ្នាក់ងារការពារពលករចំណាកស្រុកក្នុងស្រុក (BP2MI)។

ការស៊ើបអង្កេតបឋមបានរកឃើញថាក្រុមហ៊ុនជ្រើសរើសបុគ្គលិកបានប្រើប្រាស់គេហទំព័ររបស់ខ្លួនដើម្បីជ្រើសរើសពលករចំណាកស្រុកដែលមានសក្តានុពលមកពី Aceh, East Java, Jambi, Jakarta, North Sumatra និង West Kalimantan ហើយបន្ទាប់មកបានដឹកជញ្ជូនពួកគេទៅកាន់ Medan ពីកន្លែងដែលជើងហោះហើរត្រូវបានរៀបចំទៅកាន់ខេត្តព្រះសីហនុ ប្រទេសកម្ពុជា។ នគរបាលនៅតែកំពុងស៊ើបអង្កេតថា ហេតុអ្វីបានជា Medan ត្រូវបានជ្រើសរើសជាមជ្ឈមណ្ឌលឆ្លងកាត់សម្រាប់ជើងហោះហើរមកកម្ពុជា ហើយសំណួរអំពីរបៀបដែលជើងហោះហើរពិសេស (chartered flights) ត្រូវបានរៀបចំ ដឹកជនរងគ្រោះមកកម្ពុជា ក៏នៅមិនទាន់ច្បាស់នៅឡើយ។

អ្នកនាំពាក្យនគរបាលកោះស៊ូម៉ាត្រាខាងជើង លោក Sr Comr Hadi Wahyudi បានប្រាប់កាសែត Jakarta Post កាលពីថ្ងៃចន្ទថា “យើងបានដឹងពីអត្តសញ្ញាណរបស់ក្រុមហ៊ុនរួចហើយ ហើយក្រុមរបស់យើងគឺនៅក្នុងទីក្រុងហ្សាការតាដើម្បីធ្វើការស៊ើបអង្កេត ដោយមានជំនួយពីនគរបាលហ្សាកាតា” ។ យើងក៏កំពុងស៊ើបអង្កេតលើទំនាក់ទំនងរវាងក្រុមហ៊ុននិងមេក្លោងល្បែងស៊ីសងអនឡាញក្នុងប្រទេសកម្ពុជាផងដែរ»។

លោក Siti Rolijah ប្រធាន BP2MI North Sumatra បាននិយាយនៅពេលនោះថា ប្រតិបត្តិការរួមគ្នាដើម្បីទប់ស្កាត់ការចេញដំណើរនៃយន្តហោះពិសេសនេះ ត្រូវបានជំរុញដោយព័ត៌មានមួយពីក្រសួងការបរទេស។ កាសែត Jakarta Post បានរាយការណ៍ថា កម្មករចំនួន២១២នាក់ ដែលក្នុងនោះមានស្ត្រី ២០ នាក់ ត្រូវបាននាំទៅកាន់ទីស្នាក់ការនគរបាលស៊ូម៉ាត្រាខាងជើង ដើម្បីសាកសួរ ហើយបន្ទាប់មកបានបញ្ជូនទៅអន្តេវាសិកដ្ឋាន haj ក្នុងទីក្រុង Medan នៅថ្ងៃសៅរ៍ក្រោយមក។

យោងតាមទិន្នន័យពីស្ថានទូតឥណ្ឌូនេស៊ីនៅភ្នំពេញ យ៉ាងហោចណាស់មានពលករចំណាកស្រុកចំនួន ៤១៧នាក់ ត្រូវបានគេបោកបញ្ឆោតចូលទៅក្នុងគម្រោងជួញដូរមនុស្សចាប់តាំងពីនិន្នាការនេះបានចាប់ផ្តើមនៅឆ្នាំ ២០២១។ ទោះជាយ៉ាងណាក៏ដោយ គណនីពីជនរងគ្រោះជាច្រើនបានបង្ហាញថាចំនួននេះអាចមានចំនួនរាប់ពាន់

នាក់ ដោយសក្ដីកម្មមួយចំនួនបង្ហាញថា ជនរងគ្រោះជាស្ត្រីងាយរងគ្រោះដោយសារការរំលោភបំពានទម្រង់ផ្សេងទៀត។

រដ្ឋមន្ត្រីការបរទេស Retno L.P. Marsudi ថ្មីៗនេះបានពិភាក្សាជាមួយក្រសួងមហាផ្ទៃ និងអគ្គស្នងការនគរបាលកម្ពុជា ដើម្បីពិភាក្សាលម្អិតនៃអនុស្សរណៈនៃការយោគយល់គ្នា (MoU) នាពេលខាងមុខ ដែលនឹងបម្រើជាគោលការណ៍ណែនាំក្នុងការទប់ស្កាត់ និងដោះស្រាយករណីជួញដូរនាពេលអនាគតរវាងប្រទេសទាំងពីរ។ លោកស្រីរំពឹងថា MoU នឹងត្រូវបានបញ្ចប់ "ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន" ហើយអាចជួយសង្គ្រោះ និងស្តារនីតិសម្បទាជនរងគ្រោះ ក៏ដូចជាទប់ស្កាត់ករណីនាពេលអនាគត ខណៈពេលដែលការពង្រឹងការដាក់ទណ្ឌកម្មប្រឆាំងនឹងអ្នកជួញដូរមនុស្ស។ *Jakarta Post/Indonesian Police*

## ការស្រាវជ្រាវ: ការរំលោភបំពានផ្លូវភេទលើកុមារា កើតមានមិនចាញ់ករណីរំលោភបំពានលើកុមារី

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 16 August 2022 | 18:40 ICT

**ភ្នំពេញ:** ការរំលោភបំពានផ្លូវភេទលើកុមារា ត្រូវបានរកឃើញកើតឡើងច្រើនមិនចាញ់ករណីអំពើរំលោភបំពានផ្លូវភេទលើកុមារីនោះទេ ប៉ុន្តែករណីកើតឡើងចំពោះកុមារាមិនសូវមានទិន្នន័យ ដោយសារពិបាកកំណត់អត្តសញ្ញាណ ហើយការផ្ដល់សេវាគាំពារទៅដល់កុមារា គឺមានតិចតួចបំផុត ទោះបីជាបញ្ហានេះកើតឡើងជាយូរមកហើយក៏ដោយ។ នេះបើតាមលោក យ៉ុំ ចំរើន ប្រធានអង្គការជំហានដំបូងកម្ពុជា។

លោក យ៉ុំ ចំរើន បានលើកឡើងក្នុងសិក្ខាសាលាស្ដីពីកិច្ចគាំពារកុមារប្រកបដោយបរិយាបន្ននៅសណ្ឋាគារហ៊ីម៉ាវ៉ារី នៅព្រឹកថ្ងៃទី ១៦ ខែសីហាថា តាមការស្រាវជ្រាវតាមខ្នងផ្ទះដោយអង្គការយូនីសេហ្វ ក្រោមកិច្ចសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៅឆ្នាំ ២០១៥ បានរកឃើញថា កុមារា ៥,៦ ភាគរយ ធៀបទៅនឹងកុមារី ៥,៤ ភាគរយធ្លាប់រងបទពិសោធរំលោភបំពានផ្លូវភេទនៅក្នុងពេលណាមួយនៃជីវិតរបស់ពួកគេ។ លោកបានថា ការរំលោភបំពានផ្លូវភេទលើកុមារាជាបញ្ហាសំខាន់មួយ ដែលកើតឡើង មិនមែនតែនៅប្រទេសកម្ពុជានោះទេ នៅប្រទេសផ្សេងៗក៏មានផងដែរ។ តួយ៉ាងដូចជា នៅប្រទេសឥណ្ឌា មានកុមារា ៦០ ភាគរយ នៅញូដែលីធ្លាប់រងអំពើរំលោភបំពានផ្លូវភេទ ខណៈគ្មានសេវាគាំពារដល់កុមារាទាំងនោះឡើយ។ ចំណែកនៅប្រទេសចិន មានកុមារា ២០ ទៅ ៤០ ភាគរយបានរងការរំលោភបំពានផ្លូវភេទផងដែរ។ លោកថ្លែងថា៖ «បញ្ហានេះកើតឡើងយូរមកហើយ គ្រាន់តែអត់មានសេវា ដូច្នេះហើយ First Step នៅឆ្នាំ ២០១០ យើងចាប់ផ្ដើមផ្ដល់សេវានេះ។ រហូតមកដល់បច្ចុប្បន្ននេះយើងបានផ្ដល់សេវាសរុបទៅដល់កុមារ និងមនុស្សធំបានចំនួន ៤៣២ ករណី ក្នុងចំណោមនោះមាន ៣៧៥ ករណីជាកុមារ [កុមារា-កុមារី] ហើយក្នុងនោះមាន ២៩២ ករណី ជាជនរងគ្រោះ ដែលក្នុងចំនួននេះមាន ៧០ ភាគរយជាកុមារា»។ លោក ផង់ ចិន្តា ប្រធានគ្រប់គ្រងកម្មវិធីនៃអង្គការជំហានដំបូងកម្ពុជាថ្លែងថា កុមារាដែលរងការរំលោភបំពានផ្លូវភេទមិនងាយនិយាយចេញពីទុក្ខលំបាកដែលរូបគេបានជួបនោះទេ ដោយសារតែជំនឿ និងទម្លាប់ក្នុងសង្គមដែលកត់សម្គាល់ថា កុមារាជាភេទមួយខ្លាំង រឹងមាំ ដូចពាក្យមួយលើកឡើងថា មនុស្សប្រុសដើមទ្រូង ៥ ហត្ថ។

លោកថ្លែងថា៖ «ខ្ញុំគិតថា មនុស្សប្រុសដូចមាសទឹក ១០ អ៊ីចឹង ជ្រុះប្រឡាក់ភក់លើកមកលាងទឹកលាងសាប៊ូនៅតែមាសដដែល ទឹក ១០ នៅតែ ១០ ទឹក ៧ នៅតែ ៧ អត់បញ្ហាអ៊ីចឹង បណ្ដោយវាទៅមិនបាច់ Take Care វាពេកទេ អ៊ីចឹងធ្វើឱ្យកុមារាគាត់ងាយរងគ្រោះច្រើន»។ លោកបន្តទៀតថា អ្នកដែលអនុវត្តកម្មវិធីកិច្ចការពារកុមារមានច្រើន ប៉ុន្តែនៅតែចន្លោះ ចំពោះកិច្ចការពារទៅលើកុមារា ហើយអ្នកដែលមានតួនាទីជាអ្នកបំពេញសិទ្ធិដល់កុមារក៏មិនមានចំណេះដឹងទាក់ទងទៅនឹងការរំលោភបំពានផ្លូវភេទទៅលើកុមារាផងដែរ។ ប្រធានគ្រប់គ្រងកម្មវិធីនៃអង្គការជំហានដំបូងកម្ពុជាបានឱ្យដឹងទៀតថា តាមការស្រាវជ្រាវនៅលើពិភពលោកមានកុមារ ១២០ លាន

នាក់ ដែលមានអាយុក្រោម ១៨ ឆ្នាំ បានទទួលរងនូវការរំលោភបំពានផ្លូវភេទ ដែលរាប់តាំងពីការប៉ះពាល់ស្ទាប់អង្អែល រហូតទៅដល់ការស៊កបញ្ចូលនូវអង្គជាតិ ឬវត្ថុផ្សេងៗទៀត។ចំណែកកម្ពុជាវិញ ក្នុងចំណោមកុមារ ១០ នាក់ មាន ៦ នាក់ ឆ្លងកាត់ការរំលោភបំពានផ្នែករាងកាយ ស្មារតី និងផ្លូវភេទ និងកុមារ ៥ ទៅ៦ភាគរយ អាយុក្រោម ១៨ ឆ្នាំ ធ្លាប់រងនូវការរំលោភបំពានផ្លូវភេទ ដែលទិន្នន័យទាំងនេះពិបាកក្នុងការស្វែងរក ជាពិសេសសម្រាប់កុមារា។ លោកថ្លែងថា៖ «យើងមិនអាចរកទិន្នន័យបានជារួមនោះទេ ចាប់ពីឆ្នាំ ២០០៨ មកម្ល៉េះ។ យើងធ្លាប់ធ្វើការសិក្សាស្រាវជ្រាវមួយចំនួនធ្វើដោយខ្លួនឯង ប៉ុន្តែមិនមានទំហំធំតំណាងឱ្យជាតិនោះទេ»។

លោក សុខ សំបូរ មន្ត្រីសម្របសម្រួលនៃអង្គការជំហានដំបូងកម្ពុជា បានឱ្យដឹងថា ក្រៅពីកុមារា នៅមានកុមារផ្សេងទៀតក៏មានការទទួលរងនូវការរំលោភបំពានផ្លូវភេទផងដែរ នោះគឺកុមារដែលស្រឡាញ់ភេទដូចជាជាដើម។ ការរងគ្រោះនោះអាចកើតឡើងនៅពេលដែលគ្រួសារបដិសេធ រើសអើង បែងចែក ឬស្តីបន្ទោស ដែលជាហេតុមួយនាំឱ្យកុមារ ឬយុវជនដែលមានធម្មជាតិស្រឡាញ់ភេទដូចគ្នា ទៅស្វែងរកក្រុម ឬអ្នកណាមួយ ដែលអាចផ្តល់ភាពកក់ក្តៅនិងលើកទឹកចិត្តដល់រូបគេ។ ការសម្លឹងមើលអ្នកផ្សេងក្រៅក្រុមគ្រួសារដើម្បីភាពកក់ក្តៅនេះហើយ ដែលនាំឱ្យក្រុមជនខិលខូច ជនឆ្លៀតឱកាសក្នុងការរំលោភបំពានផ្លូវភេទធ្វើការអូសទាញបានជោគជ័យ ដោយពួកគេចាំទទួលផ្តល់ភាពកក់ក្តៅ និងគាំទ្រដល់កុមារដែលស្វែងរកភាពកក់ក្តៅទាំងនោះ។

លោក លី ហួ មន្ត្រីអង្គការជីវិតស្រស់បំព្រង បានលើកឡើងថា ដើម្បីកុំឱ្យអ្នកស្រឡាញ់ភេទដូចគ្នា មានការបាក់ទឹកចិត្ត និងខ្វះភាពកក់ក្តៅ សូមកុំប្រើប្រាស់ពាក្យមួយចំនួន ដែលប៉ះពាល់ដល់សតិអារម្មណ៍អ្នកស្រឡាញ់ភេទដូចគ្នា ដែលពាក្យទាំងនោះរួមមាន ខ្ទើយ ស៊ីម ២ ឡេឌីប៊យ មនុស្សប្តូរភេទ ភេទទីបី ៦៩ សក់វែង ជាដើម។ លោកថា ពាក្យដែលគួរប្រើរួមមាន ក្រុមនុស្សស្រឡាញ់ភេទដូចគ្នា ក្រុមមនុស្ស LBTGIQ+ ឬសហគមន៍ IBTGIQ+៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 17/08/2022 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៤ និង២០នាទី ថ្ងៃពុធ ៥រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន២៦នាក់ ស្រី១១នាក់ ក្មេង៤នាក់ ស្រី២នាក់ ។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្តែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

## សម្តេច ស ខេង អញ្ជើញដឹកនាំកិច្ចប្រជុំ ថ្នាក់ដឹកនាំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័ន ទាំង៦ និងក្រសួង-ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ

https://dap-news.com/ ByKD102Posted on August 19, 2022

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅព្រឹកថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ បានអញ្ជើញដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័ន ទាំង៦ និងក្រសួង-ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ ប្រចាំឆមាសទី១ ឆ្នាំ២០២២៕

## រាជរដ្ឋាភិបាលកម្ពុជាបន្តបង្កើនការលុបបំបាត់អំពើហិង្សាលើកុមារ

https://www.information.gov.kh/ ផ្សាយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២ វិទ្យុជាតិកម្ពុជា៖ សុភា វិសិទ្ធិពង្ស

MC : រាជរដ្ឋាភិបាលកម្ពុជា បានបន្តបង្កើនការលុបបំបាត់អំពើហិង្សាលើកុមារ គ្រប់ទម្រង់នានា ដើម្បីធានាឧត្តមប្រយោជន៍ និងសិទ្ធិរបស់កុមារ។ ឯកឧត្តម តូច ចាន់នី អគ្គនាយកសេវាសង្គមកិច្ច និងជាអ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ នូវវិធានការជាច្រើន ក្នុងការការពារអន្តរាគមន៍ និងផ្តល់សេវាចំពោះកុមារដែលមិនទាន់រងគ្រោះ និងកុមាររងគ្រោះ ដើម្បីធានា ដល់សិទ្ធិរបស់កុមាឱ្យរួចផុតពីការរំលោភបំពានផ្សេងៗព្រមទាំងឱ្យមានកិច្ចគាំពារចំពោះកុមារ ខណៈ កុមារគឺជាធនធានមួយដ៏ចាំបាច់នាពេលអនាគតរបស់ប្រទេសជាតិ ដូច្នេះការយកចិត្តទុកចំពោះកុមារ គឺជាការ សម្លឹងមើល ការគិតគូរ និងការរៀបចំអនាគតរបស់ប្រទេស។ ថ្លែងក្នុងសន្និសីទសារព័ត៌មានស្តីពី « សមិទ្ធផលសម្រេចបានរយៈពេល៥ឆ្នាំកន្លងមក របស់ក្រសួង សង្គមកិច្ច » នៅព្រឹកថ្ងៃទី១៨ ខែសីហា នាទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម បានបន្តថា បច្ចុប្បន្ននៅកម្ពុជា នៅមានកុមារមួយចំនួនជាជនរងគ្រោះដោយការបង្ខំឱ្យធ្វើការ និងជួញដូរ ហើយមួយចំនួនទៀតទទួល រងគ្រោះដោយអំពើហិង្សាការរំលោភបំពាន ឬពិការភាព ទៅលើកុមារទាំងផ្នែករាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលរាជរដ្ឋាភិបាលនឹងប្តេជ្ញាលុបបំបាត់ឱ្យអស់ ។

១.លើកកម្ពស់ស្មារតីចូលរួមនិងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការដែលមានស្រាប់ទាំងទ្វេភាគី និងពហុភាគី ដើម្បីលើកស្ទួយសុខុមាលភាពកុមារនិងកិច្ចការពារកុមារ ជាពិសេសពង្រឹងយន្តការសម្រប សម្រួលក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងអស់ សំដៅចែករំលែកទិន្នន័យនិងព័ត៌មានសំខាន់ៗ ដើម្បីចាត់ វិធានការទាន់ពេលនិងរឹតបន្តឹងជាច់ខាតចំពោះសកម្មភាពហិង្សាគ្រប់ទម្រង់លើកុមារ ។

ទី២.ជំរុញការប្រាជ្ញាចិត្តជាសកលតាមរយៈការកៀរគរធនធានទាំងហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ដើម្បីគាំទ្រ និងធានាចីរភាពនៃចលនានៃការបញ្ចប់អំពើហិង្សាលើកុមារទាំងក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ និង អង្គការអន្តរជាតិក៏ដូចជាតំបន់ដទៃទៀត ។

ទី៣. ពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចគោលដៅនានា របស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ពិសេសចំណុចដៅ១៦.២ បញ្ចប់រាល់ទម្រង់ទាំងអស់នៃអំពើ ហិង្សាលើកុមារត្រឹមឆ្នាំ២០៣០ » ។

ឯកឧត្តមបន្ថែមថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានសហការជាមួយអង្គការដៃគូ ជាច្រើន ដើម្បីពង្រឹងប្រសិទ្ធភាពនៃកិច្ចការពារឧត្តមប្រយោជន៍របស់កុមារឱ្យរួចផុតពីការរំលោភបំពាន អំពើហិង្សា ការជួញដូរ និងការកេងប្រវ័ញ្ច គ្រប់រូបភាព ៕

## តុលាការឧទ្ធរណ៍ ជម្រះបណ្ដឹងឧទ្ធរណ៍ ប្ដីប្រពន្ធបង់ក្លាដេស-ខ្មែរ មួយគូ ជាប់ពាក់ព័ន្ធការរត់ពន្ធ ជនជាតិបង់ក្លាដេស ១៦នាក់ ឆ្លងដែនខុសច្បាប់ មកធ្វើនៅកម្ពុជា

https://cen.com.kh/ Posted ByPen Srey NeatAugust 18, 2022

ភ្នំពេញ: សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០២២ នេះ បានធ្វើការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់បុរស ជនជាតិបង់ក្លាដេសម្នាក់ និង ស្ត្រីខ្មែរម្នាក់ ដែលជាប្ដីប្រពន្ធ នឹងគ្នា ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធ ពលករជនជាតិ បង់ក្លាដេស ចំនួន១៦ នាក់ ឆ្លងដែនខុសច្បាប់ មកធ្វើការក្នុងប្រទេសកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុង ឆ្នាំ២០២០។

លោកស្រី ខៀវ សុខា ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានថ្លែងឲ្យដឹង នៅក្នុងអង្គសវនាការថា ជនជាប់ចោទ២នាក់ មាន ឈ្មោះ ៖១- ឈ្មោះ MOHAMMAD JAHNGIR ភេទប្រុស ភេទប្រុស អាយុ ៣៧ ឆ្នាំ ជនជាតិបង់ក្លាដេស មានមុខរបរមុនចាប់ខ្លួន ជានាយកក្រុមហ៊ុន CEB BIC CIES CO,Lld ។ និង ២- ឈ្មោះ ឈ្មោះ ម៉ម សុខុម អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ។ ពួកគេទាំង២ នាក់ គឺ ត្រូវជាប្ដីប្រពន្ធនឹងគ្នា និង មានទីលំនៅ មុនចាប់ខ្លួន ផ្ទះគ្មានលេខ ផ្លូវលំ ភូមិថ្មគោល២ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

នៅក្នុងសំណុំរឿងក្ដីនេះ ជនជាប់ចោទ ទាំង២នាក់ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១ កាត់ទោស ដាក់គុក ក្នុងម្នាក់ៗ កំណត់ ម្នាក់ ៧ ឆ្នាំ ពីបទ: នាំចេញដោយមិនស្របច្បាប់ និង ជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ ។ តែពួកគេបានប្ដឹងឧទ្ធរណ៍។ ជនជាប់ចោទទាំង២នាក់ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៣០ខែ កក្កដា ឆ្នាំ ២០២១ នៅភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ សំណុំរឿងក្ដីនេះ, សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ បានលើកពេលប្រកាសសាលដីកា នៅព្រឹកថ្ងៃទ ១៦ខែ កញ្ញា ឆ្នាំ ២០២២ ខាងមុខនេះ៕រក្សាសិទ្ធិដោយ: ចន្ទា ភា

## សម្ដេច ស ខេង លើកទឹកចិត្តឱ្យមានការ គាំទ្របន្ថែមទៀតពីអង់គ្លេស លើការងារប្រយុទ្ធប្រឆាំង បទល្មើសបច្ចេកវិទ្យា

https://dap-news.com/ ByKD102Posted on August 19, 2022

**ភ្នំពេញ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានគាំទ្រ និងបន្តលើកទឹកចិត្តឲ្យមានការគាំទ្របន្ថែមទៀត ពីចក្រភពអង់គ្លេស ជាពិសេសលើការងារប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា។** នាឱកាសអនុញ្ញាតឱ្យលោកស្រី Tina Redshaw ឯកអគ្គរាជទូតចក្រភពអង់គ្លេស ចូលជួបជម្រាបលា នាថ្ងៃទី១៨ សីហា សម្ដេចក្រឡាហោម បានថ្លែងអំណរគុណ លោកស្រី ចំពោះការគាំទ្រ ក៏ដូចជាកិច្ចសហប្រតិបត្តិការនានាលើវិស័យពាក់ព័ន្ធជាមួយនឹងក្រសួងមហាផ្ទៃកម្ពុជា ជាពិសេសលើការងារ បណ្ដុះបណ្ដាលធនធានមនុស្ស ក្នុងកងកម្លាំងនគរបាលជាតិ។ សម្ដេច បានចាត់ទុកថា នេះជាកិច្ចការមួយដ៏មានសារៈសំខាន់ ខណៈក្រសួងមហាផ្ទៃកំពុងតែខិតខំ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនគរបាលជាតិ ជាមន្ត្រីបម្រើសេវាថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ សម្ដេច បានបញ្ជាក់ថា "ពិតជាគាំទ្រ និងបន្តលើកទឹកចិត្តឲ្យមានការគាំទ្របន្ថែមទៀត ពីចក្រភពអង់គ្លេស ជាពិសេសលើការងារប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា ដែលក៏ជាកិច្ចការមានសារៈសំខាន់ ខណៈធនធានមនុស្សលើវិស័យនេះរបស់កងកម្លាំងនគរបាលកម្ពុជា នៅមានកម្រិតនៅឡើយ"។ សម្ដេចបន្ថែមថា ការលើកកម្ពស់គុណភាពធនធានមនុស្សក្នុងវិស័យនគរបាលជាតិ ក៏ជាការរួមចំណែកដ៏សំខាន់មួយ ក្នុងការចូលរួមទប់ស្កាត់បទល្មើស ឆ្លងដែនគ្រប់ប្រភេទ ដែលកិច្ចការនេះក៏ជាកិច្ចការសំខាន់ និងមិនអាចប្រទេសណា

មួយធ្វើតែម្នាក់ឯងបាននោះទេ គឺពិតជាទាមទារឱ្យមាននូវកិច្ចសហប្រតិបត្តិការជាមួយ បណ្តាប្រទេសនានានៅក្នុងតំបន់ និងសកលលោក។

លោកស្រី Tina Redshaw បានថ្លែងអំណរដល់អង្គភាពពាក់ព័ន្ធចំណុះឱ្យក្រសួងមហាផ្ទៃ ដែលតែងផ្តល់នូវកិច្ចសហការគាំទ្រដល់ពលរដ្ឋអង់គ្លេស ដែលជួបប្រទះការលំបាកផ្សេងៗនៅកម្ពុជា ជាពិសេសពាក់ពាក់ព័ន្ធនឹងការងារអន្តោប្រវេសន៍ និងការជួយសម្រួលឱ្យផ្នែកកុងស៊ុលរបស់ស្ថានទូតអង់គ្លេសបានជួបប្រាស្រ័យ ជាមួយជនជាតិអង់គ្លេសដែលជាប់ឃុំនៅតាម បណ្តាពន្ធនាគាររបស់កម្ពុជា។ លោកស្រី ក៏យកឱកាសនេះជម្រាបជូន សម្តេចក្រឡាហោម ផងដែរអំពីវេទិកាអន្តរភាគីនានា ក៏ដូចជាកម្មវិធីមួយចំនួនទៀតដែលបានផ្តល់នូវការជួយគាំទ្រដល់ការអភិវឌ្ឍលើវិស័យធនធានមនុស្សរបស់កម្ពុជា ជាពិសេសពាក់ព័ន្ធទៅនឹងការលើកកម្ពស់ធនធានមនុស្សក្នុង វិស័យនគរបាលជាតិដែលកម្មវិធី ក៏ដូចជាវេទិកាទាំងនោះ មានការគាំទ្រពីចក្រភពអង់គ្លេស៕

## ហ្វីលីពីនស្នើឱ្យកម្ពុជាជួយសង្គ្រោះជនជាតិខ្លួនពីអំពើជួញដូរបោកបញ្ឆោត នៅខេត្តកោះកុង

https://khmer.voanews.com/ 18 សីហា 2022ហាន ណូយ

ភ្នំពេញ៖ ស្ថានទូតហ្វីលីពីនប្រចាំនៅកម្ពុជា បានស្នើឱ្យរដ្ឋាភិបាលកម្ពុជាជួយអន្តរាគមន៍សង្គ្រោះប្រជាពលរដ្ឋរបស់ខ្លួន ចំនួនបួននាក់ ដែលស្ថានទូតអះអាងថា ត្រូវបានបង្ខំឱ្យធ្វើការជាអ្នកបោកបញ្ឆោតតាមបច្ចេកវិទ្យា (Scammer) នៅក្នុងកាស៊ីណូឡុងបេ (Long Bay) ក្នុងតំបន់តារាសាគរ នៃស្រុកគិរីសាគរ ក្នុងខេត្តកោះកុង។ នេះបើយោងតាមលិខិតមួយច្បាប់របស់ស្ថានទូតហ្វីលីពីន ដែលបានចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០២២ ដែលវីអូអេទទួលបាន កាលពីថ្ងៃពុធ។

បើតាមលិខិតដដែលនោះ ប្រជាពលរដ្ឋហ្វីលីពីនចំនួនបួននាក់ ត្រូវបានឆបោក ហើយពួកគេមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីបរិវេណអគារ ដែលពួកគេធ្វើការឡើយ ប្រសិនបើពួកគេមិនមានលុយបង់។ លិខិតបន្តថា ទីតាំងរបស់ក្រុមហ៊ុន ស្ថិតនៅជាន់ទី ៤ បន្ទប់លេខ ៥០៨ នៅក្នុងអគារមួយ ដែលមិនស្គាល់ឈ្មោះ ក្នុងកាស៊ីណូឡុងបេ នៅតំបន់កម្សាន្តតារាសាគរ ក្នុងស្រុកគិរីសាគរ នៃខេត្តកោះកុង។ លិខិតបញ្ជាក់ក្នុងន័យដើមថា៖ «ស្ថានទូតស្នើឱ្យស្នងការនគរបាលជាតិ ជួយសម្របសម្រួលនៅក្នុងការសង្គ្រោះប្រជាពលរដ្ឋហ្វីលីពីនចំនួនបួននាក់ ពីកន្លែងការងារនៅក្នុងក្រុមហ៊ុនចិន ដោយឱ្យប្រគល់នូវលិខិតឆ្លងដែន ប្រាក់បៀវត្សរ៍ និងបញ្ជូនពួកគេទៅកាន់ទីកន្លែងដែលមានសុវត្ថិភាព»។ លិខិតសុំអន្តរាគមន៍របស់ស្ថានទូតហ្វីលីពីនប្រចាំនៅកម្ពុជា ត្រូវបានបញ្ជូនទៅសមត្ថកិច្ចខេត្តកោះកុង ហើយសមត្ថកិច្ចបញ្ជាក់ថា ខ្លួនទទួលបានលិខិតស្នើសុំអន្តរាគមន៍នេះ កាលពីថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២២។ នេះបើតាមលិខិតរបស់នគរបាលខេត្តកោះកុង ដែលវីអូអេទទួលបាន។

លោក ស សារ៉ាត អ្នកនាំពាក្យស្នងការនគរបាលខេត្តកោះកុង ប្រាប់វីអូអេនៅថ្ងៃព្រហស្បតិ៍ថា លោកទើបតែទទួលបានលិខិតសុំអន្តរាគមន៍ កាលពីថ្ងៃពុធ ហើយក្រុមជំនាញបានកំពុងស៊ើបអង្កេតទៅលើបញ្ហានេះ។ លោកថ្លែងថា៖ «យើងឲ្យចាត់ចែងទៅខាងជំនាញ ហើយជំនាញបានចាត់ចែងចុះស្រាវជ្រាវបន្ត ដើម្បីរកជនរងគ្រោះដែលបានរាយការណ៍មកហ្នឹង។ ហើយលទ្ធផលនៃការស្រាវជ្រាវបានយ៉ាងណា គឺយើងអត់ទាន់បានព័ត៌មានមកវិញទេ ព្រោះយើងទើបទទួលបានថ្ងៃទី ១៧ ម្សិលមិញ ហើយឥឡូវបាននិងកំពុងធ្វើការងារហ្នឹងហើយ»។

វីអូអេ មិនអាចសុំការអត្ថាធិប្បាយពីស្ថានទូតហ្វីលីពីនប្រចាំនៅកម្ពុជា តាមសារអ៊ីមែលបាននៅឡើយទេ នាថ្ងៃព្រហស្បតិ៍នេះ។ នៅពេលទាក់ទងតាមលេខទូរស័ព្ទរបស់ក្រុមហ៊ុនឡុងបេ ជនជាតិចិនម្នាក់បានលើកទូរសព្ទ ហើយឲ្យជួបជនជាតិខ្មែរ ដែលជាអ្នកបកប្រែ។ ជនជាតិខ្មែររូបនោះបានស្នើឲ្យវីអូអេផ្ញើសារតាមអ៊ីមែលវិញ តាមការ

បង្គាប់របស់ជនជាតិចិន។ កាលពីពេលកន្លងទៅ ក៏មានសេចក្តីរាយការណ៍ជាបន្តបន្ទាប់ ដែលបានបង្ហាញថា ជនបរទេស ដែលភាគច្រើនជាជនជាតិថៃ ត្រូវបានជួយសង្គ្រោះពីតំបន់ឡុងបេ នៅតារាសាគរផងដែរ។

លោក ថោង ច័ន្ទដារ៉ា អ្នកសម្របសម្រួលផ្នែកសិទ្ធិមនុស្ស នៃសមាគមសិទ្ធិមនុស្សអាដហុកប្រចាំខេត្តកោះកុង ប្រាប់វីអូអេថា អាជ្ញាធរហាក់មិនសូវមានសិទ្ធិចូលទៅពិនិត្យនៅក្នុងតំបន់តារាសាគរ និងតំបន់អភិវឌ្ឍន៍ផ្សេងៗទៀត ដែលមានអគារខ្ពស់ៗ និងកាស៊ីណូឡើយ ដោយសារពួកគេមានខ្សែអ្នកធំ។ ដូច្នេះហើយរឿងរ៉ាវដែលកើតឡើងនៅខាងក្នុងអគារ កម្រត្រូវបានសាធារណជនដឹងណាស់ លុះត្រាណាមានការបែកធ្លាយ តាមរយៈការសុំអន្តរាគន៍ពីសាមីខ្លួនផ្ទាល់ ឬក៏ក្រុមគ្រួសារ។ មន្ត្រីសិទ្ធិមនុស្សរូបនេះជំរុញឱ្យអាជ្ញាធរពង្រឹងការអនុវត្តច្បាប់ និងតួនាទីរបស់ខ្លួនឡើងវិញ ដើម្បីបញ្ចៀសនូវបញ្ហាកើតឡើង។ លោកថ្លែងថា៖ «កាស៊ីណូ តំបន់ក្លឹបកម្សាន្តអី អាជ្ញាធរគួរតែមានសិទ្ធិនៅក្នុងការត្រួតពិនិត្យ ឬមួយតាមដាននូវសកម្មភាពមិនប្រក្រតីទាំងឡាយ និងបទល្មើសដែលមិនស្របច្បាប់»។

កាលពីពេលកន្លងទៅ មានសេចក្តីរាយការណ៍ថា កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធើណិត ដោយប្រើប្រាស់កម្លាំងពលកម្មបរទេស ធ្វើការនៅតាមអគារខ្ពស់ៗនានានៅក្នុងប្រទេសកម្ពុជា រហូតមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឲ្យមានសេរីភាព ការធ្វើទារុណកម្ម និងការជំរិតទារប្រាក់ជាដើម។ កាលពីដើមខែសីហា ឆ្នាំ ២០២២ រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី ដែលមកចូលរួមកិច្ចប្រជុំអាស៊ានក្នុងប្រទេសកម្ពុជា បានជួបជាមួយអគ្គស្នងការនគរបាលជាតិកម្ពុជា ដោយពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើបញ្ហាការបោកប្រាស់កេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ីនធើណិត ឬហៅថា Scam និងការជួញដូរមនុស្ស ខណៈមានសេចក្តីរាយការណ៍ថា ជនជាតិឥណ្ឌូណេស៊ីក៏បានក្លាយជាជនរងគ្រោះលើទឹកដីកម្ពុជា។

គួរបញ្ជាក់ថា ក្រសួងការបរទេសអាមេរិកបានចេញរបាយការណ៍ប្រចាំឆ្នាំអំពីការជួញដូរមនុស្សនៅលើពិភពលោក កាលពីខែកក្កដា ឆ្នាំ ២០២២។ របាយការណ៍នោះបានបង្ហាញថា កម្ពុជាបានធ្លាក់ចំណាត់ថ្នាក់ពីកម្រិតពីរ (Tier 2) មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំធ្វើអ្វីជាដុំកំភួន ដើម្បីកែលម្អ ហើយមិនបានបំពេញតាមបទដ្ឋានអប្បបរមា ដូចដែលបានកំណត់។ របាយការណ៍នេះក៏បានលើកឡើងអំពីការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ីនធឺណិត ឬហៅថា Scam ផងដែរ៕

## បង្ខាំងមនុស្ស ចង់ធ្វើស្អីគេ ចាប់ជំរិត ឬជួញដូរមនុស្ស? ទើបពួកគេនាំគ្នាសម្រុកចេញ ដេញវាយរត់ប្រសាច ខ្លះលោតចុះទឹកបែបនេះ!

https://cen.com.kh/ Posted ByLeng KhunAugust 19, 2022

កាលពីម្សិលមិញនេះ (ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២) វីដេអូមួយត្រូវបានចែករំលែក បានបង្ហាញពីទិដ្ឋភាពអំពើហិង្សាបានកើតឡើងគួរឲ្យភ្ញាក់ផ្អើល ខណៈដែលបានឃើញមនុស្សប្រុសស្រីមួយក្រុមបានរត់ចេញពីក្នុងអគារកាស៊ីណូឡើងប្រសាច ដើម្បីគេចខ្លួនពីការវាយនឹងដំបង ពីសំណាក់ក្រុមសន្តិសុខ និងមេជាជនជាតិចិន។ ហេតុការណ៍នេះ បានកើតឡើងនៅកាស៊ីណូដំរី(២) នៅជាប់គល់ស្ពានឆ្លងទៅវៀតណាម ស្ថិតនៅ ជ្រៃធំ ស្រុកកោះធំ ខេត្តកណ្តាល។

បើតាមព័ត៌មានដែលទទួលបានបឋម បានឲ្យដឹងថា ករណីនេះបានកើតឡើង បន្ទាប់ពីកាស៊ីណូ «ប៉ាស៊ីហ្វិច» ហៅ(ដំរី២) បង្ខាំងក្រុមបុគ្គលិកក្នុងកាស៊ីណូ ដោយកុហកថា នឹងយកពួកគេទៅធ្វើការនៅកាស៊ីណូនៅខេត្តព្រះសីហនុ តែបែរជាយកពួកគេមកបង្ខាំងទុកនៅជ្រៃធំទៅវិញ ដែលជាហេតុធ្វើឲ្យផ្ទុះរឿងចម្រូងចម្រាសកើតជាហឹង្សា បុគ្គលិកនាំគ្នាទម្លុះទ្វាររត់ចេញមកខាងក្រៅ ដេញចាប់វាយឡើងប្រសេចប្រសាច រហូតខ្លះលោតចូលទឹកក៏មាន

ដែរ។ ប្រភពបន្តថា ក្រោយករណីនេះកើតឡើង គេក៏បានឃើញសមត្ថកិច្ចពាក់ព័ន្ធ បានចុះទៅកន្លែងកើតហេតុផង ដែរ ដើម្បីស្រាវជ្រាវរកដើមចមនៃមូលហេតុ ដែលនាំឲ្យកើតមានរឿងហេតុបែបនេះ។

ទាក់ទងករណីនេះ គេក៏មិនបានដឹងច្បាស់ថា ជនរងគ្រោះទាំងនោះគឺសុទ្ធជាជនជាតិខ្មែរ ឬជាបរទេស លាយឡំគ្នានោះទេ ប៉ុន្តែ បើតាមលោកឧត្តមសេនីយ៍ទោ ឈឿន សុចិត្ត ស្នងការនគរបាលខេត្តកណ្តាល បាន បញ្ជាក់ឲ្យដឹងថា បុគ្គលិកវៀតណាម រៀបចំផែនការប្រមូលគ្នាទម្លុះទ្វាររបង រត់ចេញក្រៅ ក៏ប៉ះគ្នាជាមួយសន្តិសុខ តែម្តង។ លោកបន្តថា មូលហេតុនៃដើមរឿងនេះ ជំនាញខេត្តកំពុងធ្វើការជាមួយក្រុមហ៊ុនហើយ៕ លឹម ហុង

## សម្តេចក្រឡាហោមៈ សមត្ថកិច្ចឃាត់ខ្លួនមេការកាស៊ីណូម្នាក់ នៅជ្រៃធំ ទាក់ទងករណីបង្ខាំងបុគ្គលិក និងមិនបើកប្រាក់ខែឲ្យ

https://www.btv.com.kh/ 2022/08/19 09:39:06 am

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានប្រសាសន៍ថា ទាក់ទងនឹងករណីបុគ្គលិកកាស៊ីណូមួយកន្លែងនៅជ្រៃធំ ខេត្តកណ្តាល សមត្ថកិច្ចបានស្រាវជ្រាវ និងឃាត់ខ្លួន មេការកាស៊ីណូម្នាក់ បន្ទាប់ពីបុគ្គលិកជាជនជាតិវៀតណាម អះអាងថា បានបង្ខាំងទុកពួកគេ និងមិនបានបើកប្រាក់ខែឲ្យ។ សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍បែបនេះ ខណៈសម្តេចបានអញ្ជើញដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័ន ទាំង៦ និងក្រសួង-ស្ថាប័នជាសមាជិក គ.ជ.ប.ជ ប្រចាំឆមាសទី១ ឆ្នាំ២០២២ នាព្រឹកថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា ករណីបុគ្គលិកកាស៊ីណូមួយនៅជ្រៃធំ ខេត្តកណ្តាល បានសម្រុករត់ចេញពីកាស៊ីណូនោះ អាជ្ញាធរឃាត់ខ្លួនបានបុគ្គលិក ម្នាក់ ជាជនជាតិវៀតណាម ប៉ុន្តែមិនមានឯកសារស្នាក់នៅជាក់លាក់នៅប្រទេសកម្ពុជានោះទេ ដូច្នេះសមត្ថកិច្ចសន្និដ្ឋានថា បុគ្គលិកនៅកាស៊ីណូប្រមាណ ៤០ នាក់ ជាជនជាតិវៀតណាមមកធ្វើការដោយខុសច្បាប់។ សម្តេចក្រឡាហោមបានបញ្ជាក់ថា ករណីនេះ ត្រូវបានសមត្ថកិច្ចស្រាវជ្រាវ និងឃាត់ខ្លួន មេការ កាស៊ីណូនេះ ម្នាក់ បន្ទាប់ពីបុគ្គលិកជាជនជាតិវៀតណាម អះអាងថា បានបង្ខាំងទុកពួកគេ និងមិនបានបើកប្រាក់ខែឲ្យពួកគេឡើយ ដូច្នេះសមត្ថកិច្ចសន្និដ្ឋានថា កាស៊ីណូនេះមិនទាន់មានច្បាប់ត្រឹមត្រូវ៕

# ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

## កម្ពុជា ផ្តើមត្រួតពិនិត្យ ការរស់នៅជនបរទេស និងឃាត់ខ្លួនមេក្លោង ជួញដូរមនុស្ស

https://dap-news.com/national/ ByPH104Posted on August 19, 2022

**ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ក្រសួងមហាផ្ទៃ ចាប់ផ្តើមបើកប្រតិបត្តិការត្រួតពិនិត្យ ការរស់នៅជនបរទេសនៅកម្ពុជា លើកលែងតែមន្ត្រីទូត ហើយឃាត់ខ្លួនមេក្លោងជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះមួយចំនួនទៀតផងដែរ។**

ក្រោយបញ្ចប់កិច្ចប្រជុំថ្នាក់ដឹកនាំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦ និងក្រសួង-ស្ថាប័ន ជាសមាសជិក គ.ជ.ប.ជ ប្រចាំឆមាសទី១ ឆ្នាំ២០២២ នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ នៅទីស្តីកាក្រសួង សម្តេច ស ខេង ប្រាប់ក្រុមអ្នកសារព័ត៌មានថា ប្រតិបត្តិការត្រួតពិនិត្យជនបរទេសនេះ ជំហានដំបូងធ្វើនៅខេត្តកណ្តាល

និងព្រះសីហនុ និងបន្តត្រួតពិនិត្យនៅខេត្តផ្សេងៗទៀត។ សម្តេច បញ្ជាក់ថា «យើងបានធ្វើហើយតាំងពីម្សិលមិញនៅកំពង់សោម និងខេត្តកណ្តាល ហើយជាបន្តបន្ទាប់ទៀត នៅគោលដៅផ្សេងៗ។ ធម្មតា យើងចុះទៅយើងឃើញថា ស្ថានភាពខ្លះវាមិនពិតទាំងស្រុងទេ ខ្លះក៏ពិតដែរ យើងសង្គ្រោះ ព្រោះបេសកម្មរបស់យើង ទីមួយ សង្គ្រោះជនរងគ្រោះ ហើយទីពីរ ចាប់មេក្លោងពាក់ព័ន្ធ ដើម្បីយកមកផ្តន្ទាទោសតាមផ្លូវច្បាប់»។ សម្តេច បន្តថា ប្រតិបត្តិការនេះធ្វើឡើងនៅខេត្តកណ្តាល និងព្រះសីហនុ ហើយបានឃាត់ខ្លួនមេក្លោង និងសង្គ្រោះជនរងគ្រោះមួយចំនួនទៀត ក្រោយសង្គ្រោះរួច អាជ្ញាធរ ពិនិត្យឃើញថា ជនរងគ្រោះទាំងនោះ គឺជនជាតិអាមេរិក, ខ្មែរអាមេរិក, ឥណ្ឌូនេស៊ី ជាដើម។

ចំពោះករណីរត់ចេញ ពីការស៊ីណូ នៅជ្រៃធំ ខេត្តកណ្តាល សម្តេច ស ខេង បានឲ្យដឹងថា តាមព័ត៌មានបឋម អ្នកទាំងនោះមកធ្វើការខុសច្បាប់ ដោយសន្យាថា ផ្តល់ប្រាក់ខែ។ សម្តេច ថា ជនរងគ្រោះទាំងនោះជាជនវៀតណាម។ សូមរំលឹកថា ប្រតិបត្តិការត្រួតពិនិត្យ ការរស់នៅរបស់ជនបរទេសនៅកម្ពុជា លើកលែងតែមន្ត្រីទូត បែបនេះ បន្ទាប់ពីអាមេរិក ដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅ ជាប្រទេសជាប់ចំណាត់ថ្នាក់លេខ៣ នៃការជួញដូរមនុស្ស៕

## ៦ខែឆ្នាំនេះ សមត្ថកិច្ចបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ៧៤ករណី ថយចុះ១២៤ករណី ធៀបនឹងឆ្នាំមុន

http://freshnewsasia.com/ 2022-08-19 03:20pm

**(ភ្នំពេញ)៖** ៦ខែ ឆ្នាំ២០២២នេះ សមត្ថកិច្ចបានបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចំនួន៧៤ករណី ថយចុះ១២៤ករណី បើធៀបនឹងឆ្នាំមុន។ នេះបើតាម លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

ថ្លែងក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រុមការងារអន្តរក្រសួង ស្ថាប័នទាំង៦ និងក្រសួង-ស្ថាប័នជាសមាជិក គ.ជ.ប.ជ ប្រចាំឆមាសទី១ ឆ្នាំ២០២២ នៅទីស្តីការក្រសួងមហាផ្ទៃ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងថា ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព សរុបចំនួន ៥២.៨០២លើក មានអ្នកចូលរួម ២.៣១២.៧៧៣នាក់ បានកើនឡើងជាង ៣០.០០០នាក់ ធៀបនឹងឆ្នាំ២០២១។ លោកស្រីបន្តថា «**ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ សមត្ថកិច្ចបានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៧៤ករណី ថយចុះ១២៤ករណី ធៀបនឹងឆ្នាំ២០២១ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៨៣នាក់ អនីតិជន៧នាក់ ក្នុងនោះជនសង្ស័យជាជនបរទេសមាន១២នាក់ ស្មើ៤សញ្ជាតិ។ សមត្ថកិច្ច ក៏បានសង្គ្រោះជនរងគ្រោះ១៥៦នាក់ ក្នុងនោះស្រី១០៥នាក់ អាយុក្រោម១៥ឆ្នាំ៦០នាក់**»។

ក្នុង៦ខែដើម ឆ្នាំ២០២២នេះដែរ សាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើបទល្មើសក្រោមច្បាប់ស្តីពីការង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយជាលទ្ធផលមាន៣ដំណាក់កាល គឺដំណាក់កាលអយ្យការអមសាលាដំបូង សរុប១៩៥សំណុំរឿង មានជនត្រូវចោទ១១១នាក់, ដំណាក់កាលចៅក្រមស៊ើបសួរមាន១៧៨សំណុំរឿង មានជនត្រូវចោទ២៥០នាក់ និងដំណាក់កាលចៅក្រមជំនុំជម្រះមាន២៨០សំណុំរឿង មានជនត្រូវចោទ៣៤៨នាក់។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានគូសបញ្ជាក់អំពីចំណុចសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ក្នុងតំបន់ និងអន្តរជាតិ។ សម្តេចក្រឡាហោម ក៏បានលើកឡើងអំពីទំនាក់ទំនងក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរវាងកម្ពុជា និងអាមេរិក

និងបានណែនាំឱ្យតាមដានរាល់ការផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដែលអាចពាក់ព័ន្ធអំពើជួញដូរមនុស្សដើម្បីមានវិធានការបង្ការ ទប់ស្កាត់ បង្ក្រាប និងបំភ្លឺ។ សម្ដេចក្រឡាហោម ស ខេង បានថ្លែងកោតសរសើរក្រុមការងារចំណុះលេខាធិការដ្ឋាន គ.ជ.ប.ជ ចំពោះលទ្ធផលដែលសម្រេចបានក្នុងរយៈពេល៦ខែដើមឆ្នាំ២០២២នេះ និងថាបើទោះបីជាបានសម្រេចកិច្ចការជាច្រើនហើយក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវបន្តរួមគ្នាដោះស្រាយ។ សម្ដេចក្រឡាហោម ក៏បានណែនាំឱ្យចម្លងលទ្ធផលលម្អិតនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ដាក់ជូនថ្នាក់ដឹកនាំក្រសួងស្ថាប័នផ្សេងៗទៀតផងដែរ៕

## លោក ស ខេង ណែនាំឱ្យតាមដានរាល់ការផ្សព្វផ្សាយព័ត៌មានផ្សេងៗដែលអាចពាក់ព័ន្ធអំពើជួញដូរមនុស្ស ដើម្បីមានវិធានការទប់ស្កាត់ទាន់ពេលវេលា

https://www.postkhmer.com/ ឡាយ សាមាន | Publication date 19 August 2022 | 14:51 ICT

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ណែនាំដល់ក្រុមការងារអន្តរក្រសួង និងស្ថាប័នដែលជាសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ គ.ជ.ប.ជ ត្រូវតាមដានរាល់ការផ្សព្វផ្សាយព័ត៌មានផ្សេងៗដែលអាចពាក់ព័ន្ធអំពើជួញដូរមនុស្ស ដើម្បីមានវិធានការទប់ស្កាត់ទាន់ពេលវេលា។ ការណែនាំនេះត្រូវបានធ្វើឡើងក្នុងឱកាស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង បានអញ្ជើញដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រុមការងារអន្តរក្រសួង ស្ថាប័នទាំង ៦ និងក្រសួង-ស្ថាប័នជាសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ ឆ្នាំ ២០២២ នៅទីស្តីការក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៩ ខែសីហានេះ។

កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការនគរបាលជាតិ និងមន្ត្រីជាន់ខ្ពស់ក្រសួងស្ថាប័នពាក់ព័ន្ធផងដែរ។ ក្នុងកិច្ចប្រជុំនោះ លោក ស ខេង បានគូសបញ្ជាក់អំពីចំណុចសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ក្នុងតំបន់ និងអន្តរជាតិ។ លោក ក៏បានលើកឡើងអំពីទំនាក់ទំនងក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរវាងកម្ពុជា និងអាមេរិក និងបានណែនាំឱ្យតាមដានរាល់ការផ្សព្វផ្សាយព័ត៌មានផ្សេងៗដែលអាចពាក់ព័ន្ធអំពើជួញដូរមនុស្សដើម្បីមានវិធានការបង្ការ ទប់ស្កាត់ បង្ក្រាប និងបំភ្លឺ។ លោកថា៖ «បើទោះបីជាលទ្ធផលបានសម្រេចកិច្ចការជាច្រើនហើយក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវបន្តរួមគ្នាដោះស្រាយ»។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានឱ្យដឹងថា ក្នុងឆមាសទី១ ឆ្នាំ ២០២២ នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព សរុបចំនួន ៥២ ៨០២ លើក មានអ្នកចូលរួមជាង ២ លាន ៣០ ម៉ឺននាក់ បានកើនឡើងជាង ៣ម៉ឺននាក់ធៀបនឹងឆ្នាំ២០២១។ លោកស្រីបានឱ្យដឹងថា ក្នុងឆមាសទី១ ឆ្នាំ ២០២២ នេះ សមត្ថកិច្ចបានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៧៤ ករណី ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៨៣នាក់ អនីតិជន៧នាក់ ក្នុងនោះជនសង្ស័យជាជនបរទេសមាន ១២ នាក់ ស្មើ ៤ សញ្ជាតិ។ លោកស្រីបន្តថា ជាមួយគ្នានោះ សមត្ថកិច្ច ក៏បានសង្គ្រោះជនរងគ្រោះ ១៥៦នាក់ ក្នុងនោះស្រី ១០៥នាក់ អាយុក្រោម ១៥ឆ្នាំ ៦០នាក់៕

## ព័ត៌មានវៀតណាមផ្សាយថា មនុស្ស៤០នាក់ រត់គេចពីកាស៊ីណូកម្ពុជា ហែលទន្លេឆ្លងទៅវៀតណាម

https://kohsantepheapdaily.com.kh/ ១៩ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ២១:១៨

វៀតណាម ៖ ឆ្មាំព្រំដែនក្នុងខេត្តអានយ៉ាង បានរាយការណ៍កាលពីថ្ងៃព្រហស្បតិ៍ ទី១៨ សីហា ២០២២ ថា មនុស្សចំនួន ៤០នាក់ បានហែលឆ្លងទន្លេមួយពីប្រទេសកម្ពុជា ចូលទៅក្នុងប្រទេសវៀតណាម ហើយពួកគេបាននិយាយថា ពួកគេរត់គេចពីការធ្វើបាបពីសំណាក់ថៅកែរបស់ពួកគេ នេះបើយោងតាមសារព័ត៌មាន Vnexpress ។

លោកវរសេនីយ៍ទោ Le Ngoc Tuan មន្ត្រីឈរជើងនៅច្រកទ្វារព្រំដែន Long Binh បាននិយាយថា អាជ្ញាធរវៀតណាម បានចាប់ឃាត់ខ្លួនមនុស្ស ចំនួន៤០នាក់ (បុរស៣៥នាក់ និងស្ត្រី០៥នាក់) ប៉ុន្តែមិនទាន់បានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេនៅឡើយទេ ។ ពួកគេបានអះអាងថា ក្នុងចំណោមមនុស្ស ៤២នាក់ ដែលបានរត់គេចពីកាស៊ីណូមួយ ក្នុងខេត្តកណ្ដាល ប្រទេសកម្ពុជា ហើយព្យាយាមហែលឆ្លងទន្លេ Binh Di ប៉ុន្តែមានម្នាក់មិនចេះហែលទឹក ហើយម្នាក់ទៀត ត្រូវបានម្ចាស់កាស៊ីណូចាប់បាន ។ ពួកគេបាននិយាយថា ពួកគេបានទៅប្រទេសកម្ពុជា និងធ្វើការនៅកាស៊ីណូ ភាគច្រើនលើហ្គេមអនឡាញ ប៉ុន្តែធ្វើការហួសកម្លាំង និងមិនបានផ្តល់ប្រាក់ឈ្នួល ឬសម្រាកគ្រប់គ្រានទេ ទើបសម្រេចចិត្តឆ្លងដែនខុសច្បាប់ រត់ទៅប្រទេសវៀតណាម តែម្តង ។ យ៉ាងណា អាជ្ញាធរវៀតណាម កំពុងស៊ើបអង្កេតករណីខាងលើនេះ ។

អាជ្ញាធរវៀតណាម បាននិយាយថា ជនជាតិវៀតណាមជាច្រើន ត្រូវបានបោកបញ្ឆោតឲ្យចូលមកប្រទេសកម្ពុជា ដើម្បីធ្វើការនៅកាស៊ីណូ និងកន្លែងស្រដៀងគ្នាផ្សេងទៀត ដែលពួកគេតែងតែត្រូវបានកេងប្រវ័ញ្ចលើកម្លាំងការងារ ។ ហើយប្រសិនបើពួកគេចង់ត្រឡប់ទៅប្រទេសវៀតណាមវិញ ពួកគេត្រូវបង់ប្រាក់ដល់កាស៊ីណូ រហូតដល់ ៣ម៉ឺនដុល្លារ ។ ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ អាជ្ញាធរវៀតណាម និងកម្ពុជា បានសហការគ្នា ជួយសង្គ្រោះមនុស្សបានជាង ២៥០នាក់ ។

ដោយឡែកនៅប្រទេសកម្ពុជាវិញ វីដេអូឃ្លីបមួយ បានបង្ហោះលើបណ្ដាញសង្គមបង្ហាញពីសកម្មភាពរបស់ក្រុមជនអន្តោប្រវេសន៍មួយក្រុម បានបុកទម្លុះរបង និងប៉ះទង្គិចគ្នាជាមួយកងសន្តិសុខកាស៊ីណូ ឃើហោ Golden Phonix Entertainment ស្ថិតនៅឃុំជ្រៃធំ ស្រុកកោះធំ ខេត្តកណ្ដាល នានៅថ្ងៃត្រង់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រត់ទៅលោតចូលទន្លេ ហែលឆ្លងសំដៅទៅត្រើយម្ខាង នៃប្រទេសវៀតណាម ។

ក្រោយពីកើតហេតុភ្លាមៗ សមត្ថកិច្ចកម្ពុជា រួមមាន កម្លាំងស្នងការនគរបាលខេត្តកណ្ដាល អភិបាលរងខេត្តកណ្ដាល ព្រមទាំងកម្លាំងយ៉ាងច្រើន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចុះទៅកន្លែងកើតហេតុផ្ទាល់ ដើម្បីស្រាវជ្រាវរកដើមចម ដែលនាំអោយកើតមានរឿងហេតុបែបនេះ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏មិនទាន់មានការបញ្ជាក់នូវមូលហេតុយ៉ាងណានៅឡើយទេ ៕

## មានសញ្ញាជួញដូរមនុស្ស! មនុស្ស ៤២ នាក់ ដែលបង្ខំចិត្តរត់ចេញពីកាស៊ីណូ Rich World (ជ្រៃធំ) ហែលទឹកចូលវៀតណាម គឺដោយសារតែ...

https://cen.com.kh/ Posted ByLeng KhunAugust 20, 2022

នៅរសៀលថ្ងៃទី១៩ ខែសីហា នគរបាលខេត្តអានយ៉ាង បានឲ្យដឹងថា ករណីមនុស្ស៤២នាក់ ដែលរត់ចេញពីកាស៊ីណូ Rich World (នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ប្រទេសកម្ពុជា) ដោយហែលទឹកឆ្លងទន្លេដោយខុសច្បាប់ ចូលប្រទេសវៀតណាម គឺជាសញ្ញានៃការជួញដូរមនុស្ស។ បច្ចុប្បន្ន នគរបាលខេត្តកំពុងបន្តស្រាវជ្រាវ និងបំភ្លឺ។

យោងតាមមេប៉ូលីសខេត្ត An Giang នាពេលខាងមុខ ក្រុមមនុស្សជាជនរងគ្រោះទាំងនោះ នឹងទទួលបានការគ្រប់គ្រង ពិនិត្យសុខភាព និងធ្វើសេចក្តីថ្លែងការណ៍។ ដំបូងឡើយ ប្រភពបានអះអាងថា មានសញ្ញាជួញដូរមនុស្ស ហើយពួកគេត្រូវបានគេបោកចូលមកប្រទេសកម្ពុជាដោយខុសច្បាប់ ដើម្បីធ្វើការដោយទទួលប្រាក់ឈ្នួលទាប។ ទោះជាយ៉ាងណា នៅពេលចូលមកដល់ស្រុកខ្មែរ ពួកគេត្រូវបានគេលក់ចូលក្នុងកាស៊ីណូក្រោមការគ្រប់គ្រងរបស់ជនជាតិចិន។ មេប៉ូលីសខេត្ត An Giang បានបញ្ជាក់ថា «ភាគច្រើននៃអ្នករត់គេចខ្លួនទាំងនោះ គឺមកពីខេត្តភាគកណ្តាល និងភាគខាងត្បូងវៀតណាម។ ទោះបីជាការចូលខុសច្បាប់ក៏ដោយតែពួកគេជាជនរងគ្រោះដែរ។ បច្ចុប្បន្ន យើងបានរាយការណ៍ និងដាក់ញត្តិទៅគណៈកម្មាធិការប្រជាជនខេត្ត ដើម្បីជូនដំណឹងដល់ខេត្ត-ក្រុងចំពោះប្រជាពលរដ្ឋពាក់ព័ន្ធករណីនេះ ដើម្បីឲ្យពួកគាត់មានផែនការបន្តនាពេលឆាប់ៗខាងមុខ»។

គួរបញ្ជាក់ថា នៅម៉ោងប្រហែល ៩ ព្រឹក ថ្ងៃទី១៨ ខែសីហា មនុស្សមួយក្រុមមកពីកាស៊ីណូ Rich World បានហែលទឹកក្នុងពេលដំណាលគ្នា ឆ្លងកាត់ទន្លេ Binh Di (ក្នុងក្រុង Long Binh ស្រុក An Phu ខេត្ត An Giang ទល់មុខបង្គោលលេខ ២១ ប៉ុស្តិ៍ការពារព្រំដែន) ប្រកព្រំដែន Long Binh។ ហើយនៅទីនោះ ឆ្មាំព្រំដែនបានចាប់ខ្លួនមនុស្ស ៤០ នាក់។ តាមរយៈការត្រួតពិនិត្យនោះ ប៉ុស្តិ៍ការពារព្រំដែន Long Binh បានកំណត់ថា ក្នុងករណីខាងលើ មានមនុស្សរហូតដល់ ៤២ នាក់បានចូលក្នុងប្រទេសកម្ពុជាដោយខុសច្បាប់។ ហើយក្រៅពីមនុស្ស ៤០ នាក់ ដែលត្រូវបានចាប់ខ្លួននោះ គឺមនុស្ស ២ នាក់ទៀត ដែលមានឈ្មោះ D.MH (អាយុ 16 ឆ្នាំ រស់នៅក្នុងទីក្រុង Kon Tum ខេត្ត Kon Tum) បានបាត់ខ្លួន បន្ទាប់ពីហែលទឹកនៅក្នុងទន្លេ Binh Di និងម្នាក់ទៀតឈ្មោះ NTH (អាយុ ២៥ ឆ្នាំរស់នៅក្នុងទីក្រុង Pleiku ខេត្ត Gia Lai) ត្រូវបានចាប់ខ្លួនដោយសន្តិសុខកាស៊ីណូ Rich World។

ជនរងគ្រោះទាំងនោះបានសារភាពថា ពួកគេភាគច្រើនបានចាកចេញដោយខុសច្បាប់តាមតំបន់ព្រំដែននៃខេត្តភាគខាងត្បូង។ បន្ទាប់ពីបានទៅប្រទេសកម្ពុជា គេបានឲ្យចុះកិច្ចសន្យា និងធ្វើការនៅកាស៊ីណូ Rich World។ មនុស្សមួយចំនួនពីមុនធ្វើការនៅកាស៊ីណូទល់មុខខេត្ត Tay Ninh, Long An ដែលគ្រប់គ្រងដោយថៅកែជាជនជាតិចិន។ ពួកគេបន្តថា ប៉ុន្តែដោយសារបង្ខំចិត្តធ្វើការងារលើសម៉ោងកំណត់ តែគ្មានពេលសម្រាក និងគ្មានប្រាក់ឈ្នួល ពួកគេក៏បានពិភាក្សា ប្រមូលផ្តុំគ្នានៅនឹងកន្លែង និងបានវាយលុកទៅលើសន្តិសុខកាស៊ីណូ ទម្លុះទ្វារត់ចេញឡើងប្រសាច ហើយលោតចុះទឹកហែលឆ្លងទន្លេ Binh Di ចូលប្រទេសវៀតណាម។ បច្ចុប្បន្ន មនុស្សទាំង ៤០ នាក់ខាងលើ ត្រូវបានអាជ្ញាធរខេត្ត An Giang រៀបចំឱ្យស្នាក់នៅផ្ទះវប្បធម៌ ឃុំ Da Phuoc ស្រុក An Phu ។ ដោយឡែកក្មេងជំទង់ដែលបាត់ខ្លួននោះ មិនទាន់រកឃើញនៅឡើយទេ៕ រក្សាសិទ្ធិដោយ៖ លឹម ហុង

## ក្រុងតៃប៉ិ និងចិនត្រូវសហការគ្នាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សមកកម្ពុជា

https://www.khmertimeskh.com/ August 20, 2022

ក្រុមប្រឹក្សាកិច្ចការដីគោករបស់តៃប៉ិ (MAC) បានពិភាក្សាអំពីវិធានការកាលពីថ្ងៃព្រហស្បតិ៍ (១៨ សីហា) ដើម្បីប្រយុទ្ធប្រឆាំងនឹងការបោកប្រាស់ការជួញដូរមនុស្សដែលផ្តោតលើពលរដ្ឋតៃវ៉ាន់នៅក្នុងប្រទេសកម្ពុជា។ ក្នុងសន្និសីទសារព័ត៌មាន អនុរដ្ឋមន្ត្រីក្រុមប្រឹក្សាកិច្ចការដីគោក លោក Chiu Chui-cheng ត្រូវបានសួរអំពីកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន ដើម្បីប្រឈមមុខនឹងបញ្ហានេះ។ លោក Chiu បានឆ្លើយតបថា តៃវ៉ាន់នឹងរក្សាទំនាក់ទំនងបើកចំហរជាមួយអាជ្ញាធរចិន ដើម្បីបង្ក្រាបបណ្តាញមេឧក្រិដ្ឋកម្មនៅកម្ពុជា។ លោក Chiu បាននិយាយថា កិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន គឺអាចធ្វើទៅបានក្រោមកិច្ចព្រមព្រៀង ជំនួយទៅវិញទៅមកខាងផ្នែកយុត្តិធម៌រួមគ្នាឆ្លងកាត់ច្រកសមុទ្រឆ្នាំ២០០៩។ បណ្តាញទំនាក់ទំនងដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងនៅតែមានជាធរមាន។ យ៉ាងណាក៏ដោយ លោកក៏បានសង្កត់ធ្ងន់ថា អាទិភាពបច្ចុប្បន្នរបស់តៃវ៉ាន់ គឺបង្កើនកិច្ចសហ

ប្រតិបត្តិការជាមួយប្រទេសថៃ និងម៉ាឡេស៊ី ដើម្បីស៊ើបអង្កេតមេខ្លោងបោកប្រាស់ និងជួយស្វែងរកមនុស្សដែលត្រូវបានបង្ខាំងខ្លួនប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។ ប៉ុន្មានសប្តាហ៍ចុងក្រោយនេះ របាយការណ៍អំពីពលរដ្ឋតៃវ៉ាន់ដែលកំពុងត្រូវបានគេបង្ខាំងទុកនៅកម្ពុជាបានធ្វើឲ្យសាធារណជននៅតៃវ៉ាន់ភ្ញាក់ផ្អើល។ ជនរងគ្រោះជាច្រើនត្រូវបានគេអូសទាញមកកម្ពុជាដោយការសន្យាផ្តល់ការងារដែលមានកម្រៃខ្ពស់។ ជនរងគ្រោះខ្លះត្រូវបានគេប្រើប្រាស់ដើម្បីជំរិតទារប្រាក់លោះពីមិត្តភក្តិ និងសមាជិកគ្រួសារនៅតៃវ៉ាន់។

ក្នុងសន្និសីទសារព័ត៌មាន លោក Chiu បានកត់សម្គាល់ថា រដ្ឋាភិបាលបានចាត់វិធានការដោះស្រាយបញ្ហានេះរួចហើយ។ នាយកប្រតិបត្តិ Yuan បានកោះប្រជុំក្រុមការងារដែលមានក្រសួងការបរទេស ក្រសួងយុត្តិធម៌ និងការិយាល័យស៊ើបអង្កេតឧក្រិដ្ឋកម្ម ក្រោមក្រសួងយុត្តិធម៌។ ក្រុមការងារមានគោលបំណងជូនដំណឹងដល់សាធារណជនអំពីហានិភ័យដែលទាក់ទងនឹងការធ្វើដំណើរ និងធ្វើការក្នុងប្រទេសកម្ពុជា។ លោក Chiu បាននិយាយថា រដ្ឋាភិបាលនឹងធ្វើអ្វីៗគ្រប់យ៉ាងនៅក្នុងអំណាចរបស់ខ្លួន ដើម្បីស៊ើបអង្កេតប្រតិបត្តិការឧក្រិដ្ឋកម្មដែលផ្តោតលើពលរដ្ឋតៃវ៉ាន់ និងដើម្បីជួយប្រសិនបើពួកគេមានទុក្ខព្រួយ។ លោកក៏បានព្រមានអ្នកដែលកំពុងពិចារណាលើការផ្តល់ជូនការងារនៅបរទេសឱ្យដឹងពីហានិភ័យដែលពាក់ព័ន្ធ និងដើម្បីពិចារណាឡើងវិញនូវការផ្តល់ជូនបែបនេះ ដែលជាករណីឧក្រិដ្ឋកម្មនាពេលថ្មីៗនេះ។ ក្នុងករណីកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរចិន លោក Chiu បាននិយាយថា ប្រតិបត្តិការរួមគ្នានឹងត្រូវបានអនុវត្តដោយគោរពចំពោះភាគីទាំងអស់។

យោងតាមរបាយការណ៍របស់ CNA ក្រសួងការបរទេសចិនក៏បានធ្វើសន្និសីទសារព័ត៌មាននៅថ្ងៃព្រហស្បតិ៍ (១៨ សីហា) ផងដែរ។ អ្នកនាំពាក្យត្រូវបានសួរអំពីបញ្ហាប្រជាជនតៃវ៉ាន់ និងចិនត្រូវបានគេកំណត់គោលដៅដោយមេខ្លោងបោកប្រាស់នៅកម្ពុជា។ ជនជាតិតៃប៉ិហូតដល់ ៣៧៣នាក់ ត្រូវបានគេជឿថាជាប់នៅក្នុងកណ្តាប់ដៃនៃក្រុមឆបោកនៅកម្ពុជា។ ពួកគេភាគច្រើនត្រូវបានបោកបញ្ឆោតដោយការផ្សាយពាណិជ្ជកម្មក្លែងក្លាយនៃការងារដែលរកប្រាក់កម្រៃខ្ពស់នៅក្នុងប្រទេសកម្ពុជា។

អ្នកនាំពាក្យលោក Wang Wenbin បានឆ្លើយតបថា ប្រទេសចិននឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីធានាសុវត្ថិភាព "ជនរួមជាតិមកពីហុងកុង និងតៃវ៉ាន់" ហើយបុគ្គលិកស្ថានទូតចិនកំពុងស៊ើបអង្កេតយ៉ាងសកម្មនូវរបាយការណ៍នៃមេខ្លោងជួញដូរមនុស្ស។ CAN

# ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២

## លោកស្រី ជូ ប៊ុនអេង៖ ៧ខែនេះ សមត្ថកិច្ចចាប់ខ្លួនអ្នករកស៊ីជួញដូរមនុស្ស ៦០នាក់ សង្គ្រោះមនុស្សជាង ៦០០នាក់

http://freshnewsasia.com/ 2022-08-22 06:59pm

**(ភ្នំពេញ)៖** រយៈពេល៧ខែ ឆ្នាំ២០២២នេះ សមត្ថកិច្ចបានចាប់ខ្លួនអ្នករកស៊ីជួញដូរមនុស្សប្រមាណ ៦០នាក់ និងសង្គ្រោះមនុស្សជាង ៦០០នាក់។ នេះបើតាមលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។ ថ្លែងក្រោយជំនួបជាមួយមន្ត្រីអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ លោកស្រី ជូ ប៊ុនអេង បានឲ្យដឹងថា បទល្មើសទាំងនេះត្រូវបានរកឃើញនៅខេត្តព្រះសីហនុ កណ្តាល កោះកុង បន្ទាយមានជ័យ ស្វាយរៀង និងរាជធានីភ្នំពេញ។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានបញ្ជាក់យ៉ាងដូច្នេះថា «**៧ខែនេះ អាជ្ញាធរកម្ពុជា បានបង្ក្រាបអំពើជួញដូរមនុស្ស ៧៤ករណី ហើយបានចាប់ខ្លួនជនជាតិចិន ម៉ាឡេស៊ី វៀតណាម និងជនជាតិខ្មែរ ៦០នាក់ បញ្ជូនទៅតុលាការ ដោយសង្ស័យជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សខុសច្បាប់**»។

លោកស្រី ជូ ប៊ុនអេង ថា ជនសង្ស័យទាំងនេះ បានបោកបញ្ឆោតជនរងគ្រោះពីប្រទេសផ្សេងៗ ចូលមកប្រទេសកម្ពុជា ដោយសន្យាឲ្យធ្វើការទទួលបានប្រាក់កម្រៃច្រើនជាដើម។ លោកស្រីបន្ថែមថា អាជ្ញាធរនៅតែដាក់ចិត្តដាក់កាយប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ដើម្បីឲ្យប្រទេសកម្ពុជា ក្លាយជាទីតាំងដ៏មានសុខដុមរមា មិនមានបញ្ហាឧក្រិដ្ឋកម្មដ៏អាក្រក់បែបនេះ។ សូមបញ្ជាក់ថា កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃ បានចាប់ផ្តើមបើកប្រតិបត្តិការទ្រង់ទ្រាយធំ ដើម្បីត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេសនៅកម្ពុជា។ ប្រតិបត្តិការរបស់ក្រសួងមហាផ្ទៃ ដែលត្រួតពិនិត្យការរស់នៅរបស់ជនបរទេសទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយលើកលែងតែមន្ត្រីការទូតប៉ុណ្ណោះ ដើម្បីពិនិត្យភាពស្របច្បាប់ និងរកមុខសញ្ញាដែលពាក់ព័ន្ធនឹងជួញដូរមនុស្ស៕

## អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ឈ្វេងយល់បញ្ហាសិទ្ធិមនុស្ស ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត នៅខេត្តព្រះសីហនុ

https://www.information.gov.kh/ AKP ព្រះសីហនុ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២

លោក វិទិត មុតតាប៊ន អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាបានជួបពិភាក្សាការងារជាមួយឯកឧត្តម គួច ចំរើន អភិ បាល នៃគណៈអភិបាលខេត្តព្រះសីហនុ ដើម្បីឈ្វេងយល់ពីស្ថានភាពសិទ្ធិមនុស្ស, ការបង្ខិតបង្ខំឱ្យប្រព្រឹត្តបទល្មើស, ការជួញដូរមនុស្ស, ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេត, ការបោកប្រាស់តាមប្រព័ន្ធអនឡាញ និងស្ថានភាពជន រងគ្រោះដែលត្រូវបានជួយសង្គ្រោះជាដើម នៅក្នុងខេត្តព្រះសីហនុ។ ជំនួបនេះ បានធ្វើឡើង កាលពីរសៀលថ្ងៃ ទី១៩ ខែសីហា ឆ្នាំ២០២២។

ឯកឧត្តម គួច ចំរើន អភិបាលខេត្តព្រះ សីហនុបានស្វាគមន៍គណៈប្រតិភូអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ដែលបានមកទស្សនកិច្ចនៅខេត្តព្រះសីហនុ និងបានជម្រាបជូនពីភូមិសាស្ត្រ វិទ្យាសាស្ត្រខេត្តព្រះសីហនុ និងការអភិវឌ្ឍនានា ជាពិសេសភាពរីកចម្រើនរបស់ខេត្តនារយៈពេលចុងក្រោយក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមអភិបាលខេត្តបានជម្រាបជូនអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិថា កម្ពុជាមានរដ្ឋធម្មនុញ្ញ និងច្បាប់ជាច្រើនទាក់ទងនឹងសិទ្ធិមនុស្ស ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត និងការបោកប្រាស់តាមប្រព័ន្ធអនឡាញជាដើម ហើយធ្វើការប្រយុទ្ធប្រឆាំងចំពោះបញ្ហានេះផងដែរ។ ឯកឧត្តមបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា មានការប្តេជ្ញាចិត្តខ្ពស់ប្រឆាំងអំពើទាំងឡាយ ណាដែលល្មើសនឹងច្បាប់កម្ពុជា និងបទដ្ឋានគតិយុត្តនានារបស់អន្តរជាតិ។

ឯកឧត្តម អភិបាលខេត្តបានអះអាងថា អាជ្ញាធរខេត្តព្រះសីហនុគ្រប់ជាន់ថ្នាក់មិនដែលគេចវេសពីតួនាទីរបស់ខ្លួន ពោលគឺសហការគ្នាអនុវត្តន៍ច្បាប់ និងបង្ក្រាបរាល់បទល្មើសដោយគ្មានការបន្ធូរដៃ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត សូមស្វាគមន៍គ្រប់ភាគីពាក់ព័ន្ធ និងបណ្តាស្ថាន ទូតប្រទេសនានាជាមិត្ត ក្នុងការសហការស្វែងរកឫសគល់នៃបទល្មើស ដើម្បី ឈានទៅដល់ការទប់ស្កាត់ បង្ក្រាបឱ្យកាន់តែមានប្រសិទ្ធភាព។ ឯកឧត្តមបានលើកឡើងថា កន្លងមកប្រទេសកម្ពុជា និងប្រទេសថៃ មានលំហូរពលករខុសច្បាប់ទៅវិញទៅមក ហើយមានពលករខ្មែរទៅធ្វើការប្រទេសថៃ និងក៏មានពលករថៃមកធ្វើការនៅប្រទេសកម្ពុជា ពិសេសក្នុងខេត្តព្រះសីហនុតាមរយៈការអូសទាញដោយខុសច្បាប់។ ឯកឧត្តមអភិបាលខេត្តបានរម្លឹកថា "២០ឆ្នាំមុនពលរដ្ឋខ្មែរជាច្រើននាក់រងការធ្វើទុក្ខបុកម្នេញ ឬជួញដូរនៅថៃ ម៉ាឡេស៊ី តៃវ៉ាន់ ចិន ហើយយើងជាខ្មែរមានការឈឺចាប់។ ដូច្នេះសម្រាប់កម្ពុជា យើងមិនឱ្យការឈឺចាប់នេះកើតមានទៀតនោះឡើយ"។

ឯកឧត្តមបន្តថា កន្លង មកមានការលើកឡើងថា មានករណីចាប់បង្ខាំងមនុស្សដោយខុសច្បាប់នៅតាមទីតាំងអាជីវកម្មមួយចំនួនក្នុងខេត្តព្រះសីហនុ តែពេលសមត្ថកិច្ចចុះទៅដល់ គឺអ្នកដែលតាំងខ្លួនជាជនរងគ្រោះទាំងនោះកំពុងធ្វើការងារជាធម្មតា និងអ្នកខ្លះកំពុងសម្រាកលេងទូរស័ព្ទជាដើម។ បន្ទាប់ពីសមត្ថកិច្ចសួរនាំ គឺពួកគេចង់ប្តូរកន្លែងធ្វើការទើបប្តឹងសមត្ថកិច្ចថា មានករណីចាប់បង្ខាំង។ ករណីខ្លះទៀត គឺដើមបណ្តឹងជាអ្នកផ្សេងដោយសាមីខ្លួនមិនបានប្តឹង ហើយក៏មិនមានករណីចាប់បង្ខាំងឡើយ គឺពួកគេស្ម័គ្រចិត្តធ្វើការងារជាធម្មតា។

ទន្ទឹមនោះ ក៏មានឧក្រិដ្ឋកម្មគ្រឿងញៀនដែលអាជ្ញាធរខេត្តធ្វើការបង្ក្រាបបានកាលពីពេលថ្មីៗនេះ គឺមានចំនួន ៨៧១គីឡូក្រាម បង្កឡើងដោយជនបរទេសនៅក្នុងខេត្តព្រះ សីហនុ។ ក្នុងឱកាសនោះដែរ ឯកឧត្តមអភិបាលខេត្ត បានឆ្លើយសំណួរជាច្រើនដែលបានចោទសួរដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ហើយសំណួរភាគច្រើនផ្តោតលើបញ្ហាសិទ្ធិមនុស្ស ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិត និងការបោកប្រាស់តាមប្រព័ន្ធអនឡាញ។ ឯកឧត្តមអភិបាលខេត្ត ក៏បានលើកឡើងបន្ថែមថាស្ថានភាពជាក់ស្តែងនៅខេត្តព្រះសីហនុ គឺខុសពីអ្វីដែលប្រព័ន្ធផ្សព្វផ្សាយមួយចំនួនបានផ្សព្វផ្សាយ។

លោក វិទិត មុនតាបិន អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពី សិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាបានថ្លែងអំណរគុណឯឧត្តមអភិបាលខេត្ត ដែលបានឱ្យប្រតិភូរបស់លោកសិក្សាឈ្វេងយល់អំពីកង្វល់ និងបញ្ហាប្រឈមនានា ដើម្បីរកវិធីដោះស្រាយឱ្យបានទាន់ពេលវេលា ក្នុងនោះមានដូចជាស្ថានភាពសិទ្ធិមនុស្ស, ការបង្ខិតបង្ខំឱ្យប្រព្រឹត្តបទល្មើស, ការជួញដូរមនុស្ស, ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេត, ការបោកប្រាស់តាមប្រព័ន្ធអនឡាញ និងស្ថានភាពជន រងគ្រោះដែលត្រូវបានជួយសង្គ្រោះជាដើម។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិរូបនេះបានបន្ថែមថា ក្រោយពីបានស្តាប់ការពន្យល់ បកស្រាយប្រតិភូអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ បានរីករាយស្វាគមន៍ចំពោះការឆ្លើយតបនឹងសំណួររបស់លោកដែលបានលើកឡើង។ លោក វិទិត មុនតាបិន ក៏បានថ្លែងអំណគុណចំពោះកិច្ចពិភាក្សានេះប្រកបដោយភាពកក់ក្តៅ និងយោគយល់គ្នាទៅវិញទៅមកពាក់ព័ន្ធសិទ្ធិមនុស្ស ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធើណេត និងការបោកប្រាស់តាមប្រព័ន្ធអនឡាញជាដើម។ លោកក៏បានអះអាងដែរថា ដំណើរទស្សនកិច្ចមកកាន់ខេត្តព្រះសីហនុ គឺចង់សិក្សាឈ្វេងយល់បន្ថែមពីបញ្ហាទាំងនេះ ដើម្បីរៀបចំដាក់ក្នុងរបាយការណ៍ការងាររបស់លោកនៅចុងឆ្នាំនេះ៕

## ក្រសួងមហាផ្ទៃថា អត្រាជួញដូរមនុស្សធ្លាក់ចុះច្រើន បើធៀបកាលពីឆ្នាំទៅ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 20/08/2022 - 09:15

ក្រសួងមហាផ្ទៃបានអះអាងថា ក្នុងរយៈពេល៦ខែឆ្នាំ២០២២នេះ អត្រាជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានបន្តធ្លាក់ចុះមកត្រឹម៧៤ករណី ពោលគឺថយចុះចំនួន១២៤ករណី បើធៀបនឹងឆ្នាំ២០២១ កន្លងទៅ។ ការអះអាងបែបនេះ ធ្វើឡើងបន្ទាប់ពីរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សនៅលើពិភពលោករបស់ក្រសួងការបរទេសអាមេរិកបង្ហាញថា កម្ពុជាធ្លាក់ចំណាត់ថ្នាក់ពីកម្រិតពីរ (Tier 2) មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំប្រឹងប្រែងដើម្បីកែលម្អនូវស្ថានភាពការជួញដូរមនុស្សឡើយ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃឲ្យដឹងថា ក្នុងឆមាសទី១ ឆ្នាំ២០២២ សមត្ថកិច្ចបានបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទបានចំនួន៧៤ករណី ថយចុះ១២៤ករណី បើធៀបក្នុងអំឡុងពេល ៦ខែ ដើមឆ្នាំ២០២១។ ក្នុងនោះ អាជ្ញាធរក៏បានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៨៣នាក់ អនីតិជន៧នាក់ ហើយជនសង្ស័យជាជនបរទេសមានចំនួន១២នាក់ ដែលមាន ៤សញ្ជាតិ។ បន្ថែមពីនេះ សមត្ថ

កិច្ចក៏បានជួយសង្គ្រោះជនរងគ្រោះចំនួន ១៥៦នាក់ ក្នុងនោះ ក្មេងស្រីអាយុក្រោម១៥ឆ្នាំ មានចំនួន ៦០នាក់។ ស្របពេលដែលរដ្ឋាភិបាលអះអាងថា អត្រាជួញដូរមនុស្សធ្លាក់ចុះ អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក ស៊ឹង សែនករុណាបានសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស។ ប៉ុន្តែទន្ទឹមនឹងការសាទរ លោក ស៊ឹង សែនករុណាបង្ហាញក្តីព្រួយបារម្ភវិញថា ប្រសិនបើតួលេខថយចុះនោះ គ្រាន់តែជាការលើកឡើងរបស់រដ្ឋាភិបាល ហើយទិន្នន័យដែលបណ្តាប្រទេសផ្សេងទៀតរកឃើញថានៅតែមានចំនួនច្រើននោះ កម្ពុជានឹងបន្តស្ថិតក្នុងបញ្ជីខ្មៅដដែល ហើយថែមប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសជាតិផង។

តែយ៉ាងណា លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានថ្លែងថា ទោះបីជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានសម្រេចលទ្ធផលល្អច្រើនក៏ដោយ ប៉ុន្តែករណីនេះនៅតែមានបញ្ហាប្រឈមដែលត្រូវបន្តដោះស្រាយបន្ថែម។ ខណៈកម្ពុជានឹងបន្តធ្វើការជាមួយអាមេរិក និងបន្តតាមដានរាល់ការផ្សព្វផ្សាយព័ត៌មានដែលអាចពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដើម្បីមានវិធានការបង្ការ ទប់ស្កាត់ បង្ក្រាប និងបំភ្លឺ។ ម្លោះហើយ លោកស្នើឱ្យរដ្ឋាភិបាលដុតដៃជើងឱ្យខ្លាំង ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សនេះ ជាជាងការលើកឡើងប៉ុន្តែស្ថានភាពនៅដដែល។ មន្ត្រីអង្គការសង្គមស៊ីវិលរូបនេះអះអាងទៀតថា ប្រសិនបើរដ្ឋាភិបាលបានអនុវត្តច្បាប់ឱ្យបានពេញលេញមែន នោះករណីជួញដូរមនុស្សក៏មិនកើតឡើងក្នុងប្រទេសកម្ពុជាដែរ។ ផ្ទុយទៅវិញ មន្ត្រីមូលដ្ឋានទទួលបានផលប្រយោជន៍ពីបុគ្គលមួយចំនួន ទើបករណីនេះបន្តកើតមាន។

ជុំវិញករណីជួញដូរមនុស្សនេះ កាលពីថ្ងៃទី១៩ កក្កដា ឆ្នាំ២០២២ របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សនៅលើពិភពលោករបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកបានបង្ហាញថា កម្ពុជាបានធ្លាក់ចុះពីចំណាត់ថ្នាក់កម្រិតពីរកាលពីឆ្នាំ២០២១ មកចំណាត់ថ្នាក់កម្រិតបី រឺបញ្ជីខ្មៅនៅឆ្នាំ២០២២។ ចំណាត់ថ្នាក់សម្រាប់ឆ្នាំនេះរបាយការណ៍បានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមស្តង់ដារអប្បបរមា ក្នុងការប្រឹងប្រែងលុបបំបាត់ការជួញដូរមនុស្សនោះទេ។ របាយការណ៍ដដែលបន្តថា កម្ពុជាដើរថយក្រោយក្នុងការលុបបំបាត់ការជួញដូរមនុស្សដោយសារ បញ្ហាអំពើពុករលួយជាប្រព័ន្ធ ដែលបានរារាំងដល់ការអនុវត្តច្បាប់ បណ្តោយឱ្យជនល្មើសនៅតែអាចប្រព្រឹត្តបទល្មើស ឬគេចខ្លួនពីការកាត់ទោស ហើយជនរងគ្រោះនៅតែមិនអាចទទួលបានការជួយសង្គ្រោះ។

ជាការពិត ការចេញផ្សាយរបាយការណ៍នេះ ធ្វើឡើងតែប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីសារព័ត៌មាន Al Jazeera បានចេញផ្សាយនូវវីដេអូឯកសារស៊ើបអង្កេត មួយស្តីអំពីការជួញដូរមនុស្សនៅកម្ពុជា។ នៅក្នុងវីដេអូជាង ៤០នាទីនោះបានបង្ហាញថា នៅកម្ពុជា មានក្រុមឧក្រិដ្ឋជនកំពុងជួញដូរយុវជន និងស្ត្រីរាប់ពាន់នាក់មកពីទូទាំងអាស៊ី (ថៃ ម៉ាឡេស៊ី ចិន វៀតណាម និងហ្វីលីពីន) ឲ្យចូលទៅក្នុងបរិវេណ ដែលមានការឃាមកាមយ៉ាងតឹងរ៉ឹងក្នុងប្រទេសកម្ពុជា និងបានបង្ខំឱ្យពួកគេធ្វើការងារបោកប្រាស់តាមអ៊ីនធឺណេត៕

## នៅក្នុងប្រទេសកម្ពុជា ជនជាតិហុងកុងដែលទើបជ្រើសរើសថ្មីពីរនាក់ បានធ្លាក់ក្នុងប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត

https://www.khmertimeskh.com/ August 20, 2022

គេជឿថា ជនជាតិហុងកុងថ្មីពីរនាក់ក្នុងចំណោមបីនាក់ កំពុងត្រូវបានគេចាប់បង្ខាំងនៅក្នុងប្រទេសកម្ពុជា ខណៈម្នាក់ទៀតកំពុងជាប់នៅក្នុងប្រទេសថៃ។

អនុរដ្ឋលេខាធិការសន្តិសុខលោក Michael Cheuk Hau-yip បានបង្ហាញព័ត៌មាននេះកាលពីថ្ងៃសុក្រ ហើយបានបន្ថែមថា ទាំងបីនាក់នេះបាននាំឱ្យចំនួនសរុបនៃជនជាតិហុងកុងដែលត្រូវបានចាប់ខ្លួនក្នុងប្រតិបត្តិការ

បោកប្រាស់ និងការផ្តល់ជូនការងារដែលរកកម្រៃខ្ពស់ក្លែងក្លាយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានកើនឡើងដល់ ២៣ នាក់។ ក្នុងចំណោមជនរងគ្រោះទាំង ២៣ នាក់ មាន ១១ នាក់នៅតែមិនអាចទាក់ទងបាន បន្ទាប់ពីត្រូវបានគេទាក់ទាញដោយការផ្តល់ជូនការងារដែលមានប្រាក់ខែខ្ពស់ នៅក្នុងប្រទេសដូចជាកម្ពុជា ថៃ និងមីយ៉ាន់ម៉ា។ ពួកគេត្រូវបានគេជឿថាត្រូវបានចាប់បង្ខាំងខណៈដែលត្រូវបានបង្ខំឱ្យធ្វើសកម្មភាពខុសច្បាប់។ ថ្លែងក្នុងកម្មវិធីវិទ្យុ លោក Cheuk បាននិយាយថា ក្នុងចំណោមជនរងគ្រោះទាំងបីនាក់ ដែលទើបនឹងរាយការណ៍ថ្មី ម្នាក់ត្រូវបានគេជឿថាស្ថិតក្នុងប្រទេសថៃ និងពីរនាក់ទៀតនៅក្នុងប្រទេសកម្ពុជា។ Cheuk បាននិយាយថា ពួកគេអាចរក្សាទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ពួកគេ ហើយត្រូវបានគេគិតថាមានសុវត្ថិភាពនៅពេលនេះ។ លោកបានបង្ហើបឱ្យដឹងថា ឧបសគ្គធំបំផុតក្នុងការអាចជួយសង្គ្រោះជនរងគ្រោះបែបនេះ គឺអសមត្ថភាពក្នុងការបញ្ជាក់ពីទីតាំងរបស់ពួកគេ។ Cheuk បាននិយាយថាខ្លួនត្រូវបានគេរាយការណ៍ថាអ្នកដែលត្រូវបានបោកប្រាស់នឹងត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងការឆបោកតាមទូរស័ព្ទនិងតាមអ៊ីនធឺណិតហើយនឹងត្រូវបានដោះលែងលុះត្រាតែពួកគេអាចបោកប្រាស់ប្រាក់មួយចំនួនពីជនរងគ្រោះ។

ក្នុងករណីខ្លះ ជនរងគ្រោះពីការបោកប្រាស់ការងារនៅហុងកុងត្រូវបានដោះលែង បន្ទាប់ពីក្រុមគ្រួសាររបស់ពួកគេបានយល់ព្រមផ្ទេរប្រាក់តាមការណែនាំ ដោយអ្នកដែលចាប់បង្ខាំងពួកគេ។ នៅក្នុងកិច្ចប្រជុំជាមួយសារព័ត៌មានកាលពីថ្ងៃព្រហស្បតិ៍ លោក Cheuk បាននិយាយថា ក្រុមការងារនាយកដ្ឋានត្រូវបានបង្កើតឡើងសម្រាប់ការជួយសង្គ្រោះជនរងគ្រោះ។ មុននេះ អ្នកនាំពាក្យការិយាល័យស្នងការនៃក្រសួងការបរទេសនៅ តំបន់រដ្ឋបាលពិសេសហុងកុង(HKSAR) បាននិយាយថា ការិយាល័យបាននិងកំពុងស្វែងរកយ៉ាងសកម្មសម្រាប់ប្រជាជនហុងកុងដែលមិនអាចទាក់ទងបាន។

ស្នងការនគរបាល លោក Raymond Siu Chak-yee កាលពីថ្ងៃសុក្រ ក៏បានបង្ហាញដែរថា ទីក្រុងបានកត់ត្រាអំពើក្លែងបន្លំប្រភេទផ្សេងៗជាង ១២,០០០ ក្នុងឆមាសទីមួយនៃឆ្នាំនេះ ដែលកើនឡើងជិត៤០ ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ចំនួនករណីក្លែងបន្លំសរុបដែលបានកត់ត្រាក្នុងឆ្នាំ២០២១ គឺមានតែ ៨,៦០០ ប៉ុណ្ណោះ។ នគរបាល និងនាយកដ្ឋានអន្តោប្រវេសន៍កាលពីថ្ងៃព្រហស្បតិ៍បានចាប់ផ្តើមចែកចាយខិត្តប័ណ្ណអំពីការបោកប្រាស់ការងារនៅតាមបញ្ជរឡើងយន្តហោះហើរដែលចាកចេញទៅកាន់បណ្តាប្រទេសអាស៊ីអាគ្នេយ៍។ ការិយាល័យសន្តិសុខក៏បានបន្ថែមការព្រមានស្រដៀងគ្នានេះលើគេហទំព័ររបស់ខ្លួន សម្រាប់ជាការជូនដំណឹងអំពីការធ្វើដំណើរទៅក្រៅប្រទេស។ ថ្មីៗនេះ តៃប៉ិបានរាយការណ៍ថា ជនជាតិរបស់ខ្លួនរហូតដល់ ១០០០ នាក់ក៏ត្រូវបានគេជឿថាបានជាប់ក្នុងស្ថានភាពស្រដៀងគ្នានៅក្នុងប្រទេសកម្ពុជា ហើយនគរបាលតៃប៉ិក៏បានចាប់ខ្លួនអ្នកជ្រើសរើសបុគ្គលិកមួយចំនួនផងដែរ។

## ការភៀសខ្លួនវ័យក្មេង
## ភាពវេទនាបានជំរុញកម្មករវៀតណាមរត់គេចខ្លួនចេញពីកាស៊ីណូនៅកម្ពុជា

https://www.khmertimeskh.com/ August 21, 2022

នៅពេលណាដែលនាងបិទភ្នែក Doan Thi Ngoc Diep ឃើញទឹក និងឮសំឡេងដំបងវាយមនុស្ស។ Diep ស្ថិតក្នុងចំណោមជនជាតិវៀតណាម ៤០នាក់ ដែលបានហែលឆ្លងទន្លេពីប្រទេសកម្ពុជាទៅកាន់ប្រទេសវៀតណាមកាលពីព្រឹកថ្ងៃព្រហស្បតិ៍ ដើម្បីគេចពីកាស៊ីណូដែលពួកគេត្រូវបានគេបោកបញ្ឆោតឱ្យធ្វើការ ហើយដែលពួកគេបាននិយាយថាជា "នរក"។ មានអ្នករត់គេចខ្លួនចំនួន ៤២នាក់ ប៉ុន្តែម្នាក់ត្រូវបានឆ្មាំកាស៊ីណូចាប់បាន ហើយម្នាក់ទៀតត្រូវបានគេប្រទះឃើញស្លាប់។ Diep អាយុ ២០ ឆ្នាំបានប្រាប់ VnExpress ថា "គ្មាននរណាម្នាក់ក្នុងចំនោមពួកយើងអាចគេងលក់កាលពីយប់មិញទេវាគួរឱ្យតក់ស្លុតណាស់" ។

នាង និងស្វាមីកំពុងស្នាក់នៅផ្ទះសហគមន៍មួយក្នុងខេត្ត An Giang ភាគខាងត្បូងប្រទេសវៀតណាម បន្ទាប់ពីបានភៀសខ្លួនចេញពីកាស៊ីណូក្នុងខេត្តកណ្តាលរបស់កម្ពុជា។ កាស៊ីណូដែលគ្រប់គ្រងដោយជនជាតិចិន ស្ថិតនៅតាមដងទន្លេ Binh Di ដែលជាព្រំដែនធម្មជាតិដែលមានទទឹងប្រហែល ៧០ ម៉ែត្រក្នុងអំឡុងរដូវវស្សារវាងប្រទេសកម្ពុជា និងវៀតណាម។ ជនជាតិវៀតណាមបានរៀបចំផែនការរត់គេចខ្លួនអស់រយៈពេលពីរយប់ ដោយចាប់ផ្តើមរត់គេចនៅពេលព្រឹកនៅពេលដែលទ្វារកាស៊ីណូបើក ហើយមានអ្នកគ្រប់គ្រងតែ៧ទៅ៨នាក់ប៉ុណ្ណោះដែលកំពុងបំពេញភារកិច្ច។

Diep បាននិយាយថា បន្ទាប់ពីធ្វើការបានមួយម៉ោងនៅម៉ោងប្រហែល ១០ ព្រឹក ពួកគេបានរត់ទៅកាន់ទ្វារ។ អ្នកមានកម្លាំងខ្លាំងនៅពីមុខដើម្បីវាយអ្នកយាម ដើម្បីអោយស្ត្រីៗរត់គេចខ្លួន។ យុវជនមួយក្រុមទៀតនៅខាងក្រោយ ដោយគប់ស្រាក្រឡុក Molotov ទៅកាន់អ្នកយាម។ ដំបូងឡើយ អ្នកយាមមានការភ្ញាក់ផ្អើល ប៉ុន្តែវាចំណាយពេលត្រឹមតែមួយនាទីសម្រាប់បុរសមាន "សាច់ដុំ" បង្ហាញខ្លួនជាមួយនឹងដំបងដែក ហើយដេញតាមជនជាតិវៀតណាម ដែល ព្យាយាមរត់គេចខ្លួន ។ ម្នាក់ក្នុងចំណោមពួកគេត្រូវបានគេចាប់បាន ខណៈអ្នកផ្សេងទៀតលោតចូលទឹកទន្លេ។ ពួកគេខ្លះមិនចេះហែលទឹកទេ តែនៅតែលោតចូល ហើយក៏ត្រូវបានអ្នកផ្សេងជួយអោយដល់ត្រើយម្ខាង។ ពួកគេបានទៅដល់ប៉ុស្តិ៍ការពារព្រំដែន Long Binh ដោយមិនមានរបួស ហើយត្រូវបានបញ្ជូនទៅផ្ទះសហគមន៍ដែលពួកគេបានទទួលការថែទាំ ហើយត្រូវបានប៉ូលិសសាកសួរ។ ក្រសួងការបរទេសវៀតណាមបានស្នើឱ្យអាជ្ញាធរកម្ពុជាជួយស៊ើបអង្កេតករណីនេះ។ Diep បាននិយាយអំពីរយៈពេល៤ខែរបស់នាងនៅកាស៊ីណូថា៖ «វាជានរក។ យើងត្រូវបានគេបោកបញ្ឆោត និងលក់ទៅប្រទេសកម្ពុជា»។

ស្ត្រីមកពីខេត្ត Cao Bang ភាគខាងជើងបាននិយាយថា គាត់និងប្តីបានទៅធ្វើការនៅរោងចក្រមួយនៅ Bac Ninh កាលពីបីឆ្នាំមុន ប៉ុន្តែប្រាក់ចំណូលមិនគ្រប់គ្រាន់ទេ ដូច្នេះហើយពួកគេសម្រេចចិត្តលាឈប់នៅខែមេសាដើម្បីស្វែងរកការងារផ្សេងទៀត។ ពួកគេបានស្វែងរកការផ្សាយពាណិជ្ជកម្មការងារនៅលើ Facebook ហើយបានរកឃើញការងារមួយដែលសន្យាថាអោយប្រាក់ខែ ២៥ លានដុង (១,០៧០ ដុល្លារ) ក្នុងមួយខែ។ "ឈ្មួញកណ្តាលបាននិយាយថាវាជាការងារធ្វើតាមកុំព្យូទ័រនៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់" ។ ប្តីប្រពន្ធមួយគូនេះត្រូវបានទាក់ទាញដោយប្រាក់ដែលច្រើនជាង៤ដងនៃការងារពីមុនរបស់ពួកគេហើយបានវេចខ្ចប់កាបូបរបស់ពួកគេ និងជិះឡានក្រុងតាមដែលមេខ្យល់ណែនាំ។

Diep បាននិយាយថា ពួកគេធ្វើដំណើររយៈពេលបីថ្ងៃ ហើយបានប្តូរឡានក្រុងចំនួន ៥ ដងមុនពេលពួកគេមកដល់ប្រទេសកម្ពុជា។ ថ្ងៃនៃការរងការគំរាមកំហែង និងការកេងប្រវ័ញ្ចរបស់ពួកគេបានចាប់ផ្តើមនៅពេលនោះ។ នៅក្នុងខែដំបូង Diep ត្រូវបានណែនាំឱ្យប្រើគណនីក្លែងក្លាយតាមអ៊ីនធឺណិតដើម្បីបញ្ឆោតមនុស្សឱ្យដាក់ប្រាក់ទៅក្នុងកម្មវិធីស្វែងរកដៃគូរ (dating game)។ នាងបាននិយាយថា នាងកំពុងបោកប្រាស់មនុស្ស ប៉ុន្តែ «បើខ្ញុំមិនធ្វើទេ ខ្ញុំនឹងត្រូវគេវាយ ជីវិតខ្ញុំនឹងប្រឈមនឹងគ្រោះថ្នាក់»។ នាងត្រូវបានគេតម្រូវឱ្យរកប្រាក់បាន ៣០០ លានដុងក្នុងមួយខែពីការបោកប្រាស់ ហើយបន្ទាប់ពីនាងមិនអាចសម្រេចបានតាមការកំណត់អស់រយៈពេលជាច្រើនខែនាងត្រូវបានគេព្រមានថានាងនឹងត្រូវបញ្ជូនទៅ "បន្ទប់អគ្គីសនី" ។ នោះបានបង្ខំនាងឱ្យធ្វើការ ១៤ ម៉ោងក្នុងមួយថ្ងៃ។ នាងបានស្នាក់ស្ទើរនៅពេល ដែលនាងបានឮអំពីផែនការរត់គេចខ្លួនចាប់តាំងពីអ្នកចាប់ខ្លួននាងបានសន្យាថានឹងដោះលែងនាងក្នុងរយៈពេល២ខែទៀត។

នាងបានគិតអំពីរឿងនេះមួយសន្ទុះ ហើនាងបានគិតថាថានាងទំនងជាត្រូវបានលក់ទៅឱ្យកាស៊ីណូមួយផ្សេងទៀត ឬអាចត្រូវគេសម្លាប់។ នាងបាននិយាយថា នាងនិងមនុស្សជាច្រើននាក់ទៀតបានសម្រេចរត់គេចខ្លួនដោយមានគំនិតមួយថា «យើងស្លាប់នៅផ្ទះប្រសើរជាង»។ ការកេងប្រវ័ញ្ចជំរុញឱ្យកម្មករវៀតណាមរត់ចេញពីកាស៊ី

ណូនរកនៅកម្ពុជា Pham Nguyen Anh Tuan អាយុ៣០ ឆ្នាំគឺជាអ្នកផ្តួចផ្តើមផែនការរត់គេចខ្លួន។ គាត់បាននិយាយថា គាត់បានទទួលយកការងារកាស៊ីណូដោយសង្ឃឹមថានឹងជម្រះបំណុលល្បែងរបស់គាត់។ «ប៉ុន្តែពួកគេមិនបាននិយាយថាការងារនេះនឹងនៅក្នុងប្រទេសកម្ពុជាទេ ពួកគេនិយាយថាវានៅក្នុងខេត្តតៃនិញ ជាប់ព្រំដែនកម្ពុជា]។ "ហើយខ្ញុំមិនបានគិតថានេះជាការងារបោកប្រាស់មនុស្សនោះទេ"។ Tuan មិនអាចរកប្រាក់គ្រប់គ្រាន់ពីការឆបោកក្នុងរយៈពេលប៉ុន្មានខែដំបូងឡើយ ដូច្នេះហើយត្រូវបានគេលក់ទៅឱ្យថៅកែផ្សេងៗគ្នា។ គាត់បានធ្វើការឱ្យថៅកែទី៣របស់គាត់អស់រយៈពេល ៤ ខែហើយអាចទទួលបានប្រាក់ខែប៉ុន្តែខឹងដែលជនជាតិវៀតណាមផ្សេងទៀតត្រូវបានគេកេងប្រវ័ញ្ចនិងសូម្បីតែធ្វើទារុណកម្ម។

ជនជាតិវៀតណាមម្នាក់បានធ្លាក់ខ្លួនឈឺ និងមិនអាចរកប្រាក់បានច្រើនសម្រាប់កាស៊ីណូ ដូច្នេះហើយថៅកែចិនគ្រោងនឹងលក់ពួកគេ។ Tuan បានសុំថៅកែឲ្យអ្នកនោះទៅផ្ទះវិញ ដោយសន្យាថាគាត់និងជនជាតិវៀតណាមម្នាក់ទៀតនឹងចេញថ្លៃដោះលែងគាត់។ ប៉ុន្តែ បុរសនោះបានបដិសេធសំណើរបស់គាត់ដោយនិយាយថាគាត់និងអ្នកផ្សេងទៀតគ្មានសិទ្ធិចរចានោះទេ។ គាត់តូចចិត្តហើយពិភាក្សាអំពីការរត់គេចជាមួយអ្នកដែលនៅសល់។ ខណៈអ្នកខ្លះយល់ព្រមរត់ អ្នកខ្លះទៀតថានឹងជួយ។ លោក Tuan បាននិយាយថា៖ «ក្រៅពីអ្នកដែលបានបាត់ខ្លួន និងម្នាក់ទៀតដែលត្រូវបានចាប់នោះ យើងមានការព្រួយបារម្ភខ្លាំងណាស់សម្រាប់អ្នកដែលបានជួយយើងអោយរត់រួច»។ ជនជាតិវៀតណាមជាច្រើនត្រូវបានបោកបញ្ឆោតឱ្យចូលមកប្រទេសកម្ពុជាដើម្បីធ្វើការនៅកាស៊ីណូ និងកន្លែងស្រដៀងគ្នាផ្សេងទៀតដែលពួកគេតែងតែត្រូវបានកេងប្រវ័ញ្ច។ បើពួកគេចង់ត្រឡប់ទៅប្រទេសវៀតណាមវិញ ពួកគេត្រូវបង់ប្រាក់ដល់កាស៊ីណូរហូតដល់ ៣ ម៉ឺនដុល្លារ។ ក្នុងឆមាសទី១នៃឆ្នាំនេះ អាជ្ញាធរវៀតណាម និងកម្ពុជាបានសហការគ្នាជួយសង្គ្រោះមនុស្សជាង ២៥០នាក់នោះ។ *VnExpress*

## ឥណ្ឌូណេស៊ីគ្រោងនឹងបញ្ជូនជនជាតិខ្លួន២០២នាក់ទៅប្រទេសវិញបន្ទាប់ពីពួកគេត្រូវបានជួយសង្គ្រោះពីកណ្តាប់ដៃអ្នកឆបោកតាមអ៊ីនធឺណិតនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 21, 2022

ប្រទេសឥណ្ឌូណេស៊ីគ្រោងនឹងបញ្ជូនជនជាតិរបស់ខ្លួនចំនួន ២០២ នាក់ទៅប្រទេសវិញ ដែលពួកគេត្រូវបានជួយសង្គ្រោះពីកន្លែងលេងល្បែងស៊ីសង និងបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេតជាច្រើនកន្លែងក្នុងប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ។

មន្ត្រីប៉ូលិសអន្តោប្រវេសន៍បានប្រាប់កាសែតខ្មែរថាមស៍ដោយសុំមិនបញ្ចេញឈ្មោះថា ឥណ្ឌូនេស៊ីនឹងបញ្ជូនពួកគេទាំង២០២នាក់ទៅវិញតាមយន្តហោះពិសេស នៅថ្ងៃចន្ទ ហើយបន្ទាប់មកជិះសាឡាង ទៅកាន់ទីក្រុងហ្សាការតា។ នៅទីក្រុងហ្សាការតា ប្រជាជនឥណ្ឌូនេស៊ីដែលបានបញ្ជូនទៅវិញត្រូវបានគេរំពឹងថានឹងត្រូវទទួលបានកម្មវិធីស្តារនីតិសម្បទាដែលត្រូវបានអនុវត្តដោយអង្គភាពពហុភ្នាក់ងារ មុនពេលត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញទៅកាន់តំបន់ផ្សេងៗនៃប្រទេសឥណ្ឌូនេស៊ី។

លោក យាង ភារម្យ អ្នកនាំពាក្យសាលាខេត្តព្រះសីហនុ បានថ្លែងថា អាជ្ញាធរបាននិងកំពុងបង្ក្រាបសកម្មភាពខុសច្បាប់ក្នុងខេត្ត។ លោក ភារម្យ បានថ្លែងថា៖ «យើងមិនធ្វើអោយខកចិត្តនោះទេ ហើយយើងនឹងបន្តស៊ើបអង្កេតករណីដើម្បីស្វែងរកជនល្មើសមកផ្តន្ទាទោសតាមច្បាប់»។ លោកបានគូសបញ្ជាក់ថា វិធានការណ៍ប្រុងប្រយ័ត្នរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត រួមមានការចុះល្បាតជាប្រចាំ និងកម្លាំងសន្តិសុខប្រចាំការនៅប៉ុស្តិ៍ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាព។ "យើងក៏មានខ្សែទូរស័ព្ទបន្ទាន់ជាភាសាខ្មែរ ចិន និងអង់គ្លេស សម្រាប់ឲ្យ

ទាក់ទងមកយើង ហើយយើងនឹងឆ្លើយតប។ យើងនឹងជួយ និងសង្គ្រោះជនរងគ្រោះរួមទាំងជនបរទេសគ្រប់ជាតិសាសន៍»។

រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី Retno Marsudi បានជួបជាមួយអគ្គស្នងការនគរបាលជាតិកម្ពុជា នេត សាវឿន នៅរាជធានីភ្នំពេញ នៅថ្ងៃទី២ ខែសីហា ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការជួញដូរមនុស្ស។ ជាការឆ្លើយតបទៅនឹងសំណើរបស់ Marsudi លោក សាវឿន បាននិយាយថា ប៉ូលីសកម្ពុជាបានសន្យាថានឹងសហការយ៉ាងពេញលេញជាមួយភ្នាក់ងារពាក់ព័ន្ធរបស់ប្រទេសឥណ្ឌូនេស៊ី។ ក្នុងជំនួបនោះ មន្ត្រីទាំងពីរក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ និងវិធានការទប់ស្កាត់ករណីបែបនេះមិនឱ្យកើតឡើងវិញ។ ពួកគេក៏បានឯកភាពថា ក្រុមបច្ចេកទេសនៃកងកម្លាំងនគរបាលនៃប្រទេសទាំងពីរនឹងបើកកិច្ចប្រជុំនាពេលឆាប់ៗនេះ ដើម្បីពិភាក្សាលើបញ្ហាជាច្រើន រួមទាំងកិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេតរួមគ្នា ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងប្រទេសទាំងពីរស្តីពីកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស។ កិច្ចប្រជុំនេះធ្វើឡើងបន្ទាប់ពីប៉ូលីសកម្ពុជាបានដោះលែងពលករឥណ្ឌូនេស៊ីចំនួន ៥៥ នាក់ ក្នុងចំណោម ៦២ នាក់ ដែលជាជនរងគ្រោះនៃការឆបោកការងារ ហើយត្រូវបានឃុំខ្លួននៅក្នុងប្រទេសកម្ពុជាកាលពីចុងខែកក្កដា។

## រដ្ឋាភិបាលជប៉ុនស៊ើបអង្កេតលើការរំលោភបំពានសិទ្ធិសិក្ខាកាមបរទេសមានផ្ទៃពោះ រួមទាំងជនជាតិខ្មែរផងដែរ

https://www.khmertimeskh.com/ August 21, 2022

រដ្ឋាភិបាលជប៉ុនកំពុងធ្វើការស្ទង់មតិ ដើម្បីកំណត់ថា តើសិក្ខាកាមបច្ចេកទេសជនជាតិបរទេសត្រូវបាននិយោជក ឬក្រុមអន្តរការីបង្ខំឱ្យចាកចេញពីប្រទេសដោយសារតែពួកគេមានផ្ទៃពោះ ឬសម្រាលកូន។ ការស្ទង់មតិធ្វើលើសិក្ខាកាមមកពីប្រទេសចំនួន៧ គឺកម្ពុជា ចិន ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ថៃ វៀតណាម និងហ្វីលីពីន។ ទីភ្នាក់ងារសេវាអន្តោប្រវេសន៍នៃប្រទេសជប៉ុន និងក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពកំពុងធ្វើការរួមគ្នាស្ទង់មតិលើកដំបូង ចំពេលមានការយកចិត្តទុកដាក់កើនឡើងលើករណីបៀតបៀន និងការរំលោភបំពានលើសិក្ខាកាមដែលកំពុងកើនឡើង។ ការស្ទង់មតិនេះមានគោលបំណងដើម្បីទទួលបានការឆ្លើយតបពីមនុស្សប្រហែល ៤៩០ នាក់លើកម្មវិធីកម្មសិក្សាបច្ចេកទេសដែលឧបត្ថម្ភដោយរដ្ឋាភិបាលដោយសួរអ្នកឆ្លើយតបថាតើពួកគេដឹងពីករណីដែលស្ត្រីត្រូវបានបញ្ជូនទៅប្រទេសកំណើតរបស់ពួកគេបន្ទាប់ពីមានផ្ទៃពោះឬមានកូន។

មានករណីបង្ខំឱ្យចុះហត្ថលេខាលើឯកសារយល់ព្រមចាកចេញ ប្រសិនបើពួកគេមានផ្ទៃពោះ និងបុគ្គលដែលបោះបង់ចោលទារកទើបនឹងកើតដោយសារខ្លាចការបណ្តេញចេញ និងបាត់បង់សិទ្ធិការងារក្នុងប្រទេសជប៉ុន។ ប្រទេសជប៉ុនបានបង្កើតកម្មវិធីនេះនៅឆ្នាំ១៩៩៣ ដោយសិក្ខាកាមត្រូវបានអនុញ្ញាតឱ្យធ្វើការរហូតដល់ ៥ ឆ្នាំនៅក្នុងក្រុមហ៊ុនជាមួយនឹងទិដ្ឋភាពនៃការប្រើប្រាស់ជំនាញដែលបានរៀននៅក្នុងប្រទេសជប៉ុន ដើម្បីរួមចំណែកដល់សេដ្ឋកិច្ចរបស់ប្រទេសកំណើតរបស់ពួកគេ។ គ្រោងការណ៍នេះត្រូវបានគេរិះគន់ថាជាការបិទបាំងដល់ក្រុមហ៊ុននានាក្នុងការនាំចូលកម្លាំងពលកម្មថោកពីទូទាំងអាស៊ី។ នៅចុងឆ្នាំ២០២១ មនុស្សប្រហែល ២៧៦,០០០ នាក់ត្រូវបានចូលរួមនៅក្នុងកម្មវិធីនេះ ភាគច្រើនមកពីប្រទេសវៀតណាម ចិន និងឥណ្ឌូនេស៊ី។ ច្បាប់របស់ប្រទេសជប៉ុនស្តីពីការងារដែលមានឱកាសស្មើគ្នាសម្រាប់បុរស និងស្ត្រី ដែលអនុវត្តចំពោះសិក្ខាកាមផងដែរនោះ ហាមប្រាមការប្រព្រឹត្តិមិនល្អដោយផ្អែកលើបុគ្គលដែលសម្រាលកូន ឬមានផ្ទៃពោះ។ ដោយផ្អែកលើលទ្ធផលនៃការស្ទង់មតិ រដ្ឋាភិបាលមានបំណងកែលម្អខ្លួនលើបញ្ហានេះ។

យោងតាមទិន្នន័យពីក្រសួងការងារ សិក្ខាកាមចំនួន ៦៣៧ នាក់ត្រូវបានបង្ខំឱ្យចាកចេញពីការងាររបស់ពួកគេដោយសារបញ្ហាទាក់ទងនឹងការមានផ្ទៃពោះនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ខែធ្នូ ឆ្នាំ២០២២។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតិគឺផ្អែកលើតែអ្នកដែលដឹងពីរបាយការណ៍ដោយក្រុមត្រួតពិនិត្យ និងប្រភពផ្សេងទៀត។ ដូច្នេះ អង្គការគ្រប់គ្រងដោយរដ្ឋាភិបាលសម្រាប់ការបណ្តុះបណ្តាលអ្នកហាត់ការបច្ចេកទេសដែលត្រួតពិនិត្យកម្មវិធីនេះកំពុងធ្វើការស្ទង់មតិដល់សិក្ខាកាមចាប់ពីខែសីហាដល់ខែតុលាឆ្នាំនេះក្នុងអំឡុងពេលត្រួតពិនិត្យជាទៀងទាត់នៃនិយោជករបស់ពួកគេ។ សំណួររួមមានថាតើអ្នកហាត់ការបច្ចេកទេសបានចុះហត្ថលេខាលើឯកសារដែលសន្យាថានឹងលាលែងពីតំណែងប្រសិនបើពួកគេមានផ្ទៃពោះ ហើយប្រសិនបើពួកគេដឹងពីសិក្ខាកាមណាម្នាក់ដែលត្រូវបានបណ្តេញចេញពីការងារដោយសារហេតុផលនោះ។ វាក៏សួរផងដែរថាតើពួកគេដឹងទេថា ពួកគេអាចឈប់សម្រាកនៅពេលមានផ្ទៃពោះ ហើយបន្តធ្វើការបន្ទាប់ពីសម្រាលកូន ហើយថាពួកគេមានសិទ្ធិទទួលបានការជួយឧបត្ថម្ភ។

បញ្ហាផ្សេងៗជាមួយកម្មវិធីបានលេចចេញតាំងពីវាត្រូវបានចាប់ផ្តើម សិក្ខាកាមខ្លះបានជំពាក់បំណុលគេច្រើនដើម្បីមកប្រទេសជប៉ុន ខណៈខ្លះទៀតតម្រូវឱ្យធ្វើការច្រើនម៉ោងខុសច្បាប់ ហើយខ្លះទៀតមិនបានទទួលប្រាក់ឈ្នួល។ លោក Yoshihisa Furukawa អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បាននិយាយថា ចំពេលមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើការរំលោភបំពាននៅក្នុងប្រព័ន្ធអ្នកហាត់ការបច្ចេកទេស លោក Yoshihisa Furukawa រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មុនបាននិយាយថានៅក្នុងខែកក្កដា រដ្ឋាភិបាលនឹងចាប់ផ្តើមការពិនិត្យឡើងវិញពេញលេញនៃកម្មវិធី បន្ថែមពីលើការស្ទង់មតិ។ *Kyodo News*

## ប៉ូលិសឥណ្ឌូណេស៊ីឆ្មក់ចូលទីស្នាក់ការល្បែងស៊ីសងតាមអ៊ីនធឺណិតដែលមានបណ្តាញនៅកម្ពុជានៅកោះជ្វាកណ្តាល ដោយចាប់ខ្លួនជនសង្ស័យបាន ៦ នាក់

https://www.khmertimeskh.com/ August 21, 2022

អគ្គនាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្ម នៃប៉ូលីសនៅកោះជ្វាកណ្តាល ( Central Java) បានឆ្មក់ចូលទីស្នាក់ការកណ្តាលលេងល្បែងតាមអ៊ីនធឺណិតនៅស្រុក Bojongsari រដ្ឋ Purbalingga Regency ។ មនុស្ស៦នាក់ជាជនសង្ស័យត្រូវបានចាប់ខ្លួនដែលជាលទ្ធផលនៃការឆ្មក់ចូលនេះ។

លោក Kombes Juhandani Rahardjo Puro នៅ Purba lingga បាននិយាយកាលពីម្សិលមិញថា ប្រធាននាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្មបាននិយាយថា "យប់ថ្ងៃសុក្រវេលាម៉ោង ៩ យើងបានបើកកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ ដែលក្នុងនោះបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា៣០៣ នៃក្រមព្រហ្មទណ្ឌសម្រាប់ល្បែងស៊ីសងត្រូវបានប្រព្រឹត្តដោយប្រើមធ្យោបាយតាមអ៊ីនធឺណិត។ យោងតាមលោក ទីស្នាក់ការល្បែងអនឡាញដែលត្រូវបានគេវាយឆ្មក់គឺជាបណ្តាញបរទេស។ លោកថាពួកគេកំពុងស៊ើបអង្កេតលើបញ្ហានេះបន្តទៀត។ លោកបានបន្តថា "បណ្តាញនេះ គឺនៅក្រៅប្រទេស បើតាមព័ត៌មានរបស់ជនល្មើស ដែលយើងបានស៊ើបអង្កេតនោះ បណ្តាញនេះគឺនៅក្នុងប្រទេសកម្ពុជា។ ជាការពិតណាស់ថាតើយើងនឹងបញ្ជាក់ដល់កម្រិតណា ហើយយើងនឹងបន្តបង្កើតវិសាលភាពនៃការអភិវឌ្ឍនៃករណីនេះ»។ Juhandani បាននិយាយថាជនសង្ស័យបានសារភាពថាគាត់ទើបតែចាប់ផ្តើមហាត់នៅ Purbalingga ។ ប៉ុន្តែជាមួយនឹងលទ្ធផលនៃការស៊ើបអង្កេតរបស់គាត់ និន្នាការនៃការលេងល្បែងតាមអនឡាញបាននិងកំពុងបន្តជាយូរមកហើយ។ លោកបានពន្យល់ថា "បច្ចុប្បន្ននេះ ជនសង្ស័យបាននិយាយថា វាទើបតែចាប់ផ្តើមទេ ពិតណាស់យើងជាអ្នកស៊ើបអង្កេតនឹងស៊ើបអង្កេតបន្ថែមទៀត ព្រោះប្រសិនបើយើងតាមដានលទ្ធផលនៃការល្បោតដែលយើងធ្វើដោយសហការជាមួយនាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្ម មិនមែនតែពេលយើងចាប់ខ្លួននោះទេ"។

នៅពេលសួរអំពីអាជីវកម្មនៃការប្រព្រឹត្តល្បែងស៊ីសងតាមអ៊ីនធឺណិតនៅតំបន់នោះ ភាគីលោកមិនអាចបញ្ជាក់បានទេ។ ទោះយ៉ាងណាក៏ដោយ វាត្រូវបានគេប៉ាន់ប្រមាណថា ប្រាក់ចំណូលប្រចាំថ្ងៃពីកន្លែងនេះបានរហូតដល់រាប់លានរូពី (crores of rupees) ។ លោកបានបន្តថា៖ «តាមលទ្ធផលទំហំទឹកប្រាក់ យើងមិនអាចនិយាយបានច្បាស់ទេ។ ដោយសារតែថ្ងៃនេះ ជាថ្ងៃឈប់សម្រាក យើងមិនទាន់អាចសម្របសម្រួលជាមួយធនាគារបានទេ ប៉ុន្តែអាចថាចំណូលពីកន្លែងនេះអាចឡើងដល់ ១០លាន ទៅដល់៣០លានក្នុងមួយថ្ងៃ»។ បើតាមលោក ក្នុងចំណោមជនសង្ស័យទាំង៦នាក់នោះ មានអ្នកដើរតួជាអ្នកគ្រប់គ្រង អ្នកទទួលប្រាក់បញ្ញើ ទីផ្សារ ទីតាំង និងអ្នកផ្តល់ដើមទុន។ ស្ថាប័នរបស់លោកបានផ្តល់ព័ត៌មានលម្អិតអំពីតួនាទីរបស់ជនសង្ស័យទាំង៦នាក់ ដែលត្រូវបានចាប់ខ្លួន។ "គួរឱ្យសង្ស័យគឺ MAM (29) ជាអ្នកដឹកនាំគ្រប់គ្រងសកម្មភាពល្បែងស៊ីសង CSG (27) ដាក់ប្រាក់ និងដកប្រាក់ភ្នាល់ AW (21) ទីផ្សារ ឬស្វែងរកអតិថិជន KAW (29) DSA (28) MAA (43)។ នេះត្រូវបានគេជឿថាជាលើកទីមួយដែលប៉ូលិសឥណ្ឌូណេស៊ីបានរកឃើញក្រុមល្បែងស៊ីសងតាមអ៊ីនធឺណិតជាមួយបណ្តាញ ដែលមានទីតាំងនៅកម្ពុជា។ Nationworldnews.com

## ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

## លោក គួច ចំរើន ប្រាប់អ្នកជំនាញសិទ្ធិមនុស្សUNថា បញ្ហាជួញដូរមនុស្សក្នុងខេត្តព្រះសីហនុមិនអាក្រក់ដូចការចោទឡើយ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 21/08/2022 - 08:30 ដោយ៖អោ ស្រីពេជ្រ

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្សប្រចាំកម្ពុជា លោក វិទិត មុនតាបន នៅថ្ងៃសុក្រថ្មីៗនេះ បានធ្វើដំណើរទៅដល់ខេត្តព្រះសីហនុ ដើម្បីសិក្សាបន្ថែមពីបញ្ហាដ៏ចម្រូងចម្រាសមួយចំនួន ជុំវិញការជួញដូរមនុស្សនិងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត។ ទឹកដីខេត្តព្រះសីហនុ បច្ចុប្បន្នដែលសម្បូរហូរហៀរទៅដោយជនជាតិបរទេស ត្រូវបានចុះផ្សាយព្រោងព្រាតថា មានឧក្រិដ្ឋកម្មប៉ះពាល់ដល់សិទ្ធិមនុស្សយ៉ាងច្រើន តែអភិបាលខេត្តព្រះសីហនុ លោក គួច ចំរើន អះអាងថា វាមិនដូចការចោទប្រកាន់នោះឡើយ ដោយស្នើឱ្យលោក វិទិត មុនតាបន ធ្វើរបាយការណ៍ឱ្យត្រឹមត្រូវនិងច្បាស់លាស់។

ជាជំនួបលើកទីមួយរបស់ លោក វិទិត មុនតាបន ជាមួយ លោកគួច ចំរើន ក្នុងការស្វែងយល់អំពីកង្វល់ និងបញ្ហាប្រឈមនានាជុំវិញស្ថានភាពសិទ្ធិមនុស្ស ការបង្ខិតបង្ខំឱ្យប្រព្រឹត្តបទល្មើស ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត ការបោកប្រាស់តាមប្រព័ន្ធអនឡាញ និងស្ថានភាពជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះនៅក្នុងខេត្តព្រះសីហនុ។ ក្នុងជំនួបនៅថ្ងៃសុក្រទី១៩សីហាជាមួយ លោក វិទិត មុនតាបន អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សប្រចាំកម្ពុជានេះ លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានថ្លែងការពារនូវអ្វីដែលចោទប្រកាន់ថា ខេត្តព្រះសីហនុ ជាទឹកដីដែលមានបរិយាសកាសអំណោយផលដល់ជនទុច្ចរិតបរទេសប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយសំអាងតែទៅលើការចុះផ្សាយដោយគ្មានការពិត។ ការចុះផ្សាយគ្មានការពិត ដោយផ្អែកតែលើការលើកឡើងរបស់អ្នកដែលតាំងខ្លួនជារងគ្រោះក្នុងករណីចាប់បង្ខាំង ដើម្បីប្តូរកន្លែងធ្វើការ និងហើយករណីខ្លះទៀត គឺដើមបណ្តឹងជាអ្នកផ្សេង ហើយក៏មិនមានករណីចាប់បង្ខាំងឡើយ គឺពួកគេស្ម័គ្រចិត្តធ្វើការងារជាធម្មតា។ ហើយអភិបាលខេត្តព្រះសីហនុ បានស្នើឱ្យលោក វិទិត មុនតាបន ធ្វើរបាយការណ៍ការងារនៅចុងឆ្នាំរបស់ខ្លួន ឱ្យត្រឹមត្រូវនិងច្បាស់លាស់។ លោកអភិបាលខេត្តព្រះសីហនុ បានប្រាប់បន្ថែមទៀតថា កន្លងមកកម្ពុជានិងថៃមានលំហូរពលករខុសច្បាប់ទៅវិញទៅមក ហើយមានពលករខ្មែរទៅធ្វើការប្រទេសថៃ និងក៏មានពលករថៃមកធ្វើការនៅ

ប្រទេសកម្ពុជា ពិសេសក្នុងខេត្តព្រះសីហនុតាមរយៈការអូសទាញដោយខុសច្បាប់។ តែយ៉ាងណាមិញ ការចុះប្រតិបត្តិការបង្ក្រាបរបស់សមត្ថកិច្ចមិនដែលបន្ធូរដៃឡើយ។

នាយកកិច្ចការទូទៅនៃអង្គការលីកាដូ លោក សំ សំអាត នៅថ្ងៃទី២១សីហានេះ ប្រាប់ពីកង្វល់ថា បញ្ហាជួញដូរមនុស្សនៅកម្ពុជា កាន់តែអាក្រក់ទៅៗ ដែលពុំមែនមានតែនៅក្នុងខេត្តព្រះសីហនុមួយទេ តែវាមានកើតមាននៅក្នុងខេត្តជាប់ព្រំដែនដូចជា កោះកុង កណ្ដាល និងពោធិ៍សាត់ជាដើម។ បញ្ហានេះ លោកថា ទាមទារអោយសមត្ថកិច្ចកម្ពុជាចុះប្រតិបត្តិបង្ក្រាបដោយឆន្ទៈខ្ពស់ និងបន្ថែមកិច្ចសហការជាមួយបរទេសឱ្យកាន់តែមានប្រសិទ្ធិភាព។

ទាក់ទិនករណីបង្ខាំង អំពើឆបោក និងការជួញដូរមនុស្សនៅកម្ពុជានេះ ក្រសួងការបរទេសអាមេរិកកាលពីខែកក្កដា បានចេញរបាយការណ៍មួយដាក់កម្ពុជាក្នុងបញ្ជីខ្មៅ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំកែលម្អ ហើយមិនបានបំពេញតាមបទដ្ឋានអប្បបរមា ដូចដែលបានកំណត់នោះទេ។ តែពីខាងកម្ពុជាវិញ តួលេខចុងក្រោយរបស់ក្រសួងមហាផ្ទៃបង្ហាញថា ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០២២នេះ សមត្ថកិច្ចជំនាញបង្ក្រាបល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៧៤ករណី ថយចុះ១២៤ករណី។ ជាតួលេខថយចុះ១០០ករណី បើធៀបរយៈពេលដូចគ្នាកាលពីឆ្នាំ២០២១៕

## កម្ពុជា កំពុងព្យាយាមជួយជនរងគ្រោះបរទេស ដែលចាញ់បោក ពីការជួញដូរមនុស្សដោយបង្ខំ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២២ សីហា ២០២២ដោយ sopheak khoun

ប្រទេសកម្ពុជា កំពុងព្យាយាមជួយជនរងគ្រោះបរទេស ដែលចាញ់បោកពីការជួញដូរមនុស្សដោយបង្ខំ ដែលឲ្យពួកគេធ្វើការឆបោកតាមរយៈការហៅទូរស័ព្ទ ឬ (Call Center)។ នេះបើតាមការអះអាងរបស់អាជ្ញាធរកម្ពុជា ហើយត្រូវបានផ្សព្វផ្សាយដោយសារព័ត៌មាន VOA Thai កាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០២២កន្លងទៅនេះ។ អាជ្ញាធរតៃវ៉ាន់ កាលពីពេលកន្លងទៅនេះ ធ្លាប់បានអំពាវនាវឲ្យដោះលែងពលរដ្ឋរបស់ខ្លួនជាង ៣០០នាក់ ដោយតៃវ៉ាន់បាននិយាយថា ជនរងគ្រោះទាំងនោះ ត្រូវបានគេបោកប្រាស់ដោយឧក្រិដ្ឋកម្មឆ្លងដែន។ នេះបើយោងតាមការផ្សព្វផ្សាយ របស់សារព័ត៌មានខាងលើដដែលនេះ។

ទីភ្នាក់ងារសារព័ត៌មាន AP បានរាយការណ៍កាលពីសប្តាហ៍មុនថា អ្នកដែលចាញ់បោកគេទាំងនោះ ភាគច្រើន គឺសុទ្ធតែជាអ្នកដែលទទួលបានការអប់រំល្អ និងមានចំណេះដឹងខ្ពង់ខ្ពស់ ហើយជឿជាក់ថា ការងារដែលពួកគេមកធ្វើនៅកម្ពុជា នឹងបានទទួលកម្រៃខ្ពស់ក្នុងឧស្សាហកម្មបច្ចេកវិទ្យា។ ប៉ុន្តែជាក់ស្តែង ពួកគេត្រូវបានគេឲ្យមកធ្វើការនៅកន្លែងហៅទូរស័ព្ទ (Call Center) ដើម្បីបោកប្រាស់ជនរងគ្រោះ ដែលភាគច្រើនជាជនជាតិចិនដីគោក ដើម្បីឲ្យពួកគេផ្ទេរប្រាក់សម្រាប់វិនិយោគ។ ប្រភពដដែលបន្តថា បន្ទាប់ពីសមត្ថកិច្ចបានចុះទៅកាន់ខេត្តព្រះសីហនុ និងខេត្តកណ្តាល កាលពីពេលថ្មីៗនេះ ដើម្បីធ្វើការស៊ើបអង្កេតទីតាំងដែលត្រូវសង្ស័យ ដែលក្នុងនោះ សមត្ថកិច្ចអាចចាប់ខ្លួនជនសង្ស័យបានមួយចំនួន លើការចោទប្រកាន់ពីបទជួញដូរមនុស្ស។

នេះបើតាមការស្រង់ប្រសាសន៍របស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ សម្តេច ស ខេង បានថ្លែងបន្តថា សមត្ថកិច្ចកម្ពុជា កំពុងព្យាយាមស៊ើបអង្កេតបន្តថា តើការអះអាងរបស់អ្នកដែលថា ខ្លួនជនរងគ្រោះនោះ តើជាការពិតដែរឬយ៉ាង៕ អត្ថបទ៖ គង់ សំអាន

# ប៉ូលីសហុងកុងចាប់ខ្លួនមនុស្ស៥នាក់ ពីបទឆបោកការងារជួញដូរមនុស្ស

https://www.khmertimeskh.com/ Khmer Times August 22, 2022

ប៉ូលីសហុងកុងបានចាប់ខ្លួនមនុស្ស ៥ នាក់ដែលជាអ្នកល្បួងជនជាតិហុងកុងអោយធ្វើការងារខុសច្បាប់ដែលជនរងគ្រោះត្រូវបានឃុំខ្លួនដោយអ្នកជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍។ គិតត្រឹមថ្ងៃម្សិលមិញ ជនរងគ្រោះចំនួន ៣៦នាក់បានស្វែងរកជំនួយពីប៉ូលីស ក្នុងនោះមានបុរស ៣២ នាក់ និងស្ត្រី ៤ នាក់ដែលមានអាយុចន្លោះពី ១៩ ទៅ ៥៧ ឆ្នាំ។ ហើយ២២នាក់ត្រូវបានគេជឿថានៅតែត្រូវបានឃុំខ្លួនដោយក្រុមជួញដូរនៅក្នុងប្រទេសកម្ពុជា និងមីយ៉ាន់ម៉ា ខណៈមនុស្ស៩នាក់នៅបន្តបាត់ខ្លួន។ មានតែករណី១ក្នុងចំណោម ៣៦ ករណីប៉ុណ្ណោះដែលទាក់ទងនឹងការឆបោកស្នេហាតាមអ៊ីនធឺណិត។ អ្នកផ្សេងទៀតសុទ្ធតែជាអ្នកចាញ់បោកដោយសន្យាអោយការងារធ្វើ។ ៣ថ្ងៃបន្ទាប់ពីក្រុមការងារពិសេសមួយត្រូវបានបង្កើតឡើងកាលពីថ្ងៃសុក្រ ប៉ូលិសបាននិយាយកាលពីម្សិលមិញថា បុរស៣នាក់និងស្ត្រី២នាក់ត្រូវបានចាប់ខ្លួនពីបទសមគំនិតក្លែងបន្លំ។

លោក Tony Ho Chun-tung អគ្គនាយកជាន់ខ្ពស់នៃការិយាល័យឧក្រិដ្ឋកម្មរៀបចំ និង Triad Bureau បាននិយាយថា "ជនសង្ស័យចំនួន ៥ នាក់មានអាយុចន្លោះពី ១៧ ទៅ៥១ ឆ្នាំ ជាមួយនឹងបុរសពីរនាក់ដែលត្រូវបានគេជឿថាជាសមាជិកសំខាន់ដើម្បីជំរុញជនសង្ស័យផ្សេងទៀតឱ្យគ្រប់គ្រងជនរងគ្រោះ" ។ "ហើយស្ត្រីម្នាក់ត្រូវបានគេបញ្ជាក់ថាបានបង្ហោះការផ្សាយពាណិជ្ជកម្មការងារក្លែងក្លាយតាមអ៊ីនធឺណិត។""សមាជិកសំខាន់ៗ" គឺជានិស្សិតផ្នែកថែទាំសុខភាពអាយុ២៣ ឆ្នាំឈ្មោះ Cheung និងបុរសគ្មានការងារធ្វើអាយុ ៣០ ឆ្នាំឈ្មោះ Ma ។ ស្ត្រីអាយុ ២៧ ឆ្នាំដែលមានឈ្មោះថា Shum ត្រូវបានគេរកឃើញថាបានបង្ហោះការផ្សាយពាណិជ្ជកម្មក្លែងក្លាយនៅលើ Facebook ដែលមានគណនីឈ្មោះ CiCi ។ ម្នាក់ក្នុងចំណោមអ្នកដែលត្រូវចាប់ខ្លួននោះឈ្មោះ Wu អាយុ ១៧ ឆ្នាំ ដែលអះអាងថាជាជាងកាត់សក់ ត្រូវបានបញ្ជូនទៅកន្លែងអប់រំកុមារ និងអនីតិជន Tuen Mun កាលពីរសៀលម្សិលមិញ។

ជនរងគ្រោះភាគច្រើនត្រូវបានឃុំខ្លួន និងបាត់បង់សេរីភាព ហើយពីរបីនាក់ទៀតត្រូវបានវាយដំដោយអ្នកជួញដូរ។ លោក Ho បាននិយាយថា ជនរងគ្រោះភាគច្រើនត្រូវបានល្បួងឱ្យទៅធ្វើការនៅកាស៊ីណូ ឬការដ្ឋានសំណង់នៅអាស៊ីអាគ្នេយ៍។ ពួកគេត្រូវបានទទួលរងនូវការធ្វើបាប ប្រសិនបើពួកគេបដិសេធមិនធ្វើការ ឬបរាជ័យក្នុងការបំពេញតួនាទី។ លោកបានបន្តថា ជនរងគ្រោះខ្លះបានរត់គេចខ្លួន ដោយមានជំនួយពីស្ថានទូតចិនក្នុងប្រទេសមីយ៉ាន់ម៉ា និងកម្ពុជា ខណៈខ្លះទៀតត្រូវបានដោះលែងវិញបន្ទាប់ពីបានបង់ថ្លៃលោះខ្លួន។ Ho បាននិយាយថាមានការលំបាកសម្រាប់ប៉ូលីសក្នុងការប្រមូលភស្តុតាងនៅបរទេស ខណៈពេលដែលជំរុញប្រជាជនឱ្យប្រុងប្រយ័ត្នចំពោះ "ឱកាសការងារដែលមិនប្រាកដប្រជា"។ ក្រៅពីការបង្ហោះការផ្សាយពាណិជ្ជកម្មប្រឆាំងការឆបោកនៅលើ Facebook ប៉ូលិសក៏បានចេញផ្សាយពាណិជ្ជកម្មអេក្រង់ LED ដ៏ធំនៅតាមផ្លូវដ៏មមាញឹកក្នុងទីក្រុង Mong Kok និងសាលចេញដំណើរនៅព្រលានយន្តហោះ។ មន្ត្រីក៏បាននិងកំពុងចែកខិតប័ណ្ណនៅព្រលានយន្តហោះ ដើម្បីក្រើនរំឭកប្រជាជនហុងកុងកុំឲ្យធ្លាក់ក្នុងអន្ទាក់ការជួញដូរមនុស្ស។

នាយកដ្ឋានអន្តោប្រវេសន៍កាលពីថ្ងៃសៅរ៍បានបង្កើតបណ្តាញទូរស័ព្ទបន្ទាន់ WhatsApp ថ្មី – 5190-8909 – សម្រាប់ករណីទាក់ទងនឹងការបោកប្រាស់ការងារនៅអាស៊ីអាគ្នេយ៍។ លេខាធិការសន្តិសុខ Chris Tang Ping-keung កាលពីម្សិលមិញបានអំពាវនាវដល់ប្រជាជនកុំឱ្យទូរស័ព្ទមកបណ្តាញទាន់ហេតុការណ៍ព្រោះនេះបណ្តាញនេះសម្រាប់ទទួលតែព័ត៌មានពាក់ព័ន្ធនឹងការប្រាស់ការងារតាមអ៊ីនធឺណែត ដោយកន្លងមានតែការហៅទូរស័ព្ទចំនួន ៤ ប៉ុណ្ណោះក្នុងចំណោម ៨៤ សារ និង ៥២សារដែលខ្សែទូរស័ព្ទទាន់ហេតុការណ៍បានទទួលគឺពាក់ព័ន្ធនឹងការបោកប្រាស់ការងារ។ ប្រសិនបើមានអ្នកកំពុងស្នើសុំសេវាកម្មពីនាយកដ្ឋានអន្តោប្រវេសន៍ គាត់បាននិយាយថា

"ពួកគេអាចប្រើលេខទូរស័ព្ទសង្គ្រោះបន្ទាន់ផ្សេងទៀត ដូច្នេះយើងអាចផ្តោតលើការហៅតាម WhatsApp ទាំងនោះដែលទាក់ទងនឹងការបោកប្រាស់ការងារ"។

គ្រួសារជនរងគ្រោះបានប្រាប់សម្ព័ន្ធប្រជាធិបតេយ្យដើម្បីភាពប្រសើរឡើង និងវឌ្ឍនភាពនៃទីក្រុងហុងកុងថា សាច់ញាតិវ័យកណ្តាលម្នាក់ត្រូវបានបោកប្រាស់ដោយការផ្សាយពាណិជ្ជកម្មជ្រើសរើសបុគ្គលិកតាមអ៊ីនធឺណិត ហើយត្រូវបានបញ្ជូនទៅ "KK Park" កាលពីមួយខែមុន។ "KK Park" គឺជាចំណុចក្តៅនៃការជួញដូរមនុស្សនៅក្នុងរដ្ឋKayinរបស់ប្រទេសមីយ៉ាន់ម៉ាហើយត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធក្នុងការលក់សរីរាង្គ និងជួញដូរផ្លូវភេទ។ បុរសនោះអាចទាក់ទងក្រុមគ្រួសាររបស់គាត់ជារៀងរាល់ថ្ងៃ ប៉ុន្តែកំពុងត្រូវបានតាមដាន ហើយគាត់បានឃើញជនជាតិហុងកុងផ្សេងទៀតនៅក្នុង KK Park រួមទាំងមិត្តរួមវិទ្យាល័យរបស់គាត់ម្នាក់ផងដែរ។ លោក Wu Cheuk-him មកពីសាខា Tai Po របស់ DAB ដែលបានទទួលសំណើសុំជំនួយបាននិយាយថា "គាត់ត្រូវបានគេបង្ខំឱ្យធ្វើការលើសពី ១០ម៉ោងក្នុងមួយថ្ងៃ" ។ "ប្រសិនបើគាត់ធ្វើមិនបានល្អ គាត់នឹងមិនត្រូវបានផ្តល់អាហារគ្រប់គ្រាន់ទេ"។

សមាជិកសភា Gary Chan Hak-kan នៃ DAB បានដកស្រង់សម្តីសមាជិកគ្រួសារជនរងគ្រោះថា បុរសនោះបានទៅប្រទេសថៃ បន្ទាប់ពីបានឃើញការផ្សាយពាណិជ្ជកម្មការងារនៅលើ Facebook ។ គាត់បានជួបអ្នកបោកប្រាស់ម្នាក់ទល់មុខគ្នា ដើម្បីមកយកសំបុត្រយន្តហោះ និងព័ត៌មានលម្អិតអំពីកន្លែងស្នាក់នៅ។ ប៉ុន្តែពេលទៅដល់ប្រទេសថៃ គាត់ត្រូវបានគេបង្ខំអោយឡើងឡាន ហើយបញ្ជូនទៅ KK Park។ DAB បានជំរុញឱ្យអាជ្ញាធរ SAR ធ្វើការជាមួយការិយាល័យស្នងការនៃក្រសួងការបរទេសចិននៅហុងកុងក្នុងការជួយសង្គ្រោះជនរងគ្រោះ និងឱ្យប៉ូលីសតាមដានព័ត៌មានហោះហើរ និងប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងការចាប់ខ្លួនអ្នកជួញដូរផ្សេងទៀត។

ស្ថានទូតចិនប្រចាំកម្ពុជាបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយកាលពីចុងសប្តាហ៍ថា ខ្លួននឹងផ្តល់សេវាទាន់ពេលវេលា និងមានប្រសិទ្ធភាពដល់ពលរដ្ឋចិនទាំងអស់នៅក្នុងប្រទេសកម្ពុជា រួមទាំងជនរួមជាតិតៃប៉ិ ស្របតាមច្បាប់ និងបទប្បញ្ញត្តិ៕ *The Standard.com*

## សមត្ថកិច្ចកម្ពុជា-វៀតណាមកំពុងស្រាវជ្រាវករណីបុគ្គលិករត់ចេញពីកាស៊ីណូនៅឃុំជ្រៃធំ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 22 August 2022 | 10:01 ICT

**កណ្តាលៈ** សមត្ថកិច្ចជំនាញពាក់ព័ន្ធកម្ពុជាកំពុងសហការជាមួយសមត្ថកិច្ចវៀតណាម ដើម្បីធ្វើការស្រាវជ្រាវបន្ថែមលើករណីបុគ្គលិកជនជាតិវៀតណាមជាង ៤០ នាក់ បានបុកទម្លុះទ្វាររត់ចេញពីអគារកាស៊ីណូមួយនៅឃុំជ្រៃធំ ស្រុកកោះធំ ជាប់ព្រំប្រទល់វៀតណាមកាលពីថ្ងៃទី ១៨ សីហា ខណៈសមត្ថកិច្ចបានឃាត់មេការកាស៊ីណូ និងអ្នកពាក់ព័ន្ធសាកសួរ។ ចំណាត់ការនេះធ្វើឡើង បន្ទាប់ពីមានបុគ្គលិកជនជាតិវៀតណាមប្រុស-ស្រីជាង ៤០ នាក់បានទម្លុះទ្វារចេញពីកាស៊ីណូឈ្មោះ Golden Phonix Entertainment ស្ថិតក្នុងស្រុកកោះធំ ខេត្តកណ្តាល ជាប់ព្រំដែនវៀតណាមកាលពីថ្ងៃទី ១៨ ខែសីហា។

អភិបាលខេត្តកណ្តាលលោក គង់ សោភ័ណ្ឌ ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ២១ សីហាថា បាតុភាពបណ្តាលឱ្យបុគ្គលិកសម្រុករត់ចេញនោះ ដោយសារមានវិវាទការងារកើតឡើងរវាងថៅកែ និងបុគ្គលិកនិយាយមិនត្រូវគ្នា។ យ៉ាងនេះក្តី លោកថា សមត្ថកិច្ចកំពុងស្រាវជ្រាវបន្ថែមទៀតពាក់ព័ន្ធច្បាប់ការងារ ក៏ដូចជាលិខិតឆ្លងដែនចំពោះអ្នករត់គេចនោះ ថា តើជនអន្តោប្រវេសន៍ទាំងនោះមកធ្វើការដោយស្របច្បាប់ឬយ៉ាងណា? លោកថា៖ «យើងជំនាញខាងខេត្ត ក្រសួងមហាផ្ទៃ ក៏ដូចជាអគ្គនាយកដ្ឋានអន្តោប្រវេសន៍កំពុងស្រាវជ្រាវបន្តទៀត តែលទ្ធផលបែបណានោះមិនទាន់បានលើកឡើងទេ ដោយសាររឿងនេះត្រូវមើលឱ្យសព្វគ្រប់ជ្រុងជ្រោយ ថាតើវិវាទកើតចេញមកពីអ្វី យើងត្រូវមើលច្បាប់ការងារ លិខិតឆ្លងដែន ថាគាត់ជនអន្តោប្រវេសន៍ស្របច្បាប់ដែរអត់?»។ លោកថា ក្នុងហេតុការណ៍

នេះ សមត្ថកិច្ចបានឃាត់ខ្លួនមេការ និងកំពុងសហការជាមួយអាជ្ញាធរវៀតណាមផងដែរ បន្ទាប់ពីបុគ្គលិកទាំងនោះមួយចំនួនបានហែលទឹកឆ្លងដែនចូលដីវៀតណាមដែលជាប់ព្រំប្រទល់កម្ពុជា។

លោកថា៖ «ព្រោះមានមនុស្សហែលទឹកចូលទៅប្រទេសវៀតណាមតាមស្ទឹងជ្រៃធំ ស្ទឹងនេះមានទទឹងប្រហែលជាង ៤០ ម៉ែត្រ អ៊ីចឹងហែលបន្តិចទៅចូលដល់ដីវៀតណាម។ អ៊ីចឹងយើងកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរវៀតណាម ដើម្បីឃាត់ពួកគាត់សួរនាំពីដំណើរដើមទង ប៉ុន្តែវាអត់មានជាបទល្មើសធំធេង គ្រាន់តែជាវិវាទមួយដែលត្រូវការដោះស្រាយរកយុត្តិធម៌ជូនជនរងគ្រោះ»។ លោក គង់ សោភ័ណ្ឌ ឱ្យដឹងដែរថា ក្នុងហេតុការណ៍នោះក៏បង្កឱ្យសន្តិសុខក្រុមហ៊ុន ២ នាក់របួសស្នាមដែរ បន្ទាប់ពីពួកគេព្យាយាមឃាត់បុគ្គលិកដែលសម្រុករត់ចេញ ប៉ុន្តែត្រូវបានបុគ្គលិកនោះយកកាំបិត និងដែកវាយទៅលើសន្តិសុខបង្កឱ្យមានរបួសជើង។

ពាក់ព័ន្ធករណីនេះដែរ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោក ស ខេង បានថ្លែងថា ក្នុងហេតុការណ៍នោះសមត្ថកិច្ចបានឃាត់ខ្លួនអ្នកពាក់ព័ន្ធមេការ និងជនរងគ្រោះមួយចំនួន ដើម្បីសួរនាំបន្តនីតិវិធី។ លោកបន្តថា៖ «ខ្ញុំមិនទាន់មានព័ត៌មានជាក់លាក់ទេ ប៉ុន្តែព័ត៌មានជាបឋមមកថា បុគ្គលិកទាំងនោះប្រហែលមកធ្វើការខុសច្បាប់ ហើយមានការសន្យាផ្តល់ប្រាក់ខែ ប៉ុន្តែការងារនោះមិនដូចទៅតាមអ្វីដែលគេបានសន្យា»។ លោក ស ខេង បានថ្លែងបែបនេះប្រាប់អ្នកសារព័ត៌មាន បន្ទាប់ពីបញ្ចប់កិច្ចប្រជុំថ្នាក់ដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័នចំនួន ៦ និងក្រសួង ស្ថាប័នជាសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី ១ ឆ្នាំ ២០២២ កាលព្រឹកថ្ងៃទី ១៩ សីហា។ លោកថ្លែងថា៖ «តាមខ្ញុំដឹងជនជាតិវៀតណាមនៅជិតព្រំដែន អ៊ីចឹងគាត់រត់ចេញឆ្លងទៅវៀតណាមហើយនៅមានសេសសល់ជនរងគ្រោះខ្លះដែលទៅវៀតណាមអត់ទាន់រួច។ បុគ្គលិកទាំងនោះមានទាំងស្របច្បាប់ និងខុសច្បាប់ ប៉ុន្តែមួយចំនួនធំចូលមកស្របច្បាប់ ប៉ុន្តែយើងត្រូវពិនិត្យទៀតថាមានបណ្ណការងារឬអត់»។

សារព័ត៌មានវៀតណាម e.-vnexpress.net បានចុះផ្សាយថា ប៉ូលិសវៀតណាមនៃខេត្ត An Giang បានរកឃើញសាកសពយុវជនម្នាក់ អាយុ ១៦ ឆ្នាំដែលរត់ចេញពីកាស៊ីណូនៅឃុំជ្រៃធំនៃប្រទេសកម្ពុជា ហើយអាជ្ញាធរកំពុងធ្វើកោសល្យវិច័យ។

ភ្នំពេញប៉ុស្តិ៍បានព្យាយាមទាក់ទងសុំការបញ្ជាក់ជុំវិញបញ្ហានេះពីភាគីកម្ពុជា ប៉ុន្តែលោក ស៊ីម ឃាង អធិការស្រុកកោះធំបានប្រាប់ភ្នំពេញប៉ុស្តិ៍ឱ្យសួរទៅថ្នាក់លើ ខណៈលោក ឈឿន សុចិត្ត ស្នងការនគរបាលខេត្តកណ្ដាលទូរស័ព្ទចូលតែពុំមានអ្នកទទួល។

នាយករងទទួលបន្ទុកផ្នែកឃ្លាំមើល និងការពារសិទ្ធិមនុស្សអង្គការលីកាដូលោក អំ សំអាត បានសម្តែងការព្រួយបារម្ភ ចំពោះហេតុការណ៍ជួញដូរមនុស្សនៅកម្ពុជា ដែលត្រូវបានលេចឡើងជាបន្តបន្ទាប់។ លោកថា៖ «ថ្មីៗនេះយើងឃើញស្ថាប័នព័ត៌មានជាតិ និងស្ថាប័នអន្តរជាតិបានចុះផ្សាយ និងចេញរបាយការណ៍ទាក់ទងបញ្ហាការជួញដូរមនុស្ស ជាពិសេសការជួញដូរកម្លាំងពលកម្ម ដែលប្រព្រឹត្តទៅតាមអនឡាញ»។ ជាមួយគ្នានេះដែរលោកជំរុញដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព បើពុំនោះទេកម្ពុជានឹងរងផលប៉ះពាល់មុខមាត់នៅលើឆាកអន្តរជាតិ ក៏ដូចជាប៉ះពាល់ដល់ការវិនិយោគជាដើម។ លោកថា៖ «យើងគាំទ្រការបង្ក្រាប និងការទប់ស្កាត់រាល់ករណីនៃការជួញដូរមនុស្ស ប៉ុន្តែយ៉ាងណាក៏ដោយត្រូវពង្រឹងបន្ថែមទៀតនូវយន្តការ ដើម្បីទប់ស្កាត់ និងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ទោះបីអ្នកពាក់ព័ន្ធនោះមានឋានន្តរស័ក្តិប៉ុនណាក៏ដោយ»។

យ៉ាងណាមិញ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង បានថ្លែងថា ក្រសួងកំពុងរៀបចំផែនការប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សជាក់ស្តែងមួយទៀត និងត្រៀម សម្រាប់ការប្រជុំជាមួយនឹងដៃគូអន្តរជាតិក្នុង

ការចូលរួមប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា ដោយមានបេសកកម្មទី ១ គឺជួយជនរងគ្រោះ និងទី ២ ចាប់មេខ្លោងពាក់ព័ន្ធ ដើម្បីយកមកផ្តន្ទាទោសតាមផ្លូវច្បាប់៕

## នគរបាលវៀតណាមចាប់ខ្លួនជនសង្ស័យ២នាក់ពាក់ព័ន្ធករណីជនជាតិវៀតណាមចំនួន ៤០នាក់ដែលរត់គេចពីការប្រើកម្លាំងពលកម្មដោយបង្ខិតបង្ខំ នៅកម្ពុជា

https://www.khmertimeskh.com/ August 23, 2022

ភ្នាក់ងារសន្តិសុខស៊ើបអង្កេតរបស់ប៉ូលីស An Giang បានចាប់ខ្លួនជនសង្ស័យចំនួន២ នាក់ ដើម្បីស៊ើបអង្កេតលើករណី "រៀបចំច្រកចេញដោយខុសច្បាប់" ក្នុងករណីជនជាតិវៀតណាមចំនួន ៤០ នាក់បានហែលទឹកឆ្លងទន្លេទៅប្រទេសវៀតណាមដើម្បីរត់គេចចេញពីកាស៊ីណូក្នុងប្រទេសកម្ពុជា។

បើតាមលោកវរសេនីយ៍ឯក Dinh Van Noi ស្នងការនគរបាលខេត្ត ជនសង្ស័យមានឈ្មោះ Nguyen Thi Le កើតនៅឆ្នាំ ១៩៨០ និង Le Van Danh កើតឆ្នាំ ១៩៨៨ អ្នកទាំងពីរមានទីលំនៅសង្កាត់ Long Binh ស្រុក An Phu។ ភ្នាក់ងារក៏បានបើកដំណើរការនីតិវិធីព្រហ្មទណ្ឌលើអ្នកទាំងពីរនិងករណីនេះផងដែរ។ ការសម្រេចចិត្តខាងលើត្រូវបានអនុម័តដោយអយ្យការប្រជាជនក្នុងកម្រិតដូចគ្នា។ ជនជាតិវៀតណាមចំនួន៤០នាក់ ប្រុស៣៥ នាក់ ស្រី៥នាក់ ត្រូវបានកម្លាំងការពារព្រំដែនខេត្ត An Giang ចាប់ខ្លួនកាលពីថ្ងៃទី១៨ ខែសីហា បន្ទាប់ពីបានចូលមកប្រទេសវៀតណាមដោយខុសច្បាប់ពីកម្ពុជា។

តាមសាក្សីពួកគេបានព្យាយាមរត់គេចពីកាស៊ីណូមួយនៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាលប្រទេសកម្ពុជា ហើយហែលឆ្លងទន្លេ Binh Ghi ដើម្បីត្រឡប់ទៅប្រទេសវៀតណាមវិញ។ ពួកគេបាននិយាយថា កន្លងមកពួកគេបានមកកម្ពុជាដើម្បីធ្វើការនៅកាស៊ីណូ។ ការងាររបស់ពួកគេគឺបង្កើតហ្គេមអនឡាញ និងចូលទៅកាន់គេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមតាមការបញ្ជារបស់ថៅកែនៅកាស៊ីណូ ប៉ុន្តែពួកគេត្រូវបានបង្ខំឱ្យធ្វើការបន្ថែមម៉ោងដោយមិនទទួលបានប្រាក់ឈ្នួលអ្វីនោះឡើយ។

លទ្ធផលស៊ើបអង្កេតដំបូងបង្ហាញថា ៦នាក់ក្នុងចំណោមពួកគេត្រូវបាន Le និង Danh នាំមកកម្ពុជាដោយខុសច្បាប់។ Le បានសារភាពថា ក្នុងខែឧសភាឆ្នាំនេះ នាងត្រូវបានបុរសមិនស្គាល់មុខម្នាក់ស្នើសុំឱ្យចូលរួមក្នុងការនាំមនុស្សខុសច្បាប់ចេញពីប្រទេសវៀតណាមមកកម្ពុជា។ បន្ទាប់មក Le បានធ្វើការជាមួយ Danh ដើម្បីរៀបចំច្រកចេញខុសច្បាប់។ Danh បាននាំមនុស្សទៅច្រាំងទន្លេខាងវៀតណាម ហើយ Leបានដឹកពួកគេមកកម្ពុជា។ អ្នកទាំងពីរត្រូវបានបង់ប្រាក់ចំនួន ១០០,០០០ ដុង (៤.២៧ ដុល្លារ) ក្នុងមនុស្សម្នាក់ដែលពួកគេយកមកប្រទេសកម្ពុជា។ ក្រៅពីមនុស្ស៦នាក់នោះ Le ក៏បានសារភាពថានាង និង Danh បានប្រព្រឹត្តិខុសច្បាប់ជាច្រើនផ្សេងទៀតក្នុងការនាំមនុស្សទៅធ្វើការកាស៊ីណូនៅកម្ពុជា។ ការស៊ើបអង្កេតបន្ថែមកំពុងដំណើរការ។ VNA

## ជនជាតិហុងកុង៥នាក់បង្កើតការងារឆបោកនៅតំបន់អាស៊ីអាគ្នេយ៍ ត្រូវចាប់ខ្លួន

https://kohsantepheapdaily.com.kh/ ២៣ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ០៨:៤៥

ហុងកុង ៖ ជនជាតិហុងកុងចំនួន ៥នាក់ត្រូវបានចាប់ខ្លួនពីបទបង្កើការងារឆបោក ដែលក្នុងនោះជនរងគ្រោះត្រូវបានទាក់ទាញឱ្យមកធ្វើការក្នុងប្រទេសជាច្រើនក្នុងតំបន់ និងត្រូវបានឃុំខ្លួនដើម្បីឱ្យធ្វើការបោកប្រាក់អ្នកដទៃផ្សេងទៀត។ ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ជនរងគ្រោះត្រូវបានរាយការណ៍ថា បានធ្វើដំណើរទៅកាន់ប្រទេសក្នុងតំបន់មានដូចជាកម្ពុជា មីយ៉ាន់ម៉ា ថៃ និងឡាវជាដើមដោយជនឆបោកសន្យាថានឹងផ្តល់ការងារប្រាក់ខែខ្ពស់ដល់ពួកគេ ប៉ុន្តែពួកគេត្រូវបានឃុំខ្លួន និងបង្ខំឱ្យធ្វើការងារ។ កាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ អាជ្ញាធរហុង

កុងបានបង្កើតក្រុមការងារដើម្បីជួយដល់ជនរងគ្រោះដែលធ្លាក់ខ្លួនក្នុងការឆបោកនេះ។ ក្នុងចំណោមសំណើរទាំង ៣៦ដែលដាក់សុំជំនួយពីប៉ូលីស មានភាគច្រើនទាក់ទងទៅនឹងការបោកប្រាស់តាមការងារ។ នេះបើយោងតាមការបញ្ជាក់របស់លោក Tony Ho ស្នងការជាន់ខ្ពស់នៃការិយាល័យឧក្រិ.ដ្ឋកម្ម។

លោកថ្លែងកាលពីថ្ងៃអាទិត្យ ទី ២១ សីហា ដូច្នេះថា ប៉ូលីសបានចាប់ខ្លួនបុរស ៣នាក់ និងស្ត្រី ២នាក់ពីបទសង្ស័យបោកបញ្ឆោតប្រជាជនហុងកុងឱ្យទទួលយកការងារមិនច្បាស់លាស់នៅក្រៅប្រទេស។ ជនរងគ្រោះចំនួន ២២នាក់ត្រូវគេជឿជាក់ថាកំពុងជាប់ឃុំនៅក្នុងប្រទេសកម្ពុជា និងមីយ៉ាន់ម៉ា ហើយមនុស្ស ៩នាក់ក្នុងចំណោមពួកគេមិនបានធ្វើការទាក់ទងគ្រួសារ ឬប៉ូលីសហុងកុងនោះទេ។ លោក Tony Ho បញ្ជាក់ទៀតថា ជនរងគ្រោះត្រូវបានគេផ្តល់សំបុត្រយន្តហោះអោយ ហើយនៅពេលធ្វើដំណើរទៅដល់គោលដៅ លិខិតឆ្លងដែនរបស់ពួកគេត្រូវបានដកហូតឡើង មុនពេលបញ្ជូនទៅកាន់មណ្ឌលការងារ និងត្រូវបានបង្ខំឱ្យធ្វើការបោកប្រាស់អ្នកដទៃ។

អ្នកនយោបាយមកពីគណបក្ស DAP របស់ហុងកុង បានថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីថ្ងៃអាទិត្យដូច្នេះថា គ្រួសាររបស់ជនរងគ្រោះបានស្វែងរកជំនួយពីពួកគេ ខណៈប្រជាជនហុងកុងម្នាក់ត្រូវបានគេបោកប្រាស់ក្នុងការជួញដូរមនុស្សប្រហែលមួយខែមកហើយនៅក្នុងរដ្ឋ Kayin ប្រទេសមីយ៉ាន់ម៉ា។ លោក Woo Cheuk-him អ្នកនយោបាយដែលត្រូវបានគ្រួសារជនរងគ្រោះស្វែងរកជំនួយបាននិយាយថា «គ្រួសាររបស់គាត់សង្ស័យថាគាត់ត្រូវបានរំលោ.ភបំពា.នលើរាងកាយ»។ លោកបញ្ជាក់ថាទៀតថា «ជនរងគ្រោះត្រូវបានបង្ខំឲ្យធ្វើការប្រហែល ១០ម៉ោងក្នុងមួយថ្ងៃ ប្រសិនគាត់ធ្វើការមិនបានល្អទេ គាត់នឹងមិនបានអាហារហូបគ្រប់គ្រាន់នោះទេ»។

មេធាវីការពារសិទ្ធិមនុស្ស Patricia Ho បាននិយាយកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះថា ច្បាប់ដែលមានប្រាប់របស់ហុងកុងមិនគ្រាន់គ្រាន់ដើម្បីដោះស្រាយការឆបោកបែបនោះទេ ដោយសារទីក្រុងមិនមានច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស និងពលកម្មដោយបង្ខំ៕ (យោងតាមប្រភព៖ AFP)

## កងកម្លាំងការពារព្រំដែនវៀតណាម ជួយសង្គ្រោះក្មេងស្រីដែលត្រូវគេជួញដូរមកកម្ពុជា

https://www.khmertimeskh.com/ Vietnam News Agency August 23, 2022

កងកម្លាំងព្រំដែនក្នុងខេត្ត Kon Tum ភាគកណ្តាលនៃប្រទេសវៀតណាម សហការជាមួយអាជ្ញាធរកម្ពុជា បានជួយសង្គ្រោះក្មេងស្រីម្នាក់ដែលត្រូវបានជួញដូរទៅប្រទេសជិតខាងកាលពីខែមេសា។ Y.L. អាយុ ១៦ ឆ្នាំត្រូវបានគេជួយសង្គ្រោះកាលពីថ្ងៃសៅរ៍សប្តាហ៍មុន ប្រហែល៤ខែបន្ទាប់ពីនាងត្រូវបានលក់មកប្រទេសកម្ពុជា ទីភ្នាក់ងារសារព័ត៌មានវៀតណាមបានដកស្រង់សម្តីរបស់កងកម្លាំងព្រំដែនខេត្តដែលរាយការណ៍នៅថ្ងៃបន្ទាប់។ កងកម្លាំងព្រំដែនក្នុងស្រុកបាននិយាយថា ក្មេងស្រីវ័យក្មេងនេះ ត្រូវបានក្រុមហ៊ុនចំនួន៥ដែលមានទីតាំងនៅកម្ពុជាចាប់ធ្វើជាកម្មករដោយប្រើកំលាំងបង្ខិតបង្ខំ ដែលលក់នាងម្តងហើយម្តងទៀតពីមួយទៅមួយ មុនពេលត្រូវបានជួយសង្គ្រោះ។

អាជ្ញាធរមូលដ្ឋានអនុវត្តនីតិវិធីបញ្ជូនក្មេងស្រីជំទង់រូបនេះទៅគ្រួសារនៅស្រុក Ngoc Hoi ង៉ុកហូយ ខណៈតាមប្រមាញ់បុរសដែលបានឆបោក L ឱ្យទៅកម្ពុជាដើម្បីធ្វើការងារងាយស្រួលប្រាក់ខែខ្ពស់ មុនពេលលក់នាងអោយក្លាយទៅជាកម្មករដោយប្រើកម្លាំងបង្ខិតបង្ខំ L. បានប្រាប់ប៉ូលីសថា បុរសនោះបានបោកប្រាស់នាង បន្ទាប់ពីគាត់បានស្គាល់នាងតាមរយៈទំព័រហ្វេសប៊ុករបស់គាត់ដែលមានឈ្មោះថា 'Le Ngoc Nhat' នៅពេលនាងធ្វើការនៅក្រុមហ៊ុនស្បែកជើងមួយក្នុងខេត្ត Binh Duong នៅខាងក្រៅទីក្រុងហូជីមិញ។

កាលពីថ្ងៃទី១៨ ខែមេសា បុរសនោះបាននាំនាង និងមនុស្ស៥នាក់ទៀត ក្នុងនោះស្រី២នាក់ និងប្រុស៣នាក់ ទៅកាន់ខេត្តLong An ហើយពួកគេបានទៅប្រទេសកម្ពុជា តាមច្រកព្រំដែនខុសច្បាប់។ ពេលទៅដល់ប្រទេស

ជិតខាង បុរសនោះបានលក់ L. ទៅឱ្យក្រុមហ៊ុនមួយក្នុងតម្លៃ ១,៨០០ ដុល្លារ ហើយបន្ទាប់មកបានកាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយនាង។ L. បាននិយាយថា ទន្ទឹមនឹងនោះ ដៃគូទាំង៥នាក់របស់នាងបានទទួលការងារនៅកន្លែងផ្សេងៗគ្នា ហើយចាប់តាំងពីពេលនោះមក នាងមិនបានទំនាក់ទំនងជាមួយពួកគេទេ។ ដោយសារនាងមិនអាចទ្រាំនឹងការងារទាំងនេះបាន L. បានសុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យនាងត្រឡប់ទៅប្រទេសវៀតណាមវិញ ប៉ុន្តែថៅកែបានបង្ខំនាងឱ្យបង់ប្រាក់ចំនួន ៣,៥០០ ដុល្លារ ឬអូសទាញជនជាតិវៀតណាមពី៣ ទៅ៥ នាក់ទៀតឱ្យមកកម្ពុជាដើម្បីធ្វើការឱ្យក្រុមហ៊ុនជាថ្នូរនឹងការដោះលែងនាង។ L. មិនអាចបំពេញលក្ខខណ្ឌទាំងពីរបានទេ ហើយនាងត្រូវបានលក់ម្តងទៅក្រុមហ៊ុនមួយផ្សេងទៀត។ ការលក់បន្តរបស់ក្មេងស្រីនេះបានកើតឡើងម្តងហើយម្តងទៀតរហូតដល់នាងធ្វើការឱ្យក្រុមហ៊ុនទី៥ ហើយនាងអាចរកវិធីទាក់ទងក្រុមគ្រួសារប្រាប់ពួកគេពីស្ថានភាពរបស់នាងនៅថ្ងៃទី ១៧ ខែកក្កដា។ ក្រុមហ៊ុននេះមានទីតាំងស្ថិតនៅក្នុងអគារមួយក្នុងខេត្តព្រះសីហនុ ចម្ងាយប្រហែល ៤៧០ គីឡូម៉ែត្រពីច្រកព្រំដែន Moc Bai ក្នុងខេត្ត Tay Ninh ភាគនិរតីប្រទេសវៀតណាម។

បន្ទាប់ពីទទួលបានរបាយការណ៍ពីគ្រួសាររបស់ L. អំពីការឆបោក កងកម្លាំងព្រំដែន Kon Tum បានសម្របសម្រួលជាមួយសមភាគី Tay Ninh និងភ្នាក់ងារមានសមត្ថកិច្ចរបស់កម្ពុជា ដើម្បីចាប់ផ្តើមផែនការជួយសង្គ្រោះនាង។ មន្ត្រីការពារព្រំដែនក្នុងស្រុកបាននិយាយថា នេះជាលើកទីមួយហើយដែលពួកគេបានដោះស្រាយករណីជួញដូរមនុស្សនៅ Kon Tum ដោយជោគជ័យ។ Tuoi Tre News

## ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២

### មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖ អាជ្ញាធរកម្ពុជា មិនទាន់រកឃើញថា មានជនជាតិចិនតៃវ៉ាន់ រងគ្រោះដោយការជួញដូរមនុស្ស ដូចការផ្សាយព័ត៌មានឡើយ

http://freshnewsasia.com/ 2022-08-23 05:04pm

**(ភ្នំពេញ)៖** អាជ្ញាធរជំនាញរបស់កម្ពុជា មិនទាន់រកឃើញថា មានជនជាតិចិនតៃវ៉ាន់ រងគ្រោះដោយសារការជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា ដូចការផ្សាយព័ត៌មាននោះឡើយ។ នេះបើតាម លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

នគរបាលក្រុងតៃប៉ិ នៃកោះតៃវ៉ាន់ កាលពីពាក់កណ្តាលខែសីហានេះ បានសន្និដ្ឋានថា មានជនជាតិចិនតៃវ៉ាន់ ចន្លោះពី ២,០០០នាក់ ទៅ ៥,០០០នាក់ ត្រូវបានរងគ្រោះដោយសារការជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះ បើតាមការផ្សាយដោយ សារព័ត៌មាន Taipei Times កាលពីថ្ងៃទី២០ ខែសីហា បានអះអាងដែរថា មានមនុស្សចំនួន ១៦នាក់ ត្រូវបានចាប់ខ្លួន ដោយនគរបាលដាក់ការសង្ស័យថា ពួកគេរួមគំនិតជាមួយអង្គការឧក្រិដ្ឋកម្មបរទេស ដើម្បីទាក់ទាញប្រជាជនកោះតៃវ៉ាន់ ទៅធ្វើការនៅប្រទេសកម្ពុជា តាមរយៈការសន្យាផ្តល់ឲ្យនូវប្រាក់ខែខ្ពស់។

ថ្លែងក្រោយជំនួបជាមួយក្រុមមន្ត្រីនៃអង្គការដៃគូរ និងអង្គការសហប្រជាជាតិ ពាក់ព័ន្ធបញ្ហាសិទ្ធិមនុស្ស នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ លោកស្រី ជូ ប៊ុនអេង បានអះអាងថា នៅក្នុងការបង្ក្រាបអំពើជួញដូរមនុស្សកន្លងមក មិនទាន់មានករណីដូចការផ្សាយនោះទេ។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានបន្ថែមថា អ្នកធ្វើដំណើរមកកម្ពុជា តែមិនឃើញទៅមាតុភូមិវិញ មិនប្រាកដថា ជួបប្រទះអំពើជួញដូរមនុស្សនោះទេ ហើយបើស្រាវជ្រាវមិនទាន់ឃើញ ក៏មិនប្រាកដថា ករណីជួញដូរមនុស្សកើតឡើងនៅកម្ពុជាដែរ។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់យ៉ាងដូច្នេះថា «**ជនជាតិចិនតៃវ៉ាន់ កន្លងមកដែលបានលើកឡើងនៅក្នុងសារព័ត៌មាន នៅក្នុងការបង្ក្រាបរបស់យើងអត់**

ទាន់ឃើញមានករណីហ្នឹងនៅឡើយទេ។ ហើយយើងអត់ចង់ឲ្យការផ្សព្វផ្សាយនេះ មានត្រឹមតែថា អត់មានឃើញមនុស្សត្រឡប់ទៅវិញគិតថាជាការវងគ្រោះនៅកម្ពុជាអីនោះពីព្រោះយើងអត់ដឹងថាដំណើរពួកគាត់ទៅណាខ្លះទេ។

ក្រោយកិច្ចប្រជុំពិភាក្សា ដើម្បីលើកឡើងពីការព្រួយបារម្ភរបស់អង្គការសហប្រជាជាតិ អំពីការកើនឡើងនូវបញ្ហាជួញដូរមនុស្សនៅកម្ពុជារវាងគណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតំណាងអង្គការសហប្រជាជាតិនៅកម្ពុជា លោកស្រី ជូ ប៊ុនអេង បានឲ្យដឹងទៀតថា ៧ខែ ឆ្នាំ២០២២នេះ អាជ្ញាធរកម្ពុជា បានបង្ក្រាបអំពើជួញដូរមនុស្ស ៧៤ករណី ហើយបានចាប់ខ្លួនជនជាតិចិន ម៉ាឡេស៊ី វៀតណាម និងជនជាតិខ្មែរ ៦០នាក់ បញ្ជូនទៅតុលាការ ដោយសង្ស័យជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សខុសច្បាប់។ ក្នុងនេះ គឺអាជ្ញាធរសង្គ្រោះមនុស្សបានជាង ៦០០នាក់ មាន ១១សញ្ជាតិ តែមិនឃើញមានសញ្ជាតិចិនតៃវ៉ាន់ឡើយ។

សារព័ត៌មាន Taipei Times បានផ្សាយទៀតថា ជនជាតិចិនតៃវ៉ាន់ ដែលត្រូវបានជួយសង្គ្រោះពីការឃុំឃាំងនៅកម្ពុជា បានអះអាងថា បានរងការវាយធ្វើបាប តាមមធ្យោបាយផ្សេងៗ ដោយអ្នកជួញដូរមនុស្ស នៅក្នុងសណ្ឋាគារមួយចំនួន ក្នុងខេត្តព្រះសីហនុ។ កាលពីល្ងាចថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ លោក វិទិត មុនតាបន អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា បានដឹកនាំប្រតិភូទៅខេត្តព្រះសីហនុ ដើម្បីជួបជាមួយលោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ ពិភាក្សាការងារពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនេះ។ លោក គួច ចំរើន បានលើកឡើងថា ស្ថានភាពជាក់ស្តែងនៅខេត្តព្រះសីហនុ គឺខុសពីអ្វីដែលប្រព័ន្ធផ្សព្វផ្សាយមួយចំនួនបានផ្សព្វផ្សាយ ដូច្នេះលោកសំណូមពរដល់ប្រតិភូ កត់ត្រាអ្វីដែលជាការពិត។

ក្រសួងការបរទេសអាមេរិក កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ បានផ្សព្វផ្សាយរបាយការណ៍ ឆ្នាំ ២០២២ ស្តីពីការជួញដូរមនុស្ស។ ក្នុងបាយការណ៍នោះ គឺអាមេរិក បានដាក់កម្ពុជា វៀតណាម តំបន់ម៉ាកាវ របស់ចិន និងប្រទេសផ្សេងទៀត ពីបញ្ជីស្ថិតក្រោមការឃ្លាំមើលនៅកម្រិត២ ទៅកម្រិត៣ ដែលគេស្គាល់ជាទូទៅថា បញ្ជីខ្មៅ ដែលជាកម្រិតដ៏អាក្រក់។ អាមេរិកចោទប្រកាន់ថា កម្ពុជា និងប្រទេសទាំងនោះ មានកិច្ចខិតខំតិចតួច និងមិនបានគោរពតាមស្តង់ដារនៃការលុបបំបាត់ការជួញដូរមនុស្ស។ អាមេរិកក៏បានដាក់ចិនជាប្រទេសមួយស្ថិតក្នុងកម្រិត ៣ នៃការជួញដូរមនុស្សផងដែរ ហើយរដ្ឋាភិបាលចិន បានប្រាទចោល និងបានលើកឡើងថា អាមេរិកជាប្រទេសដែលមានអំពើជួយដូរច្រើនជាងគេបំផុតក្នុងលោកផងដែរ។

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃ បានចាប់ផ្តើមបើកប្រតិបត្តិការទ្រង់ទ្រាយធំ ដើម្បីត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេសនៅកម្ពុជា។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានឲ្យដឹងថា ប្រតិបត្តិការរបស់ក្រសួងមហាផ្ទៃ ដែលត្រួតពិនិត្យការរស់នៅរបស់ជនបរទេសទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយលើកលែងតែមន្ត្រីការទូតប៉ុណ្ណោះ ដើម្បីពិនិត្យភាពស្របច្បាប់ និងរកមុខសញ្ញាដែលពាក់ព័ន្ធនឹងជួញដូរមនុស្ស៕

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃបញ្ជាក់ជាថ្មីថា កម្ពុជាមិនបានប្រងើយកន្តើយ ចំពោះការទប់ស្កាត់ការជួញដូរមនុស្សទេ

https://www.btv.com.kh/ 2022/08/24 10:17:42 am

ភ្នំពេញ៖ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលហៅកាត់ថាគ.ជ.ប.ជ លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលកម្ពុជាមិនបានប្រងើយកន្តើយចំពោះការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដូចការចោទប្រកាន់ពីមជ្ឈដ្ឋាននានានោះឡើយ ខណៈយុទ្ធនាការនេះកម្ពុជាបានសហការជួយប្រទេស និងអង្គការជាដៃគូ ជាច្រើន។

ថ្លែងប្រាប់អ្នកសារព័ត៌មានមុននឹងឡើងយន្តហោះឆ្ពោះទៅកាន់ប្រទេសថៃ ដើម្បីចូលរួមកិច្ចប្រជុំជាមួយភាគីថៃ ទាក់ទងនិងកិច្ចសហប្រតិបត្តិការទ្វេភាគី ស្តីពីនីតិវិធីច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២នេះ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា កម្ពុជាបានធ្វើការយ៉ាងសកម្មចំពោះកិច្ចការទប់ស្កាត់ អំពើជួញដូរមនុស្ស បើទោះបីកម្ពុជាត្រូវបានគេចោទប្រកាន់ និងបានដាក់ប្រទេសស្ថិតនៅក្នុងលេខរៀងទី៣ ក្នុងការ ប្រងើយកន្តើយ ចំពោះការជួញដូរមនុស្សនេះ។

សូមបញ្ជាក់ថា ក្នុងរយៈពេល៧ខែ ឆ្នាំ២០២២នេះ អាជ្ញាធរកម្ពុជាបានបង្ក្រាបអំពើជួញដូរមនុស្សបានចំនួន ៤៧ករណី ហើយបានចាប់ខ្លួនជនជាតិចិន ម៉ាឡេស៊ី វៀតណាម និងជនជាតិខ្មែរបានចំនួន៦០នាក់បញ្ជូនទៅកាន់ តុលាការដោយសង្ស័យជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដែលជនសង្ស័យទាំងនេះបានបោកបញ្ឆោតជនរង គ្រោះពីប្រទេសផ្សេងៗចូលមកកម្ពុជាដោយសន្យាឲ្យធ្វើការទទួលបានប្រាក់កំរៃជាច្រើននោះ។

លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ថា បទល្មើសជួញដូរមនុស្សដែលបានកើតឡើងលើទឹកដីកម្ពុជានេះ គឺ ពុំមែនកម្ពុជាជាអ្នកធ្វើខ្លួនឯងនោះទេ ពោលគឺជនបោកបញ្ឆោតជាជនបរទេស មេខ្យល់នាំចូលក៏ជាជនបរទេស ហើយបាននាំជនបរទេសមករងគ្រោះនៅប្រទេសកម្ពុជាទៅវិញ រហូតត្រូវបានគេរិះគន់ ហើយបានឈានដល់ការ ដាក់កម្ពុជាចូលទៅក្នុងបញ្ជីខ្មៅ ដែលជាប្រទេសជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សជាដើមនោះ។ យ៉ាងណាក៏ ដោយលោកជំទាវ ជូ ប៊ុន អេង បានលើកឡើងថា កម្ពុជាខិតខំប្រឹងប្រែងជានិច្ចចំពោះយុទ្ធនាការប្រយុទ្ធប្រឆាំងនូវ អំពើជួញដូរមនុស្សនេះ ដោយកម្ពុជាបានសហការជាមួយប្រទេស និងអង្គការ ជាដៃគូជាច្រើននៅលើសកលលោក ដើម្បីធ្វើយ៉ាងណាលុបបំបាត់នូវសកម្មភាពទាំងនេះឲ្យបាន៕ អត្ថបទ៖ បាន ចក់

## ឃាត់ខ្លួនជនសង្ស័យ៦នាក់នៅហុងកុងពីបទឆបោកការងារនៅអាស៊ីអាគ្នេយ៍ ជនរងគ្រោះ ៩នាក់ត្រូវបានគេជឿថាត្រូវបានគេចាប់បង្ខាំងនៅក្នុងប្រទេសកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 23, 2022

នគរបាលហុងកុងបានចាប់ខ្លួនមនុស្សចំនួន ៦នាក់ ពីបទឆបោកការងារ បន្ទាប់ពី មនុស្សចំនួន៣៧នាក់ ត្រូវបានគេរាយការណ៍ថាបានធ្លាក់ទៅក្នុងគម្រោងនេះ បន្ទាប់ពីត្រូវបានគេទាក់ទាញឱ្យមកប្រទេសអាស៊ីអាគ្នេយ៍ ដូចជាកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ឱ្យចូលរួមក្នុងការងារខុសច្បាប់ចាប់តាំងពីខែមករា។ ជនរងគ្រោះនៃការឆបោក ការងារបានបន្តកើនឡើងក្នុងរយៈពេលប៉ុន្មានសប្តាហ៍កន្លងមកនេះ។ ដោយបង្ហាញពីតួលេខចុងក្រោយ នៃជនរង គ្រោះនៅក្នុងកម្មវិធីវិទ្យុក្នុងស្រុកកាលពីថ្ងៃចន្ទ អនុរដ្ឋលេខាធិការសន្តិសុខលោក Michael Cheuk Hau-yip បាន និយាយអំពីពួកគេថា មនុស្សចំនួន ២៣ នាក់នៅតែត្រូវបានចាប់ធ្វើជាចំណាប់ខ្មាំង ដោយ ១៤ នាក់ ត្រូវបានគេជឿ ថាស្ថិតនៅក្នុងប្រទេសមីយ៉ាន់ម៉ា និង៩ នាក់នៅក្នុងប្រទេសកម្ពុជា។

លោក Cheuk បាននិយាយថា មនុស្ស ១៤ នាក់ផ្សេងទៀតបានរត់គេចខ្លួនដោយសុវត្ថិភាព ដោយ ១១ នាក់បានត្រឡប់ទៅហុងកុងវិញ។ ជាមួយគ្នានេះដែរ កាលពីថ្ងៃច័ន្ទ បុរសម្នាក់ទៀត អាយុ ២៩ ឆ្នាំ ត្រូវបានចាប់ខ្លួន ដោយសង្ស័យថាបានសមគំនិតក្នុងការបោកប្រាស់ ដែលធ្វើអោយគាត់ក្លាយជាមនុស្សទីប្រាំមួយដែលត្រូវបានឃុំ ខ្លួនពីបទឆបោក។ កន្លងមក នគរបាលបានចាប់ខ្លួនមនុស្សប្រុសបីនាក់ និងស្ត្រីពីរនាក់ អាយុចន្លោះពី ១៧ ទៅ ៥១ឆ្នាំ ជុំវិញករណីដូចគ្នានេះ។ ម្នាក់ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួនមានអាយុ ៣០ ឆ្នាំបានបង្ហាញខ្លួននៅ តុលាការកំពូលភាគខាង (Eastern Magistrates' Courts) កើតនៅព្រឹកថ្ងៃចន្ទ។

ថ្លែងទៅកាន់ប្រព័ន្ធផ្សព្វផ្សាយកាលពីថ្ងៃអាទិត្យ លោក Tony Ho Chun-tung អគ្គនាយកជាន់ខ្ពស់នៃ ការិយាល័យឧក្រិដ្ឋកម្មឆ្លងដែននិងដែលមានការរៀបចំ (Organized Crime and Triad Bureau) បាននិយាយ

ថា ក្នុងចំណោមមនុស្សប្រាំនាក់ដែលត្រូវបានចាប់ខ្លួននោះ បុរសពីរនាក់ត្រូវបានគេជឿថាជាសមាជិកសំខាន់ៗនៃក្រុមនោះ ហើយជាអ្នកទទួលខុសត្រូវក្នុងការចាត់ចែងមនុស្សបីនាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួន ដើម្បីឱ្យបង្ហោះព័ត៌មានស្វែងរកការងារក្លែងក្លាយតាមអ៊ីនធឺណិត។ លោក Ho បាននិយាយថា ពួកគេត្រូវបានគេសង្ស័យថាបានបោកបញ្ឆោតជនរងគ្រោះជាមួយនឹងការងារដែលមានប្រាក់បៀវត្សរ៍ខ្ពស់ និងតម្រូវការទាបនៅក្នុងប្រទេសភាគអាគ្នេយ៍ តាមរយៈមិត្តភក្តិ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងទីផ្សារតាមទូរស័ព្ទ មុនពេលជនរងគ្រោះធ្លាក់ចូលទៅក្នុងអន្ទាក់ ហើយបានទៅដល់ប្រទេសដែលបានកំណត់។ លោក Ho បានបន្ថែមថា នៅពេលពួកគេមកដល់ លិខិតឆ្លងដែនរបស់ជនរងគ្រោះត្រូវបានដកហូតភ្លាមៗ ហើយពួកគេត្រូវបានបង្ខំឱ្យចូលរួមក្នុងសកម្មភាពបោកប្រាស់តាមអ៊ីនធឺណិត ឬតាមរយៈការហៅទូរស័ព្ទ។ លោក Ho បាននិយាយថា ជនរងគ្រោះដែលបដិសេធមិនសហការ ឬព្យាយាមរត់គេចខ្លួន ត្រូវបានគេធ្វើបាបយ៉ាងឃោឃៅ ដោយលោកបានបន្ថែមថា ការស៊ើបអង្កេតនៅតែកំពុងបន្ត ដែលនឹងអាចឈានទៅការចាប់ខ្លួនមនុស្សកាន់តែច្រើនបន្ថែមទៀត។ លោក Ho បានសង្កត់ធ្ងន់ថា នគរបាលហុងកុងនឹងបន្តធ្វើការជាមួយអង្គភាពផ្សេងៗគ្នាដើម្បីធ្វើការរៀបចំឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីធានាសុវត្ថិភាពប្រជាជនហុងកុងនៅឯបរទេស។

នគរបាលបានអំពាវនាវដល់សាធារណជនកុំឲ្យធ្លាក់ចូលក្នុងការបោកប្រាស់ដោយជឿលើការផ្សព្វផ្សាយដែលបំភ័ន្តភ្នែក និងស្វែងរកជំនួយពីសមត្ថកិច្ចឲ្យបានទាន់ពេលវេលាប្រសិនបើមានការសង្ស័យ៕ *China Daily*

## ‘ជនរួមជាតិតៃប៉ិ’ កំពុងជួបការលំបាក ដោយត្រូវបានប្រាប់ឱ្យទាក់ទងស្ថានទូតចិនប្រចាំកម្ពុជា បន្ទាប់ពីមានរបាយការណ៍ថា មានមនុស្សជាប់ក្នុងអំពើឆបោក និងហិង្សា

https://www.khmertimeskh.com/ Khmer Times August 24, 2022

ស្ថានទូតចិនប្រចាំកម្ពុជា បានប្រាប់ជនរួមជាតិតៃប៉ិថា “ជនរួមជាតិតៃប៉ិគឺជាពលរដ្ឋចិន ដូច្នេះប្រសិនបើអ្នកមានការលំបាកណាមួយ សូមទាក់ទងស្ថានទូត” បន្ទាប់ពីពួកគេមួយចំនួនត្រូវបានគេរាយការណ៍ថាត្រូវបានគេបង្ខំឱ្យចូលរួមក្នុងល្បែងអនឡាញ ការបោកប្រាស់ទូរគមនាគមន៍ និងសកម្មភាពខុសច្បាប់ផ្សេងទៀត ហើយត្រូវបានគេដាក់កំហិតការធ្វើដំណើរនៅកម្ពុជា។

នៅក្នុងសេចក្តីថ្លែងការណ៍មួយ ដែលចេញកាលពីយប់ថ្ងៃសៅរ៍ ស្ថានទូតបាននិយាយថា ពួកគេនឹងផ្តល់សេវាការពារខាងកុងស៊ុលទាន់ពេលវេលា និងមានប្រសិទ្ធភាពដល់ពលរដ្ឋចិនទាំងអស់នៅកម្ពុជា រួមទាំងជនរួមជាតិតៃប៉ិ ដោយកត់សម្គាល់ថា ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនរួមជាតិតៃប៉ិ គឺជាកាតព្វកិច្ចរបស់បេសកកម្មការទូតរបស់ប្រទេសចិននៅក្រៅប្រទេស។ ស្ថានទូតបាននិយាយថា នៅកម្ពុជា «យើងតែងតែយកចិត្តទុកដាក់ស្មើៗគ្នាចំពោះពលរដ្ឋចិនមកពីខេត្តតៃប៉ិ» មិនថានៅក្នុងកម្មវិធីចាក់វ៉ាក់សាំង COVID-19 ដែលរដ្ឋាភិបាលចិនបើកសម្រាប់ពលរដ្ឋចិននៅក្រៅប្រទេស ឬជួយសង្គ្រោះអ្នកដែលជួបការលំបាកនោះទេ។

យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយតៃប៉ិ ប្រជាជនតៃប៉ិមួយចំនួនដែលទៅប្រទេសកម្ពុជាដើម្បីស្វែងរកការងារធ្វើត្រូវបានជួលក្នុងការងារដែលមើលទៅមិនសមស្របនឹងប្រាក់ឈ្នួលរបស់ពួកគេ ហើយខ្លះទៀតទទួលរងនូវអំពើហិង្សា រួមទាំងការចាប់បង្ខាំង ការវាយដំ ការរំលោភបំពាន និងសូម្បីតែការរំលោភផ្លូវភេទ។ របាយការណ៍បាននិយាយថា ប្រជាជនតៃប៉ិជាង ៨,៦០០ នាក់ បានទៅប្រទេសកម្ពុជាចាប់ពីខែមករាដល់ខែកក្កដា មានតែ ៥,០០០ នាក់ប៉ុណ្ណោះ ដែលបានត្រឡប់ទៅកោះតៃវ៉ាន់វិញ ដោយនៅមានមនុស្សប្រហែល ៣,០០០ នាក់ជាប់នៅក្នុងប្រទេសកម្ពុជា។

លោក Ma Xiaoguang អ្នកនាំពាក្យការិយាល័យកិច្ចការក្រុងតៃប៉ិនៃក្រុមប្រឹក្សារដ្ឋបានថ្លែងក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃសុក្រថា រដ្ឋាភិបាលចិនតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការការពារសុវត្ថិភាព និងសិទ្ធិស្របច្បាប់ និងផលប្រយោជន៍របស់ជនរួមជាតិតៃប៉ិនៅឯបរទេស តាមរយៈការផ្តល់សេវាកុងស៊ុល ជួយដោះស្រាយវិវាទរដ្ឋប្បវេណីបរទេស និងសំណុំរឿងសេដ្ឋកិច្ច និងឧក្រិដ្ឋកម្មទាក់ទងនឹងទីក្រុងតៃប៉ិ ការជម្លៀសជនជាតិចិននៅក្រៅប្រទេសក្នុងករណីអាសន្នធំៗ។ របាយការណ៍របស់ប្រជាជនតៃប៉ិ "ជាប់" នៅកម្ពុជាបាននាំមកនូវការត្អូញត្អែរ និងការមិនពេញចិត្តរបស់ប្រជាជនជុំវិញអសមត្ថភាពរបស់គណបក្សវឌ្ឍនភាពប្រជាធិបតេយ្យ (Democratic Progressive Party) ។ អាជ្ញាធរគណបក្សវឌ្ឍនភាពប្រជាធិបតេយ្យ និងប្រជាជនមួយចំនួននៅលើកោះតៃវ៉ាន់ បានបន្ទោសចិនដីគោកចំពោះករណីបែបនេះ។

ជាការឆ្លើយតប លោក Ma បានគូសបញ្ជាក់ថា ឥរិយាបថអកម្មរបស់អាជ្ញាធរ DPP ចំពោះការអំពាវនាវរបស់ប្រជាជនតៃប៉ិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពួកគេ ហើយការប្រឌិតដោយភូតកុហកដើម្បីបន្ទោសចិនដីគោកបង្ហាញយ៉ាងពេញលេញ នូវយុទ្ធសាស្ត្រតវ៉ារបស់ពួកគេ ក្នុងការចូលរួមក្នុងឧបាយកលនយោបាយ ដោយធ្វើការញុះញង់ឱ្យមានការប្រឈមមុខដាក់គ្នា និងបោកប្រាស់ប្រជាជន ដោយមិនគិតពីអាយុជីវិត និងផលប្រយោជន៍របស់ប្រជាជនតៃប៉ិ។

វិចារណកថារបស់កាសែត China Times ដែលជាប្រព័ន្ធផ្សព្វផ្សាយតៃប៉ិ បានអំពាវនាវឱ្យអាជ្ញាធរ DPP សហការជាមួយអាជ្ញាធរដីគោក ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែននៅកម្ពុជា។ ប្រព័ន្ធផ្សព្វផ្សាយបាននិយាយថា "ខ្លួន (គណបក្សវឌ្ឍនភាពប្រជាធិបតេយ្យ) បរាជ័យក្នុងការជួយសង្គ្រោះប្រជាជននៅពេលមានវិបត្តិ ដោយមិនចង់ប្រើជំនួយពីចិនដីគោក ហើយនិយាយថាវាពិបាកក្នុងការអនុវត្តវិធានការណ៍សង្គ្រោះព្រោះខ្លួនមិនមានទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជា" ។

អាជ្ញាធរ Tsai Ing-wen បានជំរុញ "គោលនយោបាយខាងត្បូងថ្មី Southbound policy" បន្ទាប់ពីចូលកាន់តំណែងក្នុងឆ្នាំ២០១៦ ហើយបានកំណត់ថវិកាចំនួន ២៥ ពាន់លានដុល្លារតៃវ៉ាន់ក្នុងរយៈពេល៤ ឆ្នាំ។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរមិនអាចបង្កើតបណ្តាញទំនាក់ទំនងផ្ទាល់ជាមួយប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើនបានទេ។ ជាឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា ប្រជាជនតៃប៉ិអាចស្វែងរកជំនួយពីការិយាល័យទីក្រុងហូជីមិញក្នុងប្រទេសវៀតណាម ប្រសិនបើពួកគេជួបប្រទះបញ្ហា នេះបើយោងតាមប្រព័ន្ធផ្សព្វផ្សាយតៃប៉ិ៕ *Global Times*

## ក្រុមជួញដូរមនុស្ស ០៤នាក់ ត្រូវប៉ូលិសកំណត់អត្តសញ្ញាណ ក្រោយវៀតណាម៤២នាក់រត់គេចខ្លួនពីកាស៊ីណូកម្ពុជា

https://kohsantepheapdaily.com.kh/ ២៤ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ២១:០៧

វៀតណាម ៖ ប៉ូលិសវៀតណាម បានកំណត់មុខសញ្ញាក្រុមជួញដូរមនុស្ស ចំនួនបួននាក់ ដែលជាប់ពាក់ព័ន្ធការរត់ពន្ធជនជាតិវៀតណាមចំនួន ៤២នាក់ ដែលបានរត់ចេញពីកាស៊ីណូកម្ពុជា កាលពីសប្តាហ៍មុន នេះបើយោងតាមសារព័ត៌មាន VnExpress ។ លោកវរសេនីយ៍ឯក Dinh Van Noi មន្ត្រីនគរបាលវៀតណាមនៅខេត្ត An Giang បាននិយាយកាលពីថ្ងៃអង្គារថា "ពាក់ព័ន្ធការរត់ពន្ធទាំងនេះ ដំណើរការក្នុងមូលដ្ឋានជាច្រើន ដោយមានសហការជាមួយអ្នកសមគំនិត ក្នុងប្រទេសកម្ពុជា ដើម្បីនាំជនជាតិវៀតណាម ចូលធ្វើការក្នុងកាស៊ីណូដោយខុសច្បាប់" ។

អាជ្ញាធរកម្ពុជា កំពុងសហការជាមួយប៉ូលិសខេត្ត An Giang របស់ប្រទេសវៀតណាម និងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីបំពេញនីតិវិធី និងបញ្ជូនជនជាតិវៀតណាម ១១នាក់ផ្សេងទៀតឲ្យទៅប្រទេសកំណើតវិញ

តាមរយៈការទូត ។ ខេត្តកណ្តាលរបស់កម្ពុជា មានកាស៊ីណូសរុបចំនួន០៨ ក្នុងចំណោមនោះកាស៊ីណូមួយបានបញ្ឈប់ប្រតិបត្តិការដោយសារជំងឺកូវីដ-១៩ ខណៈកាស៊ីណូផ្សេងទៀត នៅមានសកម្មភាព ដោយជួលកម្មករបរទេសជាច្រើននាក់ រួមទាំងជនជាតិវៀតណាម ។ ហើយក៏កើតមានករណីជនជាតិវៀតណាម ៤២នាក់ បានរត់ចេញពីកាស៊ីណូមួយ ហែលឆ្លងទន្លេចូលទៅកាន់ខេត្តអានយ៉ាង កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ។

កម្មករ បាននិយាយថា ពួកគេត្រូវបានគេបញ្ចុះបញ្ចូលឲ្យមកប្រទេសកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ឬអ្នកស្គាល់គ្នា ដោយបានទាក់ទាញការសន្យាថា "ការងារងាយស្រួល និងប្រាក់ខែខ្ពស់" ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលពួកគេទៅដល់កាស៊ីណូ ពួកគេមានការភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលដឹងថា ការងារមិនដូចអ្វីដែលពួកគេស្រមៃនោះទេ ។ ជារៀងរាល់ថ្ងៃ កម្មករត្រូវបង្ខំចិត្តចូលធ្វើការលើប្រព័ន្ធអ៊ីនធឺណិត ដើម្បីបោកបញ្ឆោតមនុស្សឲ្យចាក់ភ្នាល់ល្បែងតាមអនឡាញ។ ប្រសិនបើពួកគេមិនបានបំពេញកាតព្វកិច្ចទេ ពួកគេនឹងត្រូវគេវាយដំ រឹបអូសយកប្រាក់ខែ ឬត្រូវបានលក់ទៅឲ្យកាស៊ីណូផ្សេងទៀត ហើយប្រសិនបើពួកគេចង់ចាកចេញ ពួកគេត្រូវទាក់ទងក្រុមគ្រួសាររបស់ពួកគេ ដើម្បីបង់ប្រាក់លោះ រាប់ម៉ឺនដុល្លារ ទើបរួចខ្លួន ។

កាលពីថ្ងៃចន្ទ ទី២២ សីហា ប៉ូលិសខេត្ត An Giang បានឃុំខ្លួនជនសង្ស័យ០២នាក់ គឺឈ្មោះ Nguyen Thi Le និងឈ្មោះ Le Van Danh ដើម្បីស៊ើបអង្កេតពីបទ «ឈ្នួញកណ្តាលរត់ពន្ធមនុស្សដោយខុសច្បាប់ក្នុងប្រទេសវៀតណាម» ។ អាជ្ញាធរកម្ពុជា ក៏បានចាប់ខ្លួន ជនជាតិចិនម្នាក់ ដែលជាម្ចាស់កាស៊ីណូ ដែលជនជាតិវៀតណាមទាំង ៤២នាក់ បានរត់គេចពីទីនោះ ផងដែរ ។ វីដេអូឃ្លីបមួយបានបង្ហោះលើបណ្តាញសង្គម បង្ហាញពីក្រុមជនអន្តោប្រវេសន៍មួយក្រុម បានបុកទម្លុះរបង និងប៉ះទង្គិចគ្នាជាមួយកងសន្តិសុខកាស៊ីណូ ឈ្មោះ Golden Phonix Entertainment ស្ថិតនៅឃុំជ្រៃធំ ស្រុកកោះធំ ខេត្តកណ្តាល វេលាថ្ងៃត្រង់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ។ ពលករវៀតណាមចំនួន ៤២នាក់ បានរត់ទៅលោតចូលទឹកទន្លេ ហែលឆ្លងសំដៅទៅត្រើយម្ខាង នៃប្រទេសវៀតណាម ។ ពលករចំនួន ៤០នាក់រត់គេចដោយសុវត្ថិភាព ប៉ុន្តែម្នាក់ក្នុងចំណោមពួកគេជាក្មេងប្រុសអាយុ១៦ឆ្នាំ ត្រូវលិចបាត់ក្នុងទន្លេ ហើយម្នាក់ទៀត ត្រូវឆ្មាំកាស៊ីណូចាប់បានមកវិញ ។ ក្នុងចំណោម ៤០នាក់ មានស្រ្តី៥នាក់ ៕

## អាជ្ញាធរកម្ពុជាត្រៀមចុះពិនិត្យអគារដែលសង្ស័យថា ប្រើប្រាស់ដើម្បីជួញដូរមនុស្សក្នុងបណ្តាញ Scam

https://khmer.voanews.com/ 22 សីហា 2022

ភ្នំពេញ៖ អាជ្ញាធរពាក់ព័ន្ធនានាត្រៀមចុះពិនិត្យអគារនានានៅទូទាំងប្រទេស ខណៈមានសេចក្តីរាយការណ៍ថា កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងជួញដូរមនុស្ស តាមរយៈការប្រើប្រាស់កម្លាំងបរទេសឱ្យធ្វើការជាអ្នកឆបោកតាមបច្ចេកវិទ្យា ឬហៅថា Scam។ ចំណាត់ការនេះធ្វើឡើងក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាលពីថ្ងៃសុក្រសប្តាហ៍មុន ក្រោយមានបញ្ជារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ឱ្យបើកប្រតិបត្តិការត្រួតពិនិត្យនៅទីកន្លែងដែលមានជនបរទេសស្នាក់នៅ។

លោក ស ខេង បានថ្លែងកាលពីសប្តាហ៍មុនថា៖ «ក្រៅពីនេះ យើងក៏រៀបចំនូវផែនការ ប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សជាក់ស្តែងមួយទៀត ហើយនឹងត្រៀមសម្រាប់ការប្រជុំជាមួយនឹងដៃគូអន្តរជាតិក្នុងការចូលរួមប្រយុទ្ធប្រឆាំងការជួញដូរ»។

លោក ឡុង ឌីម៉ង់ អ្នកនាំពាក្យសាលាខេត្តព្រះសីហនុ ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា អាជ្ញាធរខេត្តបានកំពុងសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យមើលទីកន្លែង អគារនានាក្នុងខេត្តព្រះសីហនុ ដែលសម្បូរអគារខ្ពស់ និងកាស៊ីណូ។ លោកថ្លែងថា៖«សព្វថ្ងៃហ្នឹងមានការចុះត្រួតពិនិត្យទៅតាមអគារ ក៏ដូចជាសហគ្រាសនីមួយៗគឺមានការ

សហការគ្នារវាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ជាមួយនឹងស្នងការនគរបាលខេត្ត ហើយនឹងមន្ទីរការងាររបស់ខេត្ត ដើម្បីត្រួតពិនិត្យការស្នាក់នៅ»។

អ្នកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា រដ្ឋាភិបាលកំពុងតែរៀបចំរចនាសម្ព័ន្ធដើម្បីចាត់ការលើករណីនេះ ខណៈអ្នកស្រីទទួលស្គាល់ថា ពិតជាមានអំពើឆបោកតាមបច្ចេកវិទ្យានៅកម្ពុជា។ ទោះជាយ៉ាងណា អ្នកស្រីថា មិនមែនរាល់ការឆបោកទាំងអស់សុទ្ធតែជាអំពើជួញដូរមនុស្សឡើយ ហេតុនេះហើយការយកករណីទាំងអស់នេះមកលើកឡើងថា ជាអំពើជួញដូរមនុស្ស និងវាយតម្លៃកម្ពុជា វាមិនសមហេតុផលឡើយ។ អ្នកស្រីថ្លែងថា៖ «បើនិយាយពីរឿងបោកបញ្ឆោតតាមបច្ចេកវិទ្យា ជាការណ៍ពិតហើយ ពីព្រោះអ្នកដែលសង្គ្រោះបាន ពួកគាត់ថា ពួកគាត់ចាញ់បោកតាមបច្ចេកវិទ្យាហ្នឹងហើយ។ ប៉ុន្តែបើសិននិយាយថា ទាំងអស់ហ្នឹងសុទ្ធតែជាអំពើជួញដូរមនុស្ស ថា មិនមែនទេ»។

កាលពីថ្ងៃទី២០ ខែសីហា សារព័ត៌មាន Taipei Times បានចុះផ្សាយថា មនុស្សចំនួន១៦នាក់ត្រូវបានចាប់ខ្លួន ដោយប៉ូលិសដាក់ការសង្ស័យថា ពួកគេរួមគំនិតជាមួយអង្គការឧក្រិដ្ឋកម្មបរទេសដើម្បីទាក់ទាញប្រជាជនតៃវ៉ាន់ទៅធ្វើការនៅប្រទេសកម្ពុជាតាមរយៈការសន្យាផ្តល់ឱ្យនូវប្រាក់ខែខ្ពស់។ បើតាម Taipei Times ជនជាតិតៃវ៉ាន់ ដែលត្រូវបានជួយសង្គ្រោះពីការឃុំឃាំងនៅក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា ពួកគេរងការវាយធ្វើបាបលើរូបរាងកាយតាមមធ្យោបាយផ្សេងៗដោយឧក្រិដ្ឋជនជួញដូរមនុស្សនៅក្នុងសណ្ឋាគារនានា ក្នុងខេត្តព្រះសីហនុ។

កាលពីថ្ងៃសុក្រសប្តាហ៍មុន អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិដែលកំពុងបំពេញទស្សនកិច្ចនៅកម្ពុជា លោក វិទិត មុនតាប៊ន(Vitit Muntarbhorn) បានធ្វើដំណើរទៅកាន់ខេត្តព្រះសីហនុ ដើម្បីពិភាក្សាដូចជាសួរនាំអាជ្ញាធរខេត្តពាក់ព័ន្ធករណីជួញដូរមនុស្ស និងការឆបោកតាមបច្ចេកវិទ្យាផងដែរ។

លោក ឡុង ឌីម៉ង់ អភិបាលរងខេត្តព្រះសីហនុ ប្រាប់វីអូអេថា អ្នករាយការណ៍ពិសេសបានទទួលដំណឹងថា ខេត្តព្រះសីហនុបើកចំហឱ្យមានបទល្មើស ដូចជាការបង្ខាំងមនុស្សដោយខុសច្បាប់ ឬក៏ជួញដូរកម្លាំងពលកម្ម និងជួញដូរមនុស្សជាដើម។ លោកបន្ថែមថា នៅក្នុងជំនួបនោះ លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានប្រាប់អ្នករាយការណ៍ពិសេសថា រដ្ឋបាលខេត្តបានសហការជាមួយស្ថាប័នពាក់ព័ន្ធ ហើយខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការដោះស្រាយបញ្ហាទាំងឡាយ ដែលបានកើតឡើង ជាពិសេសនៅពេលដឹងថា មានអំពើជួញដូរមនុស្សនៅកន្លែងណាមួយគឺអាជ្ញាធរតែងតែចុះបង្ក្រាប។ លោកថ្លែងថា៖ «គឺថាបានខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវ ទប់ស្កាត់បទល្មើស ហើយជាពិសេសគឺនៅពេលដែលបានទទួលដំណឹងអំពីបទល្មើសជាក់ស្តែងណាមួយគឺថា កម្លាំងរបស់យើងតែងតែស្រាវជ្រាវ ដើម្បីវែកមុខហើយបង្ក្រាប»។

កាលពីពេលកន្លងទៅ មានសេចក្តីរាយការណ៍ថា កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធើណិត ដោយប្រើប្រាស់កម្លាំងពលកម្មបរទេស ធ្វើការនៅតាមអគារខ្ពស់ៗនៅក្នុងប្រទេសកម្ពុជា រហូតមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឱ្យមានសេរីភាព ធ្វើទារុណកម្ម និងជំរិតទារប្រាក់ជាដើម។

ក្រសួងការបរទេសអាមេរិកបានចេញរបាយការណ៍ប្រចាំឆ្នាំអំពីការជួញដូរមនុស្សនៅលើពិភពលោក កាលពីខែកក្កដា ឆ្នាំ ២០២២។ របាយការណ៍នោះបានបង្ហាញថា កម្ពុជាបានធ្លាក់ចំណាត់ថ្នាក់ពីកម្រិតពីរ (Tier 2)មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំធ្វើអ្វីជាដុំកំភួនដើម្បីកែលម្អ ហើយមិនបានបំពេញតាមបទដ្ឋានអប្បបរមា ដូចដែលបានកំណត់។ របាយការណ៍នេះក៏បានលើកឡើងអំពីការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ីនធើណិត ឬហៅថា Scam ផងដែរ៕

# មន្ត្រីសង្គមស៊ីវិលស្នើស៊ើបអង្កេតអគារកាស៊ីណូដែលសង្ស័យថា មានករណីចាប់បង្ខាំងមនុស្សខុសច្បាប់

https://www.rfa.org/ ដោយ សេក បណ្ឌិត 2022.08.24

មន្ត្រីអង្គការសង្គមស៊ីវិលលើកឡើងថា អាជ្ញាធររដ្ឋាភិបាលគួរតែបង្ហាញព័ត៌មានប្រកបដោយតម្លាភាព ពាក់ព័ន្ធនឹងទីតាំងអគារសហគ្រាសមួយចំនួនគ្រប់គ្រងដោយជនជាតិចិន ដែលសង្ស័យថាមានករណីចាប់បង្ខាំងមនុស្សបង្ខំឱ្យធ្វើការខុសច្បាប់នៅលើទឹកដីកម្ពុជា។ ការលើកឡើងនេះ ធ្វើឡើងបន្ទាប់ពីជនជាតិវៀតណាមជាង ៤០នាក់ថ្មីៗនេះបានសម្រុករត់គេចខ្លួនចេញពីអគារបនល្បែងកាស៊ីណូមួយកន្លែងនៅជ្រៃធំ ខេត្តកណ្ដាល ហើយហែលឆ្លងព្រែកទៅត្រើយម្ខាងនៃទឹកដីវៀតណាមរបស់ខ្លួនវិញ។ ជនជាតិវៀតណាមទាំងនោះថា មូលហេតុដែលនាំឱ្យពួកគេរត់គេចខ្លួនចេញពីអគារបនល្បែងកាស៊ីណូ គឺដោយសារមានថៅកែជនជាតិចិនបានចាប់ឃុំឃាំងពួកគេបង្ខំឱ្យធ្វើទាសករឆបោកតាមប្រព័ន្ធអ៊ីនធឺណិត (Internet) ។

អំពើជួញដូរមនុស្ស ឬករណីជនជាតិចិនចាប់បង្ខាំងជនបរទេសបង្ខំឱ្យធ្វើការខុសច្បាប់នៅកម្ពុជា ហាក់កំពុងល្បីល្បាញខ្លាំងនៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ ជនបរទេសដែលរំដោះខ្លួនចេញពីអគារគ្រប់គ្រងដោយជនជាតិចិនភាគច្រើនពួកគេសុទ្ធតែបានអះអាងប្រហាក់ប្រហែលគ្នាថា ពួកគេត្រូវបានថៅកែជនជាតិចិនបោកបញ្ឆោតឱ្យធ្វើការខុសច្បាប់ តាមរយៈការល្បួងបញ្ចុះបញ្ចូលឃោសនាការងារដែលទទួលបានប្រាក់ខែខ្ពស់។ មន្ត្រីសង្គមស៊ីវិល លើកឡើងថា អាជ្ញាធររដ្ឋាភិបាលគួរតែមានការស៊ើបអង្កេតដោយឯករាជ្យលើករណីជនបរទេសមកធ្វើការនៅកម្ពុជា ជាពិសេសអគារសហគ្រាស ឬបនល្បែងកាស៊ីណូដែលគ្រប់គ្រងដោយជនជាតិចិន ដែលសង្ស័យថាមានករណីចាប់បង្ខាំងមនុស្សនៅកម្ពុជា។

នាយកទទួលបន្ទុកផ្នែកសិទ្ធិមនុស្សអង្គការលីកាដូ (LICADHO) លោក អំ សំអាត ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២៣ សីហាថា បើករណីជនបរទេសមួយចំនួនមកធ្វើការនៅកម្ពុជាអះអាងថា ខ្លួនរងការចាប់បង្ខាំងមនុស្សឱ្យធ្វើការខុសច្បាប់ ហើយមន្ត្រីអាជ្ញាធរនៅតែគ្មានការស៊ើបអង្កេត បកស្រាយឱ្យបានច្បាស់លាស់លើករណីនេះនោះកម្ពុជានឹងអាចក្លាយជាប្រទេសមួយដែលមានកេរ្តិ៍ឈ្មោះអាក្រក់។ លោកព្រួយបារម្ភថា បើករណីជនជាតិចិនចាប់បង្ខាំងជនបរទេសឱ្យធ្វើការខុសច្បាប់នៅកម្ពុជាពិតមែននោះ វានឹងធ្វើប៉ះពាល់ដល់មុខមាត់ប្រទេសជាតិ និងគំរាមកំហែងដល់ប្រជាពលរដ្ឋខ្មែរធ្ងន់ធ្ងរ។ លោក អំ សំអាត ជំរុញដល់អាជ្ញាធរកម្ពុជាគួរមានការពង្រឹងកិច្ចសហការជាមួយបណ្ដាប្រទេសជិតខាងមួយចំនួនដែលអះអាងថា មានពលរដ្ឋខ្លួនជាប់គាំងបង្ខាំងក្នុងអគារ ដើម្បីរកឱ្យឃើញមូលហេតុពិតប្រាកដ។ លោក លើកឡើងបន្តថា ភាពចម្រូងចម្រាសពាក់ព័ន្ធនឹងករណីចាប់បង្ខាំងមនុស្សនៅកម្ពុជានេះ គឺទាមទារដល់រដ្ឋាភិបាល និងអាជ្ញាធរជំនាញ មានឆន្ទៈ និងការតាំងចិត្តខ្ពស់ ទើបមានការបង្ក្រាប និងទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជានេះមានប្រសិទ្ធភាព៖ «ហើយទីពីរពង្រឹងការអនុវត្តច្បាប់។

ប្រសិនបើមានអ្នកពាក់ព័ន្ធ ជាមួយនឹងការជួញដូរមនុស្សហ្នឹង ទោះបីជាឋានន្តរសក្តិ ឬអំណាចប៉ុណ្ណាក៏ត្រូវតែមានការតាមផ្លូវអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ហ្នឹងទើបអាចធ្វើការទប់ស្កាត់ទៅបាន។ ទីបីត្រូវសហការជាមួយបណ្ដាប្រទេសជិតខាង ព្រោះលំហូរចូល មិនដែលជនបរទេស ចូលមកស្រុកខ្មែរដោយខុសច្បាប់ ធ្លាក់ពីណាមកទេ គឺមានការឆ្លងដែន។ អ៊ីចឹងត្រូវតែមានការ កិច្ចសហប្រតិបត្តិការ ជាមួយនឹងប្រទេសជិតខាង ដើម្បីធ្វើទប់ស្កាត់»។ ក្តីបារម្ភរបស់មន្ត្រីសង្គមស៊ីវិលរូបនេះ កើតឡើងក្រោយពេលដែលកំណើននៃករណីចាប់បង្ខាំងមនុស្សបង្ខំឱ្យធ្វើការខុសច្បាប់ដែលប្រតិបត្តិការដោយក្រុមហ៊ុនចិននៅកម្ពុជាហាក់កំពុងរីកដុះដាលយ៉ាងខ្លាំង ខណៈសង្វាក់អាជីវកម្មក្រុមហ៊ុនចិនឆបោកទាំងនោះភាគច្រើនជ្រកក្រោមស្លាកអគារបនល្បែង ដែលកំពុងដំណើរការហាក់មានភាពអាថ៌កំបាំងច្រើន។

កាលពីថ្ងៃទី១៨ ខែសីហា សារព័ត៌មានតៃវ៉ាន់បានរាយការណ៍ថា យ៉ាងហោចណាស់មានពលរដ្ឋតៃវ៉ាន់ជិត ៤រយនាក់(៣៧៣នាក់) ត្រូវបានក្រុមជនល្មើសបោកបញ្ឆោតឱ្យធ្វើការឱ្យក្រុមហ៊ុនឆបោកតាមអនឡាញនៅកម្ពុជា តាមរយៈការផ្សាយពាណិជ្ជកម្មការងារក្លែងក្លាយ។ ក្នុងនោះមានពលរដ្ឋតៃវ៉ាន់ជាង១រយនាក់ (១៤៤នាក់) ត្រូវបានបង្ខាំងទុកក្នុងអគារ បង្ខំឱ្យធ្វើការដោយខុសច្បាប់នៅកម្ពុជា។ ដោយឡែក កាលពីថ្ងៃទី១៩ ខែសីហា ទីភ្នាក់ងារសារព័ត៌មានបារាំង អា.អេហ្វ.ប៉េ (AFP) បានរាយការណ៍ថា កម្មករកាស៊ីណូជនជាតិវៀតណាមប្រមាណ ៤២នាក់ ធ្វើការឱ្យកាស៊ីណូមួយឈ្មោះ ហ្គោលដឹនភិននិក អ៊ីនដឺថេនមេន កាស៊ីណូ (Golden Phoenix Entertainment Casino) ស្ថិតក្នុងឃុំជ្រៃធំ ស្រុកកោះធំ ខេត្តកណ្ដាល ត្រូវបានគេបង្ខំឱ្យធ្វើការដោយពុំបើកប្រាក់ឈ្នួល។ វីដេអូដែលគេបានផ្សព្វផ្សាយនៅលើបណ្ដាញសង្គមបានបង្ហាញថា កម្មករជនជាតិវៀតណាមទាំងនោះបានរត់ចេញពីអគារក្រុមហ៊ុនចិនទឹកមុខរបស់ពួកគាត់ហាក់មានអារម្មណ៍តក់ស្លុត និងភ័យខ្លាច។ ជាងនេះទៅទៀត ភ្លាមៗក្នុងពេលដែលជនជាតិវៀតណាមទាំងនោះបានរត់គេចខ្លួនពី កាស៊ីណូមួយឈ្មោះ ហ្គោលដឹនភិននិក អ៊ីនដឺថេនមេន កាស៊ីណូ ជនជាតិចិន និងក្រុមសន្តិសុខ ក៏បានទាញបំពង់ដែក និងដំបងដេញវាយទៅលើជនជាតិវៀតណាមទាំងនោះ ដែលបណ្ដាលឱ្យរងរបួសមួយចំនួនទៀតផង។ ជនជាតិវៀតណាមទាំងនោះ បានបង្ខំចិត្តសម្រុករត់គេចចេញពីទីតាំងកាស៊ីណូ ដោយបានលោតចូលក្នុងទឹកទន្លេស្ថិតក្នុងតំបន់ព្រែកបិនឌី (Binh Di) ឆ្លងទៅត្រើយម្ខាងទៀតនៃប្រទេសវៀតណាមវិញ។ ក្នុងនោះជនជាតិវៀតណាមម្នាក់បានស្លាប់ពេលដែលកំពុងហែលទឹកទន្លេចាកចេញពីកម្ពុជាសំដៅទៅប្រទេសកំណើតវិញ។ កម្មករជនជាតិវៀតណាម ដែលរំដោះខ្លួនចេញពីអគារក្រុមហ៊ុនចិននៅកម្ពុជា ពួកគេមួយចំនួនបានអះអាងប្រាប់អាជ្ញាធរ និងប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសពួកគេ ថាពួកគេពិតជាត្រូវបានជនជាតិចិនឃុំឃាំងក្នុងអគារដែលមានសភាពងងឹត ហើយបង្ខំឱ្យធ្វើការងារខុសច្បាប់នៅកម្ពុជា។

ទាក់ទងនឹងរឿងនេះ វិទ្យុអាស៊ីសេរីមិនអាចទាក់ទងស្នងការនគរបាលខេត្តកណ្ដាល លោក ឈឿន សុចិត្រ ដើម្បីការបំភ្លឺពីបញ្ហានេះបានទេ ដោយទូរស័ព្ទហៅចូលតែលោកចុចផ្ដាច់។ ចំណែក អភិបាលខេត្តកណ្ដាល លោក គង់ សោភ័ណ្ឌ និងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន ក៏មិនអាចទាក់ទងបានដែរនៅថ្ងៃទី២៣ សីហា។ ប៉ុន្តែ អភិបាលរងខេត្តកណ្ដាល លោក គ្រុយ ម៉ាឡែន បានប្រាប់វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ថ្មីៗនេះថា ករណីជនជាតិវៀតណាមរត់គេចខ្លួនពីអគារកាស៊ីណូក្នុងខេត្តកណ្ដាលកន្លងទៅនេះ មិនមែនជាករណីចាប់បង្ខាំងឡើយ។ លោកអះអាងថា កម្មករជនជាតិវៀតណាមទាំងនោះក្រុមហ៊ុនក៏បើកប្រាក់ខែឱ្យពួកគេត្រឹមត្រូវជាប្រចាំខែដែរ។ បន្ថែមពីនេះទៀត លោកចោទថា ក្រុមកម្មករជនជាតិវៀតណាមរត់គេចខ្លួននោះ គឺពួកគេព្យាយាមគេចពីការទទួលខុសត្រូវលើការងាររបស់ខ្លួនពាក់ព័ន្ធនឹងការខ្ចីបំណុលពីក្រុមហ៊ុនយកមកលេងល្បែង។

កាលពីថ្ងៃទី១៨ សីហា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ធ្វើសន្និសីទកាសែតមួយ ដោយអះអាងថា កម្លាំងនគរបាលធ្វើប្រតិបត្តិការឆែកឆេរការស្នាក់នៅរបស់ជនបរទេសប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្នុងបេសកកម្មសង្គ្រោះជនរងគ្រោះ និងចាប់មេខ្លោងយកមកផ្ដន្ទាទោស។ លោកឱ្យដឹងថា ករណីជនជាតិវៀតណាមរត់ចេញពីអគារបនល្បែងក្នុងខេត្តកណ្ដាល សមត្ថកិច្ចឃាត់ខ្លួនមេការ និងជនរងគ្រោះមួយចំនួន។ លោកថា នៅខេត្តព្រះសីហនុក៏ដូចគ្នាដែរ សមត្ថកិច្ចកំពុងត្រួតពិនិត្យលើការស្នាក់នៅរបស់ជនបរទេសនេះ ហើយមានអ្នកខ្លះបានអះអាងថាខ្លួនជាជនរងគ្រោះដែលសមត្ថកិច្ចពិនិត្យជាក់ស្ដែងគឺមានជនជាតិអាមេរិកខ្មែរអាមេរិក និងឥណ្ឌូណេស៊ី ជាដើម។

លោក ស ខេង បញ្ជាក់ទៀតថា ចំពោះអ្នកហែលទឹកទៅប្រទេសវៀតណាមនោះ ប្រហែលពួកគេមកធ្វើការដោយខុសច្បាប់នៅកម្ពុជា ព្រោះពេលមកដល់ជជែកមិនត្រូវគ្នារឿងកិច្ចសន្យាការងារក៏នាំគ្នារត់ចេញ ហើយហែលឆ្លងព្រែកទៅខាងវៀតណាមវិញ៖ «ស្ថានភាពខ្លះ មិនពិតទាំងស្រុងទេ ប៉ុន្តែខ្លះក៏ពិត យើងសង្គ្រោះ ព្រោះ

បេសកកម្មរបស់យើងទីមួយសង្គ្រោះជនរងគ្រោះ ទីពីរគឺយើងចាប់មេខ្លោងពាក់ព័ន្ធដើម្បីយកមកផ្ដន្ទាទោសតាមផ្លូវច្បាប់»។

ជុំវិញរឿងនេះដែរ អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) លោក ស៊ឹង សែនករុណា មានប្រសាសន៍ថា ករណីជនជាតិវៀតណាមរត់គេចខ្លួនពីអគារបនល្បែងនៅកម្ពុជានេះ អាជ្ញាធរកម្ពុជាគួរតែមានការសិក្សាឱ្យបានស៊ីជម្រៅ ជាពិសេសត្រូវដែដែកពិភាក្សាជាមួយជនជាតិវៀតណាមទាំងនោះ ដើម្បីរកឱ្យឃើញបញ្ហាពិតប្រាកដ ដើម្បីអនុវត្តការងារមានប្រសិទ្ធភាព។ លោកលើកឡើងថា សារព័ត៌មានអន្តរជាតិធំៗបានផ្សព្វផ្សាយជាបន្តបន្ទាប់ចំពោះករណីជនបរទេសរាប់រយនាក់ ត្រូវបានក្រុមជនឆបោកចាប់បង្ខាំងឱ្យធ្វើការខុសច្បាប់នៅកម្ពុជា។ លោកថា បញ្ហានេះ បើអាជ្ញាធរតែបន្តបដិសេធដោយគ្មានការស៊ើបអង្កេតជាមុននោះ នឹងធ្វើឱ្យប៉ះពាល់ដល់មុខមាត់ជាតិ និងធ្វើឱ្យអ្នកវិនិយោគល្អៗនៅកម្ពុជាមានការព្រួយបារម្ភពីបញ្ហាសុវត្ថិភាពបន្ថែមទៀត៖ «ខ្ញុំជឿជាក់ថា សារព័ត៌មានទាំងអស់នោះគេគ្មានហេតុផលអ្វីទៅប្រឌិតព័ត៌មានដើម្បីឱ្យប៉ះពាល់មុខមាត់ប្រទេសកម្ពុជាទេ ប្រសិនបើមិនមានករណីបែបនេះកើតឡើង។ អ៊ីចឹងសមត្ថកិច្ចគប្បី បើកការស្រាវជ្រាវ ឱ្យបានល្អិតល្អន់ ហើយរកឃើញហើយហ្នឹងគួរតែមានការទប់ស្កាត់ និងចាត់វិធានការទៅលើជនទាំងអស់នោះឱ្យខ្លាំងក្លា ដើម្បីបង្ហាញទៅឱ្យសហគមន៍អន្តរជាតិថា រដ្ឋាភិបាលកម្ពុជាមិនបាន នៅស្ងៀមចំពោះអំពើបង្ខាំងមនុស្ស ឬអំពើធ្វើទុក្ខបុកម្នេញទៅលើមនុស្សគ្រប់ជាតិសាសន៍ដែលមកកម្ពុជាបែបហ្នឹងទេ»។

ស្ថាប័នសារព័ត៌មានអន្តរជាតិល្បីៗមួយចំនួន បន្តរាយការណ៍ជាបន្តបន្ទាប់អំពីប្រតិបត្តិការអាជីវកម្មបែបឧក្រិដ្ឋកម្មពាក់ព័ន្ធការជួញដូរមនុស្សនៅកម្ពុជា។ ស្ថាប័នសារព័ត៌មានអន្តរជាតិមួយចំនួនក៏បានលាតត្រដាងថា ជំនួញអាជីវកម្មទាំងនោះភាគច្រើនកំពុងគ្រប់គ្រងដោយក្រុមហ៊ុនចិន និងបានឃុបឃិតគ្នាជាមួយបុគ្គលមានលុយមានអំណាច ដែលមានឥទ្ធិពលក្នុងជួររដ្ឋាភិបាល លោក ហ៊ុន សែន កំពុងប្រតិបត្តិការចាប់បង្ខាំងមនុស្សបង្ខំឱ្យធ្វើជាទាសករតាមប្រព័ន្ធអ៊ីនធឺណិត។ ទោះជាយ៉ាងណា ទន្ទឹមនឹងមានការរកឃើញករណីបែបនេះ មន្ត្រីជាន់រដ្ឋាភិបាលមួយចំនួនក៏បានចេញមុខប្រតិកម្មថាប្រព័ន្ធផ្សព្វផ្សាយរបស់ស្ថាប័នសារព័ត៌មានអន្តរជាតិទាំងនោះជាយុទ្ធនាការរបស់ក្រុមបក្សប្រឆាំងទៅវិញ៕

## ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២

### សម្ដេចស ខេង ប្រាប់អ្នករាយការណ៍ពិសេស UN ថានឹងដឹកនាំបង្ក្រាបចាប់មេខ្លោងជួញដូរមនុស្សមកផ្ដន្ទាទោសឲ្យបាន

https://kohsantepheapdaily.com.kh/ ភ្នំពេញ២៥ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ០៩:៤១

រាជធានីភ្នំពេញ ៖ សម្តេចក្រឡាហោម សខេងឧបកនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រាប់អ្នករាយការណ៍ពិសេសរបស់ UN ថា នាពេលឆាប់ៗនេះ សម្តេចនឹងបន្តដឹកនាំ ដើម្បី ដាក់ចេញផែនការតស៊ូបង្ក្រាប និងប្រយុទ្ធប្រឆាំងបទល្មើសនេះ ព្រមទាំង ដើម្បីកៀរគរការចូលរួមចំណែកផ្តល់កិច្ចសហការពីបណ្តាភាគីពាក់ព័ន្ធឈានទៅបង្ក្រាបមេខ្លោងប្រព្រឹត្តបទល្មើស ការជួយដូរមនុស្សយកមកផ្តន្ទាទោសតាមច្បាប់ ។

ក្នុងជំនួបជាមួយលោកសាស្ត្រាចារ្យ វិធិត ម៉ាន់តាផន អ្នករាយការណ៍ពិសេសសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា កាលពីថ្ងៃទី២៤ សីហា ឆ្នាំ២០២២ នៅទីស្តីការក្រសួងសម្តេចបានលើកឡើងពីប្រព័ន្ធគ្រប់គ្រងពន្ធនាគារ និងយុត្តិធម៌ព្រហ្មទណ្ឌថា បញ្ហានេះនៅមានបញ្ហាប្រឈមមួយចំនួនដែល ក្រសួងកំពុងតែខិតខំដោះស្រាយ និងរៀបចំឲ្យបានល្អប្រសើរ និងថា បច្ចុប្បន្នក្រសួងមហាផ្ទៃកំពុងយកចិត្តទុកដាក់កែលម្អ និងកសាងបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ ដើម្បីដោះស្រាយ បញ្ហាប្រឈមនៃភាពចង្អៀតណែនក្នុងពន្ធនាគារ ។ សម្តេច

បន្ថែមថា ទន្ទឹមនោះក្រសួងមហាផ្ទៃក៏កំពុងសហការជាមួយនឹងក្រសួងយុត្តិធម៌ ដើម្បីអនុវត្តនូវវិធានការមួយចំនួនដូចជា ការដោះលែងក្រោមលក្ខខណ្ឌ និងការតាមដានរបស់ តុលាការ និងមួយទៀត គឺការសិក្សាទៅលើការអនុវត្តនូវយន្តការទោសសហគមន៍ជំនួសឲ្យការឃុំឃាំង ដោយកិច្ចការទាំងនេះត្រូវតែអនុវត្តដោយមានការប្រុងប្រយ័ត្នខ្ពស់ដើម្បីធានា ដល់ ប្រសិទ្ធភាពយន្តការក៏ដូចជា រួមចំណែកកាត់បន្ថយនូវភាពមិនចង្អៀតណែនក្នុងពន្ធនាគារផង ។

ចំពោះពាក់ព័ន្ធទៅនឹងការស្តារនីតិសម្បទាអ្នកញៀនគ្រឿ.ងញៀន សម្តេចក្រឡាហោម បានជម្រាបជូនលោកសាស្ត្រាចារ្យថា ជាង៥០ភាគរយនៃអ្នកជាប់ឃុំនៅក្នុងពន្ធនាគារ គឺជាអ្នកដែលពាក់ព័ន្ធទៅនឹងបទល្មើសគ្រឿងញៀ.ន ដោយក្រសួងមហាផ្ទៃកំពុងតែយកចិត្តទុកដាក់ ដើម្បីបន្តដោះស្រាយបញ្ហានេះ តាមរយៈការខិតខំពង្រីកមជ្ឈមណ្ឌលស្តារ នីតិសម្បទា គ្រឿងញៀ.ន និងការលើកទឹកចិត្តដល់រាជធានីខេត្ត ក្នុងការបន្តគាំទ្រដល់ការបង្កើតឲ្យមានមជ្ឈមណ្ឌលស្តារនីតិសម្បទានៅក្នុងរាជធានី-ខេត្តនីមួយៗ និងបន្តកៀរគរការចូលរួមពីវិស័យឯកជន ដើម្បីគាំទ្រដល់កិច្ចការនេះ ។ សម្តេចក៏បានជម្រាបជូនទៀតថា សម្តេចសូមស្វាគមន៍ចំពោះការចូលរួមរបស់ភ្នាក់ងារពាក់ព័ន្ធនៅក្រោមឆត្ររបស់អង្គការសហប្រជាជាតិ ព្រមទាំងដៃគូនានានៅក្នុងកិច្ចការ ស្តារនីតិសម្បទាអ្នកញៀ.នគ្រឿងញៀ.ន ក៏ដូចជា ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀ.ន ដើម្បីធ្វើយ៉ាងណា ផ្តល់នូវលទ្ធភាពឲ្យកាន់តែច្រើនថែមទៀត ប្រកបដោយប្រសិទ្ធភាពក្នុងការស្តារនីតិសម្បទាអ្នកញៀ.នគ្រឿងញៀ.ននេះ ។

ពាក់ព័ន្ធទៅនឹងការប្រឆាំងនឹងអំពើជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចលើពលកម្មនោះ សម្តេចបានជម្រាបជូនលោកសាស្ត្រាចារ្យ វិធិត ម៉ាន់តាផនថា កម្ពុជាក៏ជាប្រទេសដែលរងគ្រោះដោយសារអំពើទាំងនេះដោយហេតុថា ពួកឧក្រិដ្ឋជនបានឆ្លៀតការកេងចំណេញទៅលើចំណុចខ្សោយមួយចំនួន ហើយយកកម្ពុជាជាកន្លែង ដើម្បីធ្វើការឆបោក ប្រព្រឹត្តអំពើជួញដូរគត់ពន្ធមនុស្សនេះ ។ ជាមួយគ្នានោះដែរ សម្តេចក្រឡាហោម ក៏បានជម្រាបជូនលោកសាស្ត្រាចារ្យ អំពីការ ប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា ក្រសួងមហាផ្ទៃក្នុងការចាត់វិធានការជាបន្តបន្ទាប់ ហើយបានបង្ក្រាបក៏ដូចជា ជួយសង្គ្រោះជនរងគ្រោះបានអស់ជាច្រើននាក់នៅក្នុងរយៈពេលកន្លងមក និងក៏បានបន្តធ្វើកិច្ចការនេះជាប្រចាំផងដែរ ។ សម្តេចឱ្យដឹងថា នាពេលឆាប់ៗនេះ សម្តេចនឹងបន្តដឹកនាំដើម្បីដាក់ចេញផែនការត ស៊ូបង្ក្រាប និងប្រយុទ្ធប្រឆាំងបទល្មើសនេះ ព្រមទាំងដើម្បីកៀរគរការចូលរួមចំណែកផ្តល់កិច្ចសហការពីបណ្តាភាគីពាក់ព័ន្ធឈានទៅបង្ក្រាបមេខ្លោងប្រព្រឹត្តបទល្មើសនេះយកមកផ្តន្ទាទោសតាមច្បាប់ ។

សូមជម្រាបថា កាលើកឡើងរបស់សម្តេច ស ខេង បន្ទាប់ពីលោកសាស្ត្រាចារ្យ វិធិត ម៉ាន់តាផន បានជម្រាបសម្តេចក្រឡាហោមនូវចំណុចចំនួន៥ធំៗក្នុងនោះមាន ៖ បញ្ហាទីមួយ គឺពាក់ព័ន្ធទៅនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, បញ្ហាទីពីរ គឺពាក់ព័ន្ធទៅនឹងប្រព័ន្ធនៃការរៀបចំគ្រប់គ្រងពន្ធនាគារ និងយុត្តិធម៌ព្រហ្មទណ្ឌ, បញ្ហាទីបី គឺការស្តារ នីតិសម្បទា អ្នកញៀ.នគ្រឿងញៀ.ន, បញ្ហាទីបួន គឺអំពីការជួញដូរមនុស្ស ការជួញដូរពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចលើពលកម្ម និងបញ្ហាទីប្រាំ គឺអំពីកិច្ចសហប្រតិបត្តិការ និងជំនួយអាទិភាពផ្សេងៗ របស់អង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងការងារសិទ្ធិមនុស្ស ចំពោះវិស័យស្ថិតនៅក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ៕

## សម្តេច ស ខេង ប្រាប់ UN ថា កម្ពុជា ជាប្រទេសរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងជាកន្លែងដើម្បីឆបោក

https://dap-news.com/ ByDR103Posted on August 25, 2022

ភ្នំពេញ ៖ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រាប់អ្នករាយការណ៍ពិសេស UN ថា កម្ពុជា ជាប្រទេស រងគ្រោះដោយសារអំពើជួញដូរមនុស្ស ដោយហេតុថា ពួកឧក្រិដ្ឋជនយកកម្ពុជា ជាទីកន្លែងដើម្បីធ្វើការឆបោក ប្រព្រឹត្តអំពើជួញដូរគត់ពន្ធមនុស្ស។

នាឱកាសអនុញ្ញាតជូន លោក វិធិត ម៉ាន់តាផន អ្នករាយការណ៍ពិសេស សិទ្ធិមនុស្សរបស់ អង្គការសហប្រជាជាតិ ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នាថ្ងៃទី២៤ សីហា សម្តេច ស ខេង បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជា ដូចជា ក្រសួងមហាផ្ទៃ បានប្តេជ្ញាចិត្ត ក្នុងការចាត់វិធានការជាបន្តបន្ទាប់ ហើយបានបង្ក្រាបក៏ដូចជាជួយសង្គ្រោះ ជនរងគ្រោះបានអស់ជាច្រើននាក់ នៅក្នុងរយៈពេលកន្លងមក និងក៏បានបន្តធ្វើកិច្ចការនេះ ជាប្រចាំផងដែរ។ សម្តេចបញ្ជាក់ថា «កម្ពុជាក៏ជាប្រទេស ដែលរងគ្រោះដោយសារអំពើទាំងនេះ ដោយហេតុថាពួកឧក្រិដ្ឋជន បានឆ្លៀតការកេងចំណេញទៅលើចំណុចខ្សោយមួយចំនួន ហើយយកកម្ពុជា ជាកន្លែងដើម្បីធ្វើការឆបោក ប្រព្រឹត្តអំពើជួញដូរគេចពន្ធ មនុស្សនេះ»។

សម្តេចឲ្យដឹងថា នាពេលឆាប់ៗនេះ សម្តេច នឹងបន្តដឹកនាំ ដើម្បីដាក់ចេញផែនការតស៊ូបង្ក្រាប និងប្រយុទ្ធប្រឆាំងបទល្មើសនេះ ព្រមទាំងដើម្បីកៀរគរការចូលរួមចំណែក ផ្តល់កិច្ចសហការពីបណ្តាភាគីពាក់ព័ន្ធ ឈានទៅបង្ក្រាបមេខ្លោង ប្រព្រឹត្តបទល្មើសនេះយកមកផ្តន្ទាទោសតាមច្បាប់។ ឆ្លៀតឱកាសនោះដែរ សម្តេច ស ខេង ក៏បានលើកឡើងដែរថា ក្រសួងមហាផ្ទៃ ក៏កំពុងសហការជាមួយ ក្រសួងយុត្តិធម៌ ដើម្បីអនុវត្តវិធានការមួយចំនួនដូចជាការដោះលែងក្រោមលក្ខខណ្ឌ និងការតាមដានរបស់តុលាការ និងមួយទៀត គឺការសិក្សា ទៅលើការអនុវត្តនូវយន្តការទោសសហគមន៍ ជំនួសឲ្យការឃុំឃាំង ដោយកិច្ចការទាំងនេះ ត្រូវតែអនុវត្តដោយមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាដល់ប្រសិទ្ធភាពយន្តការ ក៏ដូចជារួមចំណែកកាត់បន្ថយ នូវភាពមិនចង្អៀតណែនក្នុងពន្ធនាគារផង៕

## លោក គួច ចំរើន ប្រកាសប្រើ«ធម៌ក្តៅ»បញ្ជាឲ្យតាមចាប់ខ្លួនមេខ្លោងដែលជួញដូរ និងបង្ខាំងមនុស្សខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៥ សីហា ២០២២ដោយ vann sokunthea

លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានប្រកាសប្រើ«ធម៌ក្តៅ»ចំពោះបញ្ហាការទិញលក់ពលកម្ម ការជួញដូរ និងការបង្ខាំងមនុស្សដោយខុសច្បាប់ នៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ នៅព្រឹកថ្ងៃព្រហស្បតិ៍នេះ។ វិធានការដាច់ណាត់របស់លោក គួច ចំរើន នេះគឺបន្ទាប់ពីមានព័ត៌មានលេចលឺថា នៅក្នុងខេត្តព្រះសីហនុ មានការជួញដូរពលកម្ម និងការបង្ខាំងមនុស្សដោយខុសច្បាប់ ជាពិសេស ទៅលើជនជាតិវៀតណាម ចិន និងឥណ្ឌូនេស៊ីជាដើម។

តាមរយៈសេចក្តីប្រកាសព័ត៌មាន លោក គួច ចំរើន បានចេញបញ្ជាដាច់ខាតឲ្យគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តព្រះសីហនុ ដោយមានព្រះរាជអាជ្ញា ជាអ្នកដឹកនាំការស្រាវជ្រាវ និងសម្របសម្រួលនីតិវិធី ពាក់ព័ន្ធនឹងការទិញ-លក់ពលកម្ម ការជួញដូរ ការបង្ខាំង និងត្រូវចាប់ខ្លួនជនល្មើសយកមកផ្តន្ទាទោសតាមច្បាប់ឱ្យបានធ្ងន់ធ្ងរជាដាច់ខាត។ ដោយឡែក ចំពោះទីតាំងដែលជនល្មើសប្រើប្រាស់សម្រាប់ការទិញ-លក់កម្លាំងពលកម្ម ការជួញដូរ និងការបង្ខាំងមនុស្សដោយខុសច្បាប់ គឺត្រូវបិទអាជីវកម្មជាដាច់ខាត និងនាំយកជនល្មើស និងម្ចាស់ទីតាំងដែលចូលរួមសមគំនិត មកផ្តន្ទាទោសតាមច្បាប់ឱ្យបានធ្ងន់ធ្ងរ និងដោយគ្មានការលើកលែងឡើយ។

មិនតែប៉ុណ្ណោះ អាជ្ញាធរខេត្តព្រះសីហនុ ក៏បានអះអាងបន្ថែមថា ចំពោះប្រតិបត្តិការស្រាវជ្រាវ និងបង្ក្រាបករណីការទិញ-លក់ពលកម្ម ការជួញដូរ និងការបង្ខាំងមនុស្សដោយខុសច្បាប់ នៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ គឺអាជ្ញាធរពាក់ព័ន្ធ នឹងអនុវត្តឱ្យបានហ្មត់ចត់ជាទីបំផុត ដោយស្រាវជ្រាវឱ្យដល់ឫសគល់ និងមេក្លោង ដើម្បីនាំខ្លួនជនល្មើសមកផ្តន្ទាទោសតាមច្បាប់ឱ្យខាងតែបាន៕ ដោយ៖ វណ្ណ សុគន្ធា

# ក្រុមឆបោកទូរគមនាគមន៍ត្រូវបានគេចោទថានាំជនជាតិតៃវ៉ាន់ចូលក្នុងទាសករតាមអ៊ីនធឺណិតនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 25, 2022

ក្រុមអ្នកជួញដូរ ដែលភាគច្រើនមានទំនាក់ទំនងជាមួយក្រុមសង្គមងងឹត (triads) ដ៏ល្បី ដែលភាគច្រើនផ្តោតគោលដៅលើយុវជនអាស៊ីតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយសន្យាថាពួកគេទទួលបានការងារដែលមានប្រាក់ខែខ្ពស់ និងស្នាក់នៅក្នុងប្រទេសដូចជាកម្ពុជា ថៃ មីយ៉ាន់ម៉ា និងឡាវ។ នៅពេលដែលពួកគេមកដល់ លិខិតឆ្លងដែនរបស់ពួកគេត្រូវបានលួច ហើយពួកគេត្រូវបានលក់ជាញឹកញាប់ទៅឱ្យក្រុមផ្សេងៗ ហើយត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងគ្រឹះស្ថានដែលពាក់ព័ន្ធនឹងការលួចបន្លំតាមទូរស័ព្ទ ឬគេហទំព័រខុសច្បាប់។

កាសែត The Guardian បានរាយការណ៍ថា អាជ្ញាធរបានរាយការណ៍ថា ជនជាតិតៃវ៉ាន់រាប់រយនាក់ ស្ថិតក្នុងចំណោមអ្នកដែលត្រូវបានឃុំខ្លួនជាច្រើន ដែលកំពុងត្រូវបានបង្ខាំងខ្លួនប្រឆាំងនឹងឆន្ទៈរបស់ពួកគេ និងត្រូវបានបង្ខំឱ្យធ្វើការក្នុងបណ្តាញក្លែងបន្លំទូរគមនាគមន៍ ដោយអង្គការជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍។ ប្រតិបត្តិការចម្បងនានាត្រូវបានចាប់ផ្តើមដោយកងកម្លាំងនគរបាលនៅតៃវ៉ាន់ ចិន ហុងកុង ម៉ាកាវ និងវៀតណាម ដើម្បីជួយសង្គ្រោះពលរដ្ឋរបស់ពួកគេ និងបំបែកបណ្តាញជួញដូរមនុស្ស។ ជនជាតិវៀតណាម និងតៃវ៉ាន់ ទំនងជាមានអ្នកស្លាប់ និងរបួសច្រើនជាងគេ។ អាជ្ញាធរតៃវ៉ាន់អះអាងថា ពលរដ្ឋខ្លួនជាង ៥ពាន់នាក់បានចូលប្រទេសកម្ពុជា ហើយមិនបានត្រឡប់មកវិញទេ។ ទោះបីជាជនរងគ្រោះអះអាងថា ទំនងជាមានច្រើននាក់ទៀតក៏ដោយ ប៉ូលីសបានបញ្ជាក់ថា ពួកគេបានកំណត់អត្តសញ្ញាណយ៉ាងហោចណាស់ ៣៧០ ក្នុងចំណោមពួកគេត្រូវបានគេបង្ខាំងខ្លួនប្រឆាំងនឹងឆន្ទៈរបស់ពួកគេ។

យ៉ាងហោចណាស់មនុស្ស ៤៦ នាក់ បានធ្វើដំណើរត្រឡប់ទៅតៃវ៉ាន់វិញនាពេលថ្មីៗនេះ។ ពួកគេខ្លះអះអាងថាពួកគេ ឬអ្នកផ្សេងទៀតត្រូវបានបង្ខំឱ្យចុះហត្ថលេខាលើកិច្ចសន្យា ខណៈដែលអ្នកផ្សេងទៀតអះអាងថាពួកគេត្រូវបានគេរំលោភបំពាន រំលោភសេពសន្ថវៈ បង្អត់អាហារ និងទឹក និងត្រូវបានគំរាមកំហែងជាទៀងទាត់។ នៅកម្ពុជា ការអនុវត្តច្បាប់ដែលគ្មានប្រសិទ្ធភាព និងអំពើពុករលួយបានធ្វើឲ្យការសង្គ្រោះមានភាពស្មុគស្មាញ ឬឧបសគ្គ។ យោងតាមគណនីផ្សេងៗដែលបានរាយការណ៍ ពិរុទ្ធជនរួមមាន ជនជាតិតៃវ៉ាន់ ចិន ថៃ និងខ្មែរ។

ក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ព័ត៌មាននៃបណ្តាញជួញដូរបានទទួលការរាយការណ៍យ៉ាងទូលំទូលាយនៅអាស៊ី។ វីដេអូមួយដែលបានធ្វើអោយមានការភ្ញាក់ផ្អើលកាលពីសប្តាហ៍មុនបានអះអាងថាបង្ហាញពីពលរដ្ឋវៀតណាមរាប់សិបនាក់ដែលកំពុងរត់ចេញពីកាស៊ីណូក្បែរព្រំដែនកម្ពុជា។ សន្តិសុខកាន់ដំបងដេញតាមហ្វូងមនុស្ស ខណៈពួកគេរត់ចេញពីអគារមួយ ហើយលោតចូលទន្លេឆ្លងដែនចូលទៅប្រទេសវៀតណាម ដោយហែលទឹក។ ក្នុងពេលរត់គេចខ្លួនមានក្មេងអាយុ១៦ឆ្នាំម្នាក់បានលង់ទឹកស្លាប់។

ស្ត្រីជនជាតិតៃវ៉ាន់វ័យក្មេង Yu Tang ដែលបានសុំឱ្យ Guardian កុំប្រើនាមត្រកូលរបស់នាងបានអះអាងថា ស្ត្រីតៃវ៉ាន់ម្នាក់បានដាក់នាងនៅក្នុងក្រុមសម្រាប់អ្នកស្វែងរកការងារ ហើយបានទាក់ទងនាងតាមរយៈ Facebook កាលពីខែមេសា។ ការងារនៅក្នុងមជ្ឈមណ្ឌលហៅទូរសព្ទ ឬជំនួយសម្រាប់អាជីវកម្មហ្គេមអនឡាញ និងកាស៊ីណូត្រូវបានផ្តល់ជូននាង។ នាងបាននិយាយថា៖ «ខ្ញុំមិនជឿពួកគេទេ ប៉ុន្តែបន្ទាប់មកយើងបានជួបគ្នាជាសាធារណៈ។ Yu Tang បាននិយាយថា បុរសនោះហាក់ដូចជាធម្មតា។ នាងបានយល់ព្រមទទួលយកការងារនេះ ហើយត្រូវបានជួបនៅអាកាសយានដ្ឋានដោយបុគ្គលផ្សេងៗគ្នា ក៏ដូចជាមនុស្សមួយចំនួនទៀតដែលកំពុងស្វែងរកការងារផងដែរ។ ពួកគេត្រូវបានគេជួបម្តងទៀតដោយបុគ្គលនានាដែល «អះអាងថាពួកគេជាមេខ្យល់ធ្វើដំណើរ ប៉ុន្តែមើលទៅដូចជាឧក្រិដ្ឋជន» នៅអាកាសយានដ្ឋានភ្នំពេញ។ ប្រតិបត្តិករបានយកលិខិតឆ្លងដែនរបស់ក្រុមទាំង

នោះ ហើយអះអាងថា ពួកគេត្រូវការលិខិតឆ្លងដែនដើម្បីរៀបចំស៊ីមកាត ប៉ុន្តែមិនដែលត្រូវបានប្រគល់ឱ្យពួកគេវិញទេ។

លោក Yu Tang បានអះអាងថា នៅពេលដែលជនរងគ្រោះត្រូវបានផ្ទេរទៅខេត្តព្រះសីហនុ ហើយប្រាប់ពួកគេថានឹងចូលរួមក្នុងប្រតិបត្តិការឆបោកតាមទូរស័ព្ទនោះ ការពិភាក្សាទាំងអស់ជាមួយក្រុមជួញដូរត្រូវបានលុបចេញពីទូរស័ព្ទរបស់ពួកគេ។ បន្ថែមពីលើនេះ ពួកគេត្រូវបានគេជូនដំណឹងថា ប្រសិនបើពួកគេចង់ឱ្យគេដោះលែង ពួកគេនឹងត្រូវស្វែងរកមនុស្សដែលត្រូវបានជ្រើសរើសបន្ថែម និងបង់ប្រាក់ចំនួន១៧,០០០ ដុល្លារ ដើម្បីបានរួចខ្លួន។ Yu Tang បានអះអាងថា នៅពេលបុរសម្នាក់បានត្អូញត្អែរ គាត់ត្រូវបានគេវាយឱ្យសន្លប់ និងត្រូវបានគេឆក់នឹងកាំភ្លើងឆក់។ នាងបានអះអាងថា បុរសម្នាក់នោះនៅតែបាត់ខ្លួននៅតៃវ៉ាន់។

កាសែត Guardian រាយការណ៍ថា Yu Tang បានអះអាងថា នាងអាចទទួលបានស៊ីមកាត ហើយនាងក៏ចាប់ផ្តើមចូលក្នុងអង្គការជួញដូរមនុស្សភ្លាមៗ។ នាងបានរកឃើញព័ត៌មានសម្រាប់ការិយាល័យអ្នកនយោបាយក្នុងតំបន់ ហើយបានទាក់ទងពួកគេតាមរយៈ Facebook ។ នគរបាល និងកម្លាំងសមត្ថកិច្ច បានមកដល់និងយកនាងនៅថ្ងៃបន្ទាប់។ នាងបានអះអាងថា បើទោះជាថៅកែផ្តល់ប្រាក់ឲ្យពួកគេដើម្បី «ធ្វើពុតជាមិនមានអ្វីកើតឡើងទេ» ពួកគេបានបដិសេធ។ ចាប់តាំងពីពេលនោះមក នាងបានត្រលប់ទៅតៃវ៉ាន់វិញ។ Yu Tang បានអះអាងថា នាងបានឃើញជនជាតិតៃវ៉ាន់យ៉ាងតិច ៥០ នាក់ផ្សេងទៀតកំពុងត្រូវបានឃុំខ្លួននៅការិយាល័យដូចគ្នាដែលនាងត្រូវបានគេបង្ខាំង ហើយនៅជិតមានសំណង់ស្រដៀងគ្នា ដែលនាំឱ្យនាងសន្មត់ថាមានជនជាតិតៃវ៉ាន់ជាច្រើននាក់ទៀតកំពុងជាប់នៅក្នុងប្រទេសកម្ពុជា។

នាងបានអះអាងថា មនុស្សជាច្រើនត្រូវបានគេបង្ខំឱ្យចុះហត្ថលេខាលើឯកសារដែលនឹងបង្ហាញដល់អាជ្ញាធរដែលសួរអំពីស្ថានភាពរបស់ពួកគេ ហើយថាពេលដែលរយៈពេលបង្ខាំងខ្លួនត្រូវបានបន្ថែមប្រជាជនកាន់តែភ័យខ្លាចមិនហ៊ាននិយាយ។ Yu Tang អះអាងថា ពេលនេះនាងត្រលប់មកតៃវ៉ាន់វិញហើយ នាងត្រូវបានសាច់ញាតិជនរងគ្រោះ និងជនរងគ្រោះដែលអាចទាក់ទងបាន ដើម្បីសុំជំនួយនាងក្នុងការជួយពួកគេឱ្យរត់គេចខ្លួន ក៏ដូចជានគរបាលកំពុងស្វែងរកព័ត៌មានលម្អិត។ Yu បានអះអាងថា រហូតមកដល់ពេលនេះ នាងបានជួយមនុស្ស ៨ នាក់ក្នុងការត្រឡប់ទៅតៃវ៉ាន់វិញ។ ទាក់ទិននឹងបណ្តាញជួញដូរនេះ នគរបាលតៃវ៉ាន់បានអះអាងថា បានឃាត់ខ្លួនមនុស្សយ៉ាងតិច ៦៧ នាក់ ក្នុងនោះមាន ១៦ នាក់កាលពីថ្ងៃចន្ទ ដែលត្រូវបានចោទប្រកាន់ថា មានទំនាក់ទំនងនឹងក្រុមជនល្មើសក្នុងស្រុក។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានប្រកាសនៅថ្ងៃសុក្រនេះថា នាយកដ្ឋានរបស់លោកនឹងធ្វើការស៊ើបអង្កេតទូទាំងប្រទេស លើស្ថានភាពជនបរទេសដែលធ្វើការ ឬស្នាក់នៅតាមសណ្ឋាគារ ផ្ទះជួល និងកាស៊ីណូ៕ *WIONews.com*

## លោកហេងសួរ អំពាវនាវដល់ពលករខ្មែរនៅកូរ៉េកុំជឿទៅលើ «អប្បិយជំនឿ» ដែលមិនសមហេតុផល

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៥ សីហា ២០២២ដោយ Kang Tola

លោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការអំពាវនាវដល់បងប្អូនពលករខ្មែរធ្វើការនៅកូរ៉េកុំជឿទៅលើអប្បិយជំនឿដែលមិនសមហេតុផល ដែលបានប្រឌិតឡើងដោយបុគ្គលម្នាក់នោះ ព្រោះវានឹងធ្វើឱ្យបងប្អូននឹងបាត់បង់ប្រាក់ចំណូលនិងឱកាសត្រឡប់ទៅធ្វើការនៅប្រទេសកូរ៉េវិញ។ ការអំពាវនាវនេះបានធ្វើឡើងបន្ទាប់ពីមានពលករខ្មែរនៅកូរ៉េមួយចំនួន ដោយមានអ្នកខ្លះទើបចូលធ្វើការ និងខ្លះទៀតមិន

ទាន់ដាច់កិច្ចសន្យាការងារបាននាំគ្នាសម្រុកទិញសំបុត្រយន្តហោះត្រឡប់មកប្រទេសវិញដោយសារតែមានបុគ្គលមេដឹកនាំរបស់ខ្លួនបានទស្សន៍ទាយថា មានបាតុភូតប្រហោងលូខ្មៅផែនដីបង្កើតជាមហន្តរាយធ្វើឱ្យក្រិនផែនដីហើយមានតែប្រទេសកម្ពុជាទេដែលមានសុវត្ថិភាពនិងសុខសាន្ត។

តាមរយៈសារសំឡេងនៅក្នុងតេឡេក្រាមនៅល្ងាចថ្ងៃទី២៥សីហានេះ លោកហេងសួរបានមានប្រសាសន៍ថា ក្រសួងការងារក៏ដូចជាស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េបានសហការជាមួយសមាគមគាំពារពលករដើម្បីធ្វើការពន្យល់ដល់បងប្អូនពលករខ្មែរយើងដែលចង់វិលត្រឡប់មកស្រុកវិញតាមការអំពាវនាវរបស់បុគ្គលមួយរូប ដែលជឿលើអបិយជំនឿបានឃោសនាឱ្យបងប្អូនវិលត្រឡប់មកស្រុកវិញដើម្បីនៅក្បែរគាត់។ លោកហេងសួរបានបន្តថា « នេះជាអប្បិយជំនឿមួយដែលមិនសមហេតុមិនសមផល ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់បងប្អូនមិនថាទាំងជនជាតិខ្មែរឬជនជាតិផ្សេងទេ ភាគច្រើនចង់បានទៅធ្វើការនៅកូរ៉េឬជប៉ុន។ ប៉ុន្តែពេលដែលយើងទៅដល់ទីនោះហើយ ស្រាប់តែវិលត្រឡប់មកវិញដោយឈរលើអប្បិយជំនឿមិនសមហេតុផលនេះ គឺវាជាការសោកស្ដាយ»។

លោក ហេង សួរបានបន្តទៀតថា « ដូច្នេះខ្ញុំសូមអំពាវនាវដល់បងប្អូនពលករខ្មែរយើងសូមយកលក្ខណៈវិទ្យាសាស្ត្រជាគោលហើយសូមគិតពីផលប្រយោជន៍របស់ខ្លួនផងដែរ។ បើបងប្អូនចេញមកទាំងបង្ខំបែបនេះមិនមានច្បាប់វិលត្រឡប់ទៅកូរ៉េវិញបានទេ ដែលធ្វើឱ្យបងប្អូនបាត់បង់ឱកាសល្អនិងបាត់បង់ប្រាក់ចំណូលសម្រាប់ទ្រទ្រង់គ្រួសារផងដែរ។ដូច្នេះសូមគិតបញ្ហារបស់ខ្លួន»៕ *ដោយ ៖ សំអឿន*

## សមត្ថកិច្ចស្រាវជ្រាវករណីជួញដូរកម្លាំងពលកម្ម នៅព្រះសីហនុ ឃាត់ខ្លួនមនុស្សសរុប១១នាក់ និងដកហូតអាវុធមួយចំនួន

http://freshnewsasia.com/ 2022-08-26 10:13am

**(ភ្នំពេញ)៖** នាយឧត្តមសនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News ឱ្យដឹងថា បន្ទាប់ពីស្រាវជ្រាវលើករណីជួញដូរកម្លាំងពលកម្មមួយ នៅខេត្តព្រះសីហនុ នៅយប់រំលងអាធ្រាត្រឈានចូលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២នេះ សមត្ថកិច្ចរកឃើញអាវុធវែងខ្លីមួយចំនួន និងឃាត់ខ្លួនជនពាក់ព័ន្ធសរុប១១នាក់។

ប្រតិបត្តិការបង្ក្រាបករណីជួញដូរកម្លាំងពលកម្ម បានធ្វើឡើងតាំងពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ បន្ទាប់ពីមានបណ្ដឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃថា មាននារីម្នាក់ត្រូវបានក្រុមជនសង្ស័យចាប់បង្ខាំងទុក ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុនមួយកន្លែងនៅក្នុងខេត្តព្រះសីហនុ។ ប្រតិបត្តិការថ្ងៃដំបូងនោះ សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យ៥នាក់ ដែលជាជនជាតិចិន និងបានរំដោះនារីរងគ្រោះម្នាក់ដែលជាជនជាតិម៉ាឡេស៊ី។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានបញ្ជាក់បន្ថែមថា បន្ទាប់ពីស្រាវជ្រាវ ក្នុងកិច្ចប្រតិបត្តិការបន្តនេះ កម្លាំងសមត្ថកិច្ចឃាត់ខ្លួនបានជនសង្ស័យសរុប ០៨នាក់ ក្នុងនោះកម្លាំងសមត្ថកិច្ចដកហូតបាន អាវុធខ្លី ម៉ាក ZORAKI ចំនួន០១ដើម។ បន្តមកទៀត រហូតដល់យប់រំលងអាធ្រាត្រវេលាម៉ោង ០១៖៣០នាទី រំលងអាធ្រាត្រ ឈានចូលថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២កម្លាំងបានធ្វើការស្រាវជ្រាវបង្ក្រាបបាន ជនសង្ស័យជួញដូរអាវុធមួយដើមនោះ រហូតបន្តឈានទៅឃាត់ខ្លួនជនសង្ស័យ ០៣នាក់ទៀត ដែលមានខ្មែរ២នាក់ និងចិនម្នាក់ ព្រមទាំងដកហូតបានវត្ថុតាងអាវុធមួយចំនួនបន្ថែមទៀត ដែលមានឈ្មោះដូចខាងក្រោម៖

**១៖** ឈ្មោះ TANG GUO HUI ភេទប្រុស អាយុ ៣២ឆ្នាំ មុខរបរបុគ្គលិកក្រុមហ៊ុន លិខិតឆ្លងដែនលេខៈ EH63627501។

២៖ ឈ្មោះ សាន សុខឡេង ភេទប្រុស ជនជាតិខ្មែរ អាយុ៣៤ឆ្នាំ មុខរបរមិនពិតប្រាកដ។

៣៖ ឈ្មោះ ថៃ យាង ភេទប្រុស ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ។

ចំណែកវត្ថុតាងដែលត្រូវបានដកហូតបាន រួមមាន៖ អាវុធវែង២ដើម (ម៉ាត់ត្រយ៉ែត និងកាលីត ខ្លូ), បង់ត្រឡោក ០១, បង់អាវុធវែង AK ចំនួន ០១, អាវុធខ្លី ០៣ដើម (សរុបរួម ០៤ដើម), ម៉ាក ZORAKI ពណ៌ខ្មៅ បង់១, ម៉ាក ZORAKI ពណ៌ខ្មៅ បង់១, ម៉ាក SIG SAURER ពណ៌ខ្មៅ បង់២, គ្រាប់កាំភ្លើង ២៤០គ្រាប់ (សរុបរួម ២៦៥គ្រាប់), រថយន្ត ចំនួន ០១គ្រឿង។

សូមបញ្ជាក់ថា ពេលនេះ កម្ពុជាកំពុងបើកប្រតិបត្តិការទ្រង់ទ្រាយធំ ដើម្បីត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេសនៅកម្ពុជា លើកលែងតែមន្ត្រីការទូត ដើម្បីពិនិត្យភាពស្របច្បាប់ និងរកមុខសញ្ញាដែលពាក់ព័ន្ធនឹងជួញដូរមនុស្ស៕

## ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង ចេញសេចក្តីអំពាវនាវឱ្យសាធារណជនទាំងអស់ បន្តសហការផ្តល់ព័ត៌មាន និងតម្រុយ ដើម្បីរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សនៅកម្ពុជា

http://freshnewsasia.com/ 2022-08-26 01:30pm

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២នេះ បានចេញសេចក្តីអំពាវនាវឱ្យសាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសជាមិត្ត បន្តសហការផ្តល់ព័ត៌មាន ឬតម្រុយនានាពាក់ព័ន្ធអំពើជួញដូរមនុស្ស ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ នៅក្នុងប្រទេសកម្ពុជា។

តាមរយៈលិខិតអំពាវនាវដែលបណ្តាញព័ត៌មាន Fresh News ទទួលបាន សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា ក្នុងរយៈពេលប្រមាណជាង មួយឆ្នាំមកនេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានទទួលសំណើ និងពាក្យបណ្តឹងពីជនបរទេស និងស្ថានតំណាងបរទេសប្រចាំកម្ពុជាមួយចំនួន ពាក់ព័ន្ធនឹងការស្នើសុំកិច្ចអន្តរាគមន៍ជួយសង្គ្រោះ និងការស្នើសុំស្រាវជ្រាវស្វែងរកពលរដ្ឋ ដោយបានអះអាងថា ជាជនរងគ្រោះនៃអំពើជួញដូរ និងរត់ពន្ធមនុស្ស ដែលជាបទល្មើសដ៏ធ្ងន់ធ្ងរមួយ ក្នុងចំណោមឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង។ សម្តេចបានបន្តថា បន្ទាប់ពីបានពិនិត្យយ៉ាងយកចិត្តទុកដាក់លើសំណើ និងពាក្យបណ្តឹងទាំងនោះ ករណីភាគច្រើន ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបើកប្រតិបត្តិការស្រាវជ្រាវស្វែងរកឃើញ និងជួយសង្គ្រោះបានទាន់ពេលវេលា ព្រមទាំងបានលើកលែងការផាកពិន័យផ្សេងៗពាក់ព័ន្ធនឹង ស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ និងបានផ្តល់ការសម្របសម្រួលនីតិវិធី ដើម្បីបណ្តេញចេញពីកម្ពុជា ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជាក់ស្តែង គិតពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានរកឃើញ និងជួយសង្គ្រោះជនបរទេសដែលប្រកាសថា ជនរងគ្រោះចំនួន ៨៧ករណី ស្មើនឹងប្រមាណ ៨៦៥នាក់ ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនទៅ តុលាការចំនួន១៧ករណី ជនសង្ស័យសរុបចំនួន ៦០នាក់។ ដោយឡែកនាសប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០២២ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានបើកកិច្ចប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះសរុបចំនួន ០៧ករណី ដោយបានសង្គ្រោះជនរងគ្រោះសរុបចំនួន ២៥នាក់ (មាន ៦ សញ្ជាតិ) និងឃាត់ខ្លួនជនសង្ស័យសរុបចំនួន ២៣នាក់ (មាន ៤ សញ្ជាតិ) នៅក្នុងខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តឧត្តរមានជ័យ។ ក្រៅពីនេះ មានករណីសេសសល់បន្ថែមទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាកំពុងបន្ត

ស្រាវជ្រាវ ដើម្បីសង្គ្រោះ និងបង្ក្រាប។ សម្តេចបានបញ្ជាក់បន្ថែមថា ទន្ទឹមនេះ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ និងសួរចម្លើយ រកឃើញថា ពលរដ្ឋបរទេសទាំងនោះ មួយចំនួនធំត្រូវបានក្រុមឧក្រិដ្ឋជន ដែលមានមេក្លោងនៅក្នុងប្រទេសរបស់ខ្លួន និងមានបក្សពួកនៅកម្ពុជា ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ធ្វើការឆបោកឲ្យឆ្លងដែនដោយខុសច្បាប់ចូលមកប្រទេសកម្ពុជា ក្រោមការសន្យាផ្តល់ការងារដែលទទួលបានប្រាក់ឈ្នួលខ្ពស់។

ក៏ប៉ុន្តែជាក់ស្តែងជនទាំងនោះ ត្រូវបានចាត់ ឲ្យបម្រើការងារល្បែងស៊ីសងអនឡាញខុសច្បាប់ ហើយបានក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង រត់ពន្ធមនុស្ស ដោយត្រូវបានក្រុមឧក្រិដ្ឋជនធ្វើការជួញដូរ ឬផ្ទេរបន្តពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ឬពី ក្រុមមួយទៅក្រុមមួយ ដោយពុំមានការព្រមព្រៀងពីសាមីខ្លួន ហើយករណីខ្លះទៀតត្រូវទទួលរងនូវអំពើហិង្សា និងការគំរាមកំហែងផ្សេងៗ ប្រសិនមិនអនុវត្តតាមការបង្គាប់បញ្ជាពីក្រុមឧក្រិដ្ឋជន។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្តេចក្រឡាហោម បានសម្តែងការសោកស្តាយ និងសូមថ្កោលទោសចំពោះអំពើដ៏អមនុស្សធម៌ទាំងនេះ។ សម្តេចក៏បានថ្លែងអំណរគុណ និងស្វាគមន៍ចំពោះការផ្តល់ព័ត៌មានផ្សេងៗ ពីសំណាក់បុគ្គល និងស្ថានតំណាងបរទេសប្រចាំកម្ពុជា នាពេលកន្លងមកពាក់ព័ន្ធទៅនឹងករណីខាងលើនេះ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅតែបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជា។

កាលពីពេលថ្មីៗនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ព្រមទាំងបានបង្កើត **«គណៈបញ្ជាការដឹកនាំប្រតិបត្តិការ»** ដើម្បីធ្វើជាសេនាធិការក្នុងការដឹកនាំ និងបញ្ជា ដោយផ្ទាល់នូវប្រតិបត្តិការបង្ក្រាប និងជួយសង្គ្រោះជនរងគ្រោះ។ ក្នុងន័យនេះ សម្តេចក្រឡាហោម សូមធ្វើការអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ សូមបន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

**ការផ្តល់ព័ត៌មានអាចធ្វើទៅបានតាមរយៈ៖**

**១៖** គេហទំព័រ Facebook: Samdech Krolahom Sar Kheng, Cambodian Deputy Prime Minister

**២៖** លេខទូរសព្ទ Hotline របស់អគ្គស្នងការដ្ឋាននគរបាលជាតិ: ១១៧ និង (+៨៥៥) ៣១ ២០១ ២៣៤៥

**៣៖** គេហទំព័រ Facebook: អគ្គស្នងការដ្ឋាននគរបាលជាតិ-General Commissariat of Natioral Police

**៤៖** គេហទំព័រ Facebook: អគ្គនាយកដ្ឋានអន្តោប្រវេសន៍-General Department of Immigration-GDI

សម្តេចក្រឡាហោម ស ខេង សង្ឃឹមយ៉ាងមុតមាំថា សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេស និងអាជ្ញាធរពាក់ព័ន្ធន បណ្តាប្រទេសជាមិត្ត នឹងបន្តផ្តល់កិច្ចសហការយ៉ាងសកម្ម និងជិតស្និទ្ធ ដើម្បីរួមគ្នាលុបបំបាត់ឧក្រិដ្ឋកម្មនេះ សំដៅការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ៕

# សម្ដេច ស ខេង ៖ ជិត៨ខែនេះ
# អាជ្ញាធរកម្ពុជាសង្គ្រោះជនបរទេសជិត១ពាន់នាក់ពីការជួញដូរមនុស្ស

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២៦ សីហា ២០២២ដោយ vann sokunthea

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៅរសៀលថ្ងៃសុក្រនេះ បានបង្ហាញឲ្យដឹងថា គិតពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២នេះ អាជ្ញាធរកម្ពុជា បានរកឃើញ និងជួយសង្គ្រោះជនបរទេសដែលប្រកាសថាជាជនរងគ្រោះចំនួន៨៧ករណី ស្មើនឹងប្រមាណ៨៦៥នាក់ ដោយបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ១៧ករណី មានជនសង្ស័យសរុប៦០នាក់។

ចំណែក នៅក្នុងសប្ដាហ៍ទី៤នៃខែសីហានេះវិញ អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះជនរងគ្រោះចំនួន៧ករណី សង្គ្រោះបាន២៥នាក់ មាន៦សញ្ជាតិ និងបានឃាត់ខ្លួនជនសង្ស័យសរុបចំនួន២៣នាក់ មាន៤សញ្ជាតិ។ ការជួយសង្គ្រោះនេះ ធ្វើឡើងនៅក្នុងខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តឧត្ដរមានជ័យ។ ក្រៅពីនេះ អាជ្ញាធរកម្ពុជា ក៏កំពុងបន្តស្រាវជ្រាវ ដើម្បីសង្គ្រោះ និងបង្ក្រាបបន្ថែមទៀតផងដែរ។ នេះបើតាមការគូសបញ្ជាក់របស់សម្ដេចក្រឡាហោម ស ខេង ដដែលនៅក្នុងសេចក្ដីអំពាវនាវនៅថ្ងៃទី២៦ ខែសីហានេះ។

ចំពោះការជួញដូរមនុស្សនេះ អាជ្ញាធរកម្ពុជា បានរកឃើញថា ពលរដ្ឋបរទេសទាំងនោះ មួយចំនួនធំ ត្រូវបានក្រុមឧក្រិដ្ឋជនដែលមានមេក្លោងនៅក្នុងប្រទេសរបស់ខ្លួន និងមានបក្ខពួកនៅកម្ពុជា ប្រើប្រាស់បណ្ដាញសង្គមធ្វើការឆបោកឲ្យឆ្លងដែនខុសច្បាប់ចូលមកប្រទេសកម្ពុជា ក្រោមការសន្យាផ្ដល់ការងារដែលមានប្រាក់ឈ្នួលខ្ពស់។ ប៉ុន្តែ ជាក់ស្ដែង ជនទាំងនោះ ត្រូវបានចាត់ឲ្យបម្រើការងារល្បែងស៊ីសងអនឡាញខុសច្បាប់ ហើយបានក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងរត់ពន្ធមនុស្ស ដោយត្រូវក្រុមឧក្រិដ្ឋជនធ្វើការជួញដូរ ឬផ្ទេរពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ឬពីក្រុមមួយទៅក្រុមមួយ ដោយពុំមានការព្រមព្រៀងពីសាមីខ្លួន។ ករណីខ្លះទៀត ត្រូវទទួលរងនូវអំពើហិង្សា និងការគំរាមកំហែងផ្សេងៗ ប្រសិនបើមិនអនុវត្តតាមការបង្គាប់បញ្ជាពីក្រុមឧក្រិដ្ឋជន។

សម្ដេចក្រឡាហោម បានសម្ដែងការសោកស្ដាយ និងថ្កោលទោសចំពោះអំពើអមនុស្សធម៌ទាំងនេះ។ ជាមួយគ្នានេះ សម្ដេច ក៏បានបន្តប្ដេជ្ញាធ្វើប្រយុទ្ធប្រឆាំង និងអនុវត្តច្បាប់ទៅលើមេក្លោងដែលធ្វើសកម្មភាពទាំងអស់នេះនៅក្នុងទឹកដីរបស់កម្ពុជា។ មិនតែប៉ុណ្ណោះ សម្ដេចឧបនាយករដ្ឋមន្ត្រី ក៏បានអំពាវនាវដល់សាធារណជនជាតិ និងអន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្ដល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដទៃទៀត ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលពេលវេលាប្រកបដោយប្រសិទ្ធភាព។

ការផ្ដល់ព័ត៌មានអំពើបញ្ហានេះ អាចធ្វើឡើងតាមរយៈ ទំព័រហ្វេសប៊ុករបស់សម្ដេចក្រឡាហោម (Samdech Krolahom Sar Kheng, Cambodian Deputy Prime Minister) តាមរយៈលេខទូរស័ព្ទ Hotlineរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ៖ ១១៧ និង(+៨៥៥) ៣១ ២០១ ២៣៤៥ តាមរយៈទំព័រហ្វេសប៊ុករបស់អគ្គស្នងការដ្ឋាននគរបាលជាតិ-General Commissariat of National Police និងទំព័រហ្វេសប៊ុករបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍-General Department of Immigration-GDI៕ ដោយ៖ វណ្ណ សុគន្ធា

# សម្តេច ស ខេង សោកស្តាយ
# និងសូមថ្កោលទោស ចំពោះអំពើដ៏អមនុស្សធម៌ នៃការជួញដូរមនុស្ស

https://cen.com.kh/ Posted ByPen Srey NeatAugust 26, 2022

ភ្នំពេញ ៖ នៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០២២ សម្តេចក្រឡាហោ ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងថា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមជម្រាប់ជូនសាធារណជនជាតិ-អន្តរជាតិ ជ្រាបថា ក្នុងរយៈពេលប្រមាណជាងមួយឆ្នាំមកនេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានទទួលសំណើ និងពាក្យបណ្តឹងពីជនបរទេស និងស្ថាន តំណាងបរទេសប្រចាំកម្ពុជាមួយចំនួន ពាក់ព័ន្ធនឹងការស្នើសុំកិច្ចអន្តរាគមន៍ជួយសង្គ្រោះ និងការស្នើសុំ ស្រាវជ្រាវស្វែងរកពលរដ្ឋ ដោយបានអះអាងថា ជាជនរងគ្រោះនៃអំពើជួញដូរ និងរត់ពន្ធមនុស្ស ដែលជាបទល្មើសដ៏ធ្ងន់ធ្ងរមួយ ក្នុងចំណោមឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង។

បន្ទាប់ពីបានពិនិត្យយ៉ាងយកចិត្តទុកដាក់លើសំណើ និងពាក្យបណ្តឹងទាំងនោះ ករណីភាគច្រើន ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបើកប្រតិបត្តិការស្រាវជ្រាវស្វែងរកឃើញ និងជួយសង្គ្រោះបានទាន់ ពេលវេលា ព្រមទាំងបានលើកលែងការផាកពិន័យផ្សេងៗពាក់ព័ន្ធនឹងស្ថានភាពអន្តោប្រវេសន៍របស់ពួកគ និងបានផ្តល់ការសម្របសម្រួលនីតិវិធី ដើម្បីបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ស្របតាមការកំណត់ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ ជាក់ស្តែង គិតពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២២នេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានរកឃើញ និងជួយសង្គ្រោះជនបរទេសដែលប្រកាសថា ជនរងគ្រោះ ចំនួន ៨៧ករណី ស្មើនឹងប្រមាណ ៨៦៥នាក់ ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនទៅ តុលាការចំនួន ១៧ករណី ជនសង្ស័យសរុបចំនួន ៦០នាក់។

ដោយឡែកនាសប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០២២នេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានបើកកិច្ច ប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះសរុបចំនួន ០៧ករណី ដោយបានសង្គ្រោះជនរងគ្រោះសរុបចំនួន ២៥នាក់ (មាន ៦ សញ្ជាតិ) និងឃាត់ខ្លួនជនសង្ស័យសរុបចំនួន ២៣នាក់ (មាន ៤ សញ្ជាតិ) នៅក្នុងខេត្ត ព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តឧត្តរមានជ័យ។ ក្រៅពីនេះ មានករណីសេសសល់បន្ថែមទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាកំពុងបន្តស្រាវជ្រាវ ដើម្បីសង្គ្រោះ និងបង្ក្រាប។

ទន្ទឹមនេះ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ និងសួរចម្លើយ រកឃើញថា ពលរដ្ឋបរទេសទាំងនោះ មួយចំនួនធំត្រូវបានក្រុមឧក្រិដ្ឋជនដែលមានមេក្លោងនៅក្នុងប្រទេសរបស់ខ្លួន និងមានបក្សពួកនៅកម្ពុជា ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ធ្វើការឆបោកឲ្យឆ្លងដែនដោយខុសច្បាប់ចូលមកបទសកម្ពុជា ក្រោមការសន្យាផ្តល់ការងារដែលទទួលបានប្រាក់ឈ្នួលខ្ពស់។ ក៏ប៉ុន្តែជាក់ស្តែងជនទាំងនោះ ត្រូវបានចាត់ ឲ្យបម្រើការងារល្បែងស៊ីសងអនឡាញខុសច្បាប់ ហើយបានក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង រត់ពន្ធមនុស្ស ដោយត្រូវបានក្រុមឧក្រិដ្ឋជនធ្វើការជួញដូរ ឬផ្ទេរបន្តពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ឬពី ក្រុមមួយទៅក្រុមមួយ ដោយពុំមានការព្រមព្រៀងពីសាមីខ្លួន ហើយករណីខ្លះទៀតត្រូវទទួលរងនូវអំពើហិង្សា និងការគំរាមកំហែងផ្សេងៗ ប្រសិនមិនអនុវត្តតាមការបង្គាប់បញ្ជាពីក្រុមឧក្រិដ្ឋជន ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំពិតជា មានការសោកស្តាយ និងសូមថ្កោលទោសចំពោះអំពើដ៏អមនុស្សធម៌ទាំងនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណ និងស្វាគមន៍ចំពោះការផ្តល់ព័ត៌មានផ្សេងៗ ពីសំណាក់បុគ្គល និងស្ថានតំណាងបរទេសប្រចាំកម្ពុជា នាពេល កន្លងមកពាក់ព័ន្ធ

ទៅនឹងករណីខាងលើនេះ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចអគ្គ មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅតែបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជា។

កាលពីពេលថ្មីៗនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ព្រមទាំងបានបង្កើត "គណៈបញ្ជាការដឹកនាំប្រតិបត្តិការ ដើម្បីធ្វើជាសេនាធិការក្នុងការដឹកនាំ និងបញ្ជា ដោយផ្ទាល់នូវប្រតិបត្តិការបង្ក្រាប និងជួយសង្គ្រោះជនរងគ្រោះ។ ក្នុងន័យនេះ ខ្ញុំសូមធ្វើការអំពាវនាវដល់ សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេស ពាក់ព័ន្ធ សូមបន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បី បង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

សម្តេចក្រឡាហោម ស ខេង សង្ឃឹមយ៉ាងមុតមាំថា សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេស និងអាជ្ញាធរពាក់ព័ន្ធន បណ្តាប្រទេសជាមិត្ត នឹងបន្តផ្តល់កិច្ចសហការយ៉ាងសកម្ម និងជិតស្និទ្ធ ដើម្បីរួមគ្នាលុបបំបាត់ឧក្រិដ្ឋកម្មនេះ សំដៅការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បញ្ជាក់ពីការជួយអន្តរាគមន៍ជនទេសរងគ្រោះ ដោយសារការបង្ខាំង និងបង្ខំឱ្យធ្វើការនៅកម្ពុជា

https://cen.com.kh/ Posted ByPen Srey NeatAugust 26, 2022

ភ្នំពេញៈ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោកជុំ សុន្ទរី បានបញ្ជាក់នៅល្ងាចថ្ងៃទី២៦ ខែសីហានេះថា ក្នុងរយៈពេល ៦ខែចុងក្រោយនេះ ស្ថានទូតបរទេសមួយចំនួនបានស្នើសុំកិច្ចអន្តរាគមន៍ជួយសង្គ្រោះពលរដ្ឋរបស់ខ្លួន ដែលត្រូវបានអះអាងថា រងគ្រោះដោយសារការប.ង្ខាំង និងប.ង្ខំឱ្យធ្វើការនៅកម្ពុជា ក្នុងនោះមាន ពលរដ្ឋបង់ក្លាដែស ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ម៉ុងហ្គោលី នេប៉ាល់ ប៉ាគីស្ថាន ហ្វីលីពីន និងថៃ។ លោកជុំ សុន្ទរី បានបន្តថា ក្រសួងការបរទេសតែងតែសម្របសម្រួល បញ្ជូនសំណើសុំកិច្ចអន្តរាគមន៍របស់ស្ថានតំណាងបរទេស ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីពិនិត្យ និងធ្វើកិច្ចអន្តរាគមន៍។ ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធកម្ពុជា ដើម្បីលើកកម្ពស់យន្តការទទួលបណ្តឹង សំណើសុំអន្តរាគមន៍ និងចាត់ការពាក្យបណ្តឹងជួយសង្គ្រោះពលរដ្ឋដែលជាជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស។

បើតាមសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា តពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០២២នេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា បានរកឃើញ និងជួយសង្គ្រោះជនបរទេសដែលប្រកាសថា ជនរងគ្រោះ ចំនួន ៨៧ករណី ស្មើនឹងប្រមាណ ៨៦៥នាក់ ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនទៅ តុលាការចំនួន ១៧ករណី ជនសង្ស័យសរុបចំនួន ៦០នាក់។

ដោយឡែកនាសប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០២២នេះ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានបើកកិច្ចប្រតិបត្តិការជួយសង្គ្រោះជនរងគ្រោះសរុបចំនួន ០៧ករណី ដោយបានសង្គ្រោះជនរងគ្រោះសរុបចំនួន ២៥នាក់ (មាន ៦

សញ្ជាតិ) និងឃាត់ខ្លួនជនសង្ស័យសរុបចំនួន ២៣នាក់ (មាន ៤ សញ្ជាតិ) នៅក្នុងខេត្ត ព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និងខេត្តឧត្តរមានជ័យ។ ក្រៅពីនេះ មានករណីសេសសល់បន្ថែមទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាកំពុងបន្តស្រាវជ្រាវ ដើម្បីសង្គ្រោះ និងបង្ក្រាប។

ទន្ទឹមនេះ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ និងសួរចម្លើយ រកឃើញថា ពលរដ្ឋបរទេសទាំងនោះ មួយចំនួនធំត្រូវបានក្រុមឧក្រិដ្ឋជនដែលមានមេក្លោងនៅក្នុងប្រទេសរបស់ខ្លួន និងមានបក្ខពួកនៅកម្ពុជា ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ធ្វើការឆបោកឲ្យឆ្លងដែនដោយខុសច្បាប់ចូលមកប្រទេសកម្ពុជា ក្រោមការសន្យាផ្តល់ការងារដែលទទួលបានប្រាក់ឈ្នួលខ្ពស់។ ក៏ប៉ុន្តែជាក់ស្តែងជនទាំងនោះត្រូវបានចាត់ ឲ្យបម្រើការងារល្បែងស៊ីសងអនឡាញខុសច្បាប់ ហើយបានក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និង រត់ពន្ធមនុស្ស ដោយត្រូវបានក្រុមឧក្រិដ្ឋជនធ្វើការជួញដូរ ឬផ្ទេរបន្តពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយ ឬពី ក្រុមមួយទៅក្រុមមួយ ដោយពុំមានការព្រមព្រៀងពីសាមីខ្លួន ហើយករណីខ្លះទៀតត្រូវទទួលរងនូវអំពើហិង្សា និងការគំរាមកំហែងផ្សេងៗ ប្រសិនមិនអនុវត្តតាមការបង្គាប់បញ្ជាពីក្រុមឧក្រិដ្ឋជន៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រកាសឲ្យពលរដ្ឋទូទាំងប្រទេស និងជនបរទេស ទូរស័ព្ទទៅលេខ ១១៧ ក្នុងករណីមានការបង្ខាំងមនុស្សខុសច្បាប់ ឬ ការជួញដូរមនុស្សគ្រប់ទម្រង់ ខណៈ ១១៧ បានបន្ថែមមន្ត្រីប្រចាំការដែលចេះភាសាបរទេស

https://gntimes.com/ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២

ភ្នំពេញ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ នៅរសៀលថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២២ នេះ បានប្រកាសឲ្យប្រជាពលរដ្ឋទូទាំងប្រទេស និងជនបរទេស បើមានករណីពាក់ព័ន្ធនឹងការបង្ខាំងមនុស្សខុសច្បាប់ ឬ ការជួញដូរមនុស្សគ្រប់ទម្រង់ សូមទំនាក់មកលេខ Hotline ១១៧ ខណៈដែលបច្ចុប្បន្ន មជ្ឈមណ្ឌលប្រចាំបញ្ជា ១១៧ បានបន្ថែមមន្ត្រីនគរបាលជាតិប្រចាំការ ដែលចេះនិយាយភាសាអង់គ្លេស, ភាសាចិន និងភាសាវៀតណាម ។ អគ្គស្នងការដ្ឋាននគរបាលជាតិ ក៏បានអំពាវនាវឲ្យប្រជាជនទូទាំងប្រទេស គ្រប់មជ្ឈដ្ឋានទាំងអស់ សូមចូលរួមសហការលុបបំបាត់អំពើជួញដូរមនុស្ស បង្ខាំងមនុស្សខុសច្បាប់គ្រប់ទម្រង់ ដោយទំនាក់ទំនងមកលេខ Hotline ១១៧ និងផ្តល់ទំនុកចិត្តឲ្យ ១១៧ ។

គួរកត់សម្គាល់ថា បន្ទាប់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រកាសលេខទូរស័ព្ទ Hotline ១១៧ សម្រាប់ប្រជាពលរដ្ឋរាយការណ៍រាល់ករណីកើតឡើងពិតប្រាកដ នៅទូទាំងប្រទេស ពេញ ២៤ ម៉ោងលើ ២៤ ម៉ោងនោះមក ប្រជាពលរដ្ឋបានសម្តែងការគាំទ្រ ជឿជាក់ និងលើកសរសើរមិនដាច់ពីមាត់ ខណៈពេលពួកគាត់កំពុងមានបញ្ហាបានរាយការណ៍ទៅសមត្ថកិច្ចតាមលេខទូរស័ព្ទ ១១៧ ដើម្បីសុំកិច្ចអន្តរាគមន៍ ហើយពួកគាត់ទទួលបានការជួយអន្តរាគមន៍ទាន់ពេលវេលា ។

លេខទូរស័ព្ទ Hotline ១១៧ នេះ គឺជាមជ្ឈមណ្ឌលប្រចាំបញ្ជារបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលរង់ចាំទទួល និងឆ្លើយតបបន្ទាន់ភ្លាមៗ នៅពេលទទួលបាននូវសេចក្តីរាយការណ៍សុំជំនួយពិតប្រាកដពីនគរបាលជាតិ ដូចជា បទល្មើសព្រហ្មទណ្ឌ, គ្រោះថ្នាក់ចរាចរណ៍, គ្រោះអគ្គិភ័យ ឬភាពអសកម្មមួយចំនួនរបស់មន្ត្រីនគរបាលនៅតាមមូលដ្ឋានជាដើម ។ ប្រជាពលរដ្ឋអាចទូរស័ព្ទចូលលេខ ១១៧ មិនអស់ថ្លៃសេវានោះទេ ទោះបីជាទឹកប្រាក់ក្នុងគណនេយ្យអស់ ក៏អាចទូរស័ព្ទចូលបានផងដែរ ។

## កម្ពុជា-ថៃ ព្រមព្រៀងគ្នាបង្កើតស្តង់ដាររួម ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស

https://btv.com.kh/ 2022/08/27 03:23:06 pm

ភ្នំពេញ៖ កម្ពុជា-ថៃ បានព្រមព្រៀងគ្នា បង្កើតស្តង់ដាររួមមួយ (SOP) ដើម្បីទប់ស្កាត់ បង្ក្រាបអំពើជួញ ដូរមនុស្សបន្ថែមពីលើការធ្វើបត្យាប័ណ្ណ និងកិច្ចសហការអនុវត្តតាមច្បាប់ព្រហ្មទណ្ឌ ។ ក្នុងសន្និសីទសារព័ត៌មាន បន្ទាប់ពីអញ្ជើញដឹកនាំគណៈប្រតិភូអន្តរក្រសួង ចូលរួមកិច្ចប្រជុំជាមួយភាគីថៃ ទាក់ទងកិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពី នីតិវិធីច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ថា កិច្ចព្រមព្រៀមកិច្ចសហប្រតិបត្តិនេះមានសារសំខាន់ណាស់ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សរវាងប្រទេសទាំងពីរ ដោយនីតិវិធី អនុវត្តការងារបទល្មើសជួញដូរមនុស្សនេះ ប្រទេសទាំងពីរអនុវត្តខុសគ្នាខ្លះ ដូចនេះ ទើបកម្ពុជា-ថៃ រួមគ្នាបង្កើតស្តង់ដារតែមួយ ដើម្បីអនុវត្តនេះ ឲ្យកាន់តែមានប្រសិទ្ធភាព ។

លោកជំទាវ បានបន្តថា ប្រទេសទាំងពីរ នឹងបង្កើតមជ្ឈមណ្ឌលមួយ ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ធ្វើការរួមគ្នា ខណៈភាគីកម្ពុជាបានរៀបចំយន្តការ តាមកាគ្រោងទុករួច ហើយភាគីថៃ សូមពន្យាពេលដល់ខែតុលា ឆ្នាំ២០២២ ដើម្បីរៀបចំយន្តការរបស់ខ្លួន ដែលបន្ទាប់ពីនោះមក ប្រទេសទាំងពីរនឹងចែករំលែកនូវបទពិសោធន៍ នីតិវិធី វិស័យច្បាប់ ដើម្បីដាក់បញ្ចូលគ្នា ។ នៅខែវិច្ឆិកាចុងឆ្នាំនេះ ភាគីទាំងពីរគ្រោងរៀបចំសិក្ខាសាលារួមគ្នា ហើយមន្ត្រីជំនាញ នឹងស្នើសុំគោលកាណ៍ពីប្រមុខរាជរដ្ឋាភិបាល ដោយពេលសិក្ខាសាលាទ្វេភាគីនោះ នឹងមានការដាក់បញ្ចូលទៅជាបទដ្ឋាន ឬនីតិវិធីប្រតិបត្តិមួយ ដែលមានលក្ខណៈជាស្តង់ដារ បើមិនធ្វើបែបនេះទេ គឺប្រព្រឹត្តិទៅមិនលូន ។ លោកជំទាវ ជូន ប៊ុនអេង បានបញ្ជាក់ថា កិច្ចព្រមព្រៀងនេះ គឺជាលើកដំបូងហើយ សម្រាប់ប្រទេសក្នុងតំបន់ ហើយសង្ឃឹមថា វានឹងក្លាយជាគំរូមួយ សម្រាប់ប្រទេសសមាជិក អាស៊ាន ដើម្បីធ្វើការរួមគ្នា ឲ្យកាន់តែជិតស្និទ្ធ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

គួរបញ្ជាក់ថា កម្ពុជាតែងមានករណីអំពើជួញដូរមនុស្ស តាមលក្ខណៈពួកមេខ្យល់នាំពលករខ្មែរ លួចឆ្លងដែនដោយខុសច្បាប់ ទៅប្រទេសថៃ ដើម្បីរកការងារធ្វើ ហើយអាជ្ញាធរតាមព្រំដែន ក៏បានទប់ស្កាត់ និងបង្ក្រាបពួកមេខ្យល់ រួមទាំងកសាងនីតិវិធីបញ្ជូនទៅតុលាការផងដែរ ៕

# ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២

## ក្រសួងមហាផ្ទៃ បង្ហាញពីលទ្ធផលនៃប្រតិបត្តិការស្រាវជ្រាវស្វែងរកជនបរទេសចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី ២៦ ខែសីហា នៅខេត្តព្រះសីហនុ

http://freshnewsasia.com/ 2022-08-27 06:18pm

**(ភ្នំពេញ)៖** ក្រសួងមហាផ្ទៃ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២នេះ បានបង្ហាញលទ្ធផលនៃប្រតិបត្តិការស្រាវជ្រាវស្វែងរកជនបរទេស តាមបណ្តឹងរាយការណ៍ចូលប្រព័ន្ធ Hotline ក្រុមការងារ សម្តេចក្រឡាហោម ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។ គិតចាប់ថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានធ្វើការស្រាវជ្រាវស្វែងរកជនបរទេសចំនួន៤ករណី ពាក់ព័ន្ធករណីបង្ខាំងមនុស្សដើម្បីបម្រើការងារឲ្យក្រុមហ៊ុន នៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ។

ករណីទី១ បានធ្វើឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង២៣ និង៣០នាទី ដោយអនុវត្តតាមបណ្តឹងរាយការណ៍ ចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង កម្លាំងជំនាញនៃស្នងការដ្ឋាន

នគរបាលខេត្តព្រះសីហនុ បានធ្វើការស្រាវជ្រាវរំដោះបានជនរងគ្រោះចំនួន១នាក់ ជាស្ត្រីជនជាតិម៉ាឡេស៊ី ឈ្មោះ KHOO AI LEE អាយុ២៧ឆ្នាំ ពីក្នុងក្រុមហ៊ុនមួយកន្លែងស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ព្រះសីហនុ។ បន្ទាប់ពីធ្វើការស្រាវជ្រាវ និងសាកសួរ ជនរងគ្រោះបានឲ្យដឹងថា ខ្លួនត្រូវបានគេចាប់បង្ខាំងដោយខុសច្បាប់ ប្រើហិង្សា កំហែងយក ជួញដូរកម្លាំងពលកម្ម និងអាវុធ ដោយខុសច្បាប់។ ក្នុងកិច្ចប្រតិបត្តិកាតនេះដែរ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យជនជាតិចិនចំនួន ៨នាក់ជាបន្តបន្ទាប់ ក្នុងនោះកម្លាំងសមត្ថកិច្ចបានដកហូតបានអាវុធខ្លីម៉ាក ZORAKI ចំនួន១ដើម ។ សមត្ថកិច្ចក៏បន្តស្រាវជ្រាវពីប្រភពអាវុធខ្លីនោះ រហូតដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១ និង៣០នាទី រំលងអាធ្រាត្របានឈានដល់ការស្រាវជ្រាវបង្ក្រាបជនសង្ស័យជួញដូរអាវុធបានចំនួន៣នាក់ ភេទប្រុស ( ខ្មែរ២ ចិន១ ) និងដកហូត បានវត្ថុតាងអាវុធមួយចំនួនបន្ថែមទៀត។

ក្នុងករណីនេះ កម្លាំងជំនាញឃាត់ខ្លួនជនសង្ស័យសរុបបានចំនួន១១នាក់ ភេទប្រុស ជនជាតិចិន៩នាក់ និងជនជាតិខ្មែរ២នាក់។វត្ថុតាងដកហូតបានរួមមាន អាវុធវែង២ដើម (ម៉ាក PPSH41 និងម៉ាក កាលីតខ្លូ «KARATAY» ) បង់ត្រឡោកចំនួន១, បង់អាវុធវែងAK ចំនួន១, អាវុធខ្លីចំនួន៤ដើម (ម៉ាក ZORAKI ចំនួន៣ដើម និងម៉ាក SIG SAURER១ដើម) គ្រាប់កាំភ្លើងសរុបចំនួន ២៦៥គ្រាប់, រថយន្តចំនួន៤គ្រឿង និងសម្ភារៈផ្សេងៗ មួយចំនួន, ដោយឡែកជនរងគ្រោះសំណូមពរឱ្យជនសង្ស័យសងលុយវិញ និងចង់ត្រឡប់ទៅប្រទេសកំណើតវិញ។ ករណីនេះការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល កំពុងបន្តការស្រាវជ្រាវតាមនីតិវិធីជំនាញ ដើម្បីស្វែងរកបក្សពួកដែលនៅសេសសល់កំពុងរត់គេចខ្លួន និងកំពុងកសាងសំណុំរឿង បញ្ជូនជនសង្ស័យទៅ សាលាដំបូងខេត្តព្រះសីហនុ ដើម្បីផ្តន្ទាទោសតាមផ្លូវច្បាប់។

ករណីទី២ ធ្វើឡើងនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១១ និង៤០នាទី ដោយអនុវត្តតាមបណ្ដឹងរាយការណ៍ចូលប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានធ្វើការស្រាវជ្រាវរំដោះបានជនរងគ្រោះចំនួន៣នាក់ ជាជនជាតិម៉ាឡេស៊ី ភេទប្រុស នៅក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ និងធ្វើការឃាត់ខ្លួនអ្នកគ្រប់គ្រង១នាក់ ភេទប្រុស ជនជាតិ ម៉ាឡេស៊ី យកមកធ្វើការសាកសួរ។ បន្ទាប់ពីធ្វើការស្រាវជ្រាវ សាកសួរជនរងគ្រោះ និងអ្នកគ្រប់គ្រង បានឲ្យដឹងថា ករណីនេះមិនមែនជាករណីបង្ខាំង ឬជួញដូរមនុស្សដោយខុសច្បាប់នោះទេ ដោយជនរងគ្រោះ បានចូលធ្វើការនៅក្នុងក្រុមហ៊ុនជាធម្មតា តែដោយគាត់មិនពេញចិត្តនិងការងារ និងមិនអាចចេញដើរហើរទៅខាងក្រៅក្រុមហ៊ុនដោយសេរីបាន ទើបពួកគាត់ប្ដឹងស្នើសុំឲ្យយកពួកគាត់ចេញ ពីក្រុមហ៊ុន ដែលពួកគាត់កំពុងធ្វើការ ដើម្បីអាចត្រឡប់ទៅប្រទេសកំណើតវិញ។ ពួកគេបានសំណូមពរចង់ត្រឡប់ទៅប្រទេសកំណើតវិញ។

ករណីទី៣ដោយអនុវត្តតាមបណ្ដឹងរាយការណ៍ចូលប្រព័ន្ធHotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង កម្លាំង ជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានខិតខំព្យាយាមធ្វើការស្រាវជ្រាវ និងទាក់ទងទៅអ្នកដែល បានប្ដឹង ដើម្បីទទួលបានពត៌មានបន្ថែម អំពីទីតាំងរបស់ជនរងគ្រោះ តែមិនមានការឆ្លើយតប( សាម៉ីខ្លួនព្យាយាម មិនសហការជាមួយសមត្ថកិច្ច ) កម្លាំងជំនាញកំពុងបន្តការស្រាវជ្រាវ។

ករណីទី៤ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង១៥៖១៥នាទី ដោយអនុវត្តតាមបណ្ដឹងរាយការណ៍ចូល ប្រព័ន្ធ Hotline ក្រុមការងារសម្ដេចក្រឡាហោម ស ខេង កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានធ្វើការស្រាវជ្រាវរំដោះបានជនរងគ្រោះចំនួន៥នាក់ ( ស្រី១ ) ជាជនជាតិម៉ាឡេស៊ី នៅក្រុមហ៊ុនមួយកន្លែងស្ថិតនៅ ភូមិ៤ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ និងធ្វើការឃាត់ខ្លួនអ្នកគ្រប់គ្រង១នាក់ ភេទប្រុស ជនជាតិម៉ាឡេស៊ី យកមកធ្វើការសាកសួរ។ បន្ទាប់ពីធ្វើការស្រាវជ្រាវ សាកសួរជនរងគ្រោះ និងអ្នកគ្រប់គ្រង បានឲ្យដឹងថា ករណីនេះមិនមែនជាករណី បង្ខាំង ឬជួញដូរមនុស្សដោយខុសច្បាប់នោះទេ ដោយជនរងគ្រោះបានចូលធ្វើ ការនៅ

ក្នុងក្រុមហ៊ុនជាធម្មតា តែដោយគាត់មិនពេញចិត្តនិងការងារ និងមិនអាចចេញដើរហើរទៅខាងក្រៅក្រុមហ៊ុន ដោយសេរីបាន ទើបពួកគាត់ប្តឹងស្នើសុំឲ្យយកពួកគាត់ចេញ ពីក្រុមហ៊ុន ដែលពួកគាត់កំពុងធ្វើការ ដើម្បីអាចត្រឡប់ទៅប្រទេសកំណើតវិញ។ ពួកគេក៏បានសំណូមពរចង់ត្រឡប់ទៅប្រទេសកំណើតវិញ។

ចំពោះជនរងគ្រោះ និងជនសង្ស័យពាក់ព័ន្ធនឹងការណើទាំង៤នេះ សមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ត្រូវបានបញ្ជូនទៅកាន់អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងបានកំពុងបន្តអនុវត្តទៅតាមច្បាប់ និងនីតិវិធីជាធរមាននៃព្រះរាជាណាចក្រកម្ពុជា៕

## កូរ៉េខាងត្បូងជួយដល់ការស្តារនីតិសម្បទាពលករកម្ពុជា

https://www.khmertimeskh.com/ August 28, 2022

សាធារណរដ្ឋកូរ៉េនឹងគាំទ្រដល់ប្រទេសកម្ពុជានូវការផ្តល់ថវិកា ការបណ្តុះបណ្តាលជំនាញ និងការចែករំលែកបទពិសោធន៍ក្នុងការស្តារនីតិសម្បទាកម្មករនិយោជិតដែលរងគ្រោះដោយគ្រោះថ្នាក់ការងារ។ លោក Lee Jae-kap អតីតរដ្ឋមន្ត្រីក្រសួងការងារ និងការងារ នៃសាធារណរដ្ឋកូរ៉េ និងបច្ចុប្បន្នទទួលបន្ទុកកម្មវិធីជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់ការងារស្តារនីតិសម្បទានៅកម្ពុជា បានចែករំលែកផែនការរបស់លោកក្នុងជំនួបជាមួយលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា។ លោក Lee Jae-kap បានជម្រាបជូនលោក អ៊ិត សំហេង ថា លោកបានចូលរួមក្នុងការអភិវឌ្ឍន៍គោលនយោបាយសម្រាប់ការការពារពលករកូរ៉េដែលរងរបួស និងជួយគាំទ្រពួកគេឱ្យចូលធ្វើការវិញ។

លោក អ៊ិត សំហេង បានថ្លែងអំណរគុណគណៈប្រតិភូ ក៏ដូចជាសាធារណៈរដ្ឋកូរ៉េ ហើយជឿជាក់យ៉ាងមុតមាំថា បទពិសោធន៍របស់ លោក Lee Jae-kap នឹងមានប្រយោជន៍សម្រាប់ការងារស្តារនីតិសម្បទាកម្ពុជា។ លោករដ្ឋមន្ត្រីបានធ្វើបច្ចុប្បន្នភាពជូនលោក Lee Jae-kap អំពីការអភិវឌ្ឍន៍ចុងក្រោយបង្អស់នៃប្រព័ន្ធសន្តិសុខសង្គមរបស់ប្រទេសកម្ពុជា ដែលគ្របដណ្តប់លើប្រធានបទដូចជា ហានិភ័យការងារ ការថែទាំសុខភាព និងប្រាក់សោធននិវត្តន៍។ លោកក៏បានវាយតម្លៃខ្ពស់ចំពោះពលករកម្ពុជាជាង ៥ម៉ឺននាក់ដែលកំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េ ទទួលបានជំនាញថ្មីៗ ប្រាក់ចំណូលសមរម្យ និងបទពិសោធន៍ការងារ។ *លឹម ណារី – AKP*

## ពលករវៀតណាមដែលគេកេងប្រវ័ញ្ចដែលរត់គេចខ្លួនជាប់ពាក់ព័ន្ធនឹងជនរួមជាតិ

https://www.khmertimeskh.com/ August 28, 2022

ពលករវៀតណាមចំនួន ៤២ នាក់ដែលត្រូវបានល្បួងមកកម្ពុជា និងកេងប្រវ័ញ្ចការងារនៅកាស៊ីណូថ្មីៗនេះ បានរត់គេចខ្លួនត្រឡប់ទៅប្រទេសវៀតណាមវិញហើយ ដែលពួកគេបានប្រាប់រឿងរ៉ាវនៃការធ្វើជាទាសករ កុមារត្រូវបានគេឃុំខ្លួន ដើម្បីយកប្រាក់លោះខ្លួន និងបានទាក់ទាញជនជាតិវៀតណាមផ្សេងទៀតឱ្យចូលរួមជាមួយពួកគេ។ ជាក់ស្តែង កម្មករទាំង ៤២នាក់ បានរត់ចេញពីកាស៊ីណូ Golden Phoenix Entertainment ក្នុងខេត្តកណ្តាល ប្រទេសកម្ពុជា។ អ្នកយកព័ត៌មានកាសែត Tuoi Tre (Youth) ថ្មីៗនេះបានទៅជួប Golden Phoenix ដែលជាកន្លែងដែលគេឱ្យឈ្មោះដោយអ្នកស្រុកថា ‵នរក 4.0′។

**ត្រឡប់ទៅឋាននរក** ផ្លូវលឿនបំផុតពីប្រទេសវៀតណាមទៅកាន់ភូមិជ្រៃធំ ខេត្តកណ្តាល គឺតាមច្រកព្រំដែន Long Binh ស្រុក An Phu ខេត្ត An Giang។ យ៉ាងណាក៏ដោយ ប៉ុន្មានថ្ងៃនេះ សន្តិសុខនៅច្រកទ្វារព្រំដែនកម្ពុជាត្រូវបានពង្រឹង បន្ទាប់ពីមានព័ត៌មានថា ពលករវៀតណាម ៤២នាក់ បានភៀសខ្លួនចេញពីកាស៊ីណូ Golden Phoenix Entertainment ដែលនៅក្បែរនោះ ហើយហែលឆ្លងទន្លេទៅកាន់ប្រទេសវៀតណាម។ ផ្នែកមួយនៃការឆ្លើយតបរបស់កម្ពុជាចំពោះឧបទ្ទវហេតុនេះ រួមមានការបញ្ជូនកម្លាំងនគរបាលពីរាជធានីភ្នំពេញទៅកាន់តំបន់ព្រំ

ដែន និងធ្វើការត្រួតពិនិត្យអ្នកស្នាក់នៅបរទេសនៅក្នុងខេត្ត។ ពីច្រកទ្វារព្រំដែន ផ្លូវទៅកាន់ Golden Phoenix ដែលត្រូវបានគេស្គាល់ក្នុងស្រុកថាជា Two-Elephant Casino ត្រូវបានខូចខាត និងមានក្រលុកជាច្រើន។ នៅខាងក្រៅកាស៊ីណូ ក្រុមជនជាតិចិនបានដើរប្រសាច រកមនុស្ស ឬអ្វីមួយ ដែលហាក់ដូចជាមិនសូវស្គាល់។ "ផ្លូវជាសម្បត្តិសាធារណៈ ប៉ុន្តែ [ជនជាតិចិនក្នុងតំបន់] ចាត់ទុកពួកគេដូចជាទ្រព្យសម្បត្តិឯកជន។ អ្នកបើកបរជនជាតិខ្មែរម្នាក់បានប្រាប់អ្នកយកព័ត៌មាន Tuoi Tre មនុស្សចម្លែកត្រូវបានគេឃ្លាំមើលជាប់ជានិច្ច។ "ពួកគេតែងតែមើលទៅខឹង។ សូម្បីតែអ្នកស្រុកក៏ខ្លាចពួកនោះដែរ»។ ការពិតដែលថាកម្មករត្រូវបានគេចាប់ជាទាសករក្នុងកាស៊ីណូ មិនមែនជាការសម្ងាត់នៅភូមិជ្រៃធំនោះទេ។ អ្នកស្រុកដឹង ប៉ុន្តែមានអារម្មណ៍ថាអស់សង្ឃឹម។

L. ដែលជាអ្នកនេសាទក្នុងស្រុកដែលបានពន្យល់ថាគាត់ភ័យខ្លាចថានឹងមានអ្វីកើតឡើងប្រសិនបើគាត់ឬនរណាម្នាក់ជួយអ្នកដែលជាប់នៅខាងក្នុង ដោយបានរៀបរាប់ថា "ទាំងមនុស្សពេញវ័យនិងកុមារត្រូវបានព្រមានមិនឱ្យចូលមកជិត [កាស៊ីណូ]" ។ ស្រីម៉ៅ អាជីវករក្នុងស្រុកជ្រៃធំ បានណែនាំអ្នកយកព័ត៌មាន Tuoi Tre កុំឱ្យចូលទៅ Golden Phoenix ដោយពន្យល់ថា អ្នកដំណើរក្នុងស្រុកម្នាក់ដែលកាន់ទូរស័ព្ទដៃត្រូវបានវាយដំជិតស្លាប់ ភ្លាមៗបន្ទាប់ពីការរត់គេចរបស់កម្មករវៀតណាមទាំង ៤២ នាក់។ ម៉ៅ ក៏បានអះអាងថា កាស៊ីណូបានតាមប្រមាញ់អ្នកបើកបរដែលថតបានចំណែកនៃការរត់គេចខ្លួន។ ការងារដោយបង្ខំនៅជ្រៃធំបានក្លាយជាអាជីវកម្មដ៏ធំមួយភ្លាមៗបន្ទាប់ពីការហូរចូលនៃការវិនិយោគរបស់ចិន នៅក្នុងគម្រោងកាស៊ីណូជាបន្តបន្ទាប់នៅតាមដងទន្លេបាសាក់ក្បែរនោះ។ កាស៊ីណូទាំងនេះបានក្លាយជាការទាក់ទាញដ៏សំខាន់មួយសម្រាប់ជនជាតិវៀតណាមយ៉ាងឆាប់រហ័ស ដែលមិនអាចទៅលេងកាស៊ីណូនៅក្នុងប្រទេសរបស់ពួកគេបាន ដែលចង់បានកន្លែងសម្រាប់លេងល្បែងស៊ីសង និងភ្នាល់ជល់មាន់។ បុគ្គលិកកាស៊ីណូនៅទីបំផុតត្រូវបាននាំមកពីទូទាំងអាស៊ីអាគ្នេយ៍ និងតៃវ៉ាន់ ដែលភាគច្រើនធ្វើការក្នុងស្ថានភាពគួរឱ្យសង្វេគ ហើយត្រូវបានហាមឃាត់មិនឱ្យចាកចេញ។

យោងតាម D. នៅពាក់កណ្តាលខែមេសា គាត់បានទទួលការហៅទូរស័ព្ទពីបុរសម្នាក់ឈ្មោះ L. ដែលបានពន្យល់ថាកូនប្រុសរបស់គាត់ និងមិត្តភក្តិរបស់កូនប្រុសគាត់ត្រូវបានបោកបញ្ឆោតឱ្យធ្វើការនៅកាស៊ីណូ Rich World ។ D. បានទាក់ទងកូនប្រុសរបស់ L. ឈ្មោះ N.V.L. ដែលកើតក្នុងឆ្នាំ២០០៥ ហើយបានរកឃើញថាគាត់និងមិត្តភក្តិបីនាក់ទៀត ឈ្មោះ N.D.T. ឈ្មោះ V.D.N.Q. និង T.L.P. បានទៅប្រទេសកម្ពុជាដើម្បីស្វែងរកការងារ។ ក្រុមនេះរកបានការងារធ្វើនៅកាស៊ីណូ យ៉ុង យាន (Yong Yuan Casino) ក្នុងភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ប៉ុន្តែត្រូវបានគេប្រាប់ថា ពួកគេមិនអាចចាកចេញបានទេ លុះត្រាតែបង់ប្រាក់ចំនួន២៥០០ ដុល្លារក្នុងម្នាក់។ D. នៅទីបំផុតបានតាមដានទីតាំងពិតប្រាកដរបស់កាស៊ីណូ Yong Yuan ហើយបានទៅដល់កាស៊ីណូជាមួយឪពុកម្តាយរបស់កុមារ។ ពួកគេអាចបង់ថ្លៃលោះសម្រាប់តែ T. ប៉ុណ្ណោះនាពេលនោះ ខណៈដែលបុគ្គលិកកាស៊ីណូបាននិយាយថា បីនាក់ទៀតដែលនៅសេសសល់ចង់បន្តធ្វើការដើម្បីរកប្រាក់ ដូច្នេះពួកគេបានផ្លាស់ប្តូរពួកគេទៅកាស៊ីណូ Golden Phoenix Entertainment ក្បែរនោះ។

"ឪពុកម្តាយរបស់អនីតិជន និងខ្ញុំបានទៅដល់កាស៊ីណូ Yong Yuan នៅយប់ថ្ងៃទី២១ ខែមេសា ដើម្បីបង់ថ្លៃលោះរបស់ T.។ ចំណែកបីនាក់ផ្សេងទៀតត្រូវបានបញ្ជូនទៅកាស៊ីណូ Golden Phoenix Entertainment រួចហើយ [ចម្ងាយរាប់រយម៉ែត្រ]" D. បានរៀបរាប់ឡើងវិញ។ "នៅថ្ងៃបន្ទាប់ Golden Phoenix បានប្រាប់យើងថាយើងនឹងត្រូវបង់ប្រាក់ ៥,០០០ ដុល្លារក្នុងម្នាក់សម្រាប់កុមារផ្សេងទៀត" ។ នៅយប់នោះ D. និងឪពុកម្តាយបានសម្រេចចិត្តជួយសង្គ្រោះកូនបីនាក់ទៀត។ D. បាននិយាយថា "វាសាមញ្ញណាស់ក្នុងការបង់ប្រាក់លោះនៅកាស៊ីណូ Yong Yuan ប៉ុន្តែវាមានគ្រោះថ្នាក់នៅកាស៊ីណូ Golden Phoenix" ។ "យើងបានមកដល់ Golden Phoenix នៅពាក់កណ្តាលអធ្រាត្រ ហើយពួកគេបានត្រួតពិនិត្យរថយន្តដោយប្រុងប្រយ័ត្ន មុនពេលអនុញ្ញាតឱ្យយើងចេញ។ "បន្ទាប់ពី

បានជួបក្មេងៗនៅច្រកទ្វារកាស៊ីណូ ឪពុកម្តាយបានផ្ទេរប្រាក់លោះទៅគណនីនៅប្រទេសវៀតណាម មុនពេលត្រូវបានអនុញ្ញាតឱ្យចាកចេញ។ «បន្ទាប់មកយើងបើកឡានឲ្យលឿនតាមដែលអាចធ្វើទៅបានព្រោះខ្លាចគេប្រើល្បិចហើយចាប់ពួកយើង»។

យោងតាម L. សុបិន្តអាក្រក់របស់ក្មេងប្រុសនៅក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមនៅពេលដែលពួកគេធ្វើដំណើរទៅកាន់ទីក្រុងហូជីមិញ ប្រទេសវៀតណាមដោយរថយន្តក្រុង ហើយបន្ទាប់មកបានជិះរថយន្ត ១៦ កៅអីឆ្លងកាត់ព្រំដែនចូលប្រទេសកម្ពុជា។ L. ប្រាប់ Tuoi Tre ថា " បង្អួចឡាន ត្រូវបានបិទជិត ដូច្នេះយើងមិនដឹងថាយើងនៅឯណាទេ។ បន្ទាប់ពីឆ្លងកាត់ព្រំដែន យើងត្រូវបានគេនាំទៅផ្ទះទុកចោល ហើយបន្ទាប់មកបានប្រគល់ទៅឲ្យមនុស្សមួយក្រុមផ្សេងទៀត» ។ នៅកាស៊ីណូ Yong Yuan L. និងមិត្តភ័ក្តិរបស់គាត់ត្រូវបានគេប្រាប់ថាពួកគេនឹងធ្វើការឱ្យកម្មវិធីផ្តល់ប្រាក់កម្ចីខុសច្បាប់។ L. បានរៀបរាប់ថា "យើងត្រូវធ្វើការ១២ ម៉ោងក្នុងមួយថ្ងៃ។ ការងារចម្បងរបស់យើងគឺការផ្ញើសារទៅកាន់អ្នកខ្ចីដែលមានសក្តានុពល និងណែនាំពួកគេអំពីរបៀបទទួលបានប្រាក់កម្ចី" ។ លោកបានបន្តថា៖ «បន្ទាប់ពីធ្វើការអស់រយៈពេលជាង ៣ សប្តាហ៍ដោយមិនបានប្រាក់ខែ យើងបានសុំឈប់សម្រាក ប៉ុន្តែអ្នកគ្រប់គ្រងមិនយល់ព្រម។ «ផ្ទុយទៅវិញ គាត់បានសុំឲ្យយើងបង់ប្រាក់ម្នាក់ៗ ២៥០០ ដុល្លារ។ "យើងត្រូវបានគេឃុំខ្លួនក្នុងផ្ទះ។ "ក្រោយពីធ្វើការ យើងត្រូវបានគេប្រាប់ឲ្យស្នាក់នៅក្នុងបន្ទប់ ហើយមិនត្រូវបានគេអនុញ្ញាតឲ្យចេញទេ។ «អ្នកដែលព្យាយាមរត់គេចត្រូវបានគេវាយដំយ៉ាងព្រៃផ្សៃ»។ យោងតាម L. ឈ្មោះកម្មវិធីត្រូវបានផ្លាស់ប្តូរជារៀងរាល់ខែ ដែលធ្វើឱ្យវាមិនអាចកំណត់ព័ត៌មានលម្អិតជាក់លាក់បានទេ។

**បោកប្រាស់ជនរួមជាតិ៖** មន្ត្រីនៅខេត្តព្រះសីហនុរបស់កម្ពុជាបានចែករំលែកថា ពលរដ្ឋខ្មែរ និងចិនមានការលំបាកក្នុងការទាក់ទាញពលករពីប្រទេសផ្សេង ដូច្នេះហើយបានជួលជនជាតិវៀតណាម តៃវ៉ាន់ និងឥណ្ឌូនេស៊ីដើម្បីជ្រើសរើសជនរួមជាតិរៀងៗខ្លួន។ នៅពេលដែលត្រូវបានជ្រើសរើស ពលករទាំងនេះនឹងត្រូវទទួលរងនូវពលកម្មដោយបង្ខំ និងគ្មានប្រាក់ខែ។ V. អាយុ២០ ឆ្នាំមកពីស្រុក Ke Sach ខេត្ត Soc Trang ប្រទេសវៀតណាមគឺជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងនេះ។ V. បានរៀបរាប់ថា "ខ្ញុំបានលឺថាក្រុមហ៊ុនកម្ពុជាមួយផ្តល់ប្រាក់ខែ ៨០០ ដុល្លារក្នុងមួយខែ។ តម្រូវការតែមួយគត់គឺការមានជំនាញវាយអត្ថបទ ដូច្នេះខ្ញុំបានដើរតាមមេខ្យល់ទៅព្រំដែនក្នុងខេត្តតៃនិញ» ។ «នៅកម្ពុជា ខ្ញុំបានដឹងថាមានជនជាតិវៀតណាមជាច្រើនបានទាក់ទាញជនជាតិវៀតណាមផ្សេងទៀតឲ្យលេងហ្គេមអនឡាញ និងលេងល្បែងស៊ីសង»។ V. ត្រូវបានគេយកទៅរក្សាទុកនៅបរិវេណក្នុងខេត្តស្វាយរៀងរបស់ប្រទេសកម្ពុជា ដែលមានចម្ងាយផ្លូវខ្លីពីច្រកព្រំដែន Moc Bai ក្នុងខេត្ត Tay Ninh ប្រទេសវៀតណាម។

ពេលនៅក្នុងបរិវេណនោះ គាត់ត្រូវបង្ខំចិត្តបោកប្រាស់ជនរួមជាតិរហូតដល់ចុងក្រោយគ្រួសាររបស់គាត់បានបង់ថ្លៃលោះចំនួន ៣,៥០០ ដុល្លារ។ V. បាននិយាយថា "ក្នុងអំឡុងពេលថ្ងៃដំបូងរបស់ខ្ញុំនៅក្នុងបរិវេននោះ ខ្ញុំបានសុំមិត្តភ័ក្តិរបស់ខ្ញុំនៅប្រទេសវៀតណាមបញ្ចូលទឹកប្រាក់ក្នុងគណនីរបស់ពួកគេ។ ខ្ញុំគិតថារាល់ការប្រកួតទាំងអស់មានទាំងអ្នកឈ្នះនិងអ្នកចាញ់ ប៉ុន្តែក្រោយមកបានដឹងថាអ្នកលេងមិនអាចដកប្រាក់បានទេ ទោះបីឈ្នះឬអត់ក៏ដោយ»។ "អ្នកលេងត្រូវបានប្រាប់ថាពួកគេបានបញ្ចូល 'លេខសម្ងាត់មិនត្រឹមត្រូវ' បន្ទាប់មកគណនីរបស់ពួកគេត្រូវបានចាក់សោ និងលុប។"នៅថ្ងៃណាដែលល្អ V. អាចរកបានប្រាក់ចំនួន ១ ពាន់លានដុង (៤២,៦៧០ ដុល្លារ) ពីការបោកប្រាស់។ ជនរងគ្រោះទាំងនេះជាច្រើនបានឈប់លេង នៅពេលដែលពួកគេដឹងថាពួកគេត្រូវបានគេបោក ដែលធ្វើឱ្យវាពិបាកសម្រាប់ V. ក្នុងការធានាអាជីវកម្មឡើងវិញ។ កម្មករក៏ត្រូវកំណត់គោលដៅជាក់លាក់ដែរ ហើយអ្នកដែលធ្វើមិនបាន ត្រូវបានគេបង្អត់អាហារ ឬធ្វើទារុណកម្ម។

យោងតាមម្ចាស់កាស៊ីណូ តាមរដូវកាលក្នុងក្រុងបាវិត ខេត្តស្វាយរៀង ការបញ្ចុះបញ្ចូលអ្នកលេងឱ្យដាក់ប្រាក់ចូលទៅក្នុងគណនីល្បែងអនឡាញដែលមិនចេះសងគឺមានប្រជាប្រិយភាពចាប់តាំងពីជនជាតិចិនចាប់ផ្តើមវិនិយោគនៅក្នុងកាស៊ីណូកម្ពុជា។ ម្ចាស់កាស៊ីណូបានពន្យល់ថា "ការលេងល្បែងស៊ីសងត្រូវបានហាមឃាត់នៅក្នុងប្រទេសចិន ដូច្នេះប្រជាជនចិនបានបើកសណ្ឋាគារ និងរមណីយដ្ឋាននានាជាមួយនឹងសេវាកម្មល្បែងអនឡាញនៅក្នុងប្រទេសកម្ពុជា ដើម្បីបម្រើអ្នកលេងល្បែងមកពីប្រទេសចិនដីគោក"។ "កាលពីឆ្នាំមុន រដ្ឋាភិបាលកម្ពុជាបានហាមប្រាមការលេងល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណែត ដូច្នេះល្បែងស៊ីសងថ្មីៗ និងសូម្បីតែការលេងបណ្ណាភាគហ៊ុនត្រូវបានបើកដំណើរចំពោះលុយត្រឹមត្រូវ។ «ដើម្បីស្វែងរកអ្នកលេងថ្មី [ជនជាតិចិន] ជ្រើសរើសពលករមកពីប្រទេសអាស៊ីអាគ្នេយ៍ ដើម្បីបោកប្រាស់ជនរួមជាតិរបស់ពួកគេ។

T. ដែលជាម្ចាស់កាស៊ីណូនៅបាវិត បាននិយាយថា ជនជាតិវៀតណាមជាច្រើននាក់ពិតជាធ្វើការឱ្យប្រតិបត្តិករបណ្តាញក្លែងបន្លំ មិនមែនកាស៊ីណូទេ មានន័យថាកាស៊ីណូទាំងនេះត្រូវបានជួលដោយភាគីទីបីដែលបន្ទាប់មកបោកអ្នកភ្នាល់។

S.C. មន្ត្រីនៅក្រុងព្រះសីហនុ ដែលជាកន្លែងដែលមានកាស៊ីណូជិត ១០០កន្លែង ដែលបង្កើតឡើងដោយជនជាតិចិន បាននិយាយថា ការក្លែងបន្លំតាមអ៊ីនធឺណិតបានរីកដុះដាលក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ នេះក៏ជារយៈពេលតម្រូវការខ្ពស់សម្រាប់ការជ្រើសរើសពលករដែលអស់សង្ឃឹមផងដែរ។

**គេហទំព័រដែលគ្មានអាជ្ញាប័ណ្ណ៖** នៅប្រទេសវៀតណាម អ្នកប្រើប្រាស់អ៊ីនធឺណិតអាចមានភាពងាយស្រួលក្នុងការចូលទៅកាន់គេហទំព័រល្បែងអនឡាញ។ គេហទំព័រទាំងនេះតែងតែស្វែងរកអ្នកប្រើប្រាស់ថ្មីដោយការផ្សាយពាណិជ្ជកម្មជាបន្តបន្ទាប់ ជាពិសេសនៅលើបណ្តាញបាល់ទាត់ដែលគ្មានអាជ្ញាប័ណ្ណ។ ឧទាហរណ៍មួយនៃការនេះកើតឡើងនៅលើ Xoilac ដែលជាគេហទំព័រដែលផ្សាយការផ្សាយបន្តផ្ទាល់ការប្រកួតបាល់ទាត់អន្តរជាតិ ហើយជារឿយៗមានការផ្សាយពាណិជ្ជកម្មសម្រាប់វេទិកាភ្នាល់ Fun88, 188bet, tf88, m88, w88, jun88, និង sodo66 ។ ការផ្សព្វផ្សាយទាំងនេះមានលក្ខណៈពិសេសការផ្សព្វផ្សាយដែលចង់ទាក់ទាញអ្នកប្រើប្រាស់ថ្មីៗ ដូចជាប្រាក់រង្វាន់ ៨០០,០០០ ដុង (៣៤ ដុល្លារ) សម្រាប់សមាជិកថ្មី ទូរស័ព្ទ iPhone 13 Pro បន្ទាប់ពីការបញ្ចូលទឹកប្រាក់ ប្រាក់រង្វាន់ ១០០ ភាគរយជាមួយនឹងការបញ្ចូលទឹកប្រាក់ ១ លានដុង (៤៣ ដុល្លារ) លុយកំរៃជើងសារ ៤០ ភាគរយសម្រាប់ភ្នាក់ងារ និងការទាមទារនៃអត្រាសងប្រាក់ខ្ពស់បំផុតនៅក្នុងទីផ្សារ។ បន្ទាប់ពីចុចលើការផ្សាយពាណិជ្ជកម្ម អ្នកប្រើប្រាស់ត្រូវបានធ្វើទៅកាន់ទំព័រចុះឈ្មោះគណនីដែលពួកគេតម្រូវឱ្យផ្តល់លេខទូរស័ព្ទ អ៊ីមែល ឈ្មោះអ្នកប្រើប្រាស់គណនីនិងលេខសម្ងាត់របស់ពួកគេ។ពួកគេក៏ត្រូវបានប្រាប់ឱ្យបញ្ចូលទឹកប្រាក់ក្នុងគណនីរបស់ពួកគេផងដែរ។

ជាញឹកញាប់ អ្នកប្រើប្រាស់ទាំងនេះត្រូវបានប្រាប់ថាពួកគេនឹងទទួលបានប្រាក់រង្វាន់ ១០០ ភាគរយបន្ទាប់ពីការបញ្ចូលទឹកប្រាក់លើកដំបូងរបស់ពួកគេ។ វិធីសាស្ត្របញ្ចូលទឹកប្រាក់ជាច្រើនត្រូវបានផ្តល់ជូនជាធម្មតា រួមទាំងតាមរយៈកាបូបអេឡិចត្រូនិក ធនាគារ សេវាធនាគារអេឡិចត្រូនិក និងកាតកោស។ បន្ទាប់ពីបញ្ចូលទឹកប្រាក់ក្នុងគណនី អ្នកលេងអាចភ្នាល់លើកីឡា កីឡាអេឡិចត្រូនិក ហ្គេមកាស៊ីណូបន្តផ្ទាល់ បៀPoker និងល្បែងបាញ់ត្រី។

**ការណែនាំដ៏គួរឱ្យទាក់ទាញ៖** Shbet ដែលជាវេទិកាភ្នាល់មួយផ្សេងទៀត ហៅខ្លួនឯងថា "ធនាគារិកនៃក្រុមកម្សាន្តដែលមានស្នាក់ការ នៅក្នុងប្រទេសកម្ពុជាជាមួយនឹងប្រតិបត្តិការរយៈពេល១០ ឆ្នាំនៅក្នុងទីផ្សារភ្នាល់អនឡាញ។ Shbet ក៏ជាធនាគារឈានមុខគេនៅក្នុងទីផ្សារភ្នាល់អនឡាញវៀតណាម ហើយបានទាក់ទាញអ្នកភ្នាល់ជាច្រើនចាប់តាំងពីដើមឆ្នាំ ២០២២។ វាផ្តល់ជូននូវសំណុំហ្គេមភ្នាល់កីឡាចម្រុះ ហ្គេមកាស៊ីណូអនឡាញ ល្បែងបាញ់ត្រី ជល់មាន់ និងសេវាកម្មឆ្នោត។ យោងតាមប្រតិបត្តិករគេហទំព័រ វាបានបង្កើតក្រុមអ្នកបច្ចេកទេសដែលមាន

ជំនាញវិជ្ជាជីវៈ ដែលបន្តធ្វើបច្ចុប្បន្នភាពតំណភ្ជាប់នៅលើ Shbet ដោយមិនត្រូវបានរារាំងដោយប្រតិបត្តិករបណ្ដាញ ដើម្បីរក្សាអ្នកលេង។ *Tuoi Tre*

## នគរបាលវៀតណាមៈ ការជួយសង្គ្រោះជនអន្តោប្រវេសន៍ខុសច្បាប់ពីកម្ពុជាជាកិច្ចការដ៏លំបាក

https://www.khmertimeskh.com/ August 28, 2022

នគរបាលបាននិយាយថា ជនជាតិវៀតណាមរាប់ពាន់នាក់អាចត្រូវបានរត់ពន្ធមកកម្ពុជា ដើម្បីកេងប្រវ័ញ្ច ហើយការជួយសង្គ្រោះពួកគេពិតជាពិបាក។ លោកវរសេនីយ៍ឯក Khong Ngoc Oanh មកពីក្រសួងសន្តិសុខសាធារណៈកាលពីថ្ងៃច័ន្ទបាននិយាយថា ពលករចំណាកស្រុកខុសច្បាប់ភាគច្រើនត្រូវបានសន្យាថា "ការងារងាយស្រួល ទទួលបានប្រាក់ខែខ្ពស់" តែបែរជាត្រូវបាននាំទៅកាស៊ីណូ និងកន្លែងផលិតកម្មផ្សេងទៀត ជាកន្លែងដែលពួកគេត្រូវធ្វើការក្នុងបរិយាកាសស្រដៀងនឹងការជាប់ពន្ធនាគារ។ លោកបានបន្ថែមថា បើគ្មានលុយ ឬចំណេះដឹងអំពីច្បាប់ ពលករខុសច្បាប់ជាច្រើន ដែលមានទាំងក្មេងជំទង់ នឹងពិបាកក្នុងការរត់គេចខ្លួន។

អាជ្ញាធរបាននិយាយថា មនុស្សរាប់ពាន់នាក់ប្រហែលជាត្រូវបានរត់ពន្ធចូលមកប្រទេសកម្ពុជា ដើម្បីត្រូវបានកេងប្រវ័ញ្ច ដោយបង្ខំឱ្យធ្វើការក្នុងបរិយាកាសការងារដ៏អាក្រក់មិនគួរឱ្យជឿ និងមិនទទួលបានប្រាក់ខែដែលបានព្រមព្រៀងគ្នា។ ប្រតិបត្តិការជួយសង្គ្រោះក៏មានការលំបាកដែរ ខណៈឧប្បត្តិហេតុភាគច្រើនកើតឡើងហួសពីដែនសមត្ថកិច្ច។ ទីតាំងក៏ត្រូវបានលាក់យ៉ាងជ្រៅនៅក្នុងព្រៃ ហើយជារឿយៗត្រូវបានលាក់បាំងជាចំណុចផលិតកម្ម។ គ្មានផ្លូវសម្រាប់អ្នកខាងក្រៅដើម្បីដឹងពីអ្វីដែលពិតជាកើតឡើងនៅខាងក្នុងនោះទេ ហើយអាជ្ញាធរក៏ពិបាកក្នុងការផ្ទៀងផ្ទាត់ព័ត៌មានផងដែរ។

លោក Oanh បាននិយាយថា រដ្ឋាភិបាលវៀតណាម និងកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីរួចហើយ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដែលអាជ្ញាធរកម្ពុជាធ្វើការស្វែងរក ផ្ទៀងផ្ទាត់ព័ត៌មាន និងផ្តល់ឯកសារទាក់ទងនឹងឧប្បត្តិហេតុមួយ ដោយមានកិច្ចសហប្រតិបត្តិការពីសមភាគីវៀតណាម។ ការជួញដូរមនុស្សភាគច្រើនកើតឡើងនៅតំបន់ក្រីក្រ ឧទាហរណ៍នៅតាមតំបន់ព្រំដែន។ ជនរងគ្រោះនៃការជួញដូរមនុស្សអាចមកពីគ្រប់មជ្ឈដ្ឋាន ដោយមានមនុស្សជាច្រើនជាជនក្រីក្រ ឬសូម្បីតែក្មេងជំទង់ត្រូវបានទាក់ទាញដោយការសន្យាតាមអ៊ីនធឺណិត។ លោក Oanh បាននិយាយថា កម្មករគួរតែប្រាប់ក្រុមគ្រួសាររបស់ពួកគេឱ្យច្បាស់ថាពួកគេនឹងទៅណាជាមួយអ្នកណា និងពេលណាដែលពួកគេរំពឹងថានឹងត្រលប់មកវិញ។ កម្មករមិនគួរចាកចេញដោយខ្លួនឯងទេ ព្រោះពេលពួកគេធ្លាក់ក្នុងកណ្តាប់ដៃឧក្រិដ្ឋជន វានឹងមានការលំបាកបំផុតសម្រាប់ប្រតិបត្តិការសង្គ្រោះ។

ការថ្លែងរបស់លោកបានធ្វើឡើងបន្ទាប់ពីការរត់គេចខ្លួនជនជាតិវៀតណាម ៤២នាក់ ពីកាស៊ីណូមួយក្នុងខេត្តកណ្តាល នៃប្រទេសកម្ពុជា ដោយសារការបង្ខាំងខ្លួន និងការធ្វើទារុណកម្ម ដោយបានហែលទឹកកាត់ទន្លេ Binh Di នៃខេត្ត An Giang កាលពីថ្ងៃទី១៨ ខែសីហា ដើម្បីគេចខ្លួន។ ប៉ុន្តែមានតែមនុស្ស ៤០ នាក់ប៉ុណ្ណោះដែលបានទទួលជោគជ័យដោយមានក្មេងប្រុសអាយុ ១៦ ឆ្នាំម្នាក់បានលង់ទឹកក្នុងហេតុការណ៍នោះនិងម្នាក់ទៀតត្រូវបានចាប់ខ្លួនបានវិញពីខាងកាស៊ីណូ។

កាលពីថ្ងៃអង្គារ បន្ទាប់ពីការស៊ើបអង្កេតដំបូងត្រូវបានបញ្ចប់ អ្នករត់គេចខ្លួនទាំង ៤០ នាក់គ្រាន់តែត្រូវបង់ប្រាក់ពិន័យចន្លោះពី ២ ទៅ ៤ លានដុង (៨៥.២៤ ទៅ ១៧០.៤៨ ដុល្លារ) ហើយត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះរបស់ពួកគេវិញ ដែលស្ថិតនៅពាសពេញតំបន់ ២០ ផ្សេងៗគ្នា។

ក្នុងឆមាសទី១ឆ្នាំនេះ នគរបាលវៀតណាមសហការជាមួយអាជ្ញាធរកម្ពុជាបានជួយសង្គ្រោះមនុស្សជាង ២៥០នាក់ដែលគេបោកប្រាស់ឲ្យទៅធ្វើការងារខុសច្បាប់។ *VnExpress*

## ជនរងគ្រោះវៀតណាមចំនួន២៥នាក់ ដែលត្រូវបានគេបោកឱ្យមកធ្វើការខុសច្បាប់នៅកម្ពុជា ត្រូវបានធ្វើមាតុភូមិនិវត្តន៍

https://www.khmertimeskh.com/ August 28, 2022

ក្រសួងការបរទេសបាននិយាយកាលពីថ្ងៃព្រហស្បតិ៍ថា កម្ពុជាបានបញ្ចប់នីតិវិធីសម្រាប់ពលរដ្ឋវៀតណាម ២៥នាក់ ដែលត្រូវបានគេបោកប្រាស់ឱ្យមកធ្វើជាកម្មករនៅក្នុងប្រទេស ឱ្យត្រឡប់ទៅប្រទេសវៀតណាមវិញ។ ក្នុងចំណោមអ្នកទាំង ២៥នាក់នោះ ១១នាក់ត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការនៅកាស៊ីណូ Golden Phoenix Entertainment ក្នុងខេត្តកណ្ដាល របស់កម្ពុជា រួមទាំងមនុស្សម្នាក់ដែលត្រូវបានចាប់ខ្លួន ខណៈពេលដែលព្យាយាមរត់គេចកាលពីសប្ដាហ៍មុន នេះបើតាមអ្នកនាំពាក្យក្រសួងការបរទេសលោកស្រី Le Thi Thu Hang បាននិយាយនៅក្នុងសន្និសីទសារព័ត៌មានមួយ។ អ្នកស្រីបន្តថា អាជ្ញាធរវៀតណាមកំពុងផ្ទៀងផ្ទាត់ព័ត៌មាន និងចាត់វិធានការការពារពលរដ្ឋដើម្បីឲ្យពលរដ្ឋទាំង ២៥នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍។ លោកស្រីបានបន្ថែមថា៖ « ពលរដ្ឋទាំងអស់មានសុខភាពធម្មតា ហើយត្រូវបានធ្វើតេស្តរកសារជាតុញៀន អវិជ្ជមាន»។ លោកស្រី Hang បាននិយាយថា ក្រសួងបានស្នើឱ្យកម្ពុជាស៊ើបអង្កេតបញ្ហានេះ និងបង្កើនការត្រួតពិនិត្យលើកន្លែងនានា ជាពិសេសកន្លែងកម្សាន្ត ដើម្បីស្វែងរក និងទប់ស្កាត់ការកេងប្រវ័ញ្ចលើពលករបរទេស រួមទាំងជនជាតិវៀតណាមផងដែរ។

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំព្រំដែនខេត្ត An Giang ប្រទេសវៀតណាម ដែលជាប់ព្រំដែនចិន បានឃាត់ខ្លួនមនុស្ស ៤០នាក់ ដែលលួចចូលវៀតណាមដោយខុសច្បាប់ បន្ទាប់ពីហែលទឹកឆ្លងទន្លេ Binh Di ដើម្បីគេចចេញពីកាស៊ីណូ Phoenix ក្នុងប្រទេសកម្ពុជា។ ម្នាក់ក្នុងចំណោម២នាក់ផ្សេងទៀត ដែលបានព្យាយាមរត់គេចខ្លួនផងដែរ ពោលគឺក្មេងប្រុសជំទង់ម្នាក់ បានលង់ទឹកទន្លេ ចំណែកម្នាក់ទៀតត្រូវបានមនុស្សកាស៊ីណូចាប់បានវិញ។ ជនជាតិវៀតណាមបាននិយាយថា ពួកគេត្រូវបានគេឃុំខ្លួននៅកាស៊ីណូប្រឆាំងនឹងឆន្ទៈរបស់ពួកគេ និងទទួលរងការធ្វើទារុណកម្ម។ មកទល់ពេលនេះ អាជ្ញាធរបានជួយសង្គ្រោះពលរដ្ឋវៀតណាមជាង ៥០០នាក់ និងជួយមនុស្សរាប់ពាន់នាក់ទៀតនៅកម្ពុជាជាមួយនឹងនីតិវិធីក្នុងការវិលត្រឡប់មកវិញ។

ក្នុងឆមាសទី១ឆ្នាំនេះ ក្រសួងសន្តិសុខសាធារណៈបានបង្ក្រាបបណ្ដាញជាច្រើនដែលរត់ពន្ធមនុស្សមកកម្ពុជាដើម្បីធ្វើការខុសច្បាប់។ នាយឧត្តមសេនីយ៍ កែវ វ៉ាន់ថន អ្នកនាំពាក្យនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា បានប្រាប់សារព័ត៌មានក្នុងស្រុកកាលពីថ្ងៃច័ន្ទថា លោកបានដឹកនាំក្រុមទៅកាស៊ីណូ និងបានឃាត់ខ្លួនអ្នកគ្រប់គ្រងជនជាតិចិនម្នាក់ ដើម្បីសាកសួរ។ លោកបានបន្តថា អ្នកគ្រប់គ្រងរូបនេះបានទទួលស្គាល់ថាបានប្រើការអនុវត្ត«ពលកម្មដោយបង្ខំ»។ *VnExpress*

## បុរសវៀតណាមលក់មិត្តភ័ក្តិកូនប្រុសគាត់ ទៅកម្ពុជា

https://www.khmertimeskh.com/ August 28, 2022

ឧក្រិដ្ឋជននៅខេត្ត Hai Phong បច្ចុប្បន្នកំពុងស្ថិតក្រោមការស៊ើបអង្កេតពីបទបោកបញ្ឆោតមិត្តភ័ក្តិរបស់កូនប្រុសគាត់ និងជួញដូរពួកគេមកប្រទេសកម្ពុជាដើម្បីធ្វើការក្នុងកាស៊ីណូ។ យោងតាមនគរបាលនៅទីក្រុងភាគខាងជើង លោក Nguyen Van Anh អាយុ ៤៥ ឆ្នាំបានជាប់ពន្ធនាគារចំនួន ៤ ដងពីបទឧក្រិដ្ឋកម្មផ្សេងៗ។ ក្នុងអំឡុងពេលចុងក្រោយរបស់គាត់ គាត់បានទាក់ទងជាមួយអ្នកទោសពីរនាក់ដែលមានរហស្សនាមថា Vang និង

Cau ហើយបានជួបអ្នកទាំងនោះនៅពេលគាត់ត្រូវបានដោះលែងនៅឆ្នាំ២០២០។ នៅពេលនោះពួកគេកំពុងធ្វើការឱ្យក្រុមក្មេងទំនើងដែលរត់ពន្ធមនុស្សដែលមានអាយុពី 18-40 ឆ្នាំមកប្រទេសកម្ពុជាដើម្បីធ្វើការ ដោយផ្តល់លុយកំមីសុងច្រើន។ Anh បានសម្រេចចិត្តចូលរួមជាមួយពួកគេ ដោយកំណត់គោលដៅក្រុមមិត្តភក្តិរបស់កូនប្រុសគាត់ និងបានទៅជិតក្មេងប្រុសបួននាក់អាយុ ១៦-១៧ ឆ្នាំដែលជាអ្នកស្រុក Hai Phong ទាំងអស់។ គាត់បានបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយក្មេងប្រុសទាំងនោះ ហើយថែមទាំងព្រមធ្វើជា "ឪពុកចិញ្ចឹម" របស់ពួកគេ។ ពួកគេបានបោះបង់ការសិក្សា ហើយចង់ស្វែងរកការងារធ្វើដើម្បីផ្គត់ផ្គង់គ្រួសារ ហើយ Anh បានដាក់ទុនលើរឿងនេះ ដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យទៅធ្វើការនៅប្រទេសកម្ពុជា។

នគរបាលបាននិយាយថា កាលពីចុងខែមីនា គាត់បានប្រាប់ពួកគេទាំង៤នាក់ថា មិត្តភ័ក្តិរបស់គាត់ដែលស្នាក់នៅប្រទេសកម្ពុជាកំពុងជ្រើសរើសកម្មករវ័យក្មេង ហើយសន្យាថានឹងផ្តល់ប្រាក់ខែដល់ពួកគេចំនួន ១៨-២០ លានដុង (៧៧០-៨៥៥ ដុល្លារ) ក្នុងមួយខែ។ បន្ទាប់មកគាត់បានទាក់ទងទៅ Vang និង Cau ហើយរៀបចំឲ្យពួកគេរត់ពន្ធក្មេងប្រុសទាំងនោះចូលប្រទេសកម្ពុជា។ លុះពេលពួកគេទៅដល់ប្រទេសនោះ ទើបក្មេងប្រុសទាំងបួននាក់ដឹងថាពួកគេត្រូវបានគេលក់ទៅធ្វើការនៅកាស៊ីណូក្នុងតម្លៃ ២៤០០ ដុល្លារក្នុងម្នាក់។ ពួកគេបានប្រាប់នគរបាលបន្ទាប់ពីត្រឡប់ទៅប្រទេសវៀតណាមវិញថា ប្រសិនបើពួកគេចង់ត្រឡប់មកផ្ទះវិញ ពួកគេម្នាក់ៗត្រូវបង់ប្រាក់យ៉ាងតិច ២៤០០ ដុល្លារ ឬត្រូវលក់នៅកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជា។

ក្មេងប្រុសបានទូរស័ព្ទទៅក្រុមគ្រួសាររបស់ពួកគេដែលបានទាក់ទងទៅអ្នកគ្រប់គ្រងកាស៊ីណូដើម្បីបង់ប្រាក់លោះ។ នគរបាលបាននិយាយថា គ្រួសារមួយក្នុងចំណោមគ្រួសារនោះ បានបង់ប្រាក់ចំនួន ២៦០០ ដុល្លារ ហើយអ្នកនៅសល់បង់ចំនួន ១០,០០០ ដុល្លារក្នុងម្នាក់ៗ។ ក្មេងប្រុសទាំងនោះបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងលោក Nguyen Van Anh។ ប៉ុន្តែមុនពេលពួកគេត្រឡប់មកវិញ លោក Anh ត្រូវបានចាប់ខ្លួនពីបទកាន់កាប់ថ្នាំញៀន ៤០០ ក្រាម និងថ្នាំញៀនអេកស្តាស៊ីចំនួន ១.០០០ គ្រាប់ នៅខេត្ត Quang Ninh ដែលនៅជិតខាង។ កាលពីថ្ងៃច័ន្ទ លោកវរសេនីយ៍ឯក Khong Ngoc Oanh នៃក្រសួងសន្តិសុខសាធារណៈបានប្រាប់កិច្ចប្រជុំនៅទីក្រុងហាណូយថា មនុស្សរាប់ពាន់នាក់អាចត្រូវបានរត់ពន្ធមកកម្ពុជាដើម្បីកេងប្រវ័ញ្ច ហើយការជួយសង្គ្រោះពួកគេនឹងមានការលំបាក។

លោកបាននិយាយថា កម្មករភាគច្រើនដែលត្រូវបានជួញដូរត្រូវបានសន្យាថា "ការងារងាយស្រួលជាមួយនឹងប្រាក់ឈ្នួលខ្ពស់" តែត្រូវបាននាំយកទៅកាស៊ីណូ និងកន្លែងផលិតកម្មដែលពួកគេត្រូវបានបង្ខាំងខ្លួន។
ថ្មីៗនេះ ចំណងជើងក្នុងសារព័ត៌មាន ដែលថាមានជនជាតិវៀតណាម ៤២នាក់ ដែលព្យាយាមរត់គេចពីកាស៊ីណូក្នុងខេត្តកណ្តាល របស់កម្ពុជា ហើយត្រឡប់ទៅប្រទេសវៀតណាមវិញ ដោយហែលទឹកឆ្លងទន្លេក្នុងខេត្តអានយ៉ាង។ ប៉ុន្តែមានតែ ៤០ នាក់ប៉ុណ្ណោះដែលបានទទួលជោគជ័យ ដោយក្មេងប្រុសអាយុ ១៦ ឆ្នាំម្នាក់បានលង់ទឹក និងម្នាក់ទៀតត្រូវបានកាស៊ីណូចាប់បានមកវិញ។ នគរបាលកម្ពុជាបានបញ្ចប់នីតិវិធីក្នុងការធ្វើមាតុភូមិនិវត្តន៍ជនជាតិវៀតណាម ២៥ នាក់ផ្សេងទៀតដែលត្រូវបានគេបោកបញ្ឆោតចូលក្នុងកាស៊ីណូកម្ពុជា រួមទាំងអ្នកដែលគេចាប់បានផងដែរ។ ក្នុងឆមាសទី១ឆ្នាំនេះ នគរបាលវៀតណាមដោយធ្វើការសហការជាមួយអាជ្ញាធរកម្ពុជា បានជួយសង្គ្រោះមនុស្សបានជាង ២៥០នាក់។ *EVN Express*

# ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

## សមត្ថកិច្ច ចុះស្រាវជ្រាវតាមបណ្ដឹង Hotline ៣ករណី រកឃើញជនជាតិម៉ាឡេស៊ី៦នាក់ ប៉ុន្តែមិនមែនជាករណីបង្ខាំង ឬជួញដូរទេ

http://freshnewsasia.com/ 2022-08-28 12:16pm

**(ព្រះសីហនុ)៖** នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២ម្សិលមិញនេះ កម្លាំងសមត្ថកិច្ច ខេត្តព្រះសីហនុ បានចុះស្រាវជ្រាវតាមបណ្ដឹង Hotline ចំនួន៣ករណី នៅខេត្តព្រះសីហនុ ដោយរកឃើញជនជាតិម៉ាឡេស៊ី៦នាក់ ដែលមកបម្រើការងារនៅកម្ពុជា ប៉ុន្តែក្រោយពេលសាកសួរ លទ្ធផលបង្ហាញថាមិនមែនជាបង្ខាំង ឬជួញដូរដូចការប្ដឹងនោះទេ។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ ករណីទី១ សមត្ថកិច្ចបានចុះមកដល់ទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិ៦ សង្កាត់៤ ក្រុងព្រះសីហនុ ដើម្បីធ្វើការស្រាវជ្រាវស្វែងរកជនរងគ្រោះ។ ដោយមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ចបានស្វែងរកឃើញស្ត្រីជនជាតិម៉ាឡេស៊ីឈ្មោះ AUDREY WEE JIN YIN កំពុងធ្វើការនៅក្នុងក្រុមហ៊ុន ទើបកម្លាំងសមត្ថកិច្ចនាំគាត់ និងបាននាំអ្នកគ្រប់គ្រងជនជាតិចិន១នាក់ យកមកធ្វើការសាកសួរ។ បន្ទាប់ពីធ្វើការសាកសួរបឋម ជនរងគ្រោះបានឲ្យដឹងថាៈ មិនមានអ្នកណាបង្ខាំង វាយធ្វើបាបរូបគាត់ទេ ដោយគាត់កំពុងធ្វើការនៅក្នុងក្រុមហ៊ុនជាធម្មតា ហើយគាត់ក៏មិនបានប្ដឹងសមត្ថកិច្ចឲ្យចុះមកជួយដែរ។ បន្ទាប់ពីគាត់ទាក់ទងទៅម្ដាយរបស់គាត់ដែលនៅប្រទេសម៉ាឡេស៊ី ទើបគាត់បានដឹងថា ម្ដាយរបស់គាត់ព្រួយបារម្ភរូបគាត់ខ្លាចថា ត្រូវបានគេចាប់បង្ខាំង វាយធ្វើបាប ទើបម្ដាយគាត់ប្ដឹងសមត្ថកិច្ចឲ្យជួយ។

អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ទៀតថា ករណីទី២ គឺសមត្ថកិច្ចបានចុះមកដល់ក្រុមហ៊ុនពីរកន្លែង ដោយទីតាំងទី១ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ និងទីតាំងទី២ ស្ថិតនៅភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ដើម្បីធ្វើការស្រាវជ្រាវស្វែងរកជនរងគ្រោះឈ្មោះ Yong Kah Chun ភេទប្រុស ជនជាតិម៉ាឡេស៊ី។ ដោយមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ច បានស្វែងរកនៅក្នុងក្រុមហ៊ុនទាំង២ទីតាំង តែមិនបានឃើញជនរងគ្រោះទេ ដោយអ្នកគ្រប់គ្រងទីតាំងទី២ បានបំភ្លឺជូនសមត្ថកិច្ចយើងថា ឈ្មោះ Yong Kah Chun ភេទប្រុស ជនជាតិម៉ាឡេស៊ី បានសុំឈប់ពីការងារតាំងពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ មកម្លេះ ហើយបានចាកចេញពីក្រុមហ៊ុនទៅ។ ចំពោះករណីនេះ កម្លាំងជំនាញកំពុងបន្តការស្រាវជ្រាវ។ លោកនាយឧត្តមសេនីយ៍ បានបន្តថា ចំណែកករណីទី៣ សមត្ថកិច្ចបានចុះមកដល់ទីតាំងក្រុមហ៊ុនមួយស្ថិតនៅភូមិ៤ សង្កាត់៤ ក្រុងព្រះសីហនុ ដើម្បីធ្វើការស្រាវជ្រាវស្វែងរកបុរសជនជាតិម៉ាឡេស៊ី៥នាក់ ។

ដោយមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ច ក៏បានស្វែងរកឃើញបុរសជនជាតិម៉ាឡេស៊ីទាំង៥នាក់ កំពុងធ្វើការនៅក្នុងក្រុមហ៊ុន ទើបកម្លាំងសមត្ថកិច្ចនាំពួកគាត់មកធ្វើការសាកសួរ។ បន្ទាប់ពីធ្វើការសាកសួរបឋម ជនរងគ្រោះបានឲ្យដឹងថា ការធ្វើការនេះមិនមែនជាករណីបង្ខាំង ឬជួញដូរមនុស្សដោយខុសច្បាប់នោះទេ តែដោយសារលក្ខខណ្ឌការងារក្រុមហ៊ុនតឹងរឹងមិនអនុញ្ញាតឲ្យចេញក្រៅ ហើយពួកគាត់ត្រូវធ្វើការច្រើនម៉ោង ជាហេតុធ្វើឲ្យពួកគាត់មិនអាចទ្រាំបាន ទើបពួកគាត់ប្ដឹងស្នើសុំឲ្យយកពួកគាត់ចេញពីក្រុមហ៊ុន ដើម្បីពួកគាត់អាចត្រឡប់ទៅស្រុកកំណើតវិញ។

សូមបញ្ជាក់ថា ប្រតិបត្តិការស្រាវជ្រាវនេះ បានធ្វើលើងបន្ទាប់ពីមានបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង ថាត្រូវបានគេចាប់បង្ខាំងទុក ដើម្បីឱ្យនៅបម្រើការងារក្នុងក្រុមហ៊ុន ចំនួន ០៣ករណីនៅក្នុងខេត្តព្រះសីហនុ៕

## កងរាជអាវុធហត្ថជួយសង្គ្រោះជនជាតិថៃ ៨នាក់ តាមការស្នើសុំរបស់អនុព័ន្ធប៉ូលិសអមស្ថានទូតថៃប្រចាំកម្ពុជា

http://freshnewsasia.com/ 2022-08-28 06:54pm

**(ភ្នំពេញ)៖** ជនជាតិថៃចំនួន៨នាក់ ត្រូវបានអន្តរាគមន៍ជួយសង្គ្រោះតាមការស្នើសុំរបស់អនុព័ន្ធប៉ូលិសអមស្ថានទូតថៃប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មកបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ នេះបើតាមឧត្តមសេនីយ៍ត្រី អេង ហី អ្នកនាំពាក្យកងរាជអាវុធហត្ថលើផ្ទៃប្រទេស បញ្ជាក់បណ្តាញព័ត៌មាន Fresh News នៅព្រលប់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២នេះ។

ឧត្តមសេនីយ៍ត្រី អេង ហី បានឱ្យដឹងថា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ កម្លាំងកងរាជអាវុធហត្ថខេត្តស្វាយរៀង បានអន្តរាគមន៍ជួយសង្គ្រោះជនជាតិថៃ ចំនួន០១នាក់ និងកម្លាំងកងរាជអាវុធហត្ថខេត្តព្រះសីហនុ បានអន្តរាគមន៍ជួយសង្គ្រោះជនជាតិថៃ ចំនួន០៧នាក់។ ឧត្តមសេនីយ៍ត្រី អេង ហី បានបញ្ជាក់ថា តាមគោលការណ៍ដឹកនាំរបស់នាយឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានឱ្យកម្លាំងជំនាញស្រាវជ្រាវព័ត៌មាន និងសន្តិសុខ បញ្ជូនជនជាតិថៃទាំង៨នាក់ ទៅប្រគល់ជូននគរបាលអន្តោប្រវេសន៍ ដើម្បីអនុវត្តតាមនីតិវិធីប្រគល់ជូនភាគីថៃ។ ប៉ុន្តែដោយសារក្នុងចំណោមជនជាតិថៃចំនួន៨នាក់ មាន៤នាក់ បានធ្វើតេស្តឃើញមានវិជ្ជមានជំងឺកូវីដ១៩ ភាគីថៃបានស្នើសុំឱ្យកងរាជអាវុធហត្ថ ជួយថែទាំ និងព្យាបាលជនជាតិចំនួន៤នាក់នោះសិន ពេលជាសះស្បើយជំងឺកូវីដ១៩ ទើបភាគីថៃ ទទួលយកទៅប្រទេសថៃវិញ។ ចំណែកឯជនជាតិថៃ៤នាក់ទៀតដែលមិនមានជំងឺកូវីដ១៩នោះទេ ត្រូវបានភាគីថៃទទួលយកទៅប្រទេសថៃវិញ៕

## សមត្ថកិច្ចចុះពិនិត្យទីតាំងមួយនៅខេត្តព្រះសីហនុ រកឃើញជនជាតិថៃ១៩នាក់ ដែលចូលមកកម្ពុជាដោយខុសច្បាប់

http://freshnewsasia.com/ 2022-08-29 09:36am

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ សហការជាមួយកម្លាំងនាយកដ្ឋាននគរបាលសន្តិសុខផ្ទៃក្នុង កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ម្សិលមិញ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុនមួយ នៅភូមិ៦ សង្កាត់៤ ក្រុង សីហនុ ដោយបានរកឃើញជនជាតិថៃ ១៩នាក់ ដែលចូលមកកម្ពុជាដោយខុសច្បាប់។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា ការចុះស្រាវជ្រាវខាងលើនេះ ធ្វើឡើងបន្ទាប់ពីមានសំណើរបស់ អនុព័ន្ធនគរបាលភូមិន្ទថៃ ប្រចាំស្ថានទូតថៃ ដោយស្នើសុំជួយសង្គ្រោះជនជាតិថៃ១៩ នាក់ ដែលត្រូវបង្ខាំងឱ្យធ្វើការ នៅខេត្តព្រះសីហនុ ។ នាយឧត្តមសេនីយ៍ បានបញ្ជាក់បន្ថែមថា ក្នុងចំណោមជនជាតិថៃដែលចូលមកកម្ពុជាខុសច្បាប់ទាំង១៩ នាក់ (ស្រី ៨នាក់) មាន១៥ នាក់ (ស្រី ៦ នាក់) មានដីកា តាមចាប់ខ្លួន ពីតុលាការថៃ ពាក់ព័ន្ធ បទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា។ ចំណែក៤នាក់ទៀត ដែលពុំមានជាប់ពាក់ព័ន្ធនឹងបទល្មើសក្នុងប្រទេសថៃ បានស្ម័គ្រចិត្តសុំត្រឡប់ទៅប្រទេសថៃវិញ។

បើតាមអ្នកនាំពាក្យក្រសួងមហាផ្ទៃ, ជនជាតិថៃទាំង ១៩នាក់នេះមានអត្តសញ្ញាណបណ្ណសញ្ញាតិថៃ ប៉ុន្តែពុំមានលិខិតឆ្លងដែនទេ ហើយចូលមកប្រទេសកម្ពុជាតាមច្រកល្បៀងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយខុសច្បាប់៕

## វៀតណាមផ្តល់ប័ណ្ណសរសើរដល់មនុស្ស៦នាក់ក្នុងការជួយអ្នកផ្សេងទៀតអោយរត់គេចចេញពីកាស៊ីណូនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times August 29, 2022

មនុស្ស៦នាក់មកពីខេត្ត AnGiang ភាគខាងត្បូងបានទទួលប័ណ្ណសរសើរក្នុងការជួយសង្គ្រោះជនជាតិវៀតណាមចំនួន ៤០ នាក់ដែលរត់គេចពីការងារដោយបង្ខំនៅកាស៊ីណូក្នុងប្រទេសកម្ពុជាកាលពីសប្តាហ៍មុន។ ពិធីនេះបានធ្វើឡើងកាលពីថ្ងៃព្រហស្បតិ៍បន្ទាប់ពីមានការសម្រេចពីលោកវរសេនីយ៍ឯក Định Văn Nơi នាយកប៉ូលិសខេត្ត An Giang។ អ្នកទាំង៦នាក់បានទទួលប័ណ្ណសរសើរសម្រាប់ "សមិទ្ធិផលលេចធ្លោរបស់ពួកគេ "ប្រជាជនទាំងអស់ការពារចលនាសន្តិសុខជាតិ" ។ អ្នកទាំង៦នាក់នោះមាន Nguyễn Văn Tý អាយុ៤០ឆ្នាំ Trần Văn Trường អាយុ២០ឆ្នាំ Lê Bình Hổ អាយុ៤៨ឆ្នាំ Nguyễn Thành Công អាយុ២៦ឆ្នាំ Ngô Văn Sẹn អាយុ៣៨ឆ្នាំ និង Mai Văn Hùng អាយុ៣៦ឆ្នាំ នៅក្រុង Long Bình ស្រុក An Phú ខេត្ត An Giang ។

កាលពីថ្ងៃទី១៨ ខែសីហា ជនជាតិវៀតណាមចំនួន៤០នាក់ បានហែលឆ្លងស្ទឹង Binh Di ព្រំដែនកម្ពុជា-វៀតណាម ដោយព្យាយាមរត់គេចពីកាស៊ីណូ Golden Phoenix Entertainment ស្ថិតនៅខេត្តកណ្តាល ប្រទេសកម្ពុជា ដោយសារពួកគេត្រូវបានកេងប្រវ័ញ្ច និងបំពាននៅកន្លែងធ្វើការ។ ពេលឃើញហេតុការណ៍នេះ ក្រុមមនុស្សទាំង៦នាក់ បានបើកទូកយ៉ាងលឿនទៅកាន់ទន្លេ ដើម្បីជួយសង្គ្រោះ និងនាំមនុស្សចំនួន៤០នាក់ មកកាន់ច្រាំងដោយសុវត្ថិភាព រួចដឹកបញ្ជូនទៅអោយអាជ្ញាធរ។ កាលពីថ្ងៃព្រហស្បតិ៍ ប្រធានគណៈកម្មាធិការប្រជាជនស្រុក An Phu ខេត្ត An Giang ក៏បានប្រគល់ប័ណ្ណសរសើរដល់បុរសទាំង៦រូបផងដែរ។ *VNS*

## ទូតខ្មែរនៅកូរ៉េបារម្ភពីអនាគតពលករមួយចំនួនបោះបង់ការងារជាប្រភពចំណូលផ្គត់ផ្គង់គ្រួសារ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៩ សីហា ២០២២ដោយ Sophal Tuon

ការវិលត្រឡប់របស់ពលករខ្មែរនៅកូរ៉េ ដោយមិនមានការអនុញ្ញាតពីនិយោជក គឺជាអំពើខុសច្បាប់ ហើយប្រឈមនឹងការបាត់បង់ការងារ ផលប្រយោជន៍ កេរ្តិ៍ឈ្មោះ និងប៉ះពាល់ដល់ឱកាសការងារសម្រាប់បងប្អូនដទៃទៀតទៅថ្ងៃអនាគត។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ បានបញ្ជាក់ថា ស្ថានទូតបានទទួលព័ត៌មានអំពីការឃោសនាប្រជាភិថុតបែបអបិយជំនឿប្រាសចាកពីការពិត ដែលបានបំផុសឱ្យបងប្អូនខ្មែរកំពុងបម្រើការងារ និងរស់នៅសាធារណរដ្ឋកូរ៉េ មានការភិតភ័យ និងបោះបង់ចោលការងារ និងទ្រព្យសម្បត្តិ ហើយវិលត្រឡប់ចូលកម្ពុជាវិញយ៉ាងតក់ក្រហល់។

ជុំវិញដំណើរវិលត្រឡប់យ៉ាងតក់ក្រហល់នេះ ស្ថានទូត បានអំពាវនាវដល់ពលករខ្មែរទាំងអស់ ដែលកំពុងរស់នៅ ធ្វើការ សិក្សា នៅសាធារណរដ្ឋកូរ៉េ ចំនួនពីរចំណុច ទី១ ស្នើបងប្អូនខ្មែរកុំជឿលើការញុះញង់តាមលក្ខណៈប្រជាភិថុតរបស់ជនអគតិមួយចំនួន ឱ្យបោះបង់ចោលការងារដែលជាប្រភពចំណូលដ៏ចម្បងសម្រាប់ផ្គត់ផ្គង់ក្រុមគ្រួសារ និងកសាងអនាគត។ ទី២ ការវិលត្រឡប់ទៅកម្ពុជា យ៉ាងប្រញាប់នេះ ដោយមិនបានទទួលការអនុញ្ញាតពីនិយោជក គឺជាអំពើខុសច្បាប់ ហើយបងប្អូនប្រឈមនឹងការបាត់បង់ការងារ និងផលប្រយោជន៍ កិត្តិយស កេរ្តិ៍

ឈ្មោះ និងប៉ះពាល់ដល់ឱកាសការងារសម្រាប់បងប្អូនពលករខ្មែរដទៃទៀតទៅថ្ងៃអនាគត ព្រមទាំងធ្វើឱ្យសង្វាក់ផលិតកម្មរបស់និយោជក កូរ៉េរងនូវផលប៉ះពាល់ផងដែរ។ ស្ថានទូត បានណែនាំឱ្យសាធារណជនទាំងអស់ពិចារណាឱ្យបានម៉ត់ចត់ ជៀសវាងការជឿទៅលើសំដីបំផុសបំផុលទាំងនោះ នាំឱ្យបាត់បង់ផលប្រយោជន៍ផ្ទាល់ខ្លួននាពេលអនាគត។

សូមបញ្ជាក់ថា ពលករកម្ពុជាដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ មានប្រមាណជាង៥ម៉ឺននាក់ ទទួលបាននូវចំណេះជំនាញ ប្រាក់ចំណូល និងបទពិសោធន៍ការងាររហូតអ្នកខ្លះក្លាយជាសហគ្រិនភាពដ៏ចំណាន។ កម្ពុជា មានពលករចំណាកស្រុកជាង១លាន៣សែននាក់ បានធ្វើការងារនៅប្រទេសចំនួន៧។ យោងតាមរបាយការណ៍របស់រាជរដ្ឋាភិបាល បានបង្ហាញថា កាលពីឆ្នាំ២០២១ ពលករទាំងនោះ បានផ្ញើប្រាក់មកស្រុកកំណើតសរុបមានប្រហែល៣ពាន់លានដុល្លារអាមេរិក។

សូមបញ្ជាក់ថា ពលករខ្មែរ ដែលកំពុងបម្រើការងារនៅប្រទេសកូរ៉េខាងត្បូងមានប្រហែល៥ម៉ឺននាក់ ម៉ាឡេស៊ីមានជាង២ម៉ឺននាក់ និងជប៉ុនមានជាង១ម៉ឺននាក់ ខណៈដែលថៃទទួលបានពលករខ្មែរច្រើនជាងគេ មានចំនួនជាង១លាន២សែននាក់៕

## ចិនត្រៀមខ្លួនជួយជនជាតិតៃវ៉ាន់នៅបរទេស

https://www.khmertimeskh.com/ Khmer Times August 29, 2022

Chen Yuanfeng អនុប្រធានការិយាល័យកិច្ចការតៃវ៉ាន់នៃក្រុមប្រឹក្សារដ្ឋបាននិយាយកាលពីចុងសប្តាហ៍មុនថា ចិនដីគោកបានត្រៀមខ្លួនជាស្រេចដើម្បីជួយជនជាតិតៃវ៉ាន់រួមទាំងជនរងគ្រោះថ្មីៗដែលត្រូវបានជាប់ឃុំងដោយសារការបោកប្រាស់នៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន។ អ្នកនាំពាក្យការិយាល័យកិច្ចការតៃវ៉ាន់បាននិយាយកាលពីសប្តាហ៍មុនថា ជនជាតិតៃវ៉ាន់នៅក្រៅប្រទេសអាចទាក់ទង និងស្វែងរកជំនួយពីស្ថានទូត និងស្ថានកុងស៊ុលចិន នៅពេលដែលពួកគេជួបប្រទះការលំបាក។ អ្នកនាំពាក្យរូបនេះបានធ្វើការកត់សម្គាល់ជាការឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយដែលថាជនជាតិតៃវ៉ាន់ត្រូវបានទាក់ទាញឱ្យមកធ្វើការនៅក្នុងប្រទេសកម្ពុជាដែលពួកគេត្រូវបានបង្ខាំង និងរំលោភបំពានលើរាងកាយ។

កាលពីថ្ងៃព្រហស្បតិ៍ លោក Chen បានរំលឹកឡើងវិញនូវជំហររបស់ចិនដីគោក ក្នុងអំឡុងពេលជួបជាមួយលោក Andrew Hsia ដែលមកពិភាក្សាការងារជាមួយអនុប្រធានគណបក្ស Kuomintang (KMT) នៅទីក្រុងសៀងហៃ។ លោក Chen បានបន្តថា ចិនដីគោកតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការការពារ និងលើកកម្ពស់ផលប្រយោជន៍ និងសុខុមាលភាពរបស់ជនជាតិនៅតៃវ៉ាន់ និងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនរួមជាតិតៃវ៉ាន់ដែលកំពុងសិក្សា ធ្វើការ និងរស់នៅចិនដីគោកស្របតាមច្បាប់។ ភាគីទាំងពីរបានឯកភាពថា បក្សកុម្មុយនិស្តចិន និង KMT គួរតែពង្រឹងការផ្លាស់ប្តូរ និងការប្រាស្រ័យទាក់ទងគ្នា បង្រួបបង្រួម និងបង្កើនទំនុកចិត្តទៅវិញទៅមក ពង្រឹងកិច្ចសហប្រតិបត្តិការ និងខិតខំប្រឹងប្រែងរួមគ្នា ដើម្បីជំរុញការអភិវឌ្ឍន៍ទៅមុខនៃទំនាក់ទំនងឆ្លងដែន និងទំនាក់ទំនងរវាងភាគីទាំងពីរ។ ភាគីទាំងពីរបានផ្លាស់ប្តូរយោបល់លើប្រធានបទដូចជា សុខុមាលភាពរបស់ជនជាតិតៃវ៉ាន់ និងការផ្លាស់ប្តូរឆ្លងច្រកសមុទ្ររវាងសហគ្រិនវ័យក្មេង ក៏ដូចជានិស្សិតវ័យក្មេងផងដែរ។

លោក Chen បានសង្កត់ធ្ងន់ថា មូលហេតុនៃភាពតានតឹងនាពេលបច្ចុប្បន្ននៅច្រកសមុទ្រតៃវ៉ាន់ គឺអាជ្ញាធរគណបក្សប្រជាធិបតេយ្យ(Democratic Progressive Party) ស្វែងរកឯករាជ្យភាពតៃវ៉ាន់ និងការញុះញង់ និងការបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងខាងក្រៅដើម្បីប្រើប្រាស់តៃវ៉ាន់ ទប់ស្កាត់ប្រទេសចិន។ លោកបាន

បន្ថែមថា វិធានការឆ្លើយតបដែលចិនបានធ្វើគឺស្របច្បាប់ និងត្រឹមត្រូវ។ លោក Zhang Zhijun ប្រធានសមាគមសម្រាប់ទំនាក់ទំនងឆ្លងច្រកសមុទ្រតៃវ៉ាន់ក៏បានជួបជាមួយលោក Hsia នៅថ្ងៃទី ២៤ ខែសីហាដែរ៕ *CGTN*

## បុរសជាតិចិន៤នាក់ ត្រូវបានសមត្ថកិច្ចជួយសង្គ្រោះ បន្ទាប់ពីត្រូវបានថៅកែ ចាប់បង្ខាំងឲ្យធ្វើការហួសម៉ោង

https://cen.com.kh/ Posted ByPen Srey NeatAugust 29, 2022

ឧត្តរមានជ័យ ៖ កម្លាំងសមត្ថកិច្ចនគរបាលក្រុងអូរស្មាច់ កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២២ បានចុះអន្តរាគមន៍ និង ជួយសង្គ្រោះរំដោះ បន្ទាប់ពីប្រជាពលរដ្ឋរាយការណ៍មកកាន់សមត្ថកិច្ចនគរបាលការពារព្រំដែនថាមានជនជាតិចិន រងគ្រោះចំនួន ៤នាក់ ត្រូវបានគេប.ង្ខាំងឲ្យធ្វើការហួសម៉ោង ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនអូរស្មាច់ រីសត ភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងអរស្មាច់ ខេត្តឧត្តរមានជ័យ ។ សមត្ថកិច្ចបានឲ្យដឹងថា ការចុះអន្តរាគមន៍ និង ជួយសង្គ្រោះរំដោះ ជនរងគ្រោះខាងលើ ត្រូវបានធ្វើឡើងបន្ទាប់សមត្ថកិច្ចប្រចាំបញ្ញា ១១៧ បានផ្តល់ដំណឹងដល់កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ អំពីការចាប់បង្ខាំ.ង ជនរងគ្រោះចិន នៅក្រុមហ៊ុនអូរស្មាច់ រីសត ។

យោងតាមការបំភ្លឺ របស់ជនរងគ្រោះទាំង៤នាក់ខាងលើ គឺមិនមែនជាករណីប.ង្ខាំងចាប់ជំ.រិត ការធ្វើទារុ.ណកម្ម ឬការគំរា.មកំ.ហែងនោះទេ គ្រាន់តែធ្វើការច្រើនម៉ោង នឿយហត់ តែប៉ុណ្ណោះ ។ បច្ចុប្បន្ននេះ ជនរងគ្រោះខាងលើ ត្រូវបានបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាល ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការស្រាវជ្រាវបន្ថែម តាមនីតិវិធីច្បាប់ ៕រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## សមត្ថកិច្ច ស្រាវជ្រាវតាមបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារ សម្តេចក្រឡាហោម ស ខេង រកឃើញជនជាតិចិន២នាក់

http://freshnewsasia.com/ 2022-08-29 05:00pm

**(ព្រះសីហនុ)៖** កម្លាំងស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ កាលពីរសៀលថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០២២ បានចុះត្រួតពិនិត្យទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅ ភូមិ៤ សង្កាត់៤ ក្រុងព្រះសីហនុ ដោយរកឃើញជនជាតិចិន២នាក់ ដែលពួកគេចង់ត្រឡប់ទៅស្រុកកំណើតវិញ។

នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News ឱ្យដឹងថា ប្រតិបត្តិការនេះ បានធ្វើឡើងបន្ទាប់ពីមាន បណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង ថាមានការចាប់បង្ខាំងទុក ដើម្បីឱ្យនៅបំរើការងារក្នុងក្រុមហ៊ុន នៅក្នុងខេត្តព្រះសីហនុ ចំនួន ០១ករណី។ លោកនាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ដោយបានចុះទៅដល់ទីតាំង និងមានការចូលរួមសហការពីម្ចាស់ទីតាំង កម្លាំងសមត្ថកិច្ចបានស្វែងរកឃើញបុរសជនជាតិចិន០២នាក់ (ដែលក្នុងបណ្តឹងអះអាងថាជាជនរងគ្រោះ) កំពុងធ្វើការនៅក្នុងក្រុមហ៊ុនខាងលើ ទើបកម្លាំងសមត្ថកិច្ចនាំពួកគេទាំង២នាក់ រួមនិងអ្នកគ្រប់គ្រងជនជាតិចិន ០១នាក់ មកធ្វើការសាកសួរ បន្តនីតិវិធី ។

បុរសជនជាតិចិនទាំង២នាក់ ដែលសមត្ថកិច្ចបានរកឃើញនោះរួមមាន៖ ទី១៖ ឈ្មោះ CHENG XIANMING អាយុ២៨ឆ្នាំ និងទី២៖ ឈ្មោះ HUANG RONGPENG អាយុ៣១ឆ្នាំ។ លោកបានបញ្ជាក់ទៀតថា៖ បន្ទាប់ពីធ្វើការសាកសួរបឋម នៅក្នុងទីតាំងក្រុមហ៊ុន ជនជាតិចិនទាំង០២នាក់ បានឲ្យដឹងថា៖ ពួកគេមិនមានអ្នកណាបង្ខាំង វាយធ្វើបាបដូចបណ្តឹងនោះទេ ដោយពួកគាត់កំពុងធ្វើការនៅក្នុងក្រុមហ៊ុនជាធម្មតា ពួកគាត់ចង់ឈប់ធ្វើការ ដោយសារលក្ខខណ្ឌការងារតឹងតែង ហើយពួកគាត់ចង់ត្រឡប់ទៅប្រទេសកំណើតវិញ៕

## សមត្ថកិច្ចឃាត់ខ្លួនជនជាតិចិន៤នាក់សង្ស័យពាក់ព័ន្ធករណីជួញដូរមនុស្ស

http://nokorwatnews.com/ 30/08/2022

ភ្នំពេញ ៖ កម្លាំងសមត្ថកិច្ចធ្វើការឃាត់ខ្លួនជនជាតិចិនចំនួន៤នាក់កាលពីវេលាម៉ោង៥និង១៥នាទីល្ងាចថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២នេះចំណុចភ្លើងស្តុបផ្លូវជាតិលេខ៤ ភូមិជម្ពូវ័ន១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយសង្ស័យពាក់ព័ន្ធទៅនឹងករណីជួញដូរមនុស្ស។ តាមសមត្ថកិច្ចគ្រាន់តែឲ្យដឹងថា រថយន្តតាក់ស៊ីមួយគ្រឿង ម៉ាកឡិចស៊ីសRX300 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 2Q-3009 អ្នកបើកបរជនជាតិខ្មែរ ដឹកជនជាតិចិនចំនួន៤នាក់ សង្ស័យពាក់ព័ន្ធករណីជួញដូរមនុស្ស នៅក្រុងព្រះសីហនុ បានបើកចេញពីក្រុងព្រះសីហនុឆ្ពោះចូលរាជធានីភ្នំពេញ ហើយបានប្រកាសផ្សព្វផ្សាយឲ្យកងកម្លាំងសមត្ថកិច្ច បណ្តាខេត្ត ក្រុង ស្ទាក់ចាប់ឃាត់ ។

តាមប្រភពពីសមត្ថកិច្ចបានឲ្យដឹងថា រថយន្តកិនភាគខាងលើ ត្រូវបានកម្លាំងស្នងការខេត្តកំពង់ស្ពឺហៅឃាត់ដែរតែមិនឈប់ ព្យាយាមបន្តបើកគេចរហូត លុះដល់ចំណុចភ្លើងស្តុបជម្ពូវ័ន ផ្លូវជាតិលេខ៤ ទើបកម្លាំងនគរបាលចរាចរក្រុងភ្នំពេញ សហការជាមួយកម្លាំងនគរបាលខណ្ឌពោធិ៍សែនជ័យស្ទាក់ឃាត់បានរថយន្តមួយគ្រឿងខាងលើមានដឹកជនជាតិចិនចំនួន៤នាក់ ។ បន្ទាប់ពីឃាត់បានរថយន្តតាក់ស៊ីមួយគ្រឿងខាងលើ រួមជាមួយជនជាតិចិនចំនួន៤នាក់ សមត្ថកិច្ចនាំយកទៅប៉ុស្តិ៍ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រង់ចាំខាងនាយកដ្ឋានប្រឆាំង និងការពារការជួញដូរមនុស្ស នាំយកទៅសាកសួរបន្តតាមនីតិវិធី ៕

## អាជ្ញាធរខេត្តព្រះសីហនុសង្គ្រោះជនបរទេសប្រមាណ ៧០ នាក់ពីការបង្ខាំងទុក

https://khmer.voanews.com/ 29 សីហា 2022

ភ្នំពេញ៖ ក្នុងរយៈពេលប៉ុន្មានថ្ងៃជាប់គ្នានេះ អាជ្ញាធរខេត្តព្រះសីហនុបានជួយសង្គ្រោះជនបរទេសដែលបានចាញ់បោកមេខ្យល់មកធ្វើការនៅកម្ពុជា ប្រមាណ ៧០ នាក់ ខណៈពួកគេត្រូវបានបង្ខាំងទុកក្នុងអគារមិនឱ្យមានសេរីភាព និងបង្ខំឱ្យធ្វើការជាង ១០ ម៉ោងក្នុងមួយថ្ងៃ និងឈានទៅជំរិតទារប្រាក់ទៀតផង។ នេះបើតាមមន្ត្រីពាក់ព័ន្ធ។ ស្របពេលជាមួយគ្នានេះ រដ្ឋបាលខេត្តព្រះសីហនុក៏បានដាក់ចេញវិធានការច្បាប់លើជនល្មើស និងបញ្ជាឱ្យបិទអាជីវកម្មទាំងនោះជាដាច់ខាត និងនាំយកជនល្មើសនិងអ្នកសមគំនិត ទៅផ្តន្ទាទោសតាមច្បាប់។

លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា កាលពីថ្ងៃទី ២៦ ខែសីហា អាជ្ញាធរខេត្តព្រះសីហនុបានជួយសង្គ្រោះជនជាតិចិនចំនួន ៤០ នាក់។ លោកបន្ថែមថា ជនរងគ្រោះបានចាញ់បោកមេខ្យល់ឱ្យបម្រើការងារអនឡាញនៅក្រុមហ៊ុនកាស៊ីណូ ក្នុងខេត្តព្រះសីហនុ ដោយក្រុមហ៊ុនបានដកយកលិខិតឆ្លងដែននិងដកទូរស័ព្ទដៃទុក ហើយបានបង្ខំឱ្យធ្វើការរហូតដល់ ១៧ ទៅ ១៨ ម៉ោងក្នុងមួយថ្ងៃ។ បើតាមលោក ខៀវ សុភ័គ ជនបរទេសទាំងនោះទទួលបានប្រាក់ខែប្រមាណ ១.០០០ដុល្លារអាមេរិក ហើយពួកគេបានលេងល្បែងនៅកន្លែងធ្វើការអស់លុយ និងបានជំពាក់លុយក្រុមហ៊ុននោះ។ លុះដល់ពួកគេចង់ឈប់ពីក្រុមហ៊ុន ក្រុមហ៊ុនតម្រូវឱ្យបង់សងក្រុមហ៊ុនចំនួន ២ ម៉ឺន ២ ពាន់ដុល្លារអាមេរិក។ លោក ខៀវ សុភ័គ បានលើកឡើងអំពីករណីមួយទៀតស្រដៀងគ្នានេះថា នៅថ្ងៃទី ២៨ ខែសីហានេះ អាជ្ញាធរខេត្តព្រះសីហនុក៏បានជួយសង្គ្រោះជនជាតិថៃចំនួន ១៩ នាក់ផងដែរ ដែលបានចូលមកកម្ពុជាដោយខុសច្បាប់ ហើយត្រូវបានក្រុមហ៊ុនបង្ខាំងទុកឱ្យធ្វើការផងដែរ។ លោកថា ជនជាតិថៃ ១៥ នាក់ ក្នុងចំណោមជនជាតិថៃទាំងអស់នេះ មានដីកាតាមចាប់ខ្លួនរបស់ប្រទេសថៃពាកព័ន្ធបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ឬហៅថា Scam។

បើតាមលោក ខៀវ សុភ័គ ជនរងគ្រោះទាំងនោះបានចាញ់បោកការអូសទាញរបស់មេខ្យល់ដែលបានសន្យាផ្តល់ការងារដែលមានប្រាក់ខែខ្ពស់ ដែលការបោកបញ្ឆោតនេះ អាចក្លាយទៅជាការជួញដូរមនុស្ស។ ហើយការជួយសង្គ្រោះទាំងនេះ គឺដោយសារមានការចុះពិនិត្យតាមអគារជនបរទេសរស់នៅ និងមានកិច្ចសហប្រតិបត្តិការពីប្រទេសជិតខាង។ លោកថ្លែងថា៖ «មានករណីអ៊ីចឹងមែន មិនខុសគ្នាទេ គឺការស្វែងរកដើម្បីប្រាក់ឈ្នួលខ្ពស់ មានមេខ្យល់អូសទាញមក ទាំងមេខ្យល់ក្នុងស្រុកផង ហើយមេខ្យល់ប្រទេសសាមីផង ទាក់ទាញយកមក ចូលធ្វើការដោយខុសច្បាប់ ចូល [មកកម្ពុជា] ដោយខុសច្បាប់ [ហើយ] យកមកសន្យាថា មានប្រាក់ខែខ្ពស់អ៊ីចឹងទៅ ដល់ហើយក៏ជាប់នៅហ្នឹងទៅ»។ លោកបន្ថែមថា៖ «ដល់មកធ្វើការជាមួយបើកប្រាក់ខែឱ្យ ក៏លេងល្បែងអ៊ីចឹងទៅ ក្លាយខ្លួនទៅជាអ្នកជំពាក់លុយថៅកែវិញ ព្រោះចូលល្បែងស៊ីសង អាហ្នឹងកាស៊ីណូ។ លេងចុះលេងឡើង ចាញ់ជំពាក់លុយថៅកែ ថៅកែឱ្យសងលុយ [ហើយ] សងលុយមិនបាន [ឬ] រកលុយសងមិនបាន [គឺ] ធ្វើការ។ ហើយការការសងលុយចេះតែមានបន្តៗទៀតទៅ ហើយថៅកែបង្ខាំងមិនឱ្យចេញ ចេះតែឱ្យរកលុយសងឱ្យគ្រប់ ឬថៅកែជូនកាលលក់ទៅឱ្យក្រុមហ៊ុនណាមានលុយអ៊ីចឹងទៅ។ វាអាចអ៊ីចឹង ដូចជាការជួញដូរ [មនុស្ស] វិញ»។ ដោយឡែកចាប់ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៦ ខែសីហានេះ អាជ្ញាធរខេត្តជាប់មាត់សមុទ្រមួយនេះ ក៏បានជួយសង្គ្រោះជនជាតិម៉ាឡេស៊ីចំនួន ៩ នាក់ ពីការបង្ខាំងមិនឱ្យចេញពីក្រុមហ៊ុន ការបង្ខាំងដោយខុសច្បាប់និងប្រើហិង្សា ការកំហែងយកនិងជួញដូរកម្លាំងពលកម្ម និងកាន់កាប់អាវុធដោយខុសច្បាប់ជាដើម។ នេះបើតាមព័ត៌មានបង្ហោះលើហ្វេសប៊ុករបស់រដ្ឋបាលខេត្តព្រះសីហនុ កាលពីថ្ងៃទី ២៧ ខែសីហា។

បើយោងតាមរដ្ឋបាលខេត្តព្រះសីហនុ ការជួយសង្គ្រោះនេះ គឺនៅទីតាំង ៣ កន្លែងផ្សេងគ្នា ដោយបញ្ជាក់តែទីតាំង ប៉ុន្តែមិនបានបញ្ជាក់ឈ្មោះក្រុមហ៊ុនទាំងនោះទេ តែអាជ្ញាធរបានឃាត់ខ្លួនជនសង្ស័យទាំង ៣ ទីតាំង សរុបចំនួន ១៣ នាក់ មកធ្វើការសាកសួរ ដែលរួមមានជនជាតិចិន ៩ នាក់ និងជនជាតិខ្មែរ ២ នាក់ និងអ្នកគ្រប់គ្រងជនជាតិម៉ាឡេស៊ី ២ នាក់។ លោក យាង ភារម្យ អ្នកនាំពាក្យសាលាខេត្តព្រះសីហនុ បញ្ជាក់បន្ថែមថា ករណីបង្ក្រាបកន្លងមក គឺអាជ្ញាធរកំពុងតែដំណើរការតាមនីតិវិធីច្បាប់។ លោកប្រាប់វីអូអេថា៖ «ចំពោះម្ចាស់ទីតាំងដែលចូលរួមសមគំនិតនៅក្នុងការប្រព្រឹត្តបទល្មើស ទិញលក់កម្លាំងពលកម្ម ការជួញដូរ និងការបង្ខាំងមនុស្សដោយខុសច្បាប់ រដ្ឋបាលខេត្តនឹងបិទទីតាំង បិទអាជីវកម្ម និងនាំយកម្ចាស់ទីតាំងទាំងនោះ ទៅផ្តន្ទាទោសតាមច្បាប់។ អ៊ីចឹងចំពោះករណីបង្ក្រាបកន្លងមក យើងកំពុងតែដំណើរការក្នុងនីតិវិធី។ ហើយបើសិនជាយើងរកឃើញ យើងនឹងអនុវត្តតាមច្បាប់»។

លោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា ករណីបង្ខាំងមនុស្សឱ្យធ្វើការនេះ គឺជាការជួញដូរមនុស្ស ហើយក្រសួងការងារកំពុងធ្វើការជាមួយស្ថាប័នពាក់ព័ន្ធ។ លោកបញ្ជាក់ជាអក្សរតាមបណ្តាញតេឡេក្រាមថា៖ «នេះគឺជាករណីជួញដូរមនុស្ស។ ក្រសួងកំពុងធ្វើការសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស»។

កម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងឆបោកតាមប្រព័ន្ធអ៊ីនធើណិត (Scam) ដោយប្រើប្រាស់កម្លាំងពលកម្មបរទេស ធ្វើការនៅតាមអគារខ្ពស់ៗនៅក្នុងប្រទេសកម្ពុជា រហូតមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឱ្យមានសេរីភាព ធ្វើទារុណកម្ម និងជំរិតទារប្រាក់ជាដើម។

ក្រសួងមហាផ្ទៃបានឲ្យដឹងកាលពីសប្តាហ៍មុនថា ចាប់តាំងពីដើមខែមករា រហូតដល់ចុងខែសីហា ឆ្នាំ ២០២២ នេះ អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះជនបរទេស ដែលត្រូវបានរាយការណ៍ថាជាជនរងគ្រោះនៃអំពើជួញដូរ និងរត់ពន្ធមនុស្សជាង ៩០០ នាក់។

លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក កត់សម្គាល់ថា អាជ្ញាធរកម្ពុជាក៏បានខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការជួញដូរមនុស្សនេះផងដែរ។ ក៏ប៉ុន្តែលោកថា ការអនុវត្តច្បាប់ និងការចាត់វិធានការ មិនទាន់បានល្អប្រសើរនៅឡើយទេ។ ដូច្នេះលោកថា អាជ្ញាធរ ត្រូវយកចិត្តទុកដាក់ និងអនុវត្តចំណាត់ការ និងវិធានការឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបញ្ជាក់អំពីមន្ទិលសង្ស័យរបស់សហគមន៍អន្តរជាតិ។ លោកថ្លែងថា៖ « បើសិនជាចំណាត់ការណាមួយធ្វើឡើងដោយមានការយកចិត្តទុកដាក់ ហើយដោះស្រាយបញ្ហាហ្នឹងបាន ក៏យើងអាចលាងជម្រះមន្ទិលសង្ស័យ និងផ្តល់នូវជំនឿចិត្តពីសហគមន៍អន្តរជាតិវិញដែរ។ ប៉ុន្តែបើសិនជាការអនុវត្ត និងចំណាត់ការ ឬវិធានការរបស់ប្រទេសកម្ពុជាយើងមិនអាចធ្វើបានដោយមានការជឿទុកចិត្តបានពីសហគមន៍អន្តរជាតិទេ យើងមានការព្រួយបារម្ភអំពីបញ្ហាដែលប្រទេសកម្ពុជាអាចរងនូវវិធានការផ្សេងៗពីសហគមន៍អន្តរជាតិបន្តទៀត»។

អ្នកនាំពាក្យរបស់ក្រសួងការបរទេសកម្ពុជា លោក ជុំ សុន្ទរី ប្រាប់វីអូអេថា បទល្មើសជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្មឆ្លងដែន ដែលកំពុងកើតមានឡើងនៅគ្រប់តំបន់ និងបានរីកសាយភាយ «ប្រទាក់ក្រឡាគ្នាយ៉ាងស្មុគស្មាញ »។ ដូចនេះការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ទាមទារនូវកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងបណ្តាប្រទេសជាច្រើន។ លោកបន្ថែមថា ក្រសួងការបរទេសតែងតែសម្របសម្រួល បញ្ជូនសំណើសុំកិច្ចអន្តរាគមន៍របស់ស្ថានតំណាងបរទេស ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ បានយ៉ាងឆាប់រហ័ស ដើម្បីពិនិត្យ និងធ្វើកិច្ចអន្តរាគមន៍៕

## ពលករខ្មែរដែលត្រឡប់ពីថៃវិញ ត្រូវចូលតាមច្រកប៉ោយប៉ែត

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ៣០ ខែ សីហា ឆ្នាំ ២០២២ ម៉ោង ០៩:០០

ខេត្តបន្ទាយមានជ័យ ៖ កម្ពុជា-ថៃ សម្រេចឱ្យពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ត្រូវចូលតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត គិតចាប់ពីថ្ងៃទី០១ កញ្ញា ឆ្នាំ២០២២ ខាងមុខនេះ ។ អាជ្ញាធរខេត្តជាប់ជាយដែនកម្ពុជា-ថៃ បានប្រជុំពិភាក្សាទ្វេភាគីសម្រេចអោយពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ត្រូវឱ្យចូលតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយបិទទីតាំងទទួលពលករមានច្រករបៀង អូរបីជាន់ស្រុកអូរជ្រៅ ច្រកទ្វារតំបន់ព្រំដែនបឹងត្រកួនស្រុកថ្មពួក ក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ ។

លោកវរសេនីយ៍ទោ ម៉ាន់ ជី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរបានប្រាប់ថា នៅថ្ងៃទី២៩ ខែសីហា ថា នៅច្រកអូរជាន់ស្រុកអូរជ្រៅ ក្រុមការងារបានទទួលពលករខ្មែរត្រឡប់ពីប្រទេសថៃមានចំនួន៤៣នាក់ (ស្រី២១នាក់) កុមារ៥នាក់ ដែលទទួលបានការចាក់វ៉ាក់សាំងការពារកូវីដ.១៩ពីដូសទី២ដល់ទី៣មានចំនួន៤៣នាក់ក្រោយត្រួតពិនិត្យសុខភាព ហើយបានឱ្យទៅស្រុកកំណើត។

លោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានប្រាប់ដែរថា ភាគីថៃបានចាប់ពលករខ្មែរដែលខុសច្បាប់ បញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានជារៀងរាល់ថ្ងៃ មិនតិចជាង២០ ទៅ៣០នាក់ ដែលជាពលករខុសច្បាប់ ។ ភាគីថៃចាប់បញ្ជូនមកអោយកម្លាំងជំនាញនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ទទួលធ្វើការពិនិត្យសុខភាពហើយដឹកជញ្ជូនបន្តអោយទៅមណ្ឌលសំចត ។

## កម្ពុជា-ថៃ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

https://www.khmertimeskh.com/ Khmer Times August 30, 2022

កម្ពុជា និងថៃបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង «នីតិវិធីប្រតិបត្តិស្តង់ដា ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់» ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នេះបើយោងតាមសេចក្តីថ្លែងការណ៍របស់ប្រតិភូគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (NCCT) របស់កម្ពុជាកាលពីថ្ងៃចន្ទ។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខា ដោយលោកស្រីជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលោកស្រី Ramrung Worawat អនុលេខាអចិន្ត្រៃយ៍នៃក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សរបស់ប្រទេសថៃ នៅចុងបញ្ចប់នៃកិច្ចប្រជុំនៅទីក្រុងបាងកក ប្រទេសថៃ កាលពីចុងសប្តាហ៍មុន។

សេចក្តីថ្លែងការណ៍បាននិយាយថា កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដោយអង្គការអន្តរជាតិសម្រាប់ការធ្វើចំណាកស្រុក (IOM) ដោយបន្ថែមថានីតិវិធីប្រតិបត្តិស្តង់ដា (SOPs) នឹងបម្រើជាគោលការណ៍ណែនាំសម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងប្រទេសទាំងពីរក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ សេចក្តីថ្លែងការណ៍បានបន្តថា "ការពិភាក្សាបានដំណើរការល្អ ដោយមានគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ ហើយភាគីទាំងពីរបានឈានដល់ការសម្រេចលើកិច្ចព្រមព្រៀងស្តីពី SOPs ដោយមាន លោកស្រីជូ ប៊ុនអេង តំណាងឱ្យភាគីកម្ពុជា និងលោកស្រី Ramrung Worawat តំណាងឱ្យភាគីថៃ" ។

លោកស្រី ប៊ុនអេង បាននិយាយថា ប្រទេសកម្ពុជាបានបង្ក្រាបករណីជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទចំនួន ៣៥៩ ករណីក្នុងឆ្នាំ ២០២១ ដែលកើនឡើងគួរឱ្យកត់សម្គាល់ពីចំនួន ១៥៥ ករណីក្នុងឆ្នាំ ២០២០ ដោយបន្ថែមថា ជនសង្ស័យជួញដូរមនុស្សប្រមាណ ៥៣៨ នាក់ត្រូវបានបញ្ជូនទៅតុលាការ ខណៈដែលជនរងគ្រោះចំនួន ១.៥៧៧ នាក់ត្រូវបានជួយសង្គ្រោះកាលពីឆ្នាំមុន៕ *Xinhua*

## ស្ថានទូតចិនប្រចាំកម្ពុជាទទួលសំណើពីជនជាតិតៃវ៉ាន់ជាង២០នាក់ដើម្បីសុំជំនួយ

https://www.khmertimeskh.com/ Khmer Times August 30, 2022

ក្រសួងការបរទេសចិននៅថ្ងៃចន្ទនេះបាននិយាយថា ស្ថានទូតចិនប្រចាំកម្ពុជាបានទទួលសំណើសុំជំនួយពីជនជាតិតៃវ៉ាន់ជាង២០នាក់ និងបានជួយភាគីកម្ពុជាក្នុងការជួយសង្គ្រោះពួកគេមួយចំនួនបានដោយជោគជ័យ។ អ្នកនាំពាក្យលោក Zhao Lijian បានលើកឡើងបែបនេះនៅក្នុងសន្និសីទសារព័ត៌មានប្រចាំថ្ងៃមួយ ដើម្បីឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយដែលថាជនជាតិតៃវ៉ាន់មួយចំនួនត្រូវបានបោកប្រាស់ និងបង្ខាំងនៅក្នុងប្រទេសកម្ពុជា។ លោក Zhao បានកត់សម្គាល់ថា រដ្ឋាភិបាលចិនយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីការពារសុវត្ថិភាព សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋចិននៅក្រៅប្រទេស រួមទាំងជនរួមជាតិតៃវ៉ាន់ផងដែរ។ លោកបាននិយាយថា ស្ថានទូតចិនប្រចាំកម្ពុជា កំពុងរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីស្វែងរក និងជួយសង្គ្រោះអ្នកពាក់ព័ន្ធយ៉ាងសកម្ម។

លោក Zhao បន្ថែមថា "យើងនឹងបន្តតាមដានយ៉ាងជិតដល់លើការលុបបំបាត់ករណីនេះ។ ជនរួមជាតិតៃវ៉ាន់ និងក្រុមគ្រួសាររបស់ពួកគេដែលមានការលំបាក អាចទាក់ទងទៅស្ថានទូតចិនប្រចាំកម្ពុជាបានភ្លាមៗសម្រាប់សុំជំនួយ"។ Zhao ក៏បានក្រើនរំលឹកពលរដ្ឋចិនឱ្យប្រុងប្រយ័ត្នចំពោះព័ត៌មានជ្រើសរើសបុគ្គលិកមិនពិតនៅលើបណ្តាញក្រៅប្រទេស គោរពច្បាប់យ៉ាងម៉ឺងម៉ាត់ ជានាសុវត្ថិភាពផ្ទាល់ខ្លួន និងរាយការណ៍ព័ត៌មានទាក់ទងនឹងការក្លែងបន្លំ

និងល្បែងស៊ីសង។ Zhao បាននិយាយថា “ក្នុងករណីមានអាសន្ន សូមរាយការណ៍ទៅប៉ូលីសក្នុងតំបន់ឱ្យបានទាន់ពេលវេលា ហើយទាក់ទងទៅស្ថានទូត ឬស្ថានកុងស៊ុលចិន ដើម្បីទទួលបានជំនួយ” ។

យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយតៃវ៉ាន់ ប្រជាជនមួយចំនួនមកពីតំបន់តៃវ៉ាន់របស់ប្រទេសចិនដែលមកប្រទេសកម្ពុជា ដើម្បីស្វែងរកការងារធ្វើត្រូវបានជួលអោយធ្វើការ ដែលមិនសមស្របនឹងប្រាក់ឈ្នួលរបស់ពួកគេ ហើយខ្លះទៀតទទួលរងនូវអំពើហិង្សា រួមទាំងការបង្ខាំង ការវាយដំ ការរំលោភបំពាន និងសូម្បីតែការបំពានផ្លូវភេទ។ របាយការណ៍បាននិយាយថា មនុស្សជាង ៨,៦០០ នាក់មកពីតៃវ៉ាន់ត្រូវបានគេរាយការណ៍ថាបានមកប្រទេសកម្ពុជាចាប់ពីខែមករាដល់ខែកក្កដាហើយមានតែ ៥,០០០ នាក់បានត្រឡប់ទៅវិញ ដោយមានប្រហែល ៣,០០០ នាក់នៅតែជាប់គាំងនៅទីនោះ។

ស្ថានទូតចិនប្រចាំកម្ពុជា បាននិយាយនៅក្នុងលិខិតចំហមួយផ្ញើជូនជនរួមជាតិតៃវ៉ាន់កាលពីថ្ងៃសៅរ៍ថា “ជនជាតិតៃវ៉ាន់គឺជាពលរដ្ឋចិន” ដែលតែងតែអាចចូលទៅស្ថានទូតដើម្បីសុំជំនួយនៅពេលចាំបាច់។ CGTN

## ជនសង្ស័យ១១នាក់ ត្រូវបានបញ្ជូនទៅតុលាការ ក្នុងសំណុំរឿងជួញដូរមនុស្ស និងរក្សាទុកអាវុធដោយខុសច្បាប់

http://freshnewsasia.com/ 2022-08-30 04:51pm

**(ព្រះសីហនុ)៖** ប្រតិបត្តិការស្រាវជ្រាវករណីជួញដូរមនុស្ស រហូតឈានដល់ការបង្ក្រាបករណីរក្សាទុក អាវុធខុសច្បាប់ នៅខេត្តព្រះសីហនុ បានបិទបញ្ចប់ហើយ ក្នុងនោះមានជនសង្ស័យខ្មែរ-ចិនចំនួន១១នាក់ ត្រូវបានសមត្ថកិច្ចខេត្តព្រះសីហនុ កសាងសំណុំរឿង បញ្ជូនទៅតុលាការ។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២នេះ។ ប្រតិបត្តិការបង្ក្រាបករណីខាងលើនេះ បានចាប់ផ្តើមតាំងពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ បន្ទាប់ពីមានបណ្តឹងចូលប្រព័ន្ធ Hotline ក្រុមការងារសម្តេចក្រឡាហោម ស ខេង ថាមានករណីបង្ខាំងមនុស្សដោយខុសច្បាប់។ ដោយទទួលបានបទបញ្ជាពីលោកឧត្តមសេនីយ៍ ជួន ណារិន ស្នងការនគរបាលខេត្តព្រះសហនុ និងដោយមានការសម្របសម្រួលនីតិវិធីពី លោក ពេញ ពិសិដ្ឋ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ២៣៖៣០នាទី កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងក្រុមហ៊ុន ដើម្បីធ្វើការស្រាវជ្រាវស្វែងរកជនរងគ្រោះ ០១នាក់ ជាស្ត្រីជនជនជាតិម៉ាឡេស៊ី។

នាយឧត្តមសេនីយ៍ បានបញ្ជាក់ថា ដោយមានការចូលរួមសហការពីម្ចាស់ទីតាំងចំនួន ០២កន្លែង កម្លាំងសមត្ថកិច្ច បានស្វែងរកឃើញស្ត្រីជនជនជាតិម៉ាឡេស៊ី ដែលជាជនរងគ្រោះ នៅក្នុងក្រុមហ៊ុនដែលស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ទើបនាំគាត់មកធ្វើការសាកសួរនៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ។ ក្នុងកិច្ចប្រតិបត្តិការ ឆែកឆេរក្រុមហ៊ុនទាំង ០២នេះ កម្លាំងសមត្ថកិច្ចធ្វើការឃាត់ខ្លួនបានជនសង្ស័យជាជនជាតិចិនចំនួន ០៥នាក់ ភេទប្រុស ក្នុងនោះ ០២នាក់ ឃាត់ខ្លួននៅក្នុងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅ ភូមិ៥ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ និង ០៣នាក់ ឃាត់ខ្លួនបាននៅក្នុងក្រុមហ៊ុនមួយកន្លែងទៀត ស្ថិតនៅ ភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ (ជាកន្លែងរំដោះបានជនរងគ្រោះ)។

បន្ទាប់មកនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៣៖៣០នាទី កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានចុះមកដល់ទីតាំងក្រុមហ៊ុន ដីងឆាយទី១ ស្ថិតនៅ ភូមិ៣ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ ដែលជាកន្លែងដែលក្រុមជនសង្ស័យចាប់ជនរងគ្រោះយកទៅបង្ខាំងទុក ប្រើហិង្សា គំរាមកំហែងយកលុយនិងទូរស័ព្ទ។ តែនៅពេលដែលកម្លាំងសមត្ថកិច្ចទៅដល់ ជនសង្ស័យបានដឹងខ្លួនជាមុន ព្រោះអ្នកគ្រប់គ្រងអគារ

បានផ្តល់ដំណឹងឲ្យក្រុមជនសង្ស័យ និងបានរៀបចំផ្លូវក្រោយ ងាយជនសង្ស័យរត់គេចខ្លួនបាត់អស់ ទើបកម្លាំងសមត្ថកិច្ច បានឃាត់ខ្លួនអ្នកគ្រប់គ្រងអគារ ០១នាក់ យកមកធ្វើការសាកសួរ។

កម្លាំងសមត្ថកិច្ច បានបន្តការស្រាវជ្រាវ រហូតដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ទើបចាប់ខ្លួនបានជនសង្ស័យចំនួន ០៣នាក់ បន្ថែមទៀត។ ក្នុងកិច្ចប្រតិបត្តិការនេះ កម្លាំងសមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យសរុបបានចំនួន ០៩នាក់ ក្នុងករណី បង្ខាំងមនុស្សដោយខុសច្បាប់, កំហែងយក និង លក់-ដូរមនុស្សដោយមានគោលដៅ។ ក្នុងនោះដែរកម្លាំងសមត្ថកិច្ច ដកហូតបាន អាវុធខ្លី ០១ដើម ម៉ាក ZORAKI ពណ៌ទឹកប្រាក់ ពីជនសង្ស័យ ០១នាក់ ជនជាតិចិន ភេទប្រុស ទើបបន្តស្រាវជ្រាវពីប្រភពអាវុធខ្លីនោះ រហូតដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០១៖៣០នាទី រំលងអាធ្រាត្រ កម្លាំងសមត្ថកិច្ច បានធ្វើការស្រាវជ្រាវបង្ក្រាបបាន ជនសង្ស័យចំនួន ០២នាក់ (សរុប ៣នាក់) ( ខ្មែរ១ និងចិន១) បន្ថែមទៀត ក្នុងករណីនាំចូល និងសន្និធិអាវុធដោយខុសច្បាប់ និងដកហូតបានវត្ថុតាង អាវុធចំនួន០៦ដើម(វែង៣និងខ្លី៣) ព្រមទាំងដកហូតបានគ្រាប់កាំភ្លើង និងសម្ភារៈកែច្នៃ មួយចំនួន។

**របាយការណ៍បញ្ជាក់ដែរថា ជនរងគ្រោះជាស្ត្រីជនជាតិម៉ាឡេស៊ី អាយុ២៧ឆ្នាំ បានបាត់បង់លុយចំនួន ៩,៧០០ដុល្លារ (ប្រាំបួនពាន់ប្រាំពីររយដុល្លារអាមេរិក) និងទូរស័ព្ទដៃ ០២គ្រឿង។ ចំណែកឯជនសង្ស័យមានសរុបចំនួន ១១នាក់ (ជនជាតិចិន ១០នាក់ និងជនជាតិខ្មែរ ០១នាក់) មានឈ្មោះដូចខាងក្រោម៖**

១៖ ឈ្មោះ YU CHONGCHENG ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិន មុខរបរ អ្នកគ្រប់គ្រប់គ្រងបុគ្គលិកក្រុមហ៊ុន ស្នាក់នៅ ភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ (ជនសមគំនិត លក់-ដូរមនុស្សដោយមានគោលដៅ)។

២៖ ឈ្មោះ YU XUNCAI ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិចិន មុខរបរ ថៅកែក្រុមហ៊ុន ស្នាក់នៅ ភូមិ៥ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (សហចារី លក់-ដូរមនុស្សដោយមានគោលដៅ)។

៣៖ ឈ្មោះ LIN BAOWEN ហៅ A BAO ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិក្រុមហ៊ុន ស្នាក់នៅ ភូមិ៣ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (សហចារី បង្ខាំងមនុស្សដោយខុសច្បាប់, កំហែងយក និង លក់-ដូរមនុស្សដោយមានគោលដៅ)។

៤៖ ឈ្មោះ LIN YOUGUO ហៅ A DAN ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិចិន មុខរបរ អ្នកគ្រប់គ្រងក្រុមហ៊ុន ស្នាក់នៅ ភូមិ៣ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (សហចារី លក់-ដូរមនុស្សដោយមានគោលដៅ)។

៥៖ ឈ្មោះ LIU YUANHUANG ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិកហាងម៉ាស្សា ស្នាក់នៅ ភូមិ៥ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (ជាសហចារី លក់-ដូរមនុស្សដោយមានគោលដៅ)។

៦៖ ឈ្មោះ SHI RUI ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិកក្រុមហ៊ុន ផ្នែកធនធានមនុស្ស ស្នាក់នៅ ភូមិ៣ សង្កាត់១ ក្រុង-ខេត្តព្រះសីហនុ។ (ជនសមគំនិត លក់-ដូរមនុស្សដោយមានគោលដៅ និងជាសហចារី នាំចូល និងសន្និធិអាវុធដោយខុសច្បាប់ )។

៧៖ ឈ្មោះ JI XIANBO ហៅ DA PAN ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិចិន មុខរបរ អ្នកគ្រប់គ្រងអគារ ស្នាក់នៅ ភូមិ៣ សង្កាត់១ ក្រុង-ខេត្តព្រះសីហនុ។ (ជនសមគំនិត លក់-ដូរមនុស្សដោយមានគោលដៅ)។

៨៖ ឈ្មោះ FU ZHIKANG ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន មុខរបរ អ្នកគ្រប់គ្រងអគារ ជីងឆាយ១ ស្នាក់នៅ ភូមិ៣ សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ (សមគំនិត បង្ខាំងមនុស្សដោយខុសច្បាប់, កំហែងយក និង លក់-ដូរមនុស្សដោយមានគោលដៅ)។

៩៖ ឈ្មោះ HAN JINRUI ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន មុខរបរ ទេសចរណ៍ ស្នាក់នៅ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ។ (ជនសមគំនិត លក់-ដូរមនុស្សដោយមានគោលដៅ)។

១០៖ ឈ្មោះ TANG GUO HUI ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិចិន មុខរបរ បុគ្គលិកក្រុមហ៊ុន កាន់លិខិតឆ្លងដែនលេខ EH6362750 (មិននៅជាប់ខ្លួន) ស្នាក់នៅ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ។ (សហចារី នាំចូល និងសន្និធិអាវុធដោយខុសច្បាប់ )។

១១៖ ឈ្មោះ សាន សុខឡេង ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ អ្នកបើករថយន្ត និងការពារថៅកែចិន ស្នាក់នៅ រាជធានីភ្នំពេញ។ (សហចារី នាំចូល និងសន្និធិអាវុធដោយខុសច្បាប់)។

របាយការណ៍ដដែលបន្ថែមថា វត្ថុតាងដកហូតបានសរុបមាន៖

* រថយន្តចំនួន ០៦គ្រឿង

* ទូរស័ព្ទចំនួន ១៧គ្រឿង

* ខ្នោះដៃចំនួន ២គូ មានកូនសោរ ២គូ

* អាវុធវែង ០៣ដើម (ម៉ាក PPSH 41 គ្មានលេខសម្គាល់ មានបង់ត្រឡោក ០១ , ម៉ាក KARATAY (កាលីតឌូ) ពណ៌ទឹកប្រាក់ មានលេខ: 19254927 ,ម៉ាក EKOL ពណ៌ខ្មៅ មានលេខ: 2100760 មានបង់ ០២)

* បង់អាវុធវែង AK ចំនួន ០១

* អាវុធខ្លី ០៤ដើម (ម៉ាក ZORAKI ពណ៌ខ្មៅ មានលេខ: 2101155 បង់១ ,ម៉ាក ZORAKI ពណ៌ខ្មៅ មានលេខ: 2101156 បង់១ , ម៉ាក ZORAKI ពណ៌ស មានលេខ: 000204 បង់១ , ម៉ាក SIG SAURER ពណ៌ខ្មៅ មានលេខ: 239120 បង់២)

* គ្រាប់កាំភ្លើង ២៤០គ្រាប់ (សរុបរួម ២៦៥គ្រាប់)

* ឧបករណ៍ដុះលាងអាវុធ ០២ប្រអប់

* ឧបករណ៍ដាប់លេខអាវុធ ០១ប្រអប់

* ផ្លាកលេខរថយន្ត ០១គូ (ភ្នំពេញ 2AR-7844)

* ស្រោមអាវុធខ្លី ០២

* សម្ភារផ្សេងៗមួយចំនួន៕